សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Économiques
Royal university of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **ឃុំ ឥ័ត្រ្កា**

លោក **ហេង លីហ្ស**

ណែនាំដោយ

លោក **ហេង ម៉ូរ៉ា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Économiques

Royal university of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **ឃុំ ត័ក្រា**

លោក **ហេង លីហួ**

ណែនាំដោយ

លោក **ហេង ម៉ូរ៉ា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងពីរឈ្មោះ **ឃុំ ឥវ៉ាន្នា** និង **ហេង លីហួ** ជានិស្សិតបរិញ្ញាបត្រផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាន់ទី២៣ ឆ្នាំសិក្សា២០១៩-២០២៣។ យើងខ្ញុំទាំងពីរសូមសម្តែងនូវគារវកិច្ចគោរពថ្លែងអំណរគុណ និងដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុតជូនចំពោះ៖

**លោកអ្នកមានគុណទាំងបួន** ដែលលោកបានខិតខំចិញ្ចឹមបីបាច់ និងថែរក្សាប្រកបដោយព្រហ្មវិហារធម៌ និងសង្គហៈធម៌លះបង់អស់កម្លាំងកាយចិត្តក្នុងការថែរក្សាកូនៗតាំងពីតូច រហូតដល់ធំ ព្រមទាំងផ្តល់នូវក្តីស្រឡាញ់ និងការអប់រំទូន្មានប្រៀនប្រដៅកូនៗឱ្យប្រព្រឹត្តតែអំពើល្អ សុចរិត ស្មោះត្រង់ ព្រមទាំងជម្រុញលើកទឹកចិត្តក្នុងការបញ្ជូនកូនៗឱ្យទទួលបានការអប់រំគ្រប់កម្រិត ឱ្យក្លាយជាកូនល្អ សិស្សល្អ និងពលរដ្ឋល្អក្នុងសង្គម មិនតែប៉ុណ្ណោះតែងតែផ្តល់នូវការផ្គត់ផ្គង់គ្រប់បែបយ៉ាង ទាំងបច្ច័យទាំងបួន ផ្នែកសម្ភារៈសិក្សា និងខាងស្មារតី រហូតដល់យើងខ្ញុំទាំងពីរនាក់បានបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រនេះទាំងមូល។

សូមគោរពថ្លែងអំណរគុណផងដែរចំពោះ **ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង គណៈគ្រប់គ្រង និងលោក លោកស្រីសាស្ត្រាចារ្យ** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ទាំងអស់ដែលលោកបានយកចិត្តទុកដាក់ និងចំណាយពេលវេលាដ៏មានតម្លៃក្នុងការដឹកនាំ បណ្តុះបណ្តាល និងពង្រឹងគុណភាពកម្មវិធីសិក្សាដល់និស្សិតគ្រប់ជំនាញប្រកបដោយប្រសិទ្ធិភាពការងារ ជាពិសេសជម្រុញលើកទឹកចិត្ត តម្រង់ទិសនិងបំពេញបន្ថែមនូវពុទ្ធិល្អៗដល់និស្សិតគ្រប់រូប ព្រមទាំងយើងខ្ញុំទាំងពីរ ដើម្បីវិវត្តន៍ខ្លួនឱ្យក្លាយជាសសរទ្រូងរបស់សង្គម និងប្រទេសជាតិ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **លោក ហេង មុីរ៉ា** ដែលបានចំណាយពេលវេលាដ៏មានតម្លៃ និងកម្លាំងកាយចិត្ត ក្នុងការដឹកនាំកិច្ចការស្រាវជ្រាវមួយនេះ ដោយលោកបានផ្តល់ជាមតិល្អៗការត្រួសត្រាយផ្លូវ និងផ្តល់វិធីសាស្ត្រល្អៗ ដល់រូបយើងខ្ញុំទាំងពីរ រហូតទាល់តែទទួលបានសមិទ្ធផលមួយនេះ។

ជាចុងបញ្ចប់យើងខ្ញុំទាំងពីរសូមបួងសួងដល់វត្ថុស័ក្តសិទ្ធិទាំងឡាយ ឱ្យជួយតាមថែរក្សាដល់ **លោកអ្នកមានគុណទាំងបួន ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង គណៈគ្រប់គ្រង និងលោក លោកស្រីសាស្ត្រាចារ្យ** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឱ្យជួបប្រទះតែភាពសុខដុមរមនាមានសុខភាពល្អ ប្រកបកិច្ចការងារអ្វីអោយទទួលបានតែភាពជោគជ័យគ្រប់ភារកិច្ច និងប្រកបនូវពុទ្ធិពរទាំងបួនប្រការ គឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

## អារម្ភកថា

ក្នុងការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្ររយៈពេលបួនឆ្នាំ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចកន្លងមកនេះ គឺជាពេលវេលាដ៏មានតម្លៃសម្រាប់ឱ្យយើងខ្ញុំទាំងពីរក្នុងការសិក្សាស្វែងយល់អំពីទ្រឹស្តីច្បាប់ ព្រមទាំងទទួលបាននូវការចែករំលែកបទពិសោធន៍ផ្នែកច្បាប់ ពីសំណាក់សាស្ត្រាចារ្យ ដែលមានបទពិសោធន៍ជាច្រើនឆ្នាំនៅក្នុងវិស័យច្បាប់នេះ។ នាឱកាសដែលបានក្រេបយកចំណេះដឹងដ៏ថ្លៃថ្លាមួយនេះ បានជួយជម្រុញឱ្យយើងខ្ញុំបាទទាំងពីរមានឱកាសក្នុងការស្រាវជ្រាវ និងចងក្រងសរសេរនូវអត្ថបទសារណា ដែលមានចំណងជើង “ **ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ** ” នេះឡើង ដើម្បីជាស្នាដៃសម្រាប់ជូនសាកលវិទ្យាល័យ និងសម្រាប់ទុកតម្កល់នៃការបញ្ចប់ថ្នាក់បរិញ្ញាបត្រច្បាប់របស់យើងខ្ញុំទាំងពីរផងដែរ។ តាមរយៈស្នាដៃនេះក៏ជាឯកសារជំនួយមួយផ្នែកដល់មិត្តនិស្សិត អ្នកស្រាវជ្រាវ និងប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន ដែលមានបំណងចង់សិក្សាស្វែងយល់ពាក់ព័ន្ធជាមួយប្រធានបទខាងលើនេះ។

កិច្ចការស្រាវជ្រាវនេះចងក្រងឡើងក្នុងគោលបំណង ដើម្បីបកស្រាយ និងបង្ហាញអំពីខ្លឹមសារសំខាន់ៗ នៅក្នុងដំណាក់កាលនីមួយៗ ក៏ដូចជាការបង្ហាញនូវលំហូនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុនាពេលបច្ចុប្បន្ន ដែលមានមូលដ្ឋានគ្រឹះនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី និងច្បាប់នានាដែលពាក់ព័ន្ធ។ ថ្វីដ្បិតតែមានបញ្ញត្តិច្បាប់ចែងយ៉ាងជាក់លាក់ពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំចំពោះចលនវត្ថុនេះក៏ដោយ ក៏យើងនៅតែមើលឃើញពីចំណុចខ្វះខាត និងបញ្ហាប្រឈមមួយចំនួន ដែលធ្វើឱ្យមានការរាំងស្ទះ ឬ យឺតយ៉ាវក្នុងការអនុវត្តនូវនីតិវិធីមួយនេះនាពេលបច្ចុប្បន្ន ដោយហេតុថាក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ មានឫសគល់ និងប្រភពចេញមកពីប្រទេសជប៉ុន។ ការលើកយកប្រធានបទ “ **ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ** ” មកបកស្រាយ គឺផ្អែកទៅតាមក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៦ រួមទាំងបទប្បញ្ញត្តិផ្សេងៗ ដែលជាមេកជាង និងពាក់ព័ន្ធក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុនេះ។

ជាទីអវសានយើងខ្ញុំទាំងពីរសង្ឃឹមថា ការសិក្សាស្រាវជ្រាវទៅលើប្រធានបទមួយនេះនឹងបានចូលរួមផ្តល់ជាអត្ថប្រយោជន៍ដល់មិត្តនិស្សិត ក៏ដូចជាអ្នកសិក្សាស្រាវជ្រាវ ដែលមានបំណងចង់សិក្សាស្វែងយល់អំពីនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុនេះ។ ជាពិសេសយើងខ្ញុំទាំងពីរ សូមធ្វើការខន្តី អភ័យទោសទុកជាមុននូវរាល់កំហុស ដែលកើតមានដោយអចេតនា ឬ ការភ្លាំងភ្លាត់លើបញ្ហាអក្ខរាវិរុទ្ធ និងអត្ថន័យខ្លឹមសារមានការឆ្គាំឆ្គង ដែលកើតមានដោយប្រការណាមួយនៅក្នុងសារណាមួយនេះ។

## មាតិកា

ទំព័រ


**សេចក្តីផ្តើម** ........ ១

**ជំពូកទី ១**

**សញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ**

**១.១ គោលគំនិតនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ** ........ ៤

**១.១.១ និយមន័យនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ** ........ ៤

**១.១.២ ប្រភេទនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ** ........ ៤

១.១.២.១ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារ ដែលមានគោលបំណងឱ្យសងជាប្រាក់ ........ ៤

១.១.២.២ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារ ដែលគ្មានគោលបំណងឱ្យសងជាប្រាក់ ........ ៥

១.១.២.៣ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិប្រាតិភោគ ........ ៥

**១.២ ស្ថាប័នអនុវត្តដែលមានសមត្ថកិច្ច** ........ ៥

**១.២.១ តុលាការអនុវត្ត** ........ ៥

១.២.១.១ អត្ថន័យនៃតុលាការអនុវត្ត ........ ៥

១.២.១.២ សមត្ថកិច្ចរបស់តុលាការអនុវត្ត ........ ៦

**១.២.២ អាជ្ញាសាលា** ........ ៦

១.២.២.១ អត្ថន័យនៃអាជ្ញាសាលា ........ ៦

១.២.២.២ សមត្ថកិច្ចតួនាទីរបស់អាជ្ញាសាលា ........ ៦

១.២.២.៣ សិទ្ធិ និងករណីយកិច្ចរបស់អាជ្ញាសាលាក្នុងការអនុវត្ត ........ ៧

**១.៣ លក្ខខណ្ឌក្នុងការអនុវត្តដោយបង្ខំ** ........ ៩

**១.៣.១ ពាក្យសុំឱ្យអនុវត្តដោយបង្ខំ** ........ ៩

**១.៣.២ លិខិតអនុវត្ត** ........ ១០

១.៣.២.១ និយមន័យ ........ ១០

១.៣.២.២ ប្រភេទនៃលិខិតអនុវត្ត ........ ១១

**១.៣.៣ រូបមន្តអនុវត្ត** ........ ១៤

១.៣.៣.១ អត្ថន័យនៃរូបមន្តអនុវត្ត ........ ១៤

១.៣.៣.២ ប្រភេទនៃរូបមន្តអនុវត្ត ........ ១៤

១.៣.៣.៣ ពាក្យសុំឱ្យផ្តល់រូបមន្តអនុវត្ត ........ ១៥
១.៣.៣.៤ ស្ថាប័នផ្តល់រូបមន្តអនុវត្តដោយបង្ខំ និងនីតិវិធីផ្តល់រូបមន្តអនុវត្ត........ ១៦
១.៣.៣.៥ ពាក្យសុំតវ៉ាអំពីការផ្តល់រូបមន្តអនុវត្ត ........ ១៧
**១.៣.៤ សោហ៊ុយសម្រាប់ការអនុវត្ត និងសោហ៊ុយសម្រាប់នីតិវិធី** ........ ១៧
១.៣.៤.១ អត្ថន័យសោហ៊ុយសម្រាប់ការអនុវត្ត និងសោហ៊ុយសម្រាប់នីតិវិធី ........ ១៧
១.៣.៤.២ ការចំណាយ ........ ១៨
**១.៣.៥ វិធីប្តឹងឧបាស្រ័យចំពោះការអនុវត្ត**........ ១៨
១.៣.៥.១ ការតវ៉ាចំពោះការអនុវត្ត ........ ១៩
១.៣.៥.២ បណ្តឹងជំទាស់ ........ ១៩

## ជំពូកទី ២
## លំហូរនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ

**២.១ ការរៀបចំដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុ** ........២១
២.១.១. ការជូនដំណឹង និងការជ្រើសរើស ........២១
២.១.២ ការសរសេរពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ........២២
២.១.៣ ការដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ........២២
២.១.៤ ការពិនិត្យពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ........២២
**២.២ ការរឹបអូសចលនវត្ថុ** ........២៦
**២.២.១ គោលការណ៍សំខាន់ៗនៃការរឹបអូស**........២៧
២.២.១.១ គោលការណ៍នៃការរឹបអូស........ ២៧
២.២.១.២ ចលនវត្ថុដែលជាកម្មវត្ថុនៃការរឹបអូស........ ២៧
២.២.១.៣ ចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស........២៨
២.២.១.៤ ការប្តូរទំហំនៃចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស ........២៩
២.២.១.៥ ការហាមឃាត់មិនឱ្យរឹបអូសហួសប្រមាណ ........៣០
២.២.១.៦ ការហាមឃាត់មិនឱ្យរឹបអូស ក្នុងករណីដែលប៉ាន់ប្រមាណឃើញថាគ្មានចំនួនសេសសល់ ...៣១
**២.២.២ ការអនុវត្តការរឹបអូស**........៣១
២.២.២.១ វិធីរឹបអូស ........៣១
២.២.២.២ ការថែរក្សាវត្ថុដែលត្រូវបានរឹបអូស ........៣៤

**២.២.៣ អានុភាពនៃការរឹបអូស**...........................................................................................................៣៥
២.២.៣.១ អានុភាពចំពោះកូនបំណុលនៃការអនុវត្ត ..........................................................................៣៦
២.២.៣.២ អានុភាពចំពោះតតិយជន...........................................................................................................៣៦
២.២.៣.៣ អានុភាពចំពោះផលធម្មជាតិ ......................................................................................................៣៧
**២.៣ ការប្តូរជាប្រាក់នូវទ្រព្យសម្បត្តិដែលត្រូវរឹបអូស**........................................................................ ៣៧
២.៣.១ វិធីលក់...............................................................................................................................................៣៧
២.៣.១.១ ការលក់ឡាយឡុងដោយផ្ទាល់មាត់.............................................................................................៣៧
២.៣.១.២ ការលក់ឡាយឡុងដោយស្រោមសំបុត្រ........................................................................................៣៨
២.៣.១.៣ ការលក់តាមវិធីផ្សេងៗ..............................................................................................................៣៨
២.៣.២ បុគ្គលដែលមិនអនុញ្ញាតឱ្យដាក់សំណើទិញ.....................................................................................៣៨
២.៣.៣ នីតិវិធីនៃការលក់...............................................................................................................................៣៩
២.៣.៤ ការលក់ចលនវត្ថុដែលត្រូវបានរឹបអូសក្នុងពេល ដែលការអនុវត្តកំពុងត្រូវបានផ្អាក ............................... ៤០
២.៣.៥ ការទទួលខុសត្រូវ និងសិទ្ធិអំណាចរបស់អាជ្ញាសាលាក្នុងពេលលក់ ..................................................... ៤១
**២.៤ ការបែងចែកចំណែក**........................................................................................................................៤១
**២.៤.១ ការទាមទារឱ្យចែកចំណែក** ..............................................................................................................៤២
២.៤.១.១ ម្ចាស់បំណុលដែលមានសិទ្ធិទាមទារ ឱ្យចែកចំណែកបាន .............................................................៤២
២.៤.១.២ វិធីទាមទារឱ្យចែកចំណែក .............................................................................................................៤២
២.៤.១.៣ ពេលដែលមានអត្ថិភាពក្នុងការទាមទារឱ្យចែកចំណែក.....................................................................៤៣
**២.៤.២ ការអនុវត្តការចែកចំណែក**............................................................................................................. ៤៤
២.៤.២.១ ករណីដែលមានម្ចាស់បំណុលតែម្នាក់ ............................................................................................. ៤៤
២.៤.២.២ ករណីដែលមានម្ចាស់បំណុលច្រើននាក់ ......................................................................................... ៤៤
២.៤.២.៣ វិសាលភាពនៃម្ចាស់បំណុលដែលត្រូវទទួលចំណែក ......................................................................... ៤៥
**២.៤.៣ អានុភាពនៃការចែកចំណែក**........................................................................................................... ៤៥
២.៤.៣.១ ការចាត់ទុកថាដល់ពេលកំណត់ត្រូវសង........................................................................................ ៤៥
២.៤.៣.២ ការផ្ញើប្រាក់ចំណែករបស់ម្ចាស់បំណុលទៅតុលាការ........................................................................ ៤៦

## ជំពូកទី ៣

## បញ្ហាប្រឈម និងដំណោះស្រាយនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ

**៣.១ បញ្ហាប្រឈម** .......... ៤៧
**៣.១.១ បញ្ហាទាក់ទងនឹងនីតិវិធីច្បាប់** .......... ៤៧
៣.១.១.១ ភាពខ្វះចន្លោះ និងភាពស្មុគស្មាញនៃនីតិវិធីច្បាប់ .......... ៤៧
៣.១.១.២ កង្វះការយល់ដឹងរបស់ប្រជាពលរដ្ឋ .......... ៤៧
៣.១.១.៣ ការផ្សព្វផ្សាយច្បាប់នៅមានកម្រិត .......... ៤៨
៣.១.១.៤ ការយល់ដឹងរបស់មន្ត្រីអនុវត្តនៅមានកម្រិត .......... ៤៩
**៣.១.២ កង្វះមន្ត្រីអនុវត្ត និងកង្វះការចូលរួមពីមន្ត្រីពាក់ព័ន្ធ** .......... ៥០
៣.១.២.១ កង្វះមន្ត្រីអនុវត្ត .......... ៥០
៣.១.២.២ កង្វះការចូលរួមពីមន្ត្រីពាក់ព័ន្ធ .......... ៥០
**៣.១.៣ ការលួចចាត់ចែងទ្រព្យរបស់កូនបំណុលនៃការអនុវត្តមុនពេលការរឹបអូស** .......... ៥១
**៣.១.៤ វប្បធម៌អន្តរាគមន៍ពីអ្នកមានអំណាច** .......... ៥១
**៣.២ ដំណោះស្រាយ** .......... ៥២
៣.២.១ ដំណោះស្រាយបញ្ហាទាក់ទងនឹងនីតិវិធីច្បាប់ .......... ៥២
៣.២.១.១ ការពិនិត្យ និងកែតម្រូវនូវចំណុចខ្វះខាត ឬ ចំណុចស្មុគស្មាញនៃច្បាប់ .......... ៥២
៣.២.១.២ ការបង្កើនការយល់ដឹងផ្នែកច្បាប់ដល់ប្រជាពលរដ្ឋ .......... ៥២
៣.២.១.៣ ការបង្កើនការផ្សព្វផ្សាយច្បាប់អោយបានទូលំទូលាយ .......... ៥២
៣.២.១.៤ ពង្រឹងចំណេះដឹងដល់មន្ត្រីអនុវត្ត .......... ៥៣
៣.២.២ បង្កើនសមាសភាពមន្ត្រីអនុវត្ត និងពង្រឹងកិច្ចសហការគ្នាជាមួយស្ថាប័នពាក់ព័ន្ធ .......... ៥៣
៣.២.២.១ បង្កើនសមាសភាពមន្ត្រីអនុវត្ត .......... ៥៣
៣.២.២.២ ពង្រឹងកិច្ចសហការរវាងមន្ត្រីអនុវត្ត និងស្ថាប័នពាក់ព័ន្ធ .......... ៥៣
៣.២.៣ ចាត់វិធានការតឹងរឹង ដើម្បីទប់ស្កាត់ការលួចចាត់ចែងទ្រព្យរបស់កូនបំណុលនៃការអនុវត្ត .......... ៥៤
៣.២.៤ លុបបំបាត់វប្បធម៌អន្តរាគមន៍របស់អ្នកមានអំណាច .......... ៥៤
**សេចក្តីសន្និដ្ឋាន** .......... ៥៥
**អនុសាសន៍** .......... ៥៧
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ការរីកចម្រើននៃសង្គមជាតិ ក៏ជាការកើនឡើងនូវបញ្ហាផងដែរ កាលណាបើបញ្ហាកាន់តែកើនឡើងច្បាប់ត្រូវតែវិវត្តន៍ទៅតាមបញ្ហាក្នុងសង្គម ក្នុងគោលបំណងដើម្បីដោះស្រាវនូវបញ្ហាដែលកើតមាន។ ក្នុងជីវភាពរស់នៅប្រចាំថ្ងៃមនុស្សម្នាក់ៗតែងតែមានការប្រាស្រ័យជាមួយគ្នាទៅវិញទៅមក បង្កើតបានជាកាតព្វកិច្ច ដែលត្រូវអនុវត្ត។ កាលណាកើតមានឡើងនូវកាតព្វកិច្ច ក៏បានបង្កើតឱ្យមានម្ចាស់បំណុល និងកូនបំណុល។ កូនបំណុល គឺជាអ្នកដែលមានកាតព្វកិច្ចចំពោះម្ចាស់បំណុល ហើយកាតព្វកិច្ចមានច្រើនបែបយ៉ាង ដូចជាកាតព្វកិច្ចប្រគល់វត្ថុដែលបានកំណត់ជាក់លាក់ កាតព្វកិច្ចដែលបានកំណត់ប្រភេទនៃវត្ថុ កាតព្វកិច្ចជាប្រាក់ជាដើម។ ក្នុងសកម្មភាពនៃការបំពេញកាតព្វកិច្ចរបស់កូនបំណុល មិនមែនសុទ្ធតែអាចធ្វើទៅបានដោយពេញលេញនោះទេ ការដែលមិនអាចធ្វើបានពេញលេញនោះ គឺជាការខាតបង់ប្រយោជន៍របស់ម្ចាស់បំណុល។ ដើម្បីការពារផលប្រយោជន៍របស់ម្ចាស់បំណុល ច្បាប់បានបញ្ញត្តិបើកសិទ្ធិឱ្យម្ចាស់បំណុលធ្វើការប្តឹងទាមទារទៅតុលាការមានសមត្ថកិច្ចដើម្បីសុំឱ្យតុលាការចេញសេចក្តីសម្រេចឱ្យកូនបំណុលបំពេញកាតព្វកិច្ចចំពោះខ្លួន។ ប៉ុន្តែទោះបីជាសេចក្តីសម្រេចបានចេញមកហើយក្តី ករណីខ្លះកូនបំណុលក៏នៅតែពុំអនុវត្តនូវកាតព្វកិច្ចតាមការសម្រេចបង្គាប់របស់តុលាការផងដែរ។ ក្នុងករណីកូនបំណុលមិនអនុវត្តតាមសេចក្តីសម្រេចរបស់តុលាការ ដូច្នេះម្ចាស់បំណុលមានសិទ្ធិដាក់សំណើទៅស្ថាប័នអនុវត្ត ដើម្បីសុំឱ្យធ្វើការអនុវត្តចំពោះសេចក្តីសម្រេចនោះបាន ហៅថាដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំដោយផ្អែកលើលិខិតអនុវត្ត។ ម្យ៉ាងទៀតការអនុវត្តដោយបង្ខំ មិនមែនពឹងផ្អែកតែទៅលើលិខិតអនុវត្តរបស់តុលាការអង្គសេចក្តីមួយនោះទេ លិខិតអនុវត្តមានច្រើនដែលអាចធ្វើឱ្យ ម្ចាស់បំណុលយកជាសំអាងជូនស្ថាប័នអនុវត្តធ្វើការអនុវត្តដោយបង្ខំបាន។ សិទ្ធិត្រូវបានផ្តល់ឱ្យដល់ម្ចាស់បំណុលហើយ តែម្ចាស់បំណុលចាំបាច់ត្រូវចេះប្រើសិទ្ធិរបស់ខ្លួន ដែលច្បាប់បានផ្តល់អោយ ក្នុងករណីដែលម្ចាស់បំណុលមានបំណងចង់យកចលនវត្ថុរបស់កូនបំណុលនៃការអនុវត្តជាកម្មវត្ថុនៃការអនុវត្ត ម្ចាស់បំណុលនៃការអនុវត្ត ត្រូវដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុជាជំហ៊ានដំបូង ដែលចាប់ផ្តើមពឹងពាក់អំណាចរដ្ឋ ធ្វើការទាមទារនូវប្រយោជន៍ស្របច្បាប់របស់ខ្លួន ដោយធ្វើការលក់ដោយបង្ខំចំពោះចលនវត្ថុរបស់កូនបំណុល។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

នីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ គឺជាមធ្យោបាយមួយដែលបានជួយការពារសិទ្ធិមនុស្សលើផ្នែកទ្រព្យសម្បត្តិស្របច្បាប់ វាមានន័យថាការអនុវត្តដោយបង្ខំបានជួយឱ្យម្ចាស់បំណុល ដែលទទួលរងផលប៉ះពាល់ខូចខាតប្រយោជន៍ដោយសារតែកូនបំណុល អាចទទួលបានការសងត្រឡប់មកវិញដោយការរឹបអូសចលនវត្ថុរបស់កូនបំណុល ឬជាប្រាក់សងមកខ្លួនដែលជាម្ចាស់បំណុលវិញ។ គន្លឹទី៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី

បានកំណត់អំពីសញ្ញាណ និងលំហូរនីតិវិធីអនុវត្តដោយបង្ខំ គឺជាមូលដ្ឋានដើម្បីអនុវត្តនីតិវិធីអនុវត្តដោយបង្ខំចំពោះចលនវត្ថុឱ្យបានត្រឹមត្រូវ កាលណាការអនុវត្តបានត្រឹមត្រូវមានន័យថា បានជួយដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋបានទាន់ពេលវេលា។

តែយ៉ាងណាមិញចំពោះការអនុវត្តជាក់ស្តែង គឺពុំបានដំណើរការទៅរលូន និងស្របទៅតាមបញ្ញត្តិច្បាប់ទាំងស្រុងនោះទេ ពោលគឺនៅមានចំណុចមួយចំនួនជាចំណុចខ្វះខាតក្នុងការអនុវត្ត ជាពិសេសការអនុវត្តត្រូវចំណាយពេលយូរ ដែលជាបញ្ហាយើងត្រូវលើកយកមកពិចារណា និងធ្វើការដោះស្រាយ។

តើអ្វីទៅជាការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ?

តើដើម្បីអាចអនុវត្តដោយបង្ខំចំពោះចលនវត្ថុបាន ម្ចាស់បំណុលត្រូវគោរពតាមលក្ខខណ្ឌនីតិវិធីអ្វីខ្លះ?

តើការអនុវត្តដោយបង្ខំចំពោះចលនវត្ថុនេះមានបញ្ហាប្រឈមអ្វីខ្លះ? ហើយថាតើមានយន្តការដោះស្រាយបែបណាខ្លះចំពោះបញ្ហាប្រឈមទាំងនោះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវរបស់យើងខ្ញុំ គឺមានគោលបំណងចម្បងដូចតទៅ៖

**ទី១.** ចងក្រងនូវលំហូរនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ចាប់តាំងពីមុនពេលដាក់ពាក្យសុំរហូតដល់ការបែងចែកចំណែក។

**ទី២.** លើកយកបញ្ហាប្រឈមមកបង្ហាញ ដើម្បីធ្វើការសិក្សាស្វែងយល់ និងរកដំណោះស្រាយ។

**ទី៣.** ជាឯកសារដល់និស្សិត និងអ្នកសិក្សាស្រាវជ្រាវច្បាប់ ក៏ដូចជាអ្នកអនុវត្តច្បាប់ និងពលរដ្ឋអាចធ្វើការសិក្សាអំពីការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ។

**ទី៤.** ជាផ្នែកមួយនៃស្មារតីលើកស្ទួយការចែករំលែក “ មានចំណេះត្រូវចេះចែករំលែក ”។

**ទី៥.** ជាការចូលរួមមួយក្នុងការផ្សព្វផ្សាយច្បាប់ តាមរយៈការផ្សព្វផ្សាយរបស់សាកលវិទ្យាល័យ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ប្រធានបទសារណារបស់យើងខ្ញុំ “ **ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ** ” បានកំណត់យ៉ាងជាក់លាក់អំពីទំហំ និងដែនកំណត់នៃការស្រាវជ្រាវ មានន័យថាយើងខ្ញុំនឹងបកស្រាយត្រឹមកម្រិតនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ដែលបានអនុវត្តចន្លោះឆ្នាំ២០២០ ដល់ ឆ្នាំ២០២៣ តែប៉ុណ្ណោះ ដោយយកក្រមនីតិវិធីរដ្ឋប្បវេណីធ្វើជាមូលដ្ឋានគោល។ យើងខ្ញុំក៏បានបញ្ចូលនូវខ្លឹមសារមួយចំនួន ដែលត្រូវបានប្រើប្រាស់ជាទូទៅទោះបីជាការអនុវត្តប្រភេទណាក៏ដោយ ក្នុងន័យនេះចំពោះជំពូកទី១ អំពី “ **សញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ** ” យើងអាចប្រើប្រាស់នូវខ្លឹមសារមួយចំនួនក្នុងជំពូកនេះ ចំពោះការអនុវត្តដោយបង្ខំផ្សេងៗទៀតបាន។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

សារណាប្រធានបទ " **ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ** " គឺចងក្រងឡើងក្នុងគោលបំណងនាំអ្នកសិក្សាស្រាវជ្រាវ ក៏ដូចជាមិត្តនិស្សិតបានស្វែងយល់ពីនីតិវិធីមួយនេះឱ្យកាន់តែស៊ីជម្រៅ។ ពោលនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុនេះ គឺជានីតិវិធីមួយ ដែលពុំសូវមានការយល់ដឹងច្រើននៅឡើយទេជាពិសេស គឺនិស្សិតដែលកំពុងសិក្សាបរិញ្ញាបត្រនីតិសាស្ត្រ។ ដោយឆ្លងកាត់ការសិក្សារយៈពេលបួនឆ្នាំកន្លងមកនេះ យើងខ្ញុំសង្កេតឃើញថាកម្មវិធីសិក្សាផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី គឺពុំទាន់មានការសិក្សាឱ្យស៊ីជម្រៅទៅលើផ្នែកណាមួយនៃនីតិវិធីនៃការអនុវត្តដោយបង្ខំនៅឡើយទេ។ ជាងនេះទៅទៀត យើងខ្ញុំបានបញ្ចូលទៅក្នុងសារណាមួយនេះ នូវរាល់បញ្ហាប្រឈម ដែលតែងតែកើតមានក្នុងការអនុវត្តដោយបង្ខំចំពោះចលនវត្ថុក្នុងសង្គមជាក់ស្តែង។ យើងខ្ញុំក៏មានគោលបំណង ដើម្បីពង្រឹងការអនុវត្តឱ្យកាន់តែល្អប្រសើរ និងស្របទៅតាមបញ្ញត្តិច្បាប់ដែលចូលជាធរមាន។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីទទួលសមិទ្ធិផលមួយនេះ យើងខ្ញុំទាំងពីរនាក់បានព្យាយាមប្រមែប្រមូលព័ត៌មានពីប្រភពជាច្រើនមានប្រភពចេញពីរូបវន្ត និងជាឯកសារ (ឯកសាររឹង និងឯកសារទន់) រួមទាំងវីដេអូ ដែលបកស្រាយអំពីការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ។ យើងខ្ញុំបានសុំការណែនាំ និងពន្យល់អំពីលំហូរនីតិវិធីអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ពីអ្នកប្រកបវិជ្ជាជីវៈច្បាប់ មានចៅក្រម មេធាវី អាជ្ញាសាលា និងសាស្ត្រាចារ្យច្បាប់ជាច្រើន។ ក្រៅពីនេះ យើងខ្ញុំក៏បានទទួលនូវព័ត៌មានអំពីបញ្ហាប្រឈម ដែលកំពុងតែកើតឡើងក្នុងពេលបច្ចុប្បន្ន ដែលរាំងស្ទះដល់ការអនុវត្តរបស់ស្ថាប័នអនុវត្តដែលបានកើតឡើងជារឿយៗ។

ច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ និងលិខិតបទដ្ឋានគតិយុត្តជាច្រើនទៀត ដែលប្រើប្រាស់ក្នុងនីតិវិធីអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ជាធាតុផ្សំចម្បងនៃសារណារបស់យើងខ្ញុំ។ ក្រោយពីទទួលបានព័ត៌មានពីប្រភពជាច្រើនរួចហើយ យើងខ្ញុំបានធ្វើការប្រៀបធៀបរវាងទ្រឹស្តី និងការអនុវត្តជាក់ស្តែង ហើយធ្វើការចងក្រងសារណានេះឡើង ដោយយកចិត្តទុកដាក់ជាទីបំផុត។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

បន្ទាប់ពីបានសិក្សាស្រាវជ្រាវ និងពិចារណាទៅលើប្រធានបទ " **ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ** " រួចមក យើងខ្ញុំទាំងពីរបានសម្រេចធ្វើការបែងចែកចេញជា ៣ ជំពូក មានដូចតទៅ៖

- **ជំពូកទី ១ សញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ**
- **ជំពូកទី ២ លំហូរនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ**
- **ជំពូកទី ៣ បញ្ហាប្រឈម និងដំណោះស្រាយនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ**

# ជំពូកទី ១
# សញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំ
# ចំពោះចលនវត្ថុ

# ជំពូកទី ១

# សញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ

## ១.១ គោលគំនិតនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ

### ១.១.១ និយមន័យនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ

ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ គឺជានីតិវិធី ដែលធ្វើឡើងដោយអាជ្ញាសាលាជាអ្នកអនុវត្តរឹបអូសយកចលនវត្ថុ ដែលធ្លាក់ទៅលើកូនបំណុលនៃការអនុវត្ត ដើម្បីជួយសម្រេចសិទ្ធិទាមទារ ដែលមានគោលបំណងឱ្យសងជាប្រាក់របស់ម្ចាស់បំណុលនៃការអនុវត្ត ហើយសិទ្ធិទាមទារនេះមានកំណត់ក្នុងលិខិតអនុវត្ត។ តាមរយៈនេះយើងអាចទាញសញ្ញាណ ឬ ធាតុផ្សំនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុបានដូចខាងក្រោម៖

- ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ គឺជាការរឹបអូសចលនវត្ថុរបស់កូនបំណុលដើម្បីលក់។
- ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ មានគោលបំណងជួយសម្រេចនូវសិទ្ធិទាមទាររបស់ម្ចាស់បំណុលនៃការអនុវត្ត។
- ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ត្រូវបានធ្វើឡើងដើម្បីសម្រេចសិទ្ធិទាមទារ ដែលមានកំណត់ក្នុងលិខិតអនុវត្ត។
- ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ត្រូវបានធ្វើឡើងដោយអាជ្ញាសាលា ដែលជាស្ថាប័នអនុវត្តមានសមត្ថកិច្ច។

### ១.១.២ ប្រភេទនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ

ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ បានបែងចែកប្រភេទនៃការអនុវត្តដោយបង្ខំជា បី ប្រភេទធំៗគឺ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារ ដែលមានគោលបំណងឱ្យសងជាប្រាក់ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលគ្មានគោលបំណងឱ្យសងជាប្រាក់ និងការអនុវត្តដោយបង្ខំចំពោះសិទ្ធិប្រាតិភោគ។

#### ១.១.២.១ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារ ដែលមានគោលបំណងឱ្យសងជាប្រាក់

ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារ ដែលមានគោលបំណងឱ្យសងជាប្រាក់ គឺជានីតិវិធីនៃការអនុវត្តដោយបង្ខំ ដែលស្ថាប័នអនុវត្តធ្វើការរឹបអូសទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្តហើយធ្វើការលក់ដោយបង្ខំប្តូរជាប្រាក់ រួចយកប្រាក់នោះមកចែកចំណែកឱ្យម្ចាស់បំណុលនៃការអនុវត្ត ដើម្បីសម្រេចនូវសិទ្ធិទាមទាររបស់ម្ចាស់បំណុលនៃការអនុវត្តដែលមានគោលបំណងឱ្យសងជាប្រាក់។ ការអនុវត្តដោយបង្ខំដែលមានគោលបំណងឱ្យសងជាប្រាក់មានដូចជា ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល និងទ្រព្យសម្បត្តិផ្សេងទៀត និងការអនុវត្តដោយបង្ខំចំពោះនាវា។ នីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារ ដែលមានគោលបំណងឱ្យសងជាប្រាក់មានលក្ខណៈខុសគ្នាពីមួយទៅមួយ

អាស្រ័យទៅតាមប្រភេទនៃទ្រព្យសម្បត្តិ ដែលជាកម្មវត្ថុនៃការអនុវត្តនោះ។ ជាគោលការណ៍ទ្រព្យសម្បត្តិ ដែលអាចក្លាយទៅជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ គឺជាទ្រព្យសម្បត្តិទទួលខុសត្រូវរបស់កូនបំណុលនៃការអនុវត្ត ដែលជាទ្រព្យសម្បត្តិទាំងអស់របស់កូនបំណុលនៃការអនុវត្ត ។

**១.១.២.២ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារ ដែលគ្មានគោលបំណងឱ្យសងជាប្រាក់**

ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារ ដែលគ្មានគោលបំណងឱ្យសងជាប្រាក់ គឺជានីតិវិធីនៃការអនុវត្តដោយបង្ខំ ដែលស្ថាប័នអនុវត្តរំលាយការកាន់កាប់ ឬ ដកហូតការកាន់កាប់របស់កូនបំណុលនៃការអនុវត្តលើវត្ថុដែលជាកម្មវត្ថុនៃការអនុវត្ត រួចធ្វើការប្រគល់វត្ថុរូបិយក្រៅពីប្រាក់ទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត ឬ បង្ខំឱ្យកូនបំណុលនៃការអនុវត្តធ្វើ ឬ មិនធ្វើសកម្មភាពណាមួយ ដើម្បីសម្រេចនូវសិទ្ធិទាមទាររបស់ម្ចាស់បំណុលនៃការអនុវត្ត ដែលកូនបំណុលនៃការអនុវត្តមានកាតព្វកិច្ចត្រូវអនុវត្តចំពោះម្ចាស់បំណុល។ ការអនុវត្តដោយបង្ខំដែលគ្មានគោលបំណងឱ្យសងជាប្រាក់ មានដូចជា ការអនុវត្តដោយបង្ខំឱ្យប្រគល់ចលនវត្ថុ ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ការអនុវត្តជំនួស ការអនុវត្តដោយបង្ខំតាមវិធានបង្ខំដោយប្រយោល និងការចាត់ទុកថាបានបង្ហាញឆន្ទៈ។ ជាគោលការណ៍ការអនុវត្តសិទ្ធិទាមទារ ដែលមានគោលបំណងឱ្យប្រគល់វត្ថុរូបិយ ត្រូវធ្វើឡើងតាមវិធីអនុវត្តដោយបង្ខំឱ្យប្រគល់វត្ថុរូបិយទាំងនោះ។ ប៉ុន្តែប្រសិនបើវត្ថុ ដែលជាកម្មវត្ថុនៃការប្រគល់នោះមានមនុស្សរស់នៅ នីតិវិធីនៃការអនុវត្តដោយបណ្តេញចេញត្រូវយកមកអនុវត្ត។

**១.១.២.៣ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិប្រាតិភោគ**

ការអនុវត្តដោយបង្ខំចំពោះសិទ្ធិប្រាតិភោគ គឺជានីតិវិធី ដែលត្រូវអនុវត្តដើម្បីសម្រេចគោលបំណងរបស់បុគ្គលដែលមានសិទ្ធិប្រាតិភោគ ដូចជាហ៊ីប៉ូតែក សិទ្ធិលើការបញ្ចាំ ជាអាទិ៍ ដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី ហើយដែលអាចធ្វើការប្តូរជាប្រាក់ដោយបង្ខំនូវទ្រព្យសម្បត្តិ ដែលត្រូវបានធានាតាមរយៈស្ថាប័នអនុវត្តហើយទទួលការសងពីប្រាក់ ដែលបានមកនោះបានមុនម្ចាស់បំណុលដទៃទៀត។ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិប្រាតិភោគត្រូវបានកំណត់ទៅតាមប្រភេទនៃទ្រព្យសម្បត្តិ ដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគរួមមានការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ ការអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ និងការអនុវត្តសិទ្ធិប្រាតិភោគចំពោះនាវា។

## ១.២ ស្ថាប័នអនុវត្តដែលមានសមត្ថកិច្ច

### ១.២.១ តុលាការអនុវត្ត

**១.២.១.១ អត្ថន័យនៃតុលាការអនុវត្ត**

តុលាការ ដែលមានសមត្ថកិច្ចធ្វើការអនុវត្តដោយបង្ខំ ឬ ដែលធ្វើការពាក់ព័ន្ធនៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ(តុលាការតាមន័យចង្អៀត) ហៅថាតុលាការអនុវត្ត។

សាលាដំបូង ដែលត្រូវអនុវត្តដោយបង្ខំតាមបញ្ញត្តិនៃគន្លីនេះ គឺជាតុលាការអនុវត្ត[1]។

**១.២.១.២ សមត្ថកិច្ចរបស់តុលាការអនុវត្ត**

ក្នុងករណីដែលតុលាការអនុវត្តដើរតួជាស្ថាប័នអនុវត្តដោយផ្ទាល់ ប្រភេទនៃនីតិវិធីនៃការអនុវត្តដោយបង្ខំ ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការអនុវត្តរួមមាន៖ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ការអនុវត្តដោយបង្ខំចំពោះនាវា និងការអនុវត្តដោយបង្ខំចំពោះកាតព្វកិច្ច ដែលមានគោលបំណងឱ្យធ្វើ ឬ មិនឱ្យធ្វើសកម្មភាពណាមួយ។ ក្រៅពីការដើរតួនាទីជាអ្នកអនុវត្តដោយផ្ទាល់ តុលាការអនុវត្តក៏ចាំបាច់ជាអ្នកផ្តល់កិច្ចសហការ និងមើលការខុសត្រូវលើនីតិវិធីនៃការអនុវត្តដោយអាជ្ញាផងដែរ។

**១.២.២ អាជ្ញាសាលា**

**១.២.២.១ អត្ថន័យនៃអាជ្ញាសាលា**

អាជ្ញាសាលា គឺជាស្ថាប័នយុត្តាធិការឯករាជ្យមួយ ដែលទទួលបន្ទុកធ្វើការបញ្ជូនឯកសារនានាដែលចេញដោយតុលាការ និងធ្វើការអនុវត្តដោយបង្ខំមួយចំនួន ដែលច្បាប់បានកំណត់[2]។ ស្ថាប័នយុត្តាធិការនេះស្ថិតនៅក្រោមក្រសួងយុត្តិធម៌នឹងមានសមាសភាពជាមន្រ្តីរាជការ ដែលមានឈ្មោះថាជាអាជ្ញាសាលា ដែលបំពេញការងារនៅសាលាដំបូង ដែលរដ្ឋមន្រ្តីក្រសួងយុត្តិធម៌បង្គាប់ឱ្យធ្វើការ[3]។

អាជ្ញាសាលា គឺជាមន្រ្តីរាជការ ដែលត្រូវតែងតាំងដោយប្រកាសរបស់ក្រសួងយុត្តិធម៌ ហើយអាជ្ញាសាលាមិនទទួលប្រាក់ខែពីរដ្ឋទេ គឺទទួលចំណូលជាប្រាក់កម្រៃពីអ្នកដាក់ពាក្យសុំចំពោះការអនុវត្តមុខងាររបស់ខ្លួន[4]។

អាជ្ញាសាលា ត្រូវអនុវត្តកិច្ចការ ដែលក្រមនីតិវិធីរដ្ឋប្បវេណី ក្រមនីតិវិធីព្រហ្មទណ្ឌ ឬ បទដ្ឋានគតិយុត្តផ្សេងទៀតកំណត់ថាត្រូវអនុវត្តដោយអាជ្ញាសាលា និងកិច្ចការពាក់ព័ន្ធនឹងការរក្សាការគ្រប់គ្រងវត្ថុ ឬ សកម្មភាពផ្សេងទៀត ដែលសេចក្តីសម្រេចរបស់តុលាការកំណត់ថាត្រូវចាត់ចែងដោយអាជ្ញាសាលា[5]។

**១.២.២.២ សមត្ថកិច្ចតួនាទីរបស់អាជ្ញាសាលា**

អាជ្ញាសាលា ត្រូវបំពេញមុខងាររបស់ខ្លួននៅក្នុងដែនសមត្ថកិច្ចរបស់សាលាដំបូង ដែលខ្លួនបំពេញការងារ[6]។ នីតិវិធីនៃការអនុវត្តដោយបង្ខំ ដែលអាជ្ញាសាលាជាអ្នកទទួលបន្ទុកដោយឯករាជ្យក្នុងនាមជាស្ថាប័ន

[1]. មាត្រា ៣៣៦ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[2]. មាត្រា ២៤៦ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[3]. មាត្រា ២ នៃសេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា ឆ្នាំ ២០១៥
[4]. មាត្រា ៣ នៃសេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា ឆ្នាំ ២០១៥
[5]. មាត្រា ៨ កថាខណ្ឌទី ៤ នៃសេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា ឆ្នាំ ២០១៥
[6]. មាត្រា ៧ នៃសេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា ឆ្នាំ ២០១៥

អនុវត្តរួមមាន៖ ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ[7] ការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ[8] ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ[9] និងការអនុវត្តដោយបង្ខំឱ្យប្រគល់ចលនវត្ថុ[10]។ ក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំដែលតុលាការអនុវត្តជាអ្នកទទួល ក្នុងនាមជាស្ថាប័នអនុវត្តអាជ្ញាសាលាមានសិទ្ធិអំណាចដូចជា៖

-ការថែរក្សាគ្រប់គ្រងអចលនវត្ថុ ដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ[11]។

-ការអនុវត្តការលក់[12]។

-ការដកហូតលិខិតបញ្ជាក់នានា[13]។

-នៅក្នុងនីតិវិធីនៃការអនុវត្តរក្សាការពារ អាជ្ញាសាលាមានសិទ្ធិអំណាចនៅក្នុងការថែរក្សាគ្រប់គ្រងអចលនវត្ថុ ដែលជាកម្មវត្ថុនៃការចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការផ្ទេរការកាន់កាប់[14]។

**១.២.២.៣ សិទ្ធិ និងករណីយកិច្ចរបស់អាជ្ញាសាលាក្នុងការអនុវត្ត**

នៅក្នុងការអនុវត្តមុខនាទីរបស់ខ្លួនអាជ្ញាសាលាមានសិទ្ធិ និងករណីយកិច្ចមួយចំនួនដូចខាងក្រោម៖

. **សិទ្ធិប្រើប្រាស់ត្រារបស់សាលាដំបូងរាជធានី-ខេត្ត** ៖ មន្ត្រីអាជ្ញាសាលា ដែលប្រចាំការនៅសាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត មានសិទ្ធិប្រើប្រាស់ត្រារបស់សាលាដំបូងរាជធានី-ខេត្តនោះ[15]។

. **សិទ្ធិប្រើកម្លាំង ឬ នគរបាល** ៖ នៅក្នុងការអនុវត្តផ្លូវមុខងាររបស់ខ្លួន អាជ្ញាសាលាអាចប្រើកម្លាំងនគរបាល ឬ កម្លាំងផ្សេងទៀត ដើម្បីជួយសម្រួលដល់កិច្ចការងាររបស់ខ្លួន[16]។

. **សិទ្ធិឆែកឆេរ** ៖ នៅក្នុងអំឡុងពេលចុះអនុវត្តរឹបអូសចលនវត្ថុ ដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត អាជ្ញាសាលាអាចចុះឆែកឆេរ ស្វែងរកផ្លូវចលនវត្ថុរបស់កូនបំណុលនៃការអនុវត្ត ដើម្បីធ្វើការរឹបអូសបាន[17]។

. **សិទ្ធិរកអ្នកសង្កេតការណ៍** ៖ នៅពេលចូលទៅដល់ទីកន្លែងរស់នៅ ដើម្បីបំពេញមុខនាទីរបស់ខ្លួនបើមិនបានជួបនឹងអ្នកចម្បងនៃទីកន្លែងរស់នៅ ឬ អ្នកតំណាងរបស់អ្នកនោះ ឬញាតិនៅជាមួយ ឬអ្នកបម្រើ ឬអ្នកផ្សេង

[7] . មាត្រា ៣៨៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[8] . មាត្រា ៥០០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[9] . មាត្រា ៥២៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[10] . មាត្រា ៥២៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[11] . មាត្រា ៤២៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[12] . មាត្រា ៤៣៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[13] . មាត្រា ៤៥៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[14] . មាត្រា ៥៧១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[15] . ប្រការ២.២ នៃប្រកាសលេខ០៦២ កយ.ប្រក/១៩ ស្តីពីបែបបទសម្រាប់អនុវត្តការងាររបស់មន្ត្រីអាជ្ញាសាលា នៃក្រសួងយុត្តិធម៌
[16] . មាត្រា ៣៣៨ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[17] . មាត្រា ៣៨៥ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

ពីអ្នកដែលធ្វើការនៅទីនោះទេ អាជ្ញាសាលាត្រូវឱ្យមានវត្តមាន មន្ត្រីឃុំ-សង្កាត់ មន្ត្រីនគរបាល ឬ អ្នកផ្សេងទៀត ដែលអាចទទួលស្គាល់ថាជាសាក្សីសមរម្យបាន[18]។

. **សិទ្ធិរកអ្នកវាយតម្លៃ** ៖ ចំពោះការលក់ចលនវត្ថុ ដែលមានតម្លៃខ្ពស់ អាជ្ញាសាលាអាចចាត់តាំងអ្នកវាយតម្លៃឱ្យធ្វើការវាយតម្លៃលើចលនវត្ថុនោះបាន[19]។

. **សិទ្ធិរក្សាសណ្តាប់ធ្នាប់ក្នុងពេលអនុវត្តការលក់** ៖ ក្នុងពេលប្រតិបត្តិការលក់ចលនវត្ថុ ដែលត្រូវបានរឹបអូសនោះ អាជ្ញាសាលាមានភារកិច្ចរក្សាសណ្តាប់ធ្នាប់ នៅក្នុងពេលលក់ដោយបង្ខំនោះ ករណីនេះអាជ្ញាសាលាអាចហាមបុគ្គលមួយចំនួនមិនចូលកន្លែងលក់ ឬ មិនអនុញ្ញាតឱ្យអ្នកទិញ ដែលមិនបានបង់ប្រាក់ថ្លៃទិញលើកទី១ ក្នុងការលក់លើកទី២[20]។

. **សិទ្ធិជ្រើសរើសវត្ថុរឹបអូស** ៖ នៅពេលចុះអនុវត្តការរឹបអូសចលនវត្ថុ ដែលជាកម្មវត្ថុនៃការអនុវត្តនោះ អាជ្ញាសាលាមានសិទ្ធិជ្រើសរើសចលនវត្ថុក្នុងការរឹបអូសបាន ប៉ុន្តែធ្វើយ៉ាងណាមិនត្រូវឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ម្ចាស់បំណុលទេ[21]។

. **សិទ្ធិលុបចោលការរឹបអូស** ៖ បើអាជ្ញាសាលាយល់ឃើញថា ការរឹបអូសចលនវត្ថុមានទំហំហួសប្រមាណ ករណីប៉ាន់ប្រមាណថាគ្មានចំនួនសេសសល់ ឬ ចលនវត្ថុដែលត្រូវបានរឹបអូសមិនអាចប្តូរជាប្រាក់បានអាជ្ញាសាលាអាចលុបចោលការរឹបអូសទាំងនោះបាន[22]។

. **ការអនុញ្ញាតឱ្យកូនបំណុលនៃការអនុវត្តរក្សាទុកវត្ថុរឹបអូស** ៖ ជាគោលការណ៍ អានុភាពនៃការរឹបអូសត្រូវបានកើតឡើងតាមរយៈការកាន់កាប់ដោយអាជ្ញាសាលា ប៉ុន្តែបើយល់ឃើញថា មានផលលំបាកក្នុងការដឹកជញ្ជូន មានការចំណាយច្រើនក្នុងការរក្សាចលនវត្ថុ ដែលត្រូវបានរឹបអូសនោះ អាជ្ញាសាលាអាចអនុញ្ញាតឱ្យកូនបំណុលនៃការអនុវត្តរក្សាប្រើប្រាស់ចលនវត្ថុនោះបានដោយតម្រូវឱ្យបិតស្លាក ឬ ដាក់សញ្ញាសម្គាល់លើចលនវត្ថុនោះ[23]។

. **សិទ្ធិបញ្ចូលរឿងក្តី** ៖ ក្នុងករណីដែលមានពាក្យសុំឱ្យអនុវត្តដោយបង្ខំលើចលនវត្ថុថ្មីមួយទៀតចំពោះកូនបំណុលនៃការអនុវត្ត និងកន្លែងអនុវត្តដដែលនោះ ហើយព្រមទាំងគ្មានចលនវត្ថុណាសម្រាប់រឹបអូសជាថ្មីទេ ឬ ក៏មានពាក្យសុំឱ្យបញ្ចូលរឿងក្តីនោះអាជ្ញាសាលាអាចបញ្ចូលរឿងក្តីនេះបាន[24]។

---

[18] . មាត្រា ៣៣៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[19] . មាត្រា ៣៩៥ កថាខណ្ឌទី ៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[20] . មាត្រា ៣៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[21] . មាត្រា ៣៨៥ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[22] . មាត្រា ៣៩១ មាត្រា ៣៩២ និង មាត្រា ៣៩៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[23] . មាត្រា ៣៨៥ កថាខណ្ឌទី ៤ និងទី ៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[24] . មាត្រា ៣៨៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

. **ករណីយកិច្ចត្រូវយកតាមខ្លួននូវអត្តសញ្ញាណប័ណ្ណ** ៖ នៅក្នុងប្រតិបត្តិការក្នុងការបំពេញមុខនាទីរបស់ខ្លួន អាជ្ញាសាលាត្រូវយកមកជាមួយនូវអត្តសញ្ញាណប័ណ្ណសម្គាល់ខ្លួន[25]។

. **ករណីយកិច្ចសុំការអនុញ្ញាតចុះអនុវត្តក្នុងថ្ងៃសម្រាក** ៖ ក្នុងករណីមានការចុះអនុវត្តនៅថ្ងៃឈប់សម្រាក ឬ នៅចន្លោះម៉ោង ៦ ល្ងាច ដល់ម៉ោង ៦ ព្រឹកត្រូវសុំការអនុញ្ញាតពីសាលាដំបូងដែលខ្លួនបិតនៅ[26]។

. **ការធ្វើកំណត់ហេតុ** គឺជាកត្តាសំខាន់ ដែលអាជ្ញាសាលាមិនអាចរំលងបាន ហើយអាជ្ញាសាលាត្រូវធ្វើកំណត់ហេតុគ្រប់ពេលមានការអនុវត្តទាំងអស់ដូចជា អំឡុងពេលអនុវត្តឱ្យប្រគល់កំណត់ហេតុលក់ចលនវត្ថុ ដែលមិនអាចប្រគល់ឱ្យកូនបំណុលបាន កំណត់ហេតុអនុវត្តសាលក្រមមិនបានសម្រេចជាដើម។ល។

## ១.៣ លក្ខខណ្ឌក្នុងការអនុវត្តដោយបង្ខំ

### ១.៣.១ ពាក្យសុំឱ្យអនុវត្តដោយបង្ខំ

ជាគោលការណ៍ការអនុវត្តដោយបង្ខំ ត្រូវធ្វើឡើងដោយស្ថាប័នអនុវត្តតាមពាក្យសុំរបស់ភាគី[27] ហើយពាក្យសុំត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ[28]។ ការសរសេរពាក្យឱ្យអនុវត្តចំពោះចលនវត្ថុ ត្រូវអនុលោមតាមមាត្រា ៣៨៤ កថាខណ្ឌទី១ ទី២ និងមាត្រា ៣៤៩ កថាខណ្ឌទី២ ដែលក្នុងនោះម្ចាស់បំណុលនៃការអនុវត្តត្រូវសរសេរដូចខាងក្រោម ៖

. ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត ហើយនិងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។

. ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់កូនបំណុលនៃការអនុវត្ត ហើយនិងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។

. សញ្ញាណនៃលិខិតអនុវត្ត ៖ អាចសរសេរបញ្ជាក់អំពីប្រភេទនៃលិខិតអនុវត្ត ប្រភពនៃលិខិតអនុវត្ត រួមទាំងកាលបរិច្ឆេទនៃលិខិតអនុវត្តជាដើម។

. សញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុអនុវត្ត ៖ ដែលក្នុងករណីនេះ ម្ចាស់បំណុលនៃការអនុវត្ត មិនចាំបាច់រៀបរាប់លម្អិតអំពីចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តក៏បាន ពោលគឺម្ចាស់បំណុលនៃការអនុវត្ត គ្រាន់តែបញ្ជាក់អំពីទីតាំងនៃចលនវត្ថុរបស់កូនបំណុលគឺគ្រប់គ្រាន់ហើយ[29]។

[25] . មាត្រា ៣៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[26] . មាត្រា ៣៤០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[27] . មាត្រា ៣៣៦ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[28] . មាត្រា ៣៤៩ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[29] . មាត្រា ៣៨៤ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

### ១.៣.២ លិខិតអនុវត្ត

ជាគោលការណ៍ ការអនុវត្តដោយបង្ខំ ត្រូវធ្វើឡើងដោយលិខិតអនុវត្ត[30]។ មានន័យថាស្ថាប័នអនុវត្តពុំអាចចាប់ផ្តើមការអនុវត្តបានទេ បើពុំមានលិខិតអនុវត្តភ្ជាប់ជាមួយនូវពាក្យសុំឱ្យអនុវត្តដោយបង្ខំ លើកលែងតែការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ ដែលអាជ្ញាសាលាអាចធ្វើការចាប់ផ្តើមការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ ដោយគ្រាន់តែម្ចាស់បំណុលនៃការអនុវត្តធ្វើការប្រគល់នូវចលនវត្ថុ ដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគមកឱ្យអាជ្ញាសាលា ឬ ដាក់លិខិតបញ្ជាក់ថាអ្នកកាន់កាប់ចលនវត្ថុនោះយល់ព្រមប្រគល់ឱ្យអាជ្ញាសាលាជាការស្រេច[31]។

#### ១.៣.២.១ និយមន័យ

លិខិតអនុវត្ត គឺជាឯកសារដែលបញ្ជាក់អំពីសិទ្ធិទាមទារឱ្យផ្តល់តាវកាលិកណាមួយជាក់លាក់ ដែលកំណត់នៅក្រោមនីតិឯកជន លិខិតនេះ គឺច្បាប់ផ្តល់ឱ្យនូវអំណាចបង្ខំឱ្យអនុវត្តដើម្បីសម្រេចនូវអត្ថន័យនៃសិទ្ធិតាមរយៈការអនុវត្តដោយបង្ខំ។

ខ្លឹមសារ និងវិធីនៃការអនុវត្តដោយបង្ខំ ត្រូវកំណត់ដោយផ្អែកទៅលើលិខិតអនុវត្តអាស្រ័យទៅតាមស្ថានភាពផ្សេងៗ។ ខ្លឹមសារ និងវិធីនៃការអនុវត្តដោយបង្ខំអាចត្រូវបានកម្រិត ឬ បន្ថែមដោយរូបមន្តអនុវត្ត។ ខ្លឹមសារ នៃលិខិតអនុវត្តត្រូវបកស្រាយដោយស្ថាប័នអនុវត្តនៅពេលធ្វើការអនុវត្ត ។ ភាគីណាមួយដែលមិនពេញចិត្តនិងការបកស្រាយរបស់ស្ថាប័នអនុវត្ត នៅក្នុងករណីនេះអាចធ្វើបណ្តឹងជំទាស់ ឬ តាមរយៈការតវ៉ាចំពោះការអនុវត្ត[32] អាស្រ័យទៅតាមប្រភេទនៃការចាត់ចែងការអនុវត្តដែលពាក់ព័ន្ធ។ ប៉ុន្តែបើខ្លឹមសារ ឬវិធីនៃការអនុវត្តដោយបង្ខំនៅក្នុងលិខិតអនុវត្តមិនអាចធ្វើការកំណត់ដោយហេតុមានភាពស្រពេចស្រពិល ឬ ដោយសារតែមានភាពមិនច្បាស់លាស់ នោះការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើទៅបាន ហើយម្ចាស់បំណុលនៃការអនុវត្តត្រូវទៅទទួលលិខិតអនុវត្តម្តងទៀត។

នៅក្នុងនីតិវិធីអនុវត្តដោយបង្ខំ ច្បាប់តម្រូវឱ្យមានលិខិតចម្លងយថាភូតនៃលិខិតអនុវត្ត ដែលមានអានុភាពអនុវត្តយកជាលិខិតអនុវត្ត។ តួនាទីរបស់លិខិតចម្លងយថាភូតនៃលិខិតអនុវត្ត គឺដើម្បីឱ្យម្ចាស់បំណុលនៃការអនុវត្ត ធ្វើការបញ្ជាក់អំពីអត្ថិភាព និងអត្ថន័យនៃសិទ្ធិទាមទារឱ្យផ្តល់តាវកាលិក ដែលកំណត់ដោយច្បាប់សារធាតុ និងដែលត្រូវកំណត់ដោយការអនុវត្តដោយបង្ខំ តាមវិធីនៃការដាក់លិខិតចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្តដែលខ្លួនមានទៅឱ្យស្ថាប័នអនុវត្ត។ សិទ្ធិទាមទារឱ្យផ្តល់តាវកាលិក ដែលកំណត់

[30] . មាត្រា ៣៥០ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[31] . មាត្រា ៥០០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[32] . មាត្រា ៣៨៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

ដោយច្បាប់សារធាតុត្រូវបានបញ្ជាក់នៅក្នុងលិខិតអនុវត្ត ហើយអានុភាពអនុវត្តនៃលិខិតអនុវត្តនោះត្រូវបានបញ្ជាក់តាមទម្រង់យថាភូតដោយការផ្តល់រូបមន្តអនុវត្ត ដែលជាសេចក្តីសរសេរបន្ថែមនៅក្នុងលិខិតនោះ។

តាមរយៈវិធីនេះធ្វើឱ្យមានភាពប្រាកដថា ម្ចាស់បំណុលនៃការអនុវត្តមានសិទ្ធិទាមទារ ចំពោះអាជ្ញាធរឱ្យធ្វើការអនុវត្តដោយបង្ខំ។ ក្នុងន័យនេះ សិទ្ធិទាមទារផ្តល់តាវកាលិក ដែលកំណត់ដោយច្បាប់សារធាតុត្រូវបានបញ្ជាក់នៅក្នុងឯកសារមួយ ដែលហៅថាលិខិតចម្លងយថាភូតនៃលិខិតអនុវត្ត ដែលមានអានុភាពអនុវត្តហើយឯកសារនេះនឹងក្លាយទៅជាមូលដ្ឋាននៃនីតិវិធីនៃការអនុវត្តដោយបង្ខំ។

**១.៣.២.២ ប្រភេទនៃលិខិតអនុវត្ត**

ដើម្បីធ្វើការអនុវត្តដោយបង្ខំបានលិខិតអនុវត្ត គឺជាឯកសារយ៉ាងសំខាន់ដែលមិនអាចខ្វះបានក្នុងការចាប់ផ្តើមការអនុវត្តដោយបង្ខំ។ លិខិតអនុវត្តមានច្រើនប្រភេទដូចជា៖

**ក. សាលក្រម ឬ សាលដីកាបង្គាប់ឱ្យផ្តល់តាវកាលិកដែលបានចូលជាស្ថាពរ**

សាលក្រម ឬ សាលដីកាបង្គាប់ឱ្យផ្តល់តាវកាលិក ដែលចេញដោយតុលាការនៃព្រះរាជាណាចក្រកម្ពុជាហើយបានចូលជាស្ថាពរត្រូវបានទទួលស្គាល់ថាជាលិខិតអនុវត្ត ដែលមានបញ្ញត្តិក្នុងមាត្រា ៣៥០ កថាខណ្ឌទី២ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ក្នុងចំណោមសាលក្រម ឬ សាលដីកាចុងក្រោយ ដែលបានចូលជាស្ថាពរមានតែសាលក្រម ឬ សាលដីកា ដែលបង្គាប់ឱ្យផ្តល់តាវកាលិកប៉ុណ្ណោះ ដែលមានអានុភាពអនុវត្ត។ ទោះបីជាក្នុងករណីសាលក្រម ឬ សាលដីកា ដែលពាក់ព័ន្ធជាសាលក្រម ឬ សាលដីកាបង្គាប់ឱ្យផ្តល់តាវកាលិកក៏ដោយប្រសិនបើការអនុវត្តដោយបង្ខំមិនអាចធ្វើទៅបាន អាស្រ័យដោយចរិតលក្ខណៈនៃសិទ្ធិទាមទារឱ្យផ្តល់តាវកាលិកនោះ មានន័យថាសាលក្រម ឬ សាលដីកាពុំមានអានុភាពអនុវត្តទេ។

**ខ. សាលក្រម ឬ សាលដីកាចុងក្រោយ ដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន**

លិខិតអនុវត្តចំពោះសាលក្រម ឬ សាលដីកាចុងក្រោយ ដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ដែលចែងក្នុងមាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច ខ នៃក្រមនីតិវិធីរដ្ឋប្បវេណី គឺស្រដៀងគ្នាទៅនឹងករណីនៃសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរដែរ ដោយសារថាការអនុវត្តដោយបង្ខំដែលផ្អែកលើសាលក្រម ឬ សាលដីកាបង្គាប់ឱ្យផ្តល់តាវកាលិក ដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តដោយបង្ខំ និងធ្វើឱ្យមានការវិវត្តទៅដល់ការសម្រេចនូវសិទ្ធិទាមទារជាស្ថាពរ។ ដូច្នេះការសម្រេចសិទ្ធិនេះមិនមានលក្ខណៈបណ្តោះអាសន្នទេ។

**គ. ដីកាសម្រេចបង្គាប់ឱ្យផ្តល់តាវកាលិក**

ជាគោលការណ៍ដីកាសម្រេចមានអានុភាពភ្លាមបន្ទាប់ពីបានធ្វើការជូនដំណឹង។ ប្រសិនបើដីកាសម្រេចនោះ គឺជាដីកាសម្រេចបង្គាប់ឱ្យផ្តល់តាវកាលិក ដីកាសម្រេចនោះត្រូវមានអានុភាពអនុវត្ត។ ក៏ប៉ុន្តែដីកាសម្រេច

ដែលត្រូវបានកំណត់ថាមិនមានអានុភាពបើមិនទាន់ចូលជាស្ថាពរ មិនអាចក្លាយជាលិខិតអនុវត្តបានទេរហូតដល់ពេលចូលជាស្ថាពរ។

**ឃ.ដីកាសម្រេចដាស់តឿន ដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន**

បញ្ញត្តិមាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច ឃ កំណត់ថាប្រសិនបើកូនបំណុលមិនបានដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿនក្នុងអំឡុងពេលពីរសប្តាហ៍បន្ទាប់ពីថ្ងៃ ដែលបានទទួលការបញ្ជូនដីកាសម្រេចដាស់តឿន ឬ ប្រសិនបើដីកាសម្រេច ដែលលើកចោលនូវពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿនបានចូលជាស្ថាពរ[33] នោះការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន នឹងត្រូវបានភ្ជាប់ជាមួយដីកាសម្រេចដាស់តឿន ហើយដីកាសម្រេចដាស់តឿន ដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តដោយបណ្តោះអាសន្ននោះ នឹងក្លាយទៅជាលិខិតអនុវត្ត។

**ខ. ការចាត់ចែងរបស់ក្រឡាបញ្ជី ដែលកំណត់អំពីចំនួនប្រាក់ប្រដាប់ក្តី**

បន្ទាប់ពីតុលាការបានវិនិច្ឆ័យអំពីភាគ និងបន្ទុកនៃប្រាក់ប្រដាប់ក្តី ហើយចំនួនទឹកប្រាក់លម្អិតត្រូវកំណត់ដោយក្រឡាបញ្ជីនៃសាលាដំបូងតាមពាក្យសុំរបស់ភាគី[34]។ ភាគីម្ខាងអាចធ្វើការអនុវត្តដោយបង្ខំឱ្យភាគីម្ខាងទៀតសងប្រាក់ប្រដាប់ក្តី ដោយយកការចាត់ចែងរបស់ក្រឡាបញ្ជីនេះធ្វើជាលិខិតអនុវត្ត។

**ច. លិខិតយថាភូត ដែលធ្វើឡើងដោយសារការី**

កថាខណ្ឌទី ២ ចំណុច ច ក្នុងមាត្រា ៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី មានខ្លឹមសារចែងថាលិខិតយថាភូតដែលធ្វើដោយសារការី និងបានបំពេញតាមលក្ខខណ្ឌទាមទារមួយចំនួន ត្រូវបានទទួលស្គាល់ថាមានអានុភាពអនុវត្តក្នុងលក្ខណៈជាលិខិតអនុវត្ត ហៅថាលិខិតបញ្ជាក់អនុវត្ត។ ដោយសារថាការអនុវត្តដោយបង្ខំអាចធ្វើឡើងបានភ្លាមដោយពុំចាំបាច់ឆ្លងកាត់តាមបណ្តឹង។ ម៉្យាងវិញទៀតទោះបីជាលិខិតយថាភូត ដែលធ្វើដោយសារការីត្រូវបានធ្វើឡើងដោយយកសុពលភាពនៃកិច្ចសន្យានៅក្រោមច្បាប់សារធាតុមកជាបុរេលក្ខខណ្ឌក៏ដោយ លិខិតនេះមិនកំណត់ជាស្ថាពរនូវសុពលភាពនៃកិច្ចសន្យាទេ ពោលគឺពុំដូចគ្នាទៅនឹងសាលក្រម ឬ សាលដីកាស្ថាពរឡើយ។

គ្រាន់តែជាសិទ្ធិអំណាចនៅក្នុងការត្រួតពិនិត្យរបស់សារការី ដែលត្រូវបានកម្រិតតែប៉ុណ្ណោះ ដោយហេតុថាលិខិតយថាភូត ដែលធ្វើដោយ សារការីត្រូវបានធ្វើឡើងមិនផ្អែកទៅលើការពិនិត្យ និងទទួលស្គាល់អង្គហេតុ និងការសម្រេចសេចក្តីតាមផ្លូវច្បាប់របស់ចៅក្រមទេ។ ដោយសារថាលទ្ធភាពដែលនាំឱ្យមានការអនុវត្តមិនត្រឹមត្រូវមាន ទ្រង់ទ្រាយធំទើបអានុភាពអនុវត្តត្រូវបានទទួលស្គាល់តែចំពោះលិខិតយថាភូតធ្វើដោយសារការី ដែលមានកម្មវត្ថុជាសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ប៉ុណ្ណោះ ព្រោះមានភាពងាយស្រួលក្នុងការធ្វើ

[33] . មាត្រា ៣២៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[34] . មាត្រា ៦៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

បដិទាននូវផលប្រយោជន៍ ដែលបានទទួលរងដោយសារការអនុវត្តដោយបង្ខំ ឬ ក្នុងការសងសំណងនៃការខូចខាត ប្រសិនបើការអនុវត្តដោយបង្ខំនោះធ្វើឡើងដោយមិនត្រឹមត្រូវ។

**ឆ. សាលក្រម ឬ សាលដីការបស់តុលាការបរទេស ដែលមានសាលក្រមអនុវត្តបានចូលជាស្ថាពរ**

លិខិតអនុវត្ត អាចជាសាលក្រម ដែលផ្តល់អានុភាពស្ថាពរទៅឱ្យសាលក្រម ឬ សាលដីការបស់តុលាការបរទេស ប្រសិនបើសាលក្រម ឬ សាលដីការបរទេសបានបំពេញគ្រប់លក្ខខណ្ឌនាំឱ្យសាលក្រម ឬ សាលដីកាបរទេសនោះ ត្រូវបានទទួលស្គាល់នូវអានុភាព ដូចជាសាលក្រម ឬ សាលដីកាស្ថាពររបស់តុលាការកម្ពុជាដែរ[35]។ ក្នុងករណីដែលអានុភាពនៃសាលក្រម ឬ សាលដីកាបរទេសក្លាយទៅជាបញ្ហាវិវាទនៅក្នុងនីតិវិធីបណ្តឹងនៅតុលាការកម្ពុជា នោះតុលាការ ដែលទទួលបន្ទុកនូវបណ្តឹងនេះគ្រាន់តែធ្វើការវិនិច្ឆ័យថា តើលក្ខខណ្ឌទាមទារនៃមាត្រា ១៩៩ ត្រូវបានបំពេញគ្រប់ដែរឬទេនោះគឺជាការគ្រប់គ្រាន់ហើយ។

ម្យ៉ាងវិញទៀត ប្រសិនបើការអនុវត្តដោយបង្ខំត្រូវបានធ្វើឡើងដោយផ្អែកលើសាលក្រម ឬ សាលដីកាបរទេសនោះ ការវិនិច្ឆ័យអំពីលក្ខខណ្ឌទាមទារសម្រាប់ការទទួលស្គាល់សាលក្រម ឬសាលដីកាបរទេសនៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំពុំមែនជាទង្វើត្រឹមត្រូវឡើយព្រោះថាស្ថាប័ន ដែលផ្តល់រូបមន្តអនុវត្ត និងស្ថាប័នអនុវត្តត្រូវបានបង្កើតឡើងដោយផ្តោតភាពសំខាន់ទៅលើការសម្រេចនូវសិទ្ធិ ដែលមានលក្ខណៈឆាប់រហ័ស និងមានប្រសិទ្ធិភាព។

**ជ.សេចក្តីសម្រេចមជ្ឈត្តករ ដែលមានដីកាសម្រេចអនុវត្ត ដែលបានចូលជាស្ថាពរ**

នីតិវិធីមជ្ឈត្តកម្ម គឺជានីតិវិធីនៃការដោះស្រាយវិវាទទៅជំនួសនីតិវិធីបណ្តឹងតាមផ្លូវតុលាការ ឬ ការដោះស្រាយពិសេស ដែលចេញដោយមជ្ឈត្តករហៅថា មជ្ឈត្តវិនិច្ឆ័យដែលជាលទ្ធផលនៃពីវិធីនេះមានអានុភាពចងចំពោះភាគីដូចជាសាលក្រម ឬ សាលដីកាស្ថាពរដែរ។ យ៉ាងណាក៏ដោយ ប្រសិនបើមានវិការៈនៅក្នុងនីតិវិធីមជ្ឈត្តកម្ម ភាគីអាចសុំឱ្យតុលាការលុបចោលមជ្ឈត្តវិនិច្ឆ័យបាន។

មាត្រា ៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណីបានទទួលស្គាល់ថាសេចក្តីសម្រេចមជ្ឈត្តករ គឺជាលិខិតអនុវត្ត។ ភាពចាំបាច់នៃការទទួលស្គាល់ដោយតុលាការកម្ពុជានូវអានុភាពនៃសេចក្តីសម្រេចរបស់មជ្ឈត្តករ ដោយចាត់ទុកថានេះ គឺជាបុរេលក្ខខណ្ឌសម្រាប់ការអនុវត្តដោយបង្ខំដោយផ្អែកលើសេចក្តីសម្រេច គឺដូចគ្នាទៅនឹងករណីនៃការអនុវត្តដោយបង្ខំតាមសាលក្រម ឬ សាលដីកាបរទេសដែរ។ ប៉ុន្តែចរិតលក្ខណៈ និងគុណសម្បត្តិនៃនីតិវិធីមជ្ឈត្តកម្ម គឺដោះស្រាយវិវាទបានយ៉ាងងាយស្រួល និងឆាប់រហ័សតាមរយៈនីតិវិធី ដែលមានលក្ខណៈបត់បែនដោយមជ្ឈត្តករជាបុគ្គលឯកជន។ ជាគោលការណ៍ ពាក្យសុំឱ្យចេញដីកាសម្រេចអនុវត្តសេចក្តីសម្រេចមជ្ឈត្តករ

[35]. មាត្រា ១៩៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការ ដែលបានកំណត់ទៅតាមលំនៅឋានជាអាទិ៍ របស់កូនបំណុលនៃការអនុវត្ត។ ប៉ុន្តែក្នុងករណីដែលពុំមានលំនៅឋានជាអាទិ៍ តុលាការ ដែលមានសមត្ថកិច្ច គឺសាលាដំបូងដែលមានសមត្ថកិច្ចលើកន្លែង ដែលកម្មវត្ថុនៃការទាមទារ ឬ ទ្រព្យរបស់កូនបំណុលនៃការអនុវត្ត ដែលអាចរឹបអូសបានស្ថិតនៅ។

**ឈ.កំណត់ហេតុ ដែលមានអានុភាពដូចសាលក្រម ឬសាលដីកា ដែលបានចូលជាស្ថាពរ**

កំណត់ហេតុនៃការទទួលស្គាល់ការទាមទារ និងកំណត់ហេតុនៃការសះជាតាមផ្លូវតុលាការ[36]សុទ្ធតែត្រូវបានរាប់ចូលជាកំណត់ហេតុ ដែលមានអានុភាពដូចសាលក្រម ឬ សាលដីកាស្ថាពរ ដែលបានកំណត់ក្នុងមាត្រា ៣៥០ កថាខណ្ឌទី២ ចំណុច ឈ។

**១.៣.៣ រូបមន្តអនុវត្ត**

ការអនុវត្តដោយបង្ខំត្រូវធ្វើឡើងដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្ត[37]។

**១.៣.៣.១ អត្ថន័យនៃរូបមន្តអនុវត្ត**

រូបមន្តអនុវត្ត គឺជាប្រយោគដែលក្រឡាបញ្ជី ឬ សារការីសរសេរភ្ជាប់បន្ថែមនៅផ្នែកខាងក្រោមនៃឯកសារចម្លងយថាភូតនៃលិខិតអនុវត្តវាបញ្ជាក់ជាផ្លូវការនូវអត្ថិភាព និងអត្ថន័យនៃអំណាចបង្ខំឱ្យអនុវត្តនៃលិខិតអនុវត្តនោះ។ ជាគោលការណ៍ ស្ថាប័នអនុវត្តត្រូវធ្វើការអនុវត្តដោយបង្ខំដោយផ្អែកលើឯកសារចម្លងយថាភូត នៃលិខិតអនុវត្ត ដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្ត។

**១.៣.៣.២ ប្រភេទនៃរូបមន្តអនុវត្ត**

ស្ថាប័នផ្តល់រូបមន្តអនុវត្តអាចផ្តល់រូបមន្តអនុវត្តពីរបែប ឬ ពីរប្រភេទ គឺរូបមន្តអនុវត្តធម្មតា និងរូបមន្តអនុវត្តពិសេស។

**- រូបមន្តអនុវត្តធម្មតា**

រូបមន្តអនុវត្តធម្មតា គឺជារូបមន្តដែលមានចុះសេចក្តីអនុញ្ញាតនៃការអនុវត្តដោយបង្ខំដូចបានកំណត់នៅក្នុងលិខិតអនុវត្ត។

ប្រសិនម្ចាស់បំណុលនៃការអនុវត្ត ដាក់ពាក្យសុំឱ្យផ្តល់រូបមន្តអនុវត្តចំពោះលិខិតអនុវត្ត ម្ចាស់បំណុលនៃការអនុវត្ត ត្រូវភ្ជាប់មកជាមួយនូវពាក្យសុំលិខិតបញ្ជាក់ការចូលជាស្ថាពរនៃសេចក្តីសម្រេចនោះ លើកលែងតែចំពោះករណី ដែលច្បាស់លាស់ថាសេចក្តីសម្រេចនោះបានចូលជាស្ថាពរហើយក្នុងសំណុំរឿង[38]។

[36] . មាត្រា ២២២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[37] . មាត្រា ៣៥៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[38] . មាត្រា ៣៥៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

**- រូបមន្តអនុវត្តពិសេស**

រូបមន្តអនុវត្តពិសេស គឺជារូបមន្តអនុវត្ត ដែលត្រូវបានផ្តល់ ដោយក្រឡាបញ្ជី ឬ សារការី ក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្តបានបញ្ជាក់អំពីការបំពេញនូវលក្ខខណ្ឌ ឬ បញ្ជាក់ពីការមកដល់នូវពេលកំណត់មិនពិតប្រាកដ ក្នុងករណីដែលសិទ្ធិទាមទារត្រូវបានកំណត់ក្នុងលិខិតអនុវត្តមានភ្ជាប់ជាមួយនឹងលក្ខខណ្ឌបង្អង់ ឬ ពេលកំណត់មិនពិតប្រាកដ។ ដើម្បីធ្វើការអនុវត្តដោយបង្ខំ ដោយយកបុគ្គលផ្សេងក្រៅពីភាគី ដែលត្រូវបានសរសេរនៅក្នុងលិខិតអនុវត្តធ្វើជាម្ចាស់បំណុលនៃការអនុវត្ត ឬ កូនបំណុលនៃការអនុវត្ត ម្ចាស់បំណុលនៃការអនុវត្តត្រូវទទួលការផ្តល់រូបមន្តអនុវត្ត ដែលសរសេរនូវហេតុការណ៍នោះ។

ក្នុងករណីដែលមានភាពច្បាស់លាស់ថា អាចនឹងធ្វើការអនុវត្តដោយបង្ខំបាន ដោយយកបុគ្គលផ្សេងក្រៅពីភាគី ដែលត្រូវបានកំណត់នៅក្នុងលិខិតអនុវត្ត ធ្វើជាម្ចាស់បំណុលនៃការអនុវត្ត ឬ កូនបំណុលនៃការអនុវត្ត ឬ ក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្តបានបញ្ជាក់អំពីហេតុការណ៍នោះ ក្រឡាបញ្ជី ឬ សារការីអាចផ្តល់នូវរូបមន្តអនុវត្តបាន។ នៅពេលដែលក្រឡាបញ្ជី ផ្តល់រូបមន្តអនុវត្ត ក្រឡាបញ្ជីនោះត្រូវទទួលសេចក្តីអនុញ្ញាតពីតុលាការ ដែលខ្លួនស្ថិតនៅ[39]។

**១.៣.៣.៣ ពាក្យសុំឱ្យផ្តល់រូបមន្តអនុវត្ត**

ពាក្យសុំឱ្យផ្តល់រូបមន្តអនុវត្ត ត្រូវធ្វើឡើងដោយលិខិតជាលាយលក្ខណ៍អក្សរ ដែលសរសេរចំណុចដូចខាងក្រោមនេះ៖

**ក.** ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត ហើយនិងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។

**ខ.** សញ្ញាណនៃលិខិតអនុវត្ត។

**គ.** ហេតុការណ៍ និងមូលហេតុបើការទាមទារឱ្យផ្តល់រូបមន្តអនុវត្ត ត្រូវធ្វើឡើងតាមបញ្ញត្តិនៃមាត្រា ៣៥៦ ឬ កថាខណ្ឌទី១ នៃមាត្រា ៣៥៨។ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវបញ្ជាក់អំពីចំណុចនានា ដែលស្ថាប័នផ្តល់រូបមន្ត ត្រូវស្រាវជ្រាវប្រសិនបើមានការចាំបាច់។ ឧទាហរណ៍៖ ម្ចាស់បំណុលនៃការអនុវត្តត្រូវដាក់លិខិតបញ្ជាក់អំពីការចូលជាស្ថាពរនៃសាលក្រម ឬ សាលដីកា។ ហើយប្រសិនបើពុំមានភាពច្បាស់លាស់នៅក្នុងសំណុំរឿងថាតើសាលក្រម ឬ សាលដីកានោះត្រូវបញ្ជាក់អំពីការផ្ទេរសមត្ថភាពធ្វើជាភាគីនៃការអនុវត្តដោយបង្ខំ ដោយគ្រាន់តែបញ្ជាក់នូវលិខិតអនុប្បទានសិទ្ធិលើបំណុល[40]។

---

[39]. មាត្រា ៣៥៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[40]. មាត្រា ៣៥៥ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

**១.៣.៣.៤ ស្ថាប័នផ្តល់រូបមន្តអនុវត្តដោយបង្ខំ និងនីតិវិធីផ្តល់រូបមន្តអនុវត្ត**

**ក.ស្ថាប័នផ្តល់រូបមន្តអនុវត្តដោយបង្ខំ**

ក្នុងករណីលិខិតអនុវត្ត គឺជាសាលក្រម ឬ សាលដីកា ស្ថាប័នដែលមានសិទ្ធិអំណាចក្នុងការផ្តល់រូបមន្តអនុវត្ត គឺក្រឡាបញ្ជីនៃតុលាការ ដែលមានសំណុំរឿងនោះ យោងទៅលើមាត្រា ៣៥៤ កថាខណ្ឌទី២ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ចំពោះករណីដែលលិខិតអនុវត្ត ជាសេចក្តីសម្រេចផ្សេងទៀតដូចជាកំណត់ហេតុរបស់តុលាការ (កំណត់ហេតុសះជា) ឬ ការចាត់ចែងរបស់ក្រឡាបញ្ជី ស្ថាប័នផ្តល់រូបមន្តអនុវត្ត គឺជាក្រឡាបញ្ជីដែលរក្សាទុកសំណុំរឿង ដែលជាឯកសារចាំបាច់សម្រាប់ការស្រាវជ្រាវអំពីអានុភាពនៃលិខិតអនុវត្តនោះ។ ប៉ុន្តែត្រូវបានលើកលែង ករណីដែលលិខិតអនុវត្តជាលិខិតយថាភូត ដែលធ្វើដោយសារការី រូបមន្តអនុវត្តត្រូវផ្តល់ដោយសារការី ដែលរក្សាទុកនូវលិខិតយថាភូតដើមនោះ។ មុនធ្វើការផ្តល់រូបមន្តអនុវត្តស្ថាប័នអនុវត្តត្រូវពិនិត្យនូវចំណុចមួយចំនួនដូចជា៖

- ស្ថាប័នអនុវត្តចាំបាច់ត្រូវតែស្រាវជ្រាវទៅលើសុពលភាពនៃលិខិតអនុវត្តថាតើមានអានុភាពអនុវត្តដែរ ឬយ៉ាងណា។
- ភាពសមស្របទៅនឹងស្ថានភាពជាក់ស្តែង ខ្លឹមសារនៃលិខិតអនុវត្ត គឺសំដៅលើការពិនិត្យកម្មវត្ថុ ដែលអាចអនុវត្តបាន សេចក្តីសម្រេចបានកំណត់ជាក់លាក់ និងលិខិតបញ្ជាក់អនុវត្តត្រូវបានបំពេញលក្ខខណ្ឌទាមទារគ្រប់ជ្រុងជ្រោយ។
- ការកើតឡើង និងមានអត្ថិភាព នៃអានុភាពអនុវត្ត របស់លិខិតអនុវត្ត សំដៅលើការចូលជាស្ថាពរនៃសេចក្តីសម្រេចរបស់តុលាការ ហើយបន្តមានអានុភាពបើពុំទាន់ចូលជាស្ថាពរតម្រូវឱ្យមានភ្ជាប់នូវការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន និងមិនត្រូវបានរលត់។
- បានបំពេញលក្ខខណ្ឌបង្អង់ និងការមកដល់នូវពេលកំណត់។

**ខ.នីតិវិធីផ្តល់រូបមន្តអនុវត្ត**

ជាគោលការណ៍ការផ្តល់រូបមន្តអនុវត្ត មិនចាំបាច់ជូនដំណឹងទៅកូនបំណុលនៃការអនុវត្តនោះទេ។ ការផ្តល់រូបមន្តអនុវត្តត្រូវធ្វើឡើងតាមវិធីសរសេរភ្ជាប់បន្ថែមនៅផ្នែកក្រោយ នៃឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត។ នៅក្នុងរូបមន្តអនុវត្តមានចំណុចមួយចំនួនចាំបាច់ត្រូវតែសរសេរដូចជា៖

- បុគ្គលដែលអាចទាមទារ ឱ្យធ្វើការអនុវត្តដោយបង្ខំបានដោយលិខិតអនុវត្ត និងភាគីម្ខាងទៀត
- ហេតុការណ៍ក្នុងករណី ដែលត្រូវបានផ្តល់រូបមន្តអនុវត្ត តាមបញ្ញត្តិស្តីពីការផ្តល់រូបមន្តពិសេស
- ទំហំដែលអាចអនុវត្តដោយបង្ខំបាន បើបានផ្តល់រូបមន្តអនុវត្តតែមួយផ្នែក នៃសិទ្ធិទាមទារដែលត្រូវបានកំណត់នៅក្នុងលិខិតអនុវត្ត
- ហេតុការណ៍ក្នុងករណី ដែលផ្តល់រូបមន្តអនុវត្តច្រើនច្បាប់។

នៅចុងបញ្ចប់នៃរូបមន្តអនុវត្ត ក្រឡាបញ្ជី ឬ សារការីត្រូវចុះហត្ថលេខាលើរូបមន្តអនុវត្តដោយសរសេរកាលបរិច្ឆេទនៃការផ្តល់។

យ៉ាងណាមិញ ក្នុងករណីមួយចំនួនពុំចាំបាច់ត្រូវការរូបមន្តអនុវត្តនោះទេ ដូចជារឿងក្តីទឹកប្រាក់តិច[41] រឿងក្តីដែលភ្ជាប់ជាមួយប្រកាសឱ្យអនុវត្តដោយបង្ខំជាបណ្តោះអាសន្ន និងដីការសម្រេចដាស់តឿន ដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន។

**១.៣.៣.៥ ពាក្យសុំតវ៉ាអំពីការផ្តល់រូបមន្តអនុវត្ត**

ពាក្យសុំតវ៉ាអំពីការផ្តល់រូបមន្តអនុវត្ត គឺជាការសង្គ្រោះមួយសម្រាប់ម្ចាស់បំណុលនៃការអនុវត្ត ក្នុងនីតិវិធីផ្តល់រូបមន្តអនុវត្ត។ ពាក្យសុំតវ៉ាអាចនឹងដោយសារមូលហេតុដូចជា៖

- ដើម្បីបដិសេធការផ្តល់រូបមន្តអនុវត្តរបស់ក្រឡាបញ្ជី ឬ សារការី។

- តវ៉ាការមិនផ្តល់រូបមន្តអនុវត្តពិសេសរបស់ស្ថាប័នផ្តល់រូបមន្តអនុវត្ត។

របៀបនៃការដាក់ពាក្យសុំតវ៉ា គឺត្រូវដាក់ទៅកាន់តុលាការដែលក្រឡាបញ្ជីស្ថិតនៅ ឬ សាលាដំបូងនៃទីតាំងការិយាល័យសារការីស្ថិតនៅ។

ការសម្រេចសេចក្តីចំពោះការសុំតវ៉ា គឺចេញដោយដីកាសម្រេចដោយពិនិត្យទៅលើភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃការតវ៉ា ហើយតុលាការអាចធ្វើការលើកចោលនូវពាក្យសុំតវ៉ា បើយល់ថាពាក្យស្នើសុំពុំត្រឹមត្រូវ ឬ អាចបង្គាប់ឱ្យស្ថាប័នផ្តល់រូបមន្តអនុវត្ត ធ្វើការផ្តល់រូបមន្តអនុវត្តដោយបញ្ជាក់អំពីមូលហេតុ ដែលត្រូវផ្តល់នូវក្នុងដីកាសម្រេច។

**១.៣.៤ សោហ៊ុយសម្រាប់ការអនុវត្ត និងសោហ៊ុយសម្រាប់នីតិវិធី**

**១.៣.៤.១ អត្ថន័យសោហ៊ុយសម្រាប់ការអនុវត្ត និងសោហ៊ុយសម្រាប់នីតិវិធី**

សោហ៊ុយសម្រាប់ការអនុវត្ត គឺសំដៅទៅលើការចំណាយរបស់ភាគីត្រូវចំណាយមុននឹងតុលាការអនុវត្តចាប់ផ្តើមធ្វើការអនុវត្តដោយបង្ខំ។ សោហ៊ុយសម្រាប់ការអនុវត្តរួមមាន[42]៖

- ពន្ធដាក់ពាក្យសុំ

- សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ

- និងសោហ៊ុយភាគី សំដៅលើសោហ៊ុយ ដែលតុលាការយល់ឃើញថាចាំបាច់ដើម្បីធ្វើការអនុវត្តដោយបង្ខំ។

រីឯសោហ៊ុយសម្រាប់នីតិវិធី គឺសំដៅទៅលើសោហ៊ុយសម្រាប់ផលប្រយោជន៍រួម ក្នុងចំណោមសោហ៊ុយសម្រាប់ការអនុវត្ត[43]។

[41] . មាត្រា ២២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[42] . មាត្រា ៣៧១ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[43] . មាត្រា ៣៧១ ចំណុច ខ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

**១.៣.៤.២ ការចំណាយ**

**ក. ការបង់ពន្ធដាក់ពាក្យសុំ និងប្រាក់សោហ៊ុយសម្រាប់ការអនុវត្ត**

ផ្អែកតាមបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា ៣៧២ បានកំណត់ថា ការបង់ពន្ធដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ត្រូវបានបែងចែកចេញជាពីរយ៉ាង បើការដាក់ពាក្យសុំអនុវត្តដោយបង្ខំនៅតុលាការអនុវត្ត គឺម្ចាស់បំណុលនៃការអនុវត្តត្រូវបង់ពន្ធដាក់ពាក្យសុំ ១០,០០០រៀល ក៏ប៉ុន្តែបើការដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំនៅអាជ្ញាសាលា ម្ចាស់បំណុលនៃការអនុវត្តត្រូវបង់ពន្ធតាមបញ្ញត្តិដែលកំណត់ផ្សេងទៀត។ ការបង់សោហ៊ុយត្រូវតែធ្វើឡើងជាមុន មានន័យថាអ្នកដាក់ពាក្យសុំ (ម្ចាស់បំណុលនៃការអនុវត្ត) ត្រូវតែបង់ជាមុននូវចំនួនទឹកប្រាក់ ដែលតុលាការអនុវត្តកំណត់ថាជាសោហ៊ុយចាំបាច់ ក្នុងការអនុវត្តនីតិវិធីនៃការអនុវត្តដោយបង្ខំ[44]។ ម៉្យាងវិញទៀត ប្រសិនបើកំឡុងពេលនៃនីតិវិធីមានការខ្វះខាត ឬ ប្រើប្រាស់មិនគ្រប់តុលាការមានសិទ្ធិពេញលេញបង្គាប់ឱ្យបង់បន្ថែម។

ការដែលមិនបង់សោហ៊ុយនៃការអនុវត្តជាមុនទេ តុលាការអនុវត្ត អាចធ្វើការលើកចោលនូវពាក្យសុំឱ្យអនុវត្តដោយបង្ខំ ឬ អាចលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំនោះបាន[45]។ ចំពោះដីកាសម្រេចលើកចោលនូវពាក្យសុំនេះអាចធ្វើការប្តឹងជំទាស់បាន[46]។

បន្ទុកនៃសោហ៊ុយសម្រាប់ការអនុវត្តផ្អែកទៅតាមក្រមនីតិវិធីរដ្ឋប្បវេណី គឺជាបន្ទុករបស់កូនបំណុលនៃការអនុវត្ត ដោយហេតុថាកូនបំណុលនៃការអនុវត្ត ជាអ្នកដែលធ្វើឱ្យខូចខាតដល់ម្ចាស់បំណុលនៃការអនុវត្ត ដូច្នេះហើយវាជារឿងសមរម្យ ដែលកូនបំណុលនៃការអនុវត្តត្រូវតែជាអ្នកចំណាយ។

**ខ. ការដាក់ប្រាតិភោគ**

ការដាក់ប្រាតិភោគ គឺមានគោលបំណង ដើម្បីស្នើសុំទៅកាន់តុលាការអនុវត្តឱ្យផ្អាក ឬ លុបចោលការអនុវត្តដោយបង្ខំ ពោលកូនបំណុលនៃការអនុវត្តដាក់ប្រាក់តម្កល់ ដើម្បីធានាការផ្អាក ឬ លុបចោលការអនុវត្តដោយបង្ខំនោះ។ ការដាក់ប្រាតិភោគ នៅក្នុងនីតិវិធីអនុវត្តដោយបង្ខំត្រូវធ្វើឡើងតាមវិធីផ្ញើប្រាក់ ឬ ឧបករណ៍អាចជួញដូរបាន ហើយចាំបាច់ត្រូវបានតុលាការទទួលស្គាល់ថាសមរម្យទើបអាចធ្វើទៅបាន[47]។

**១.៣.៥ វិធីប្តឹងឧបាស្រ័យចំពោះការអនុវត្ត**

នៅពេលដែលធ្វើការអនុវត្តដោយបង្ខំស្ថាប័នអនុវត្ត (តុលាការអនុវត្ត និងអាជ្ញាសាលា) ត្រូវតែអនុវត្តអនុលោមទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានបានកំណត់ទុក។ ក៏ប៉ុន្តែក្នុងករណី ដែលមានការអនុវត្តបំពាន

[44]. មាត្រា ៣៧៥ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[45]. មាត្រា ៣៧៥ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[46]. មាត្រា ៣៧៥ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[47]. មាត្រា ៣៧៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

ទៅនឹងនីតិវិធីជាដើម ភាគីពាក់ព័ន្ធមានសិទ្ធិធ្វើបណ្ដឹងឧបាស្រ័យការពារផលប្រយោជន៍ស្របច្បាប់របស់ខ្លួន។ នីតិវិធីដើម្បីការពារផលប្រយោជន៍ខ្លួនចំពោះការអនុវត្តបំពានកិច្ចនីតិវិធី គឺធ្វើវិធីឧបាស្រ័យចំពោះការអនុវត្តដែលមានពីរយ៉ាងដូចជា ការតវ៉ាចំពោះការអនុវត្ត និងបណ្ដឹងជំទាស់។

**១.៣.៥.១ ការតវ៉ាចំពោះការអនុវត្ត**

ការតវ៉ា គឺជាបែបបទសម្រាប់ភាគី ឬ តតិយជន ដែលទទួលរងផលប៉ះពាល់ចំពោះផលប្រយោជន៍ខ្លួនក្នុងពេលដំណើរការការអនុវត្តដោយបង្ខំ។ ការតវ៉ាចំពោះការអនុវត្ត គឺជាវិធីឧបាស្រ័យ ដែលមានភាពងាយស្រួល និងឆាប់រហ័សជាងការដាក់ពាក្យបណ្ដឹងជំទាស់។

បុគ្គលដែលមានសិទ្ធិក្នុងការតវ៉ាចំពោះការអនុវត្ត គឺជាបុគ្គលដែលទទួលរងនូវផលប៉ះពាល់ដោយសារការចាត់ចែងការអនុវត្តខុសច្បាប់ ឬ ការធ្វេសប្រហែស ក្នុងការចាត់ចែងការអនុវត្ត រួមមានម្ចាស់បំណុលនៃការអនុវត្ត កូនបំណុលនៃការអនុវត្ត ម្ចាស់បំណុលដែលទាមទារការចែកចំណែក និងតតិយជនជាដើម។

នីតិវិធីនៃការប្ដឹងតវ៉ាចំពោះការអនុវត្ត អាចធ្វើបានដោយផ្ទាល់មាត់នៅកាលបរិច្ឆេទនៃនីតិវិធី ឬ ធ្វើជាលាយលក្ខណ៍អក្សរ[48] ទៅកាន់៖

- តុលាការអនុវត្តដែលពាក់ព័ន្ធផ្ទាល់ ប្រសិនបើការតវ៉ានោះជាការតវ៉ាចំពោះ ការចាត់ចែងការអនុវត្តរបស់តុលាការអនុវត្ត ហើយមិនអាចធ្វើការប្ដឹងជំទាស់បាន។
- សាលាដំបូង ដែលអាជ្ញាសាលាពាក់ព័ន្ធស្ថិតនៅ ប្រសិនបើការតវ៉ានោះធ្វើឡើងចំពោះការចាត់ចែងការអនុវត្តរបស់អាជ្ញាសាលា និងការយឺតយ៉ាវ ឬ ការធ្វេសប្រហែសក្នុងការចាត់ចែងការអនុវត្ត។

នៅពេលដែលមានការតវ៉ាចំពោះការអនុវត្ត ក៏ដំណើរការនៃនីតិវិធីអនុវត្តដោយបង្ខំ មិនត្រូវបានផ្អាកនោះទេ ក៏ប៉ុន្តែក្នុងអំឡុងពេលនៃដំណើរការនីតិវិធីដោះស្រាយចំពោះការតវ៉ានោះ ពោលគឺចាប់ពីពេលធ្វើការតវ៉ារហូតដល់ការចេញសេចក្ដីសម្រេចអំពីការតវ៉ាចំពោះការអនុវត្តកើតមានអានុភាព។

តុលាការអនុវត្តអាចចេញដីការសម្រេចផ្អាកនូវអានុភាពនៃដីកាសម្រេចដើម ដោយតម្រូវឱ្យមានការដាក់ប្រាតិភោគ ឬ មិនដាក់ប្រាតិភោគ ឬ ក៏ផ្អាកនូវនីតិវិធីនៃការអនុវត្តដោយបង្ខំទាំងស្រុង ឬ មួយផ្នែកដោយដាក់ ឬ មិនដាក់ប្រាតិភោគបាន[49]។

**១.៣.៥.២ បណ្ដឹងជំទាស់**

បណ្ដឹងជំទាស់ក្នុងនីតិវិធីអនុវត្តដោយបង្ខំ សំដៅទៅលើការប្ដឹងឧបាស្រ័យចំពោះការចាត់ចែងការអនុវត្តដោយតុលាការអនុវត្ត ដែលមានលក្ខណៈជាការសម្រេចសេចក្ដី ពោលគឺដីកាសម្រេចរបស់តុលាការអនុវត្ត

[48] . មាត្រា ៣៨៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[49] . មាត្រា ៣៨៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

ដូចជាសេចក្តីសម្រេចអនុញ្ញាតឱ្យលក់ជាដើមទៅកាន់តុលាការជាន់ខ្ពស់។ ជាគោលការណ៍ បណ្តឹងជំទាស់អាចធ្វើឡើងបានលុះត្រាតែសេចក្តីសម្រេចនោះបំពានទៅលើនីតិវិធីក្នុងច្បាប់ ឬ ផ្ទុយនឹងច្បាប់ហើយមានបញ្ញត្តិចែងច្បាស់លាស់បើកសិទ្ធិឱ្យធ្វើឧបាស្រ័យប្តឹងជំទាស់បាន។

បុគ្គលដែលមានសិទ្ធិក្នុងការធ្វើបណ្តឹងជំទាស់ គឺជាបុគ្គលដែលទទួលរងនូវផលប៉ះពាល់ដោយផ្ទាល់ ឬ ប្រយោល ដោយដីកាសម្រេចរួមមានម្ចាស់បំណុលនៃការអនុវត្ត កូនបំណុលនៃការអនុវត្ត ម្ចាស់បំណុលដែលទាមទារការចែកចំណែក និងតតិយជនជាដើម។

សេចក្តីសម្រេចដែលអាចធ្វើឧបាស្រ័យបណ្តឹងជំទាស់បានមានដូចជា៖

- ដីកាសម្រេចរបស់តុលាការអនុវត្ត ដែលលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំ
- ដីកាសម្រេចរបស់សាលាដំបូង ដែលបង្គាប់ឱ្យអាជ្ញាសាលាលុបចោលនីតិវិធីអនុវត្តដោយបង្ខំ
- ដីកាសម្រេចរបស់សាលាដំបូង ដែលលើកចោលពាក្យសុំតវ៉ាចំពោះការចាត់ចែងរបស់អាជ្ញាសាលាដែលលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំ
- និងដីកាសម្រេចផ្សេងៗទៀត ដែលបំពានទៅលើនីតិវិធីច្បាប់ ឬ ផ្ទុយនឹងច្បាប់។

ដើម្បីធ្វើបណ្តឹងជំទាស់បាន អ្នកដែលមានសិទ្ធិធ្វើបណ្តឹងជំទាស់ចាំបាច់ ធ្វើការដាក់ពាក្យប្តឹងជំទាស់ជាលាយលក្ខណ៍អក្សរក្នុងអំឡុងពេលមួយសប្តាហ៍[50] ដោយគិតចាប់ពីថ្ងៃ ដែលបានទទួលដំណឹងអំពីដីកាសម្រេចដោយមិនអាចពន្យារពេលបានឡើយទៅកាន់តុលាការដើម[51]។ បន្ទាប់ពីទទួលបានពាក្យបណ្តឹងជំទាស់ហើយតុលាការដើមត្រូវបញ្ជូនឱ្យបានឆាប់រហ័ស នូវពាក្យបណ្តឹងជំទាស់ និងសំណុំរឿងទៅតុលាការនៃបណ្តឹងជំទាស់[52]។ នៅពេលដែលមានការប្តឹងជំទាស់ អានុភាពនៃដីកាសម្រេចដើមមិនត្រូវបានផ្អាកឡើយ ក៏ប៉ុន្តែក្នុងអំឡុងពេលនៃដំណើរការនីតិវិធីដោះស្រាយបណ្តឹងជំទាស់ ពោលគឺចាប់ពីពេលដាក់ពាក្យបណ្តឹងជំទាស់ រហូតដល់សេចក្តីសម្រេចអំពីបណ្តឹងជំទាស់កើតមានអានុភាព តុលាការនៃបណ្តឹងជំទាស់អាចចេញដីកាសម្រេចផ្អាកនូវអានុភាពនៃដីកាសម្រេចដើម ដោយតម្រូវឱ្យមានការដាក់ប្រាតិភោគ ឬ មិនដាក់ប្រាតិភោគ ឬ មួយក៏ផ្អាកនូវនីតិវិធីនៃការអនុវត្តដោយបង្ខំមួយផ្នែក ឬ ទាំងស្រុង ដោយបង្គាប់ឱ្យមានការដាក់ប្រាតិភោគ ឬ មិនឱ្យដាក់ប្រាតិភោគ[53]។

[50] . មាត្រា ៣០៣ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[51] . មាត្រា ៣០១ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[52] . មាត្រា ៣០១ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[53] . មាត្រា ៣៤៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

# ជំពូកទី ២

# លំហូនីតិវិធីនៃការអនុវត្តដោយបង្ខំ

# ចំពោះចលនវត្ថុ

# ជំពូកទី ២

# លំហូរនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ

## ២.១ ការរៀបចំដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុ

### ២.១.១. ការជូនដំណឹង និងការជ្រើសរើស

មុនពេលចាប់ផ្ដើមការអនុវត្តដោយបង្ខំ ម្ចាស់បំណុលនៃការអនុវត្តតែងចង់បានការអនុវត្តដោយស្ម័គ្រចិត្ត ព្រោះអាចទទួលបានការចំណេញប្រាក់ និងពេលវេលា។ ហើយបើគ្មានការអនុវត្តដោយស្ម័គ្រចិត្តទេ ទើបឈានដល់ការអនុវត្តដោយបង្ខំ។ នៅក្នុងការអនុវត្តនាពេលបច្ចុប្បន្ន គេសង្កេតឃើញមានការជូនដំណឹងអំពីការអនុវត្តដោយស្ម័គ្រចិត្ត បន្ទាប់ពីស្ថាប័នអនុវត្តបានទទួលនូវពាក្យសុំឱ្យអនុវត្តដោយបង្ខំ ដែលនៅក្នុងករណីនេះអាចមាននូវចំណុចវិជ្ជមាន និងអវិជ្ជមាន ដូចខាងក្រោម៖

- **ចំណុចវិជ្ជមាន៖** ប្រសិនបើមានការជូនដំណឹងឱ្យកូនបំណុលនៃការអនុវត្ត ព្រមអនុវត្តដោយស្ម័គ្រចិត្ត ហើយនៅពេលដែលកូនបំណុលនៃការអនុវត្តបានទទួលលិខិតជូនដំណឹងនេះ កូនបំណុលនៃការអនុវត្តអាចនឹងមានការភ័យខ្លាច ហើយកូនបំណុលនៃការអនុវត្ត ក៏អាចយកប្រាក់មកសងតាមការបង្គាប់របស់ស្ថាប័នអនុវត្ត នោះនឹងឆាប់សម្រេចបាននូវសិទ្ធិទាមទាររបស់ម្ចាស់បំណុលនៃការអនុវត្ត ក៏ដូចជាធ្វើឱ្យស្ថាប័នអនុវត្តឆាប់បានបញ្ចប់រឿងក្ដីអនុវត្តផងដែរ។
- **ចំណុចអវិជ្ជមាន៖** ផ្ទុយទៅវិញប្រសិនបើកូនបំណុលនៃការអនុវត្តបន្ទាប់ពីទទួលបានលិខិតជូនដំណឹងនោះរួចមក កូនបំណុលនៃការអនុវត្ត ក៏អាចមានឱកាសធ្វើការចាត់ចែងនូវទ្រព្យ ដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំបានដូចជា ការផ្ទេរ ការប្រទានកម្ម ជាដើម។ ករណីនេះ អាចនឹងធ្វើឱ្យម្ចាស់បំណុលនៃការអនុវត្ត រងនូវការខូចខាតប្រយោជន៍យ៉ាងធ្ងន់ធ្ងរ តាមរយៈការជូនដំណឹងឱ្យអនុវត្តដោយស្ម័គ្រចិត្តនេះ ហើយជាពិសេស ចំពោះការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ប្រសិនបើអាជ្ញាសាលា ដែលទទួលបន្ទុកក្នុងការអនុវត្ត បានជូនដំណឹងឱ្យអនុវត្តដោយស្ម័គ្រចិត្ត គឺកូនបំណុលនៃការអនុវត្តមានឱកាសជាច្រើនក្នុងការធ្វើអនុប្បទាន ចាត់ចែងនូវចលនវត្ថុនោះ។ ហេតុដូច្នេះ ហើយស្ថាប័នអនុវត្តពុំគួរធ្វើការជូនដំណឹងឱ្យអនុវត្តដោយស្ម័គ្រចិត្ត នៅមុនពេល ការរឹបអូសមានអានុភាពនោះទេ។

ក្នុងករណី ដែលកូនបំណុលមិនយល់ព្រមអនុវត្តដោយស្ម័គ្រចិត្តអំពីការសងសិទ្ធិលើបំណុល ដែលមានចែងក្នុងលិខិតអនុវត្តនោះទេ ទើបឈានដល់ដំណាក់កាល ដែលម្ចាស់បំណុលនៃការអនុវត្តត្រូវប្រើសិទ្ធិ ដើម្បីសម្រេចនូវសិទ្ធិទាមទាររបស់ខ្លួន តាមរយៈនីតិវិធីនៃការអនុវត្តដោយបង្ខំ។ ដូចដែលយើងបានដឹងហើយថាការអនុវត្តដោយបង្ខំដែលមានគោលបំណងឱ្យសងជាប្រាក់មានចំនួន **៤ វិធី** ដូចជា៖ **ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ឬសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត**

និង**ការអនុវត្តដោយបង្ខំចំពោះនាវា**។ ជាមួយគ្នានេះដែរ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវធ្វើការថ្លឹងថ្លែង និងគប្បីធ្វើការជ្រើសរើសនូវប្រភេទនៃការអនុវត្តដោយបង្ខំណាមួយ ដែលងាយ និងឆាប់សម្រេចនូវសិទ្ធិទាមទាររបស់ខ្លួន។ ជាក់ស្តែងករណីសិទ្ធិទាមទារជាប្រាក់ដែលមានចំនួនតិច គប្បីជ្រើសរើសនូវការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ដែលងាយ និងឆាប់រហ័សជាងប្រភេទនៃការអនុវត្តដោយបង្ខំផ្សេងទៀត។ នៅក្នុងការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ មិនចាំបាច់ទាមទារឱ្យម្ចាស់បំណុលនៃការអនុវត្ត ធ្វើការស្រាវជ្រាវអំពីទ្រព្យសម្បត្តិជាចលនវត្ថុរបស់កូនបំណុលនៃការអនុវត្តនោះទេ ពោលគឺគ្រាន់តែបញ្ជាក់ថាសុំអនុវត្តចំពោះចលនវត្ថុរបស់កូនបំណុលដោយត្រូវបញ្ជាក់អំពីទីតាំងនៃចលនវត្ថុជាការចាំបាច់។

### ២.១.២ ការសរសេរពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុ

ជាគោលការណ៍ការអនុវត្តដោយបង្ខំ ត្រូវធ្វើឡើងដោយស្ថាប័នអនុវត្ត តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត[54] ដែលម្ចាស់បំណុលនៃការអនុវត្ត ត្រូវសរសេរពាក្យសុំឱ្យអនុវត្តចំពោះចលនវត្ថុ អនុលោមតាមមាត្រា ៣៤៩ កថាខណ្ឌទី២ ត្រូវសរសេរដូចខាងក្រោម៖

- ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត ហើយនិងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។ អ្នកតំណាងដែលច្បាប់បានកំណត់រួមមាន អ្នកដែលមានអំណាចមេបា អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកអាណាព្យាបាលទូទៅ និងហិតូបត្ថម្ភកៈ។
- សញ្ញាណនៃលិខិតអនុវត្ត៖ ត្រូវបញ្ជាក់អំពីប្រភព និងកាលបរិច្ឆេទនៃលិខិតអនុវត្ត។
- សញ្ញាណនៃទ្រព្យសម្បត្តិរបស់កូនបំណុល៖ គឺគ្រាន់តែបញ្ជាក់អំពីទីតាំងនៃចលនវត្ថុបានហើយ។

### ២.១.៣ ការដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុ

ម្ចាស់បំណុលនៃការអនុវត្ត ត្រូវយកពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ទៅដាក់នៅការិយាល័យអាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ច លើទីកន្លែងដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំស្ថិតនៅ[55]។

នៅក្នុងពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ត្រូវសរសេរអំពីទីកន្លែងដែលចលនវត្ថុស្ថិតនៅ ប៉ុន្តែមិនចាំបាច់ចង្អុលបង្ហាញចំៗ អំពីទ្រព្យសម្បត្តិ ដែលជាកម្មវត្ថុនៃការរឹបអូសនោះទេ[56]។

### ២.១.៤ ការពិនិត្យពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុ

នៅក្នុងមាត្រា ៣៣៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី បានអនុញ្ញាតឱ្យយកបញ្ញត្តិនៃមាត្រាមួយចំនួនដែលមានចែងក្នុងនីតិវិធីបណ្តឹងចាប់ពីគន្ថីទី២ ដល់គន្ថីទី៤ លើកលែងតែមានបញ្ញត្តិពិសេសក្នុងគន្ថីទី៦។ មានន័យថា

[54] . មាត្រា ៣៥៦ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[55] . មាត្រា ៣៨៥ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[56] . មាត្រា ៣៨៥ កថាខណ្ឌទី ២ នៃក្រមនីតិវិធិរដ្ឋប្បវេណី ឆ្នាំ ២០០៦

ការពិនិត្យពាក្យបណ្តឹង ដែលចែងក្នុងមាត្រា ៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ក៏អាចត្រូវយកមកអនុវត្តនៅក្នុងការពិនិត្យពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុដោយអាជ្ញាសាលាផងដែរ។

អាជ្ញាសាលា ត្រូវធ្វើការពិនិត្យនូវពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ដែលបានធ្វើឡើងដោយម្ចាស់បំណុលនៃការអនុវត្ត នៅមុនការចាប់ផ្តើមនីតិវិធីនៃការអនុវត្តដោយបង្ខំ ដូចខាងក្រោមៈ

- **តើអាជ្ញាសាលាមានសមត្ថកិច្ចលើការអនុវត្តនេះដែរ ឬទេ?**

នៅពេលអាជ្ញាសាលា ទទួលបានពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុ អាជ្ញាសាលា ត្រូវធ្វើការពិនិត្យជាបឋមអំពីសមត្ថកិច្ចនៃការអនុវត្តជាមុនសិន ថាតើការអនុវត្តដោយបង្ខំនេះ ស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួនដែរ ឬទេ?

ក្នុងករណីដែលអាជ្ញាសាលា ពិនិត្យឃើញថា ការអនុវត្តដោយបង្ខំនេះមិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួនទេនោះ អាជ្ញាសាលា អាចធ្វើការចាត់ចែងផ្ទេររឿងក្តីទៅឱ្យអាជ្ញាសាលា ដែលមានសមត្ថកិច្ច ឬ ស្ថាប័នអនុវត្តដែលមានសមត្ថកិច្ចបាន[57]។ ប្រសិនបើអាជ្ញាសាលា បានធ្វើការពិនិត្យលើពាក្យសុំទៅឃើញថាខ្លួនមានសមត្ថកិច្ចហើយ អាជ្ញាសាលា នឹងចាប់ផ្តើមធ្វើការពិនិត្យលើពាក្យសុំបន្តទៀតបាន។

- **តើពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុ បានបំពេញនូវលក្ខខណ្ឌត្រឹមត្រូវតាមមាត្រា ៣៤៩ និងមាត្រា ៥២៤ ដែរ ឬទេ?**

ជាបន្ទាប់មកទៀត អាជ្ញាសាលា ត្រូវធ្វើការពិនិត្យលើទម្រង់នៃពាក្យសុំ ថាតើពាក្យសុំបានបំពេញតាមមាត្រា ៣៤៩ និងមាត្រា ៥២៥ ដែរ ឬទេ?

ក្នុងករណីអាជ្ញាសាលា ពិនិត្យឃើញថាពាក្យសុំឱ្យអនុវត្តនៅមានលក្ខណៈខ្វះខាត អាជ្ញាសាលាអាចបង្គាប់ឱ្យម្ចាស់បំណុលនៃការអនុវត្តធ្វើការកែតម្រូវតាមមាត្រា ៣៣៥ និងមាត្រា ៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីបាន។ ប្រសិនបើម្ចាស់បំណុលនៃការអនុវត្ត ពុំបានធ្វើការកែតម្រូវតាមការបង្គាប់ទេនោះ អាជ្ញាសាលា អាចលើកចោលនូវពាក្យសុំឱ្យអនុវត្តដោយបង្ខំនោះបាន។ ហើយប្រសិនបើអាជ្ញាសាលា បានធ្វើការពិនិត្យលើពាក្យសុំទៅឃើញថាពាក្យសុំឱ្យអនុវត្ត បានសរសេរត្រឹមត្រូវហើយនោះ អាជ្ញាសាលានឹងចាប់ផ្តើមធ្វើការពិនិត្យលើពាក្យសុំបន្តទៀតបាន។

- **តើភាគីនៅក្នុងពាក្យសុំឱ្យអនុវត្តដោយបង្ខំ និងភាគីនៅក្នុងលិខិតអនុវត្តនោះត្រឹមត្រូវ និងដូចគ្នាដែរ ឬទេ?**

បន្តមកទៀតនេះ អាជ្ញាសាលា ត្រូវធ្វើការផ្ទៀងផ្ទាត់មើលថា តើភាគីនៅក្នុងពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុ និងឈ្មោះភាគីនៅក្នុងលិខិតអនុវត្ត ក៏ដូចជារូបមន្តអនុវត្ត នោះមានដូចគ្នាដែរ ឬទេ?

---

[57]. មាត្រា ៣៣៥ និង មាត្រា ១៨ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

➢ **តើមានឯកសារភ្ជាប់គ្រប់គ្រាន់ដែរ ឬទេ?**

អាជ្ញាសាលាត្រូវធ្វើការពិនិត្យថាតើឯកសារ ដែលបានភ្ជាប់ជាមួយនឹងពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុមានភ្ជាប់ជាមួយនូវ លិខិតបញ្ជាក់ការចូលជាស្ថាពរ រូមមន្តអនុវត្ត លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិដែរ ឬទេ?

➢ **តើបានបង់ពន្ធលើពាក្យសុំឱ្យអនុវត្តតាមបញ្ញត្តិនៃមាត្រា ៣៧២ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី និងប្រការ ១៣ កថាខណ្ឌទី ១ នៃប្រកាសស្តីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាដែរ ឬទេ?**

នៅពេលដែលម្ចាស់បំណុលនៃការអនុវត្ត ដាក់ពាក្យសុំឱ្យអនុវត្តទៅអាជ្ញាសាលា ម្ចាស់បំណុលនៃការអនុវត្តត្រូវបង់ពន្ធដាក់ពាក្យសុំចំនួន ៥,០០០ រៀល ទៅសាលាដំបូងដែលមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលានោះស្ថិតនៅកក្រោម។

➢ **តើមានបានបញ្ជូននូវលិខិតអនុវត្តទៅកូនបំណុលនៃការអនុវត្តដែរ ឬទេ?**

ជាគោលការណ៍ លិខិតអនុវត្ត គឺជាមូលដ្ឋាននៃការអនុវត្តដោយបង្ខំ ហើយត្រូវតែបញ្ជូនទៅកូនបំណុលនៃការអនុវត្ត នៅមុនពេលចាប់ផ្តើមការអនុវត្ត ឬ យ៉ាងយូរបំផុតស្របពេលជាមួយនឹងការចាប់ផ្តើមការអនុវត្ត[58]។ មូលហេតុដែលមាត្រានេះតម្រូវឱ្យបញ្ជូនលិខិតអនុវត្តទៅជាអាទិ៍ គឺដើម្បីជូនដំណឹងទៅកូនបំណុលនៃការអនុវត្តឱ្យបានដឹងថា នីតិវិធីនៃការអនុវត្តនឹងចាប់ផ្តើមចំពោះសិទ្ធិលើបំណុលណាមួយ ក្នុងបំណងផ្តល់ឱកាសការពារខ្លួនដល់កូនបំណុលនៃការអនុវត្ត ប៉ុន្តែក្នុងករណីដែលត្រូវធ្វើការអនុវត្តដោយបង្ខំដោយសាលក្រម ឬ សាលដីកាស្ថាពរធ្វើជាលិខិតអនុវត្ត សាលក្រម ឬ សាលដីកានោះ ត្រូវប្រាកដថាបានបញ្ជូនទៅឱ្យភាគីរួចហើយ[59]។

ការបញ្ជូនលិខិតអនុវត្តជាមុន គឺជាភាពចាំបាច់ដែលត្រូវតែធ្វើ ហើយអាចមានលក្ខណៈខុសគ្នាអាស្រ័យទៅតាមប្រភេទនៃការអនុវត្តដោយបង្ខំ ជាក់ស្តែងដូចជា ចំពោះការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ឬ ការប្រគល់វត្ថុដោយអាជ្ញាសាលានោះ ការបញ្ជូនលិខិតអនុវត្តជាមុន អាជ្ញាសាលា គ្រាន់តែធ្វើការបញ្ជូននៅពេលជាមួយគ្នានឹងការចាប់ផ្តើមការអនុវត្តនៅទីកន្លែងនោះបាន។ តែចំពោះការអនុវត្តសិទ្ធិលើបំណុល ឬ អចលនវត្ថុ ការបញ្ជូនលិខិតបញ្ជាក់អនុវត្ត ចាំបាច់ត្រូវធ្វើនៅពេលដែលម្ចាស់បំណុលដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ។

➢ **តើមានបានបញ្ជូនរូបមន្តអនុវត្តពិសេស និងលិខិតបញ្ជាក់ហើយ ឬនៅ?**

ក្នុងករណីការអនុវត្តដោយបង្ខំ ត្រូវបានធ្វើឡើងដោយផ្អែក លើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្តពិសេសនោះ អាជ្ញាសាលា ត្រូវធ្វើការពិនិត្យមើលថាតើរូបមន្តអនុវត្តពិសេស និងលិខិតបញ្ជាក់ផ្សេងទៀត បានបញ្ជូនទៅឱ្យកូនបំណុលនៃការអនុវត្តហើយ ឬនៅ? ម៉្យាងវិញទៀត ប្រសិនបើ

[58]. មាត្រា ៣៦០ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[59]. មាត្រា ១៩០ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

រូបមន្តអនុវត្ត ត្រូវបានផ្តល់ដោយផ្អែកលើឯកសារដែលម្ចាស់បំណុលនៃការអនុវត្តបានដាក់នោះ ក៏ត្រូវធ្វើការបញ្ជូនឯកសារចម្លង ដែលមានសេចក្តីបញ្ជាក់នោះផងដែរ[60]។

- **តើពេលកំណត់ដែលត្រូវផ្តល់តាវកាលិកបានមកដល់ ឬនៅ ក្នុងករណីលិខិតអនុវត្តមានភ្ជាប់ជាមួយនឹងពេលកំណត់ពិតប្រាកដ?**

ក្នុងករណីសិទ្ធិលើបំណុល ដែលបានកំណត់ក្នុងលិខិតអនុវត្តមានភ្ជាប់ជាមួយនឹងរយៈពេលពិតប្រាកដ អាជ្ញាសាលា អាចចាប់ផ្តើមការអនុវត្តដោយបង្ខំចំពោះចលនវត្ថុបាន លុះត្រាណាតែពេលកំណត់នោះបានមកដល់[61]។ ទោះបីជាសិទ្ធិលើបំណុល ដែលមានពេលកំណត់ពិតប្រាកដ គឺជាចំណុចសារធាតុក៏ដោយ ប៉ុន្តែក៏មានភាពងាយស្រួល និងដឹងថាតើពេលកំណត់មកដល់ឬនៅដែរ។ ហេតុដូចនេះហើយក្នុងនាមអាជ្ញាសាលាជាស្ថាប័នអនុវត្ត ជាពិសេសចំពោះចលនវត្ថុផងនោះ ត្រូវធ្វើការស្រាវជ្រាវអំពីការមកដល់នៃពេលដែលត្រូវផ្តល់តាវកាលិក មុននឹងចាប់ផ្តើមអនុវត្តនីតិវិធីនៃការអនុវត្តដោយបង្ខំ។

ផ្ទុយទៅវិញ ក្នុងករណីដែលសិទ្ធិទាមទារ មានកំណត់នៅក្នុងលិខិតអនុវត្តភ្ជាប់ជាមួយនូវពេលកំណត់មិនពិតប្រាកដវិញនោះ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវធ្វើការបញ្ជាក់អំពីពេលកំណត់ដែលនឹងមកដល់ពិតប្រាកដជាមុនសិន ទើបទទួលការផ្តល់រូបមន្តអនុវត្តពិសេសជាក្រោយ។ ប្រសិនបើអាជ្ញាសាលា បានចាប់ផ្តើមការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ នៅមុនពេលការមកដល់នូវពេលកំណត់ពិតប្រាកដ សកម្មភាពនៃការអនុវត្តនោះ គឺជាសកម្មភាពខុសច្បាប់។ ប៉ុន្តែប្រសិនបើពេលកំណត់ពិតប្រាកដមកដល់មុនពេល ដែលសកម្មភាពនោះត្រូវបានលុបចោល វិការៈនោះនឹងត្រូវបានស្រោចស្រង់ឡើងវិញ។

- **តើម្ចាស់បំណុលនៃការអនុវត្តបានដាក់ប្រាតិភោគហើយ ឬនៅ ករណីនៅក្នុងលិខិតអនុវត្តអាចនឹងមានអានុភាពបានលុះត្រាតែមានការដាក់ប្រាតិភោគ[62]?**

ក្នុងករណីដែលការអនុវត្តដោយបង្ខំ ត្រូវធ្វើឡើងដោយផ្អែកលើលិខិតអនុវត្ត ដែលមានដាក់លក្ខខណ្ឌត្រូវដាក់ប្រាតិភោគ ដើម្បីអនុវត្តដោយបង្ខំបាន អាជ្ញាសាលា ដែលជាស្ថាប័នអនុវត្តចំពោះចលនវត្ថុ ត្រូវធ្វើការស្រាវជ្រាវអំពីករណីនេះ ដោយឱ្យម្ចាស់បំណុលនៃការអនុវត្តដាក់លិខិត ដែលបញ្ជាក់ថាខ្លួនបានដាក់ប្រាតិភោគនោះរួចហើយ មុននឹងចាប់ផ្តើមការអនុវត្តដោយបង្ខំ។ ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ដោយពុំមានការដាក់នូវលិខិតបញ្ជាក់អំពីការដាក់ប្រាតិភោគ គឺជាការអនុវត្តដោយខុសច្បាប់។

ប៉ុន្តែប្រសិនបើលិខិតនោះ ត្រូវបានដាក់នៅពេលក្រោយមក ការអនុវត្តនោះនឹងក្លាយទៅជាស្របច្បាប់វិញចាប់ពីពេលដាក់នោះ។

---

[60] . មាត្រា ៣៦០ វាក្យខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[61] . មាត្រា ៣៦១ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[62] . មាត្រា ៣៦១ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

- **តើម្ចាស់បំណុលនៃការអនុវត្ត បានផ្តល់តាវកាលិកតបហើយ ឬនៅ ករណីក្នុងលិខិតអនុវត្តកំណត់ឱ្យម្ចាស់បំណុលផ្តល់តាវកាលិកតប**[63] ?

ក្នុងករណីដែលលិខិតអនុវត្តកំណត់ថា តាវកាលិករបស់កូនបំណុលនៃការអនុវត្ត ត្រូវផ្តល់ដោយប្តូរនឹងតាវកាលិកតបរបស់ម្ចាស់បំណុលនៃការអនុវត្ត អាជ្ញាសាលា អាចចាប់ផ្តើមការអនុវត្តដោយបង្ខំបាន លុះត្រាតែម្ចាស់បំណុលនៃកាអនុវត្ត បញ្ជាក់ថាខ្លួនបានផ្តល់តាវកាលិកតប ឬ បានស្នើផ្តល់តាវកលិកតបរួចហើយ។

- **តើមានឧបសគ្គចំពោះការអនុវត្តដោយបង្ខំដែរ ឬទេ** ?

ឧបសគ្គចំពោះការអនុវត្តដោយបង្ខំ សំដៅទៅលើហេតុការណ៍ដែលរារាំងក្នុងការចាប់ផ្តើម ឬ បន្តនីតិវិធីនៃការអនុវត្តដោយបង្ខំ ពោលគឺលក្ខខណ្ឌអវិជ្ជមានសម្រាប់ការអនុវត្ត។ ឧបសគ្គចំពោះការអនុវត្តដោយបង្ខំ គឺជាហេតុដែលនឹងក្លាយជាឧបសគ្គចំពោះការអនុវត្តដោយបង្ខំទាំងស្រុង ចំពោះសិទ្ធិទាមទារ ឬ សិទ្ធិប្រាតិភោគដែលនឹងក្លាយជាឧបសគ្គពិសេសក្នុងការធ្វើសកម្មភាពណាមួយ ក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ។ ឧទាហរណ៍៖ **ការបើកសំណុំរឿងក្ស័យធន** (**មាត្រា ១៩ នៃច្បាប់ស្តីពីក្ស័យធន**)។

## ២.២ ការរឹបអូសចលនវត្ថុ

នៅក្នុងគ្រប់នីតិវិធីទាំងអស់ តែងតែមាននីតិវិធីនៃការចាប់ផ្តើម និងបញ្ចប់ដោយឡែកៗពីគ្នា។ ហើយនៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ ក៏អាចចាប់ផ្តើមការអនុវត្តមានលក្ខណៈខុសៗគ្នា អាស្រ័យទៅតាមប្រភេទនៃការអនុវត្តនីមួយៗផងដែរ។ ជាក់ស្តែងនៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ត្រូវបានចាប់ផ្តើមដោយដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ[64] នីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ត្រូវបានចាប់ផ្តើមដោយដីកាសម្រេចរឹបអូស[65] នីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះនាវា ត្រូវបានចាប់ផ្តើមដោយដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ[66]ជាដើម។

រីឯការអនុវត្តដោយបង្ខំចំពោះចលនវត្ថុវិញ ត្រូវបានចាប់ផ្តើមការអនុវត្តដោយការរឹបអូសចលនវត្ថុដោយអាជ្ញាសាលា[67] ដោយផ្អែកលើពាក្យសុំឱ្យអនុវត្តដោយបង្ខំ។ តាមន័យនេះ គឺថាលុះត្រាតែមានការរឹបអូសចលនវត្ថុដែលជាកម្មវត្ថុនៃការរឹបអូស ទើបអាចចាត់ទុកថាជាការចាប់ផ្តើមនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុដោយអាជ្ញាសាលាបាន។ ហើយបើទោះបីជាម្ចាស់បំណុលនៃការអនុវត្ត បានដាក់ពាក្យសុំឱ្យអាជ្ញាសាលា ធ្វើការអនុវត្តដោយបង្ខំលើចលនវត្ថុ របស់កូនបំណុលនៃការអនុវត្តក៏ដោយ ក៏មិនទាន់ចាត់ទុកថាការអនុវត្តដោយបង្ខំ

[63] . មាត្រា ៣៦១ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[64] . មាត្រា ៤១៩ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[65] . មាត្រា ៤០៣ កថាខណ្ឌទី ៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[66] . មាត្រា ៤៥៧ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[67] . មាត្រា ៣៨៤ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

បានចាប់ផ្តើមដែរ។ ម្យ៉ាងទៀតនៅតែចាត់ទុកថា ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុមិនទាន់បានចាប់ផ្តើមដដែល បើទោះបីជាអាជ្ញាសាលា បានធ្វើការដាស់តឿនឱ្យកូនបំណុលនៃការអនុវត្ត អនុវត្តការសងដោយស្ម័គ្រចិត្តនៅទីកន្លែង នៃកាអនុវត្តតាមមាត្រា ៣៨៤ កថាខណ្ឌទី ៥ ក៏ដោយ។

## ២.២.១ គោលការណ៍សំខាន់ៗនៃការរឹបអូស

### ២.២.១.១ គោលការណ៍នៃការរឹបអូស

ជាគោលការណ៍ ការរឹបអូសអាចធ្វើបានចំពោះរូបទ្រព្យ ឬ អរូបទ្រព្យដែលធ្លាក់ទៅលើកូនបំណុលនៃការអនុវត្ត[68]។ មានន័យថា ទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិ ឬ ស្ថិតក្រោមការកាន់កាប់របស់កូនបំណុលនៃការអនុវត្តនោះ គឺសុទ្ធតែក្លាយជាកម្មវត្ថុនៃការរឹបអូស ដើម្បីសម្រេចនូវសិទ្ធិទាមទាររបស់ម្ចាស់បំណុលនៃការអនុវត្ត។

ដូចគ្នានេះដែរ ចំពោះការអនុវត្តដោយបង្ខំចំពោះចលនវត្ថុវិញ ជាគោលការណ៍ គ្រប់ចលនវត្ថុដែលជាកម្មសិទ្ធិ ឬ ស្ថិតក្រោមការកាន់កាប់របស់កូនបំណុលនៃការអនុវត្ត សុទ្ធតែជាកម្មវត្ថុនៃការរឹបអូសទាំងអស់ ដោយពុំចាំបាច់ធ្វើការស្រាវជ្រាវអំពីកម្មសិទ្ធិនៅមុនការរឹបអូសនោះទេ លើកលែងតែមានកំណត់ជាពិសេសក្នុងច្បាប់។

### ២.២.១.២ ចលនវត្ថុដែលជាកម្មវត្ថុនៃការរឹបអូស

ចំពោះចលនវត្ថុដែលក្លាយជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំបានរួមមាន ៖

**១.ចលនវត្ថុដែលមានចែងក្នុងមាត្រា ១២០ កថាខណ្ឌទី ៣ និងទី ៤ នៃក្រមរដ្ឋប្បវេណី៖** យោងតាមមាត្រា១១៩ នៃក្រមរដ្ឋប្បវេណីបានបញ្ញត្តិថា មានតែវត្ថុដែលមានរូបរាងតែប៉ុណ្ណោះ ដែលត្រូវកំណត់ថាជាវត្ថុ។ ថាមពលអគ្គិសនី មិនអាចក្លាយជាវត្ថុ តាមបញ្ញត្តិនេះបានទេ។ ប៉ុន្តែមាត្រា ១២០ កថាខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណីដែលបានបញ្ញត្តិថា “ **បញ្ញត្តិស្តីពីចលនវត្ថុ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះទ្រព្យសម្បត្តិគ្មានរូបរាងដែលអាចគ្រប់គ្រងបាន** ” ពីព្រោះអគ្គិសនី អាចគ្រប់គ្រងដូចជាចលនវត្ថុដែលមានរូបរាងដែរ ហេតុដូចនេះមានលក្ខណៈងាយស្រួល ដែលអគ្គិសនីអាចគ្រប់គ្រងបានប្រសិនបើជាវត្ថុ។

**២.ផលធម្មជាតិ ដែលមិនទាន់បានបំបែកពីដីនៅឡើយ ហើយអាចនឹងទទួលផលយ៉ាងច្បាស់ក្នុងអំឡុងពេល១ ខែ៖** ដូចដែលយើងបានដឹងរួចមកហើយថា ចំពោះវត្ថុដែលមិនទាន់បំបែកចេញពីដី គឺជាសមាសភាគនៃដី ដែលមានបញ្ញត្តិក្នុង មាត្រា ១២២ នៃក្រមរដ្ឋប្បវេណី។ រីឯផលដែលមិនទាន់បំបែកពីដី ក៏នៅតែគេទទួលស្គាល់ថាជាសមាសភាគនៃដីដែរ។ ការអនុវត្តដោយបង្ខំចំពោះផលធម្មជាតិដែលមិនទាន់បំបែកពីដី អាចជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ ដោយអាជ្ញាសាលា ប្រសិនបើដឹងច្បាស់ថា ផលនោះនឹងត្រូវទទួលក្នុងអំឡុងពេល១ខែ។ ប៉ុន្តែវាក៏អាចក្លាយជាកម្មវត្ថុនៃ ការអនុវត្តដោយតុលាការអនុវត្តដែរ ប្រសិនបើផលនោះនឹងត្រូវទទួលក្នុងអំឡុងពេល លើសពី ១ខែ។

[68] . មាត្រា ៣៧៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

**៣.រូបិយវត្ថុដូចជាក្រដាស់ប្រាក់ ឬ ប្រាក់កាក់** ដែលមិនទាមទារឱ្យមាននីតិវិធីនៃការប្តូរជាប្រាក់[69]។

**២.២.១.៣ ចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស**

ជាគោលការណ៍ ទ្រព្យសម្បត្តិទាំងអស់របស់កូនបំណុលនៃការអនុវត្ត អាចក្លាយជាកម្មវត្ថុនៃការរឹបអូស តាមមាត្រា ៣៧៩ ប៉ុន្តែដោយមានមូលហេតុពាក់ព័ន្ធនឹងគោលនយោបាយ ទ្រព្យសម្បត្តិមួយចំនួនត្រូវបាន ហាមឃាត់មិនឱ្យរឹបអូស។

ចលនវត្ថុដែលត្រូវបានហាមឃាត់មិនឱ្យរឹបអូសរួមមាន[70]៖

- ប្រដាប់ស្លៀកពាក់ ប្រដាប់សម្រាប់ដំណេក តុ ទូ ប្រដាប់សម្រាប់ដាំស្ល និងប្រដាប់សម្រាប់បិទយាំង បន្ទប់ របស់កូនបំណុលនៃការអនុវត្ត និងញាតិដែលរស់នៅជាមួយកូនបំណុលនៃការអនុវត្ត ហើយមាន ជីវភាពរួមគ្នា។
- គ្រឿងឧបភោគបរិភោគ និងទហនវត្ថុ ដែលត្រូវការចាំបាច់ដើម្បីចិញ្ចឹមជីវិតក្នុងអំឡុងពេល ២ (ពីរ) ខែរបស់កូនបំណុលនៃការអនុវត្ត និងញាតិដែលរស់នៅជាមួយកូនបំណុលនៃការអនុវត្ត ហើយមាន ជីវភាពរួមគ្នា។
- របបឧបត្ថម្ភជីវភាព របបឧបត្ថម្ភផ្ទេកអប់រំ របបឧបត្ថម្ភសុខភាព និងប្រាក់ឧបត្ថម្ភផ្សេងទៀត ដែលផ្តល់ ពីរដ្ឋ ឬ ពីអាជ្ញាធរដែនដី ដើម្បីការពារដល់ជីវភាពរបស់កូនបំណុលនៃការអនុវត្ត។
- ផ្នែកប្រាក់តិចជាង ឬ ស្មើនឹង ១,០០០,០០០ (មួយលាន) រៀល ក្រៅពីប្រាក់ដែលបានកំណត់ក្នុងចំណុច គខាងលើនេះ។
- ឧបករណ៍ ដី សត្វពាហនៈដែលជាចាំបាច់សម្រាប់ការងារកសិកម្មរបស់ខ្លួន និងចំណីសត្វទាំងនោះ ព្រមទាំងគ្រាប់ពូជ ឬ កសិផលដែលមានប្រភេទដូចគ្នា ដែលត្រូវការជាចាំបាច់សម្រាប់បន្តការងារ កសិកម្មរហូតដល់រដូវបានផលបន្ទាប់ របស់កសិករក្នុងការប្រកបការងារកសិកម្ម។
- មង សំណាញ់ ឬ នេសាទុបករណ៍ផ្សេងៗចាំបាច់ ចំណី និងកូនត្រី ឬ ជលផលប្រភេទដូចគ្នាដែលត្រូវការ ចាំបាច់សម្រាប់រកជលផល ឬ ចិញ្ចឹមជលផលរបស់អ្នកប្រកបរបរនេសាទ។
- ឧបករណ៍ និងវត្ថុផ្សេងៗទៀត ដែលចាំបាច់សម្រាប់អ្នកបច្ចេកទេស សិប្បករ កម្មករ និងអ្នកផ្សេងទៀត ដែលប្រកបរបរវិជ្ជាជីវៈ ឬ សាជីវកម្ម ដោយប្រើកម្លាំងប្រាជ្ញា កម្លាំងកាយ។ ប៉ុន្តែបើវត្ថុដែលអ្នកនោះមាន ក្នុងគោលបំណងសម្រាប់លក់ ឬ ជួលវិញ អាចរឹបអូសបាន។
- ព្រះពុទ្ធរូប ក្បួនវិត៏សាសនា និងវត្ថុផ្សេងៗទៀតដែលចាំបាច់សម្រាប់ពិធីក្នុងសាសនា។

---

[69] . មាត្រា ៣៨៤ កថាខណ្ឌទី ៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[70] . មាត្រា ៣៨០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

- ពង្សាវលី កំណត់ប្រចាំថ្ងៃ បញ្ជីប្រកបមុខរបរ និងឯកសារប្រភេទដូចគ្នា ដែលចាំបាច់របស់កូនបំណុល នៃកាអនុវត្ត។
- គ្រឿងឥស្សរិយយស និងប័ណ្ណសរសើរផ្សេងៗទៀតរបស់កូនបំណុលនៃការអនុវត្ត ឬ របស់ញាតិរបស់ជននោះ។
- ឯកសារ និង ឧបករណ៍ ដែលចាំបាច់ក្នុងការសិក្សា នៅសាលា ឬ នៅស្ថាប័នអប់រំផ្សេងទៀតរបស់កូនបំណុលនៃកាអនុវត្ត និងញាតិដែលរស់នៅជាមួយកូនបំណុលនៃការអនុវត្ត ហើយមានជីវភាពរួមគ្នា។
- វត្ថុដែលទាក់ទងនឹងតក្កកម្ម ឬ ស្នាដៃនិពន្ធ ដែលមិនទាន់ផ្សាយជាសាធារណៈ។
- អវយវៈសិប្បនិមិត្ត សរីរាង្គសិប្បនិមិត្តផ្សេងទៀត និងឧបករណ៍ជំនួយខ្លួនប្រាណផ្សេងទៀត ដែលចាំបាច់សម្រាប់កូនបំណុលនៃការអនុវត្ត និងញាតិដែលរស់នៅជាមួយកូនបំណុលនៃការអនុវត្ត ហើយមានជីវភាពរួមគ្នា ព្រមទាំងវត្ថុផ្សេងៗសម្រាប់ថែទាំ អ្នកជម្ងឺដែលជាកូនបំណុលនៃការអនុវត្ត និងញាតិដែលរស់នៅជាមួយកូនបំណុលនៃការអនុវត្ត ហើយមានជីវភាពរួមគ្នា។
- ម៉ាស៊ីន ឧបករណ៍ពន្លត់ភ្លើង ឧបករណ៍ជម្លៀសខ្លួនពេលមានអាសន្ន ឬ ឧបករណ៍ផ្សេងទៀត សម្រាប់អាគារ ឬ សំណង់ផ្សេងទៀត ដែលច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងៗតម្រូវឱ្យមានបរិក្ខារ ដើម្បីបង្ការមហន្តរាយ ឬ ការពារសន្តិសុខ។

**២.២.១.៤ ការប្តូរទំហំនៃចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស**

ដោយផ្អែកលើស្ថានភាពជីវភាពរស់នៅ ឬ ស្ថានភាពពិសេសរបស់កូនបំណុលនៃការអនុវត្ត ឬ ម្ចាស់បំណុលនៃការអនុវត្ត នោះកូនបំណុលនៃការអនុវត្ត ឬ ម្ចាស់បំណុលនៃការអនុវត្ត អាចដាក់ពាក្យសុំទៅសាលាដំបូង ដែលអាជ្ញាសាលាស្ថិតនៅ ដើម្បីឱ្យតុលាការចេញដីកាសម្រេចអនុញ្ញារឹបអូស ឬ មិនឱ្យរឹបអូសចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូសបាន[71]។ ការផ្លាស់ប្តូរទំហំនៃចលនវត្ថុ ដែលហាមឃាត់មិនឱ្យរឹបអូស គឺអាស្រ័យទៅតាមអ្នកដាក់ពាក្យសុំឱ្យផ្លាស់ប្តូរ ពោលបើម្ចាស់បំណុលនៃការអនុវត្តសុំឱ្យផ្លាស់ប្តូរនោះ គឺចលនវត្ថុដែលបានហាមឃាត់មិនឱ្យរឹបអូស ដែលបានកំណត់ក្នុងមាត្រា ៣៨០ នោះនឹងត្រូវរឹតត្បិត មានន័យថា ចលនវត្ថុមួយដែលជាកម្មវត្ថុ នៃការហាមឃាត់ក្នុងមាត្រា ៣៨០ តែប្រសិនបើមានពាក្យសុំឱ្យផ្លាស់ប្តូរនោះ ចលនវត្ថុនោះនឹងលែងជាកម្មវត្ថុនៃការហាមឃាត់តទៅទៀតហើយ ដូច្នេះអាជ្ញាសាលាអាចរឹបអូសបាន។ ប៉ុន្តែប្រសិនបើពាក្យសុំធ្វើឡើងដោយកូនបំណុលនៃការអនុវត្តវិញនោះ មិនត្រឹមតែចលនវត្ថុដែលបានកំណត់ក្នុងមាត្រា ៣៨០ ទេដែលត្រូវបានហាមឃាត់មិនឱ្យរឹបអូស សូម្បីចលនវត្ថុដែលបានស្នើសុំមិនឱ្យរឹបអូសនោះ ក៏មិនអាចរឹបអូសបានដែរ ប្រសិនបើមាន ដីកាសម្រេចមិនអនុញ្ញាតឱ្យរឹបអូស។ មូលហេតុដែលកូនបំណុលនៃការអនុវត្ត ឬ ម្ចាស់បំណុលនៃការ

[71] . មាត្រា ៣៨១ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

អនុវត្ត អាចស្នើសុំទៅសាលាដំបូង ដែលអាជ្ញាសាលាស្ថិតនៅ ដើម្បីផ្លាស់ប្តូរទំហំនៃចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូសបាននោះគឺ អាស្រ័យលើស្ថានភាពជីវភាព ឬ ស្ថានភាពផ្សេងទៀតរបស់កូនបំណុលនៃការអនុវត្ត ឬ ម្ចាស់បំណុលនៃការអនុវត្តដែលដាក់ពាក្យសុំនោះ។ ស្ថានភាពទាំងនោះ អាចជាម្ចាស់បំណុលនៃការអនុវត្តមានជីវភាពរស់នៅធ្លាក់ចុះ ហើយទាមទារឱ្យអនុវត្តដោយបង្ខំ ដើម្បីទទួលបាននូវការគាំទ្រនូវជីវភាពរបស់ខ្លួន ស្ថានភាពដែលកូនបំណុលនៃការអនុវត្តគ្មានឆន្ទៈ ក្នុងការអនុវត្តតាមកិច្ចសន្យាទាល់តែសោះជាដើម។

ប្រសិនបើស្ថានភាពមានការផ្លាស់ប្តូរ សាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅ អាចអនុញ្ញាតឱ្យរឹបអូសចលនវត្ថុ ដែលបានលុបចោលការរឹបអូសមួយផ្នែក ឬ ទាំងមូលបានតាមពាក្យសុំ[72]។ ដីកាសម្រេចខាងលើអាចប្តឹងជំទាស់បាន[73]។

**២.២.១.៥ ការហាមឃាត់មិនឱ្យរឹបអូសហួសប្រមាណ**

ជាគោលការណ៍ ការរឹបអូសចលនវត្ថុ មិនត្រូវធ្វើឱ្យហួសកម្រិតចាំបាច់សម្រាប់សំណងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្ត និងសោហ៊ុយចាំបាច់សម្រាប់អនុវត្តទេ[74]។ ករណីនេះ វាហាក់ដូចជាទាមទារឱ្យអាជ្ញាសាលា ដែលជាស្ថាប័នអនុវត្ត ធ្វើការប៉ានស្មានវាយតម្លៃលើចលនវត្ថុ ដែលជាកម្មវត្ថុនៃការអនុវត្តភ្លាមៗ ដើម្បីអាចដឹងថាចលនវត្ថុដែលនឹងត្រូវរឹបអូស នៅពេលដែលប្តូរជាប្រាក់ ហើយទូទាត់សងសិទ្ធិលើបំណុលទៅម្ចាស់បំណុលនៃការអនុវត្ត និងសោហ៊ុយសម្រាប់ការអនុវត្តរួចហើយ នៅមានចំនួនទឹកប្រាក់សេសសល់ច្រើនឬសមល្មម។

ឧទាហរណ៍ សិទ្ធិទាមទាររបស់ម្ចាស់បំណុលនៃការអនុវត្តដែលកំណត់នៅក្នុងលិខិតអនុវត្តនោះ មានចំនួន ២០,០០០ ដុល្លារអាមេរិក និងសោហ៊ុយសម្រាប់ការអនុវត្ត មានចំនួន ៧០០ ដុល្លារអាមេរិក។ នៅពេលចុះទៅអនុវត្ត បើកូនបំណុលនៃការអនុវត្ត មានប្រាក់ក្នុងទូដែកចំនួន ៥០,០០០ ដុល្លារអាមេរិកនោះ ករណីនេះ អាជ្ញាសាលា អាចរឹបអូសប្រាក់នោះបានត្រឹមតែចំនួនប្រហែល ២២,០០០ ដុល្លារអាមេរិក ឬ អាចលើសត្រឹមកម្រិតបន្តិចបន្តួចតែប៉ុណ្ណោះ ដើម្បីបង្ការទុកសម្រាប់ការសុំឱ្យចែកចំណែក។ តែបើកូនបំណុលមានជាចលនវត្ថុដូចជារថយន្តទំនើប ២ គ្រឿងវិញ ករណីនេះអាជ្ញាសាលា អាចប៉ាន់ប្រមាណបានថាត្រឹមរថយន្តមួយ គឺធួនល្មមសម្រាប់ការសងសិទ្ធិលើបំណុល និងសោហ៊ុយអនុវត្តបានហើយ ដូច្នេះអាជ្ញាសាលា រឹបអូសតែរថយន្តមួយទេ។ ផ្ទុយមកវិញ ក្នុងករណីដែលចលនវត្ថុនោះ អាជ្ញាសាលា មិនធ្វើការវាយតម្លៃបានភ្លាមៗនៅកន្លែងរឹបអូសទេ អាជ្ញាសាលា គួរគប្បីធ្វើការរឹបអូសមករក្សាទុកសិនបាន។ ហើយក្រោយមកបានប៉ាន់ស្មានឃើញថា ចលនវត្ថុ

72 . មាត្រា ៣៨១ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

73 . មាត្រា ៣៨១ កថាខណ្ឌទី ៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

74 . មាត្រា ៣៩១ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

ដែលជាកម្មវត្ថុនៃការរឹបអូស លើសពីកម្រិតចាំបាច់នៃការសងសិទ្ធិលើបំណុល និងសោហ៊ុយសម្រាប់ការអនុវត្ត ទៅហើយ អាជ្ញាសាលា ត្រូវលុបចោលការរឹបអូសត្រឹមកម្រិតដែលលើសពីភាពចាំបាច់បាន។

**២.២.១.៦ ការហាមឃាត់មិនឱ្យរឹបអូស ក្នុងករណីដែលប៉ាន់ប្រមាណឃើញថាគ្មានចំនួនសេសសល់**

អាជ្ញាសាលាមិនត្រូវធ្វើការរឹបអូសឡើយ ប្រសិនបើប៉ាន់ប្រមាណឃើញថាចំនួនទឹកប្រាក់ដែលបានមកពីការលក់ចលនវត្ថុ ដែលត្រូវបានរឹបអូសនោះគ្មានចំនួនសេសសល់ ក្រោយពីបានបង់សោយហ៊ុយសម្រាប់នីតិវិធីហើយ[75]។ មានន័យថា អាជ្ញាសាលា ចាំបាច់ត្រូវធ្វើការប៉ាន់ប្រមាណជាបឋមនូវតម្លៃនៃចលនវត្ថុ ដែលជាកម្មវត្ថុនៃការរឹបអូស នៅក្នុងពេលចុះអនុវត្តការរឹបអូស ហើយករណីដែលប៉ានប្រមាណឃើញថា ទោះបីជាចលនវត្ថុត្រូវបានលក់ក៏ដោយ ក៏ប្រាក់ដែលបានមកពីការលក់នោះនឹងគ្មានចំនួនសេសសល់ បន្ទាប់ពីសងសោហ៊ុយនីតិវិធីរួចហើយ។

ករណីបែបនេះ អាជ្ញាសាលា ត្រូវលុបចោលការរឹបអូស ប្រសិនបើប៉ាន់ប្រមាណឃើញថា ចំនួនទឹកប្រាក់ដែលបានមកពីការលក់ចលនវត្ថុ ដែលត្រូវបានរឹបអូសនោះ គ្មានចំនួនសេសសល់ ក្រោយពីបានសងសិទ្ធិលើបំណុល ដែលមានអាទិភាពជាងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃកាអនុវត្ត និងសោហ៊ុយសម្រាប់នីតិវិធីហើយ[76]។

**២.២.២ ការអនុវត្តការរឹបអូស**

**២.២.២.១ វិធីរឹបអូស**

**ក. ការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយកូនបំណុល**

នៅមុនពេលចាប់ផ្តើមធ្វើការរឹបអូសចលនវត្ថុ ប្រសិនបើបានជួបប្រទះកូនបំណុលនៃការអនុវត្តនៅកន្លែងដែលត្រូវរឹបអូស អាជ្ញាសាលា ត្រូវធ្វើការដាស់តឿនឱ្យកូនបំណុលនៃការអនុវត្តនោះ សងបំណុលដោយស្ម័គ្រចិត្ត[77]។ ករណីនេះ ប្រសិនបើកូនបំណុលយល់ព្រមប្រគល់ប្រាក់សំណងដោយស្ម័គ្រចិត្ត អាជ្ញាសាលាអាចទទួលយកសំណង និងសោហ៊ុយសម្រាប់ការអនុវត្តបាន[78]។តែបើកូនបំណុលនៃការអនុវត្តបដិសេធនោះ អាជ្ញាសាលាត្រូវចាប់ផ្តើមការរឹបអូសចលនវត្ថុ ដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត ដើម្បីសម្រេចនូវសិទ្ធិទាមទាររបស់ម្ចាស់បំណុលនៃការអនុវត្ត និងសោហ៊ុយសម្រាប់ការអនុវត្ត។

75 . មាត្រា ៣៩២ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

76 . មាត្រា ៣៩២ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

77 . មាត្រា៣៨៤ កថាខណ្ឌទី ៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

78 . មាត្រា៣៨៤ កថាខណ្ឌទី ៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

❖ **ក្នុងករណីដែលកម្មវត្ថុនៃការរឹបអូសគឺជាប្រាក់៖**

ប្រសិនបើកម្មវត្ថុនៃការរឹបអូសគឺជាប្រាក់ អាជ្ញាសាលាអាចដកហូតប្រាក់នោះបាន។ ការអនុវត្តប្រភេទនេះគឺមានលក្ខណៈងាយស្រួល ដែលមិនចាំបាច់ទាមទារឱ្យមានអនុវត្តចាត់ចែងប្តូរជាប្រាក់ម្តងទៀតទេ ពោលគឺអាជ្ញាសាលា អាចអនុវត្តនីតិវិធីនៃការចែកចំណែកបាន។

❖ **ក្នុងករណីដែលកម្មវត្ថុនៃការរឹបអូសគឺជាវត្ថុផ្សេងក្រៅពីប្រាក់៖**

ក្នុងករណីរឹបអូសចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត អាជ្ញាសាលាអាចរឹបអូសចលនវត្ថុនោះ ដោយគ្រាន់តែផ្អែកទៅលើរូបភាពខាងក្រៅនៃការកាន់កាប់របស់កូនបំណុលប៉ុណ្ណោះ ដោយមិនចាំបាច់ស្រាវជ្រាវអំពីរឿងរ៉ាវពាក់ព័ន្ធ ជាមួយនឹងកម្មសិទ្ធិអ្វីទេ។ មូលហេតុដែលអាជ្ញាសាលាមិនចាំបាច់ធ្វើការស្រាវជ្រាវអំពីកម្មសិទ្ធិនៃចលនវត្ថុ ដែលជាកម្មវត្ថុនៃការរឹបអូសនោះមានដូចជា៖

- **ជាទ្រឹស្តីច្បាប់៖** ចលនវត្ថុនៅក្នុងដៃអ្នកណា អ្នកនោះជាម្ចាស់។ ដែលករណីនេះ គឺជាគោលការណ៍សន្មត់នៃច្បាប់ ដែលគ្រាន់តែទាមទារឱ្យមានការកាន់កាប់ដោយកូនបំណុលនៃការអនុវត្តតែប៉ុណ្ណោះ ពោលគឺអាជ្ញាសាលា អាចសន្មត់ថាចលនវត្ថុនោះជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្តបាន ដោយពុំចាំបាច់ធ្វើការស្រាវជ្រាវជាមុនឡើយ។ មានន័យថា ប្រសិនបើអាជ្ញាសាលាប្រទះឃើញចលនវត្ថុ ដែលកំពុងស្ថិតនៅទីកន្លែងដែលត្រូវរឹបអូសនោះ ទោះបីជាចលនវត្ថុនោះ ជាកម្មសិទ្ធិរបស់តតិយជនក៏ដោយ ក៏អាជ្ញាសាលា អាចរឹបអូសបានដែរ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើមើលពីរូបភាពខាងក្រៅនៃការកាន់កាប់ គេអាចដឹងយ៉ាងច្បាស់ថា ទ្រព្យនោះជារបស់អ្នកដទៃ ការរឹបអូសនោះមិនត្រូវធ្វើឡើងទេ។ **ឧទាហរណ៍៖** ម៉ូតូ ឬ រថយន្ត មានបិទសញ្ញាអង្គការ ជាអាទិ៍។ ករណីបែបនេះ អាជ្ញាសាលាមិនអាចរឹបអូសបានទេ។
- **ដើម្បីពន្លឿននូវនីតិវិធីអនុវត្តដោយបង្ខំ៖** ដូចដែលយើងបានដឹងរួចមកហើយថា ទោះបីជាមានបណ្តឹងតវ៉ា បណ្តឹងជំទាស់ អំពីការអនុវត្តដោយបង្ខំ ត្រូវបានធ្វើឡើងក៏ដោយ ក៏អានុភាពនៃការផ្អាកការអនុវត្ត ក៏មិនត្រូវបានកើតឡើងដោយឯកឯងនោះដែរ ដោយហេតុថា គឺជាបញ្ញត្តិដើម្បីមិនឱ្យមានការរារាំង ឬ មានការរាំងស្ទះដល់ដំណើរការនីតិវិធីនៃការអនុវត្តដោយបង្ខំ។ ដូចគ្នានេះដែរ ការស្រាវជ្រាវអំពីកម្មសិទ្ធិលើចលនវត្ថុ គឺជានីតិវិធីមួយ ដែលទាមទារឱ្យចំណាយពេលយូរអង្វែង និងឆ្លងកាត់នីតិវិធីដ៏ស្មុគស្មាញ ដែលក្នុងនោះប្រសិនបើច្បាប់កំណត់ឱ្យអាជ្ញាសាលា ត្រូវស្រាវជ្រាវអំពីកម្មសិទ្ធិលើចលនវត្ថុ នៅមុនការរឹបអូសនោះ ប្រាកដជាមានការពិបាក និងធ្វើឱ្យម្ចាស់បំណុលមិនអាចសម្រេចសិទ្ធិរបស់ខ្លួនបានឡើយ។ ពោលគឺជាការរាំងស្ទះនូវដំណើរការនៃនីតិវិធី នៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុដោយអាជ្ញាសាលា។

- **បើកផ្លូវឱ្យមានបណ្តឹងតវ៉ាដោយតតិយជន**[79]៖ ទោះបីជាច្បាប់មិនបានតម្រូវឱ្យអាជ្ញាសាលាធ្វើស្រាវជ្រាវអំពីកម្មសិទ្ធិនៅមុនការរឹបអូសក៏ពិតមែន ប៉ុន្តែក៏មិនត្រូវធ្វើឱ្យប៉ះពាល់ដល់តតិយជន ដែលមានសិទ្ធិស្របច្បាប់លើចលនវត្ថុ ដែលត្រូវបានរឹបអូសនោះទេ។ ដោយហេតុថានៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំបានបើកផ្លូវឱ្យតតិយជន ដែលមានសិទ្ធិស្របច្បាប់ អាចដាក់ពាក្យបណ្តឹងតវ៉ាបាន ដោយអនុលោមតាមមាត្រា ៣៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ដើម្បីសម្រេចនូវសិទ្ធិទាមទាររបស់ម្ចាស់បំណុលនៃការអនុវត្ត អាជ្ញាសាលា អាចចូលទៅក្នុងទីកន្លែងរស់នៅរបស់កូនបំណុលនៃការអនុវត្ត ឬ កន្លែងផ្សេងទៀត ដែលកូនបំណុលនៃការអនុវត្តកាន់កាប់ ហើយអាចឆែកឆេររកចលនវត្ថុដែលអាចរឹបអូសនោះបាន[80]។ មានន័យថា គ្រប់ទីកន្លែងដែលកូនបំណុលនៃការអនុវត្តកាន់កាប់ អាជ្ញាសាលា អាចចូលទៅធ្វើការឆែកឆេររកគ្រប់ចលនវត្ថុដែលអាចរឹបអូសបានទាំងអស់។ ហើយបើមានការចាំបាច់ អាជ្ញាសាលា អាចធ្វើការចាត់ចែង ដើម្បីបើកទ្វាដែលបិទជិត ទូដែក និងប្រអប់ផ្សេងៗបាន។ ជាមួយគ្នានេះដែរ នៅពេលចុះអនុវត្តការរឹបអូស អាជ្ញាសាលា អាចធ្វើការជ្រើសរើសនូវចលនវត្ថុដើម្បីរឹបអូសបាន ដោយថ្លឹងថ្លែងអំពីផលប្រយោជន៍ របស់កូនបំណុលនៃកាអនុវត្ត និងម្ចាស់បំណុលនៃកាអនុវត្តបាន[81]។ អានុភាពនៃការរឹបអូសនឹងកើតមានឡើងនៅពេលដែលអាជ្ញាសាលាកាន់កាប់ចលនវត្ថុរឹបអូសនោះ[82]។

❖ **ករណីកម្មវត្ថុនៃការរឹបអូសជារថយន្ត ជាអាទិ៍ ដែលបានចុះបញ្ជីះ**

ប្រសិនបើចលនវត្ថុ ដែលជាកម្មវត្ថុនៃការរឹបអូសនោះ គឺចលនវត្ថុដែលបានចុះបញ្ជីរួចហើយនោះ រួមមានរថយន្ត ទោចក្រយានយន្ត ជាអាទិ៍ អាជ្ញាសាលា ត្រូវផ្ទុកផ្តាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីសរសេរអំពីហេតុការណ៍នៃការរឹបអូស ចូលទៅក្នុងសៀវភៅចុះបញ្ជីនោះ ទើបធ្វើឱ្យការរឹបអូសមានអានុភាព[83]។

**ខ.ការរឹបអូសចលនវត្ថុ ដែលកាន់កាប់ដោយម្ចាស់បំណុល**

ក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្ត ជាអ្នកដែលកាន់កាប់នូវចលនវត្ថុរបស់កូនបំណុលនៃកាអនុវត្ត ម្ចាស់បំណុលនៃការអនុវត្ត អាចប្រគល់ដោយស្ម័គ្រចិត្តនូវចលនវត្ថុនោះទៅអាជ្ញាសាលា ដើម្បីធ្វើការរឹបអូស[84]។

**ឧទាហរណ៍**៖ ចំពោះស្ថានភាពបែបនេះ ដូចជាករណីដែលម្ចាស់បំណុលនៃការអនុវត្តកាន់កាប់ចលនវត្ថុរបស់កូនបំណុល ក្នុងករណីដែលចលនវត្ថុនោះជាកម្មវត្ថុនៃការបញ្ចាំ ឬ ជាកម្មវត្ថុនៃការឃាត់ទុក។ល។

---

[79] . មាត្រា ៣៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[80] . មាត្រា ៣៨៥ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[81] . មាត្រា ៣៨៥ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[82] . មាត្រា ៣៨៥ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[83] . មាត្រា ៣៨៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[84] . មាត្រា ៣៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

**គ.ការរឹបអូសចលនវត្ថុ ដែលកាន់កាប់ដោយតតិយជន**

ក្នុងករណីដែលចលនវត្ថុ ជាកម្មវត្ថុនៃការអនុវត្ត ស្ថិតនៅក្រោមការកាន់កាប់ដោយតតិយជន អាជ្ញាសាលា អាចរឹបអូសចលនវត្ថុនោះបាន លុះត្រាតែតតិយជននោះ មិនបដិសេធអំពីការប្រគល់ចលនវត្ថុនោះ[85]។ ព្រោះថា អាជ្ញាសាលា មិនអាចធ្វើការរឹបអូសនូវចលនវត្ថុ ដែលកាន់កាប់ដោយបុគ្គលផ្សេងក្រៅពីកូនបំណុលនៃការអនុវត្ត ដោយផ្អែកលើលិខិតអនុវត្ត ដែលកំណត់ឈ្មោះរបស់កូនបំណុលនៃការអនុវត្តនោះបានទេ។ ប្រសិនបើតតិយជន បដិសេធមិនព្រមប្រគល់ចលនវត្ថុទេនោះ ម្ចាស់បំណុលនៃការអនុវត្ត ពុំមានជម្រើសអ្វីក្រៅពីធ្វើការរឹបអូសសិទ្ធិទាមទារឱ្យប្រគល់វត្ថុ ដែលកូនបំណុលមានចំពោះតតិយជននោះ តាមរយៈការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ហើយប្រមូល និងប្រគល់វត្ថុនោះទៅឱ្យអាជ្ញាសាលា។ ប្រសិនបើតតិយជនបដិសេធមិនឱ្យអាជ្ញាសាលាធ្វើការរឹបអូសទេ ម្ចាស់បំណុលនៃការអនុវត្តគ្មានជម្រើសអ្វីផ្សេងក្រៅពីការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ឬ សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀតរបស់កូនបំណុលនៃការអនុវត្តឡើយ។

**២.២.២.២ ការថែរក្សាវត្ថុដែលត្រូវបានរឹបអូស**

**ក.គោលការណ៍នៃការកាន់កាប់ដោយអាជ្ញាសាលា**

ជាគោលការណ៍ ចលនវត្ថុដែលត្រូវបានរឹបអូស ត្រូវស្ថិតនៅក្រោមការកាន់កាប់ដោយអាជ្ញាសាលា[86]។ មានន័យថា មានតែអាជ្ញាសាលាទេ ដែលមានសិទ្ធិក្នុងការកាន់កាប់ និងថែរក្សានូវចលនវត្ថុដែលត្រូវបានរឹបអូស។ ហើយមានតែករណី ដែលអាជ្ញាសាលាបានកាន់កាប់ចលនវត្ថុ ដែលបានរឹបអូសតែប៉ុណ្ណោះ ទើបធ្វើឱ្យអានុភាពនៃការរឹបអូសចលនវត្ថុកើតមានឡើង មានន័យថា ប្រសិនបើអាជ្ញាសាលា មិនបានកាន់កាប់នូវចលនវត្ថុនៃការរឹបអូសទេ នោះកូនបំណុលនៃការអនុវត្ត មានឱកាសគ្រប់ពេល ក្នុងការចាត់ចែងនូវចលនវត្ថុនោះ ដែលអាចនឹងធ្វើឱ្យម្ចាស់បំណុលនៃការអនុវត្ត ជួបបញ្ហាលំបាក ក្នុងការសម្រេចនូវសិទ្ធិទាមទាររបស់ខ្លួន។ ការកាន់កាប់ដោយអាជ្ញាសាលានៅទីនេះ គឺសំដៅដល់ការកាន់កាប់ដោយផ្ទាល់ដោយអាជ្ញាសាលា ពោលគឺការកាន់កាប់ មិនអាចត្រូវបកស្រាយ រហូតដល់ការកាន់កាប់ដោយប្រយោលដោយអាជ្ញាសាលានោះទេ។

**ខ.ការអនុញ្ញាតឱ្យកូនបំណុលនៃការអនុវត្ត ឬ បុគ្គលផ្សេងទៀតថែរក្សា**

អាជ្ញាសាលាអាចអនុញ្ញាតឱ្យកូនបំណុលនៃការអនុវត្ត ឬ ម្ចាស់ម្ចាស់បំណុលនៃការអនុវត្ត ឬ តតិយជនឱ្យថែរក្សា ឬ ប្រើប្រាស់ចលនវត្ថុដែលត្រូវបានរឹបអូសនោះបានដែរ ប្រសិនបើអាជ្ញាសាលាយល់ថាសមរម្យ។

- **ចំពោះការរឹបអូសចលនវត្ថុ ដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត៖** ដូចដែលបានរៀបរាប់ខាងលើរួចមកហើយអំពីការរឹបអូសចលនវត្ថុ ដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្តនឹងមានអានុភាពតាមរយៈការកាន់កាប់ដោយអាជ្ញាសាលា ប៉ុន្តែប្រសិនបើយល់ថាសមរម្យ ដូចជាការគ្រប់គ្រងថែរក្សា

[85] . មាត្រា ៣៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[86] . មាត្រា ៣៨៥ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

ចលនវត្ថុដែលបានរឹបអូស ដោយអាជ្ញាសាលានឹងត្រូវចំណាយច្រើន ឬ មានការលំបាកក្នុងការដឹកជញ្ជូន ឬ ការគ្រប់គ្រងដោយកូនបំណុលមានភាពងាយស្រួលជាងនោះ អាជ្ញាសាលា អាចអនុញ្ញាតឱ្យកូនបំណុលនៃការអនុវត្តគ្រប់គ្រងថែរក្សាបាន[87]។ ករណីនេះ អានុភាពនៃការរឹបអូសចលនវត្ថុនោះនឹងកើតមានឡើងតាមរយៈ ការបិទស្លាក ឬ ដាក់សញ្ញារឹបអូសផ្សេងទៀត លើចលនវត្ថុដែលត្រូវបានរឹបអូសនោះ។ លើសពីនេះទៅទៀត បើយល់ថាសមរម្យ អាជ្ញាសាលា អាចអនុញ្ញាតឱ្យ កូនបំណុលប្រើប្រាស់ចលនវត្ថុនោះបាន[88]។ ការអនុញ្ញាតនេះ អាជ្ញាសាលា អាចលុបចោលវិញបាន ប្រសិនបើចលនវត្ថុដែលអាជ្ញាសាលាអនុញ្ញាតឱ្យកូនបំណុលគ្រប់គ្រង បែរជាធ្លាក់ទៅដល់ដៃតតិយជន ម្ចាស់បំណុលនៃការអនុវត្តអាចដាក់ពាក្យសុំទៅសាលាដំបូង ដែលអាជ្ញាសាលាស្ថិតនៅ ដើម្បីចេញដីកាសម្រេចបង្គាប់ឱ្យប្រគល់ចលនវត្ថុ ដែលត្រូវបានរឹបអូស ទៅឱ្យអាជ្ញាសាលាគ្រប់គ្រងបាន ដែលពាក្យសុំនេះអាចត្រូវបានធ្វើឡើងក្នុងអំឡុង ពេល ១ សប្តាហ៍ គិតចាប់ពីថ្ងៃដែលដឹងថា តតិយជនបានកាប់កាប់[89]។

- **ចំពោះការរឹបអូសចលនវត្ថុ ដែលកាន់កាប់ដោយម្ចាស់បំណុលនៃការអនុវត្ត៖** ប្រសិនបើយល់ថាសមរម្យអាជ្ញាសាលា ក៏អាចប្រគល់ចលនវត្ថុ ដែលត្រូវបានរឹបអូសនោះទៅឱ្យម្ចាស់បំណុលនៃការអនុវត្តថែរក្សាគ្រប់គ្រងបានដែរ ហើយករណីនេះ អាជ្ញាសាលា ត្រូវបិទស្លាក ឬ ដាក់សញ្ញារឹបអូសផ្សេងទៀតលើចលនវត្ថុរឹបអូសនោះ ទើបធ្វើឱ្យការរឹបអូសមានអានុភាព។
- **ចំពោះការរឹបអូសចលនវត្ថុ ដែលកាន់កាប់ដោយតតិយជន៖** ដូចគ្នានេះដែរ ប្រសិនបើយល់ឃើញថា សមរម្យ អាជ្ញាសាលា ក៏អាចប្រគល់ចលនវត្ថុ ដែលត្រូវបានរឹបអូសនោះ ឱ្យទៅតតិយជនថែរក្សាបានដែរហើយករណីនេះ អាជ្ញាសាលាត្រូវបិទស្លាក ឬ ដាក់សញ្ញារឹបអូសផ្សេងទៀតលើចលនវត្ថុរឹបអូសនោះទើបធ្វើឱ្យការរឹបអូសមានអានុភាព។

### ២.២.៣ អានុភាពនៃការរឹបអូស

ជាគោលការណ៍ អានុភាពនៃការរឹបអូសចលនវត្ថុកើតមានតាមរយៈ ការកាន់កាប់ដោយអាជ្ញាសាលា។ លើកលែងតែការរឹបអូសចលនវត្ថុដែលមានការចុះបញ្ជី ដែលអានុភាពនៃការរឹបអូសនឹងកើតមាននៅពេលចុះបញ្ជីអំពីការរឹបអូសនៅក្នុងសៀវភៅចុះបញ្ជី និងការរឹបអូសចលនវត្ថុ ដែលអាជ្ញាសាលាអនុញ្ញាតឱ្យកូនបំណុលនៃការអនុវត្ត ឬ បុគ្គលផ្សេងពីកូនបំណុលនៃការអនុវត្តថែរក្សា ដែលអានុភាពនឹងកើតមាននៅពេលចលនវត្ថុនោះបានបិតស្លាក ឬ ដាក់សញ្ញាសម្គាល់ថាបានរឹបអូស។ អានុភាពនៃការរឹបអូសចលនវត្ថុ រួមមាន៖

87 . មាត្រា ៣៨៥ កថាខណ្ឌទី ៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
88 . មាត្រា ៣៨៥ កថាខណ្ឌទី ៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
89 . មាត្រា ៣៩០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

### ២.២.៣.១ អានុភាពចំពោះកូនបំណុលនៃការអនុវត្ត

ការរឹបអូសចលនវត្ថុដោយអាជ្ញាសាលា នៅក្នុងនីតិវិធីអនុវត្តដោយបង្ខំចំពោះចលនវត្ថុនឹងមានអានុភាពហាមឃាត់កូនបំណុលនៃការអនុវត្ត មិនឱ្យធ្វើការចាត់ចែងនូវចលនវត្ថុ ដែលត្រូវបានរឹបអូសនោះបានទេ។ ទោះបីជាការរឹបអូសចលនវត្ថុ ត្រូវធ្វើឡើងតាមរយៈការកាន់កាប់ដោយអាជ្ញាសាលាក៏ដោយ ករណីនេះជាលក្ខខណ្ឌតតាំងមួយ ដែលមិនអនុញ្ញាតឱ្យកូនបំណុលនៃការអនុវត្តមានលទ្ធភាព ក្នុងការចាត់ចែងនូវចលនវត្ថុនោះបានឡើយ។ ហើយបើទោះបីជាមានបញ្ញត្តិនៃមាត្រា ៣៨៥ កថាខណ្ឌទី៤ ដែលអាជ្ញាសាលា អាចអនុញ្ញាតឱ្យកូនបំណុលនៃការអនុវត្តធ្វើការគ្រប់គ្រងចលនវត្ថុ ដែលរឹបអូសនោះក៏ដោយ វាហាក់បីដូចជាការផ្តល់ឱកាសឱ្យកូនបំណុលនៃការអនុវត្តអាចធ្វើការចាត់ចែងនូវចលនវត្ថុនោះក្តី តែតតិយជន ដែលទទួលការផ្ទេរការកាន់កាប់ នៅក្រោយពេលការរឹបអូសនោះ មិនអាចតតាំងជាមួយនឹងម្ចាស់បំណុលនៃការអនុវត្តបានឡើយ។ ទោះជាបីជាខ្លួនបានបំពេញនូវលក្ខខណ្ឌតតាំងតាមក្រមរដ្ឋប្បវេណីក៏ដោយ។ ចំណែកឯកូនបំណុលនៃការអនុវត្ត ដែលបានធ្វើការចាត់ចែងនូវចលនវត្ថុ ដែលត្រូវបានរឹបអូសនោះ ក៏ត្រូវប្រឈមមុខនឹងការទទួលខុសត្រូវព្រហ្មទណ្ឌផងដែរ។

### ២.២.៣.២ អានុភាពចំពោះតតិយជន

ប្រសិនបើចលនវត្ថុ ដែលត្រូវបានរឹបអូស បែរជាធ្លាក់ទៅក្រោមការកាន់កាប់របស់តតិយជនដោយមិនមែនផ្អែកលើការចាត់ចែងរបស់អាជ្ញាសាលា ( **ឧទាហរណ៍៖ ករណីដែលកូនបំណុលនៃការអនុវត្ត ដែលមានបន្ទុកក្នុងការថែរក្សាគ្រប់គ្រងចលនវត្ថុដែលបានរឹបអូស បានផ្ទេរការកាន់កាប់ចលនវត្ថុនោះទៅឱ្យតតិយជន ដោយពុំមានការអនុញ្ញាត** ) សាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅ អាចបង្គាប់ឱ្យតតិយជននោះ ប្រគល់ចលនវត្ថុនោះទៅអាជ្ញាសាលាបាន ដោយដីកាសម្រេច តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត[90]។ ដីកាសម្រេចនេះអាចចេញបាន ទោះបីជាតតិយជនលើកយកសិទ្ធិកាន់កាប់វត្ថុនោះមកអះអាងក៏ដោយ ព្រោះថាប្រព័ន្ធនេះបានរៀបចំឡើងដើម្បីធ្វើបដិទានស្ថានភាពដើមឱ្យបានងាយស្រួល និងឆាប់រហ័ស។ ដើម្បីអាចលើកយកសិទ្ធិកាន់កាប់មកអះអាងបាន តតិយជនត្រូវធ្វើការដាក់ពាក្យបណ្តឹងតវ៉ារបស់តតិយជន[91]។

ពាក្យសុំចេញដីកាសម្រេចបង្គាប់ឱ្យប្រគល់ចលនវត្ថុ ដែលត្រូវបានរឹបអូស ត្រូវធ្វើឡើងក្នុងអំឡុងពេល ០១ សប្តាហ៍ គិតចាប់ពីថ្ងៃដែលម្ចាស់បំណុលនៃការអនុវត្តបានដឹងថាចលនវត្ថុ ដែលត្រូវបានរឹបអូសនោះកាន់កាប់ដោយតតិយជន[92]។ បើអំឡុងពេល ០១ សប្តាហ៍កន្លងផុត ម្ចាស់បំណុលមិនអាចដាក់ពាក្យសុំបានទេ។ មូលហេតុនៃការកំណត់បែបនេះ ព្រោះថាបើទុករយៈពេលវែងពេកសម្រាប់ការដាក់ពាក្យសុំ នោះនឹងប៉ះពាល់ទៅដល់ស្ថិរភាពនៃទំនាក់ទំនងគតិយុត្ត។

---

90 . មាត្រា ៣៩០ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

91 . មាត្រា ៣៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

92 . មាត្រា ៣៩០ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

**២.២.៣.៣ អានុភាពចំពោះផលធម្មជាតិ**

ការរឹបអូសក៏មានអានុភាពទៅលើផលធម្មជាតិ ដែលកើតចេញពីចលនវត្ថុ ដែលត្រូវបានរឹបអូសនោះផង ដែរ។ មានន័យថា នៅពេលដែលអាជ្ញាសាលាបានរឹបអូសចលនវត្ថុរបស់កូនបំណុលនៃកាអនុវត្ត ដែលជាវត្ថុ បង្កើតផល(វត្ថុដើម)[93]នោះ ហើយបន្ទាប់ពីបានរឹបអូសមក ចលនវត្ថុនោះបានបង្កើតបានជាផលធម្មជាតិ។ ករណី នេះវិសាលភាពនៃការរឹបអូស ក៏ត្រូវមានលើផលធម្មជាតិនោះផងដែរ ដោយម្ចាស់បំណុលនៃការអនុវត្តពុំចាំបាច់ សុំធ្វើការរឹបអូសចលនវត្ថុ ដែលជាផលធម្មជាតិនោះជាថ្មីទេ។

ឧទាហរណ៍៖ ការរឹបអូសសត្វគោដើម ដែលអំឡុងពេលនៃការរឹបអូសនោះ មេគោនោះបានកើតកូនគោ ដូច្នេះកូនគោនោះក៏ត្រូវស្ថិតនៅក្រោមការរឹបអូសដែរ។ មូលហេតុដែលកំណត់បែបនេះដោយហេតុថា គឺមិនចង់ឱ្យ មាននីតិវិធីសុំរឹបអូសជាថ្មីចំពោះផល ដែលកើតពីវត្ថុដើម (ដែលជាចលនវត្ថុត្រូវបានរឹបអូសរួច)។ ប្រសិនបើ អាជ្ញាសាលាប្រគល់ចលនវត្ថុ ដែលបានរឹបអូសទៅឱ្យកូនបំណុលនៃការអនុវត្ត ដើម្បីគ្រប់គ្រង និងប្រើប្រាស់តាម បញ្ញត្តិមាត្រា៣៨៥ កថាខណ្ឌទី៤ និងកថាខណ្ឌទី៥ នោះ កូនបំណុលនៃការអនុវត្តអាចគ្រប់គ្រង និងប្រើប្រាស់ ផលនោះបាន លុះត្រាតែទទួលការអនុញ្ញាតពីអាជ្ញាសាលា ហើយអានុភាពនៃការរឹបអូសនឹងត្រូវបិទស្លាក ឬ ដាក់ សញ្ញារឹបអូស។

## ២.៣ ការប្តូរជាប្រាក់នូវទ្រព្យសម្បត្តិដែលត្រូវរឹបអូស

បន្ទាប់ពីចលនវត្ថុត្រូវបានរឹបអូសរួចរាល់អស់ហើយ អាជ្ញាសាលាត្រូវរៀបចំចាត់ចែងធ្វើការប្តូរជាប្រាក់នូវ ចលនវត្ថុដែលត្រូវបានរឹបអូស តាមរយៈការលក់ដោយបង្ខំ។

**២.៣.១ វិធីលក់**

ការលក់ចលនវត្ថុ ដែលត្រូវបានរឹបអូស គឺត្រូវធ្វើតាមវិធីលក់ឡាយឡុងដោយផ្ទាល់មាត់ ឬ ដាក់លក់ដោយ ស្រោមសំបុត្រ ឬ ដាក់លក់តាមវិធីផ្សេងទៀត ដែលអាជ្ញាសាលាយល់ថាសមរម្យ ដោយទទួលការអនុញ្ញាតពី សាលាដំបូង ដែលអាជ្ញាសាលាស្ថិតនៅ[94] ដែលក្នុងនោះអ្នកប្រតិបត្តិការលក់គឺអាជ្ញាសាលា។

**២.៣.១.១ ការលក់ឡាយឡុងដោយផ្ទាល់មាត់**

ការលក់ឡាយឡុងដោយផ្ទាល់មាត់ ធ្វើឡើងដោយការស្នើចំនួនទឹកប្រាក់ថ្លៃទិញ ហើយអាជ្ញាសាលានឹង ប្រកាសអំពីការអនុញ្ញាតឱ្យទិញ ចំពោះអ្នកស្នើដែលហ៊ានឱ្យតម្លៃខ្ពស់ជាងគេ។ ក្នុងចំណោមវិធីលក់ចលនវត្ថុ ការលក់ឡាយឡុងដោយផ្ទាល់មាត់ គឺជាវិធីមួយដែលសមរម្យ និងងាយស្រួលក្នុងការអនុវត្ត។

---

[93] . មាត្រា ១២៧ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[94] . មាត្រា ៣៩៥ កថាខណ្ឌទី ១ និងកថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

### ២.៣.១.២ ការលក់ឡាយឡុងដោយស្រោមសំបុត្រ

ការលក់ឡាយឡុងដោយស្រោមសំបុត្រ ធ្វើឡើងតាមវិធីដែលអ្នកស្នើសុំទិញបានដាក់ពាក្យសុំទិញជាលាយលក្ខណ៍អក្សរ ហើយអាជ្ញាសាលានឹងបើកស្រោមសំបុត្រភ្លាមបន្ទាប់ពីដេញថ្លៃ រួចប្រកាសឈ្មោះ និងតម្លៃដេញរបស់បុគ្គល ដែលហ៊ានឱ្យថ្លៃជាងគេ ព្រមទាំងការអនុញ្ញាតឱ្យបុគ្គលនោះទិញ។ វិធីលក់ឡាយឡុងដោយស្រោមសំបុត្រនេះ គេច្រើនយកមកអនុវត្តនៅក្នុងការលក់ចលនវត្ថុ ដែលមានតម្លៃខ្ពស់ ហើយដែលអាចកំណត់តម្លៃអប្បបរមា តាមការវាយតម្លៃរបស់អ្នកវាយតម្លៃ។

### ២.៣.១.៣ ការលក់តាមវិធីផ្សេងៗ

ប្រសិនបើអាជ្ញាសាលាយល់ឃើញថាសមរម្យ ដោយគិតពិចារណាអំពីប្រភេទ និងចំនួននៃចលនវត្ថុ ជាអាទិ៍ អាជ្ញាសាលាអាចអនុវត្តការលក់ចលនវត្ថុ ដែលត្រូវបានរឹបអូសផ្សេងក្រៅពីវិធីទាំងពីរនោះ ឬ ឱ្យបុគ្គលផ្សេងពីអាជ្ញាសាលាអនុវត្តការលក់ចលនវត្ថុ ដែលត្រូវបានរឹបអូសនោះ ដោយទទួលការអនុញ្ញាតពីសាលាដំបូងដែលខ្លួនស្ថិតនៅបាន។ វិធីផ្សេងនោះអាចមានដូចជា៖ ការលក់ចលនវត្ថុនៅក្នុងពិធីតាំងពិពណ៌ ការយកចលនវត្ថុដែលត្រូវបានរឹបអូសទៅលក់នៅកន្លែងដែលងាយលក់ ឬ ការអនុញ្ញាតឱ្យបុគ្គល ដែលមានបទពិសោធន៍ខ្លាំងក្នុងការលក់ចលនវត្ថុ ដែលមានប្រភេទដូចគ្នានឹងចលនវត្ថុ ដែលត្រូវបានរឹបអូស។ល។ ឧទាហរណ៍៖ អាជ្ញាសាលាបានរឹបអូសគ្រឿងម៉ាស៊ីនរថយន្ត ករណីបើយល់ថាសមរម្យ អាជ្ញាសាលាគួរអនុញ្ញាតឱ្យអ្នកលក់គ្រឿងម៉ាស៊ីនជាអ្នកលក់ជំនួសវិញ ព្រោះអាចមានភាពងាយស្រួលក្នុងការលក់ និងមានភាពច្បាស់លាស់។

### ២.៣.២ បុគ្គលដែលមិនអនុញ្ញាតឱ្យដាក់សំណើទិញ

នៅពេលដែលអាជ្ញាសាលា អនុវត្តការលក់ចលនវត្ថុដែលត្រូវបានរឹបអូស បុគ្គលដែលមិនត្រូវបានអនុញ្ញាតឱ្យដាក់សំណើទិញចលនវត្ថុនោះរួមមាន៖

- កូនបំណុលនៃការអនុវត្ត[95]។
- បុគ្គលដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពមានដូចជាអនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ ជននៅស្ថិតនៅក្រោមរបបហិតូបត្ថម្ភ[96] និងបុគ្គលដែលខ្វះសមត្ថភាពខាងបង្ហាញឆន្ទៈ[97]។
- បុគ្គលដែលច្បាប់កំណត់មិនអាចក្លាយជាអ្នកទិញបាន[98] រួមមាន៖
  - មន្ត្រីរាជការដែលទទួលបន្ទុកចាត់ការ ការលក់ដោយបង្ខំ ឬ ទទួលបន្ទុកគ្រប់គ្រងការលក់ ដោយបង្ខំក៏មិនអាចក្លាយជាអ្នកទិញបានដែរ។

---

[95] . មាត្រា ៣៩៥ កថាខណ្ឌទី ៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[96] . មាត្រា ១៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[97] . មាត្រា ១៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[98] . មាត្រា ៥២៥ និង មាត្រា ៥២៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

- អ្នកគ្រប់គ្រងទ្រព្យសម្បត្តិតាមច្បាប់ តាមផ្លូវតុលាការ ឬ តាមកិច្ចសន្យា មិនអាចក្លាយជាអ្នកទិញដោយការលក់ដោយបង្ខំនូវទ្រព្យសម្បត្តិ ដែលខ្លួនទទួលភារកិច្ចលក់ដោយផ្ទាល់ខ្លួន ឬ តាមរយៈអន្តរការីបានឡើយ។
- ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី ឬ មន្ត្រីតុលាការផ្សេងទៀត មិនអាចក្លាយជាអ្នកទិញដោយការលក់ដោយបង្ខំ ដោយផ្ទាល់ខ្លួន ឬ តាមរយៈអន្តរការីនូវវត្ថុ ឬ សិទ្ធិដែលជាកម្មវត្ថុនៃវិវាទ ដែលកំពុងចាត់ការនៅតុលាការដែលខ្លួនបំពេញភារកិច្ចបានទេ។
- មេធាវី ឬ សារការី មិនអាចក្លាយជាអ្នកទិញដោយការលក់ដោយបង្ខំនូវវត្ថុ ឬ សិទ្ធិដែលទាក់ទងនឹងរឿងក្តីដែលខ្លួនទទួលបន្ទុក។

➢ អ្នកទិញ ដែលមិនបានបង់ថ្លៃទិញចលនវត្ថុក្នុងពេលលក់លើកមុន មិនអាចដាក់សំណើទិញជាថ្មីនៅក្នុងការលក់ចលនវត្ថុដោយបង្ខំម្តងទៀតបានទេ[99]។

➢ បុគ្គលដែលអាជ្ញាសាលាមិនអនុញ្ញាតឱ្យដាក់សំណើទិញ ដោយសារបានធ្វើសកម្មភាពរំខានកុំឱ្យការលក់ធ្វើឡើងដោយត្រឹមត្រូវ ដូចជាធ្វើឱ្យរំខានដល់បុគ្គលដទៃក្នុងការធ្វើសំណើទិញ ឬ បានឃុបឃិតដើម្បីបញ្ចុះតម្លៃដោយមិនត្រឹមត្រូវ[100]។

### ២.៣.៣ នីតិវិធីនៃការលក់

ការលក់ចលនវត្ថុ ដែលត្រូវបានរឹបអូស អាចមានលក្ខណៈប្រែប្រួលអាស្រ័យទៅតាមវិធីនៃការលក់ និងប្រភេទនៃចលនវត្ថុដែលនឹងត្រូវលក់។

❖ **ចំពោះចលនវត្ថុដែលនឹងត្រូវលក់ អាចកំណត់តម្លៃដោយអាជ្ញាសាលាបាន**

ការលក់ចលនវត្ថុ ដែលអាជ្ញាសាលាអាចវាយតម្លៃបាននោះ ជាដំបូងអាជ្ញាសាលាត្រូវកំណត់តម្លៃអប្បបរមានៃចលនវត្ថុ វិធីនៃការលក់ចលនវត្ថុ (ស្រោមសំបុត្រ ឬ ផ្ទាល់មាត់) កាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃការលក់ជាមុនសិន។ បន្ទាប់មកអាជ្ញាសាលា ត្រូវជូនដំណឹងជាសាធារណៈអំពីចលនវត្ថុ ដែលនឹងត្រូវដាក់លក់ និងវិធីលក់ចលនវត្ថុ ដោយបិទប្រកាសនៅកន្លែងបិទប្រកាសរបស់តុលាការ[101]។

នៅថ្ងៃលក់ អាជ្ញាសាលា ត្រូវប្រកាសលក់ចលនវត្ថុនោះ ដោយបញ្ជាក់អំពីតម្លៃអប្បបរមា ហើយចាប់ផ្តើមឱ្យអ្នកទិញដាក់សំណើទិញតាមវិធីដែលបានជូនដំណឹង។ នៅពេលបញ្ចប់ការដាក់សំណើទិញអាជ្ញាសាលាត្រូវប្រកាសឈ្មោះអ្នកទិញ និងតម្លៃដែលខ្ពង់ជាងគេ។ បន្ទាប់មកអាជ្ញាសាលា ត្រូវប្រកាសអនុញ្ញាតឱ្យទិញ ដែលករណីនេះ អ្នកទិញត្រូវបង់ថ្លៃទិញភ្លាមៗ ទើបទទួលបាននូវលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុនោះបាន។

[99] . មាត្រា ៣៩៥ កថាខណ្ឌទី ៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[100] . មាត្រា ៣៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[101] . មាត្រា ៣៩៥ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

ក្នុងករណីដែលអ្នកទិញ មិនបានបង់ថ្លៃទិញទេ អាជ្ញាសាលាត្រូវដាក់លក់ឡាយឡុងម្តងទៀត តាមវិធីដូចខាងដើម ហើយអ្នកទិញមុន មិនអាចដាក់សំណើទិញបានទៀតទេ។

❖ **ចំពោះចលនវត្ថុដែលនឹងត្រូវលក់ ទាមទារឱ្យមានការវាយតម្លៃពីអ្នកវាយតម្លៃ**

ប្រសិនបើចលនវត្ថុ ដែលជាកម្មវត្ថុនៃការដាក់លក់ឡាយឡុងនោះមានតម្លៃខ្ពស់ ជាដំបូងអាជ្ញាសាលាត្រូវជ្រើសតាំងអ្នកវាយតម្លៃ ហើយឱ្យអ្នកវាយតម្លៃនោះ វាយតម្លៃលើចលនវត្ថុនោះជាមុនសិន។ បន្ទាប់ពីបានទទួលរបាយការណ៍ពីអ្នកវាយតម្លៃរួចហើយ អាជ្ញាសាលាត្រូវកំណត់តម្លៃអប្បបរមានៃចលនវត្ថុនោះ វិធីលក់ឡាយឡុង កាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃការលក់។ បន្ទាប់មកអាជ្ញាសាលា ត្រូវជូនដំណឹងជាសាធារណៈអំពីចលនវត្ថុ ដែលនឹងត្រូវដាក់លក់ និងវិធីលក់ចលនវត្ថុ ដោយបិទប្រកាសនៅកន្លែងបិទប្រកាសរបស់តុលាការ។

នៅថ្ងៃលក់ អាជ្ញាសាលា ត្រូវប្រកាសលក់ចលនវត្ថុនោះ ដោយបញ្ជាក់អំពីតម្លៃអប្បបរមា ហើយចាប់ផ្តើមឱ្យអ្នកទិញដាក់សំណើទិញតាមវិធីដែលបានជូនដំណឹង។ នៅពេលបញ្ចប់ការដាក់សំណើទិញ អាជ្ញាសាលាត្រូវប្រកាសឈ្មោះអ្នកទិញ និងតម្លៃដែលខ្ពង់ជាងគេ។ បន្ទាប់មកអាជ្ញាសាលា ត្រូវប្រកាសអនុញ្ញាតឱ្យទិញ ដែលករណីនេះ អ្នកទិញត្រូវបង់ថ្លៃទិញភ្លាមៗ ទើបទទួលបាននូវលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុនោះបាន។

ក្នុងករណីដែលអ្នកទិញ មិនបានបង់ថ្លៃទិញទេ អាជ្ញាសាលាត្រូវដាក់លក់ឡាយឡុងម្តងទៀត តាមវិធីដូចខាងដើម ហើយអ្នកទិញមុន មិនអាចដាក់សំណើទិញបានទៀតទេ។

### ២.៣.៤ ការលក់ចលនវត្ថុដែលត្រូវបានរឹបអូសក្នុងពេល ដែលការអនុវត្តកំពុងត្រូវបានផ្អាក

ជាគោលការណ៍ នៅពេលដែលការអនុវត្តដោយបង្ខំត្រូវបានផ្អាក ស្ថាប័នអនុវត្ត មិនអាចចំណាត់ការនីតិវិធីអនុវត្តណាមួយឡើយ។ ដូចគ្នានេះដែរ ប្រសិនបើការអនុវត្តដោយបង្ខំចំពោះចលនវត្ថុត្រូវបានផ្អាក អាជ្ញាសាលាដែលជាស្ថាប័នអនុវត្ត ក៏មិនអាចធ្វើចំណាត់បន្តនីតិវិធីឡើយ។ ប៉ុន្តែប្រសិនបើការអនុវត្តដោយបង្ខំចំពោះចលនវត្ថុត្រូវបានផ្អាកដោយសារការដាក់ឯកសារចម្លងយថាភូតនៃសេចក្តីសម្រេច ដែលកំណត់ការបង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំមួយរយៈ ឬ ឯកសារដែលសរសេរថាម្ចាស់បំណុលទទួលសំណង ឬ បានយល់ព្រមពន្យារពេល ដែលត្រូវសងនៅក្រោយពេលលិខិតអនុវត្តត្រូវបានបង្កើត ហើយប្រសិនបើមានការបារម្ភថាតម្លៃចលនវត្ថុ ដែលបានរឹបអូសនឹងចុះថោកខ្លាំង ឬ សោហ៊ុយចំណាយសម្រាប់រក្សាទុកចលនវត្ថុ ដែលត្រូវបានរឹបអូសនឹងមានចំនួនច្រើនមិនសមរម្យ អាជ្ញាសាលា អាចលក់ចលនវត្ថុ ដែលត្រូវរឹបអូសនោះតាមវិធីលក់ចលនវត្ថុធម្មតាបាន[102]។

[102] . មាត្រា ៣៩៧ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

អាជ្ញាសាលា អាចធ្វើការលក់ចលនវត្ថុ ដែលត្រូវបានរឹបអូសនៅក្នុងអំឡុងពេលនៃការផ្អាកការអនុវត្តបាន លុះត្រាតែ៖

• ការផ្អាកការអនុវត្តនោះកើតឡើងដោយសារតែមានការដាក់ឯកសារចម្លងយថាភូត នៃសេចក្ដីសម្រេច ដែលកំណត់ការបង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំមួយរយៈ ឬ ឯកសារ ដែលសរសេរថាម្ចាស់បំណុលបានទទួលសំណង ឬ បានយល់ព្រមពន្យាពេល ដែលត្រូវសងនៅក្រោយពេលលិខិតអនុវត្តត្រូវបានបង្កើត។ ពោលគឺ មិនមែនគ្រប់ការផ្អាកការអនុវត្តទាំងអស់ សុទ្ធតែអាចឱ្យអាជ្ញាសាលា ធ្វើការលក់ចលនវត្ថុដែលត្រូវបានរឹបអូសបាននោះទេ។ មូលដ្ឋានដែលកំណត់បែបនេះដោយសារតែ ការផ្អាកអនុវត្តទាំងពីរខាងលើនេះ គឺមានអានុភាពផ្អាកតែមួយរយៈ និងមិនបង្ហាញអំពីលទ្ធភាពនៃការលុបចោលការអនុវត្តផងដែរ។

• មានការបារម្ភថាតម្លៃចលនវត្ថុ ដែលត្រូវរឹបអូសនោះនឹងធ្លាក់តម្លៃ ឬ មានការចំណាយសោហ៊ុយគ្រប់គ្រងចលនវត្ថុដែលត្រូវរឹបអូសច្រើនមិនសមរម្យ។

ហើយនៅពេលអាជ្ញាសាលាលក់បានប្រាក់ហើយនោះ អាជ្ញាសាលា ត្រូវធ្វើប្រាក់នោះទុកនៅសាលាដំបូងដែលខ្លួនស្ថិតនៅ[103]។

### ២.៣.៥ ការទទួលខុសត្រូវ និងសិទ្ធិអំណាចរបស់អាជ្ញាសាលាក្នុងពេលលក់

អាជ្ញាសាលា ត្រូវទទួលខុសត្រូវនៅក្នុងការរៀបចំ និងការរក្សាសណ្ដាប់ធ្នាប់នៅកន្លែងលក់ ធ្វើយ៉ាងណាឱ្យការលក់ឡាយឡុងចលនវត្ថុនោះ អាចប្រព្រឹត្តទៅបានត្រឹមត្រូវតាមនីតិវិធីច្បាប់។ ដើម្បីបញ្ចៀសនូវការរំខានផ្សេងៗ ដូចជា ការធ្វើឱ្យរំខានដល់អ្នកដទៃទៀតក្នុងពេលធ្វើសំណើទិញ ឬ បានឃុបឃិត ដើម្បីបញ្ចុះតម្លៃលក់ដោយមិនត្រឹមត្រូវ ឬ ចំពោះជនដែលប្រើឱ្យធ្វើសកម្មភាពនោះ អាជ្ញាសាលា អាចកម្រិតមិនឱ្យជននោះចូលកន្លែងលក់ អាចដេញជននោះចេញពីកន្លែងលក់ ឬ អាចមិនឱ្យស្នើសុំទិញបាន។ ហើយក្នុងករណី ដែលការលក់មិនអាចធ្វើទៅបាន បើទោះបីជាបានអនុវត្តការលក់តាមវិធីសមរម្យក៏ដោយ ហើយប៉ាន់ប្រមាណឃើញថា មិនអាចលក់បាននាពេលអនាគត អាជ្ញាសាលា អាចលុបចោលការរឹបអូសចលនវត្ថុនោះបាន[104]។

## ២.៤ ការបែងចែកចំណែក

ការបែងចែកចំណែក ជានីតិវិធីមួយនៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ដែលអាជ្ញាសាលាត្រូវយកប្រាក់ ដែលបានពីការលក់ចលនវត្ថុ ឬ ប្រាក់ដែលបានមកពីការរឹបអូសនោះ សងទៅឱ្យម្ចាស់បំណុលដែលមានសិទ្ធិលើបំណុលទៅកូនបំណុលនៃការអនុវត្ត។

[103] . មាត្រា ៣៩៧ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[104] . មាត្រា ៣៩៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

### ២.៤.១ ការទាមទារឱ្យចែកចំណែក

#### ២.៤.១.១ ម្ចាស់បំណុលដែលមានសិទ្ធិទាមទារ ឱ្យចែកចំណែកបាន

ម្ចាស់បំណុល ដែលមានសិទ្ធិទាមទារឱ្យអាជ្ញាសាលាចែកចំណែក នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុបាន រួមមាន៖

• ម្ចាស់បំណុល ដែលបានទាមទារឱ្យចែកចំណែកតាមរយៈការរួមបញ្ចូលរឿងក្តី។ ជាទូទៅមិនមែនគ្រប់ម្ចាស់បំណុល ដែលមានសិទ្ធិលើបំណុលលើកូនបំណុល សុទ្ធតែអាចស្នើរួមបញ្ចូលរឿងក្តីជាមួយនឹងម្ចាស់បំណុលនៃការអនុវត្ត ដើម្បីទទួលបានចំណែកនោះទេ។ ម្ចាស់បំណុល ដែលអាចស្នើរួមបញ្ចូលរឿងក្តីបាននោះគឺមានតែម្ចាស់បំណុល ដែលមានលិខិតអនុវត្តតាមមាត្រា៣៥០ កថាខណ្ឌទី២ ហើយបានដាក់ពាក្យសុំឱ្យអនុវត្ត ដោយបង្ខំចំពោះចលនវត្ថុលើកូនបំណុលនៅកន្លែងដដែល ឬ ម្ចាស់បំណុល ដែលអនុវត្តការរឹបអូសជាបណ្តោះអាសន្នរួចហើយតែប៉ុណ្ណោះ។ មានន័យថា ទោះបីជាម្ចាស់បំណុល ដែលមានលិខិតអនុវត្តហើយមិនទាន់បានអនុវត្ត ឬ មិនទាន់អនុវត្តការរឹបអូសជាបណ្តោះអាសន្ននៅឡើយទេនោះ មិនអាចទាមទារឱ្យអាជ្ញាសាលាចែកចំណែកឱ្យមកខ្លួនបានទេ[105]។

• ម្ចាស់បំណុលដែលមានឯកសិទ្ធិ ឬ សិទ្ធិលើការបញ្ចាំ អាចទាមទារឱ្យអាជ្ញាសាលាធ្វើការ ចែកចំណែកឱ្យមកខ្លួនបានដែរ[106]។

#### ២.៤.១.២ វិធីទាមទារឱ្យចែកចំណែក

ការទាមទារឱ្យចែកចំណែកមានភាពខុសប្លែកគ្នាអាស្រ័យទៅតាមប្រភេទនៃម្ចាស់បំណុល ដែលមានសិទ្ធិទាមទារឱ្យចែកចំណែក ដែលក្នុងនោះរួមមាន៖

• **ចំពោះម្ចាស់បំណុល ដែលទាមទារឱ្យចែកចំណែកតាមរយៈការរួមបញ្ចូលរឿងក្តី៖** ដើម្បីអាចក្លាយជាម្ចាស់បំណុល ដែលមានសិទ្ធិទទួលចំណែកបាន ម្ចាស់បំណុលប្រភេទនេះមិនអាចដាក់ពាក្យសុំទាមទារឱ្យចែកចំណែកបានទេ គឺមានតែវិធីដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំលើចលនវត្ថុ ឬ ដាក់ពាក្យសុំឱ្យអនុវត្តរឹបអូសជាបណ្តោះអាសន្ន ដោយសំអាងលើលិខិតអនុវត្តរបស់ខ្លួន។ ករណីនេះនៅពេល ដែលអាជ្ញាសាលាបានទទួលនូវពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ឬ ពាក្យសុំឱ្យអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុលើកូនបំណុលនៅទីតាំងដដែលហើយនោះ ជាដំបូងអាជ្ញាសាលា ត្រូវរឹបអូសចលនវត្ថុរបស់កូនបំណុលដែលនៅសេសសល់ជាមុនសិន តែបើគ្មានសេសសល់ទេ អាជ្ញាសាលាត្រូវបញ្ជាក់អំពីហេតុការណ៍នេះ ហើយត្រូវរួមបញ្ចូលរឿងក្តីអនុវត្តចំពោះចលនវត្ថុ ការរឹបអូសចលនវត្ថុថ្មី ជាមួយនឹងរឿងក្តីអនុវត្តដោយបង្ខំចំពោះចលនវត្ថុមុន ដែលមាន

---

105 . មាត្រា ៣៨៨ និង ៣៩៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

106 . មាត្រា ៣៩៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

អានុភាពជាការចែកចំណែក[107]។ ការរួមបញ្ចូលរឿងក្តី ក៏អាចត្រូវធ្វើឡើងតាមរយៈពាក្យសុំរបស់ម្ចាស់បំណុលនៅក្នុងសំណុំរឿងក្តីអនុវត្តថ្មី ក៏អានុភាពនៃការចែកចំណែកកើតមានដែរ[108]។

• **ចំពោះម្ចាស់បំណុល ដែលមានឯកសិទ្ធិ ឬ សិទ្ធិលើការបញ្ចាំ៖** ដើម្បីអាចក្លាយខ្លួនជាម្ចាស់បំណុលដែលមានសិទ្ធិទទួលចំណែក ដែលបានមកពីការលក់ចលនវត្ថុបាន ម្ចាស់បំណុលដែលមានឯកសិទ្ធិ សិទ្ធិលើការបញ្ចាំ ត្រូវដាក់ពាក្យសុំទាមទារឱ្យចែកចំណែក (មិនដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំទេ) ប៉ុន្តែម្ចាស់បំណុលត្រូវភ្ជាប់មកជាមួយឯកសារ ដែលមានបញ្ជាក់អំពីឯកសិទ្ធិ ឬ សិទ្ធិលើការបញ្ចាំនោះ។

**២.៤.១.៣ ពេលដែលមានអត្ថិភាពក្នុងការទាមទារឱ្យចែកចំណែក**

ទោះបីជាខ្លួនជាម្ចាស់បំណុល ដែលមានសិទ្ធិទាមទារឱ្យចែកចំណែកក៏ដោយ ប៉ុន្តែប្រសិនបើម្ចាស់បំណុលមិនបានសុំទាមទារឱ្យចែកចំណែកក្នុងអំឡុងពេល ដែលច្បាប់បានកំណត់ទេនោះ ក៏ម្ចាស់បំណុលនោះនៅតែមិនអាចក្លាយជាម្ចាស់បំណុល ដែលមានសិទ្ធិទទួលចំណែកបានដដែល។

នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ពុំបានចែងអំពីអំឡុងពេលនៃការទាមទារចែកចំណែកឱ្យបានច្បាស់លាស់នោះទេ ប៉ុន្តែបើយើងពិនិត្យមើលមាត្រា ៣៩៨ នោះវិញ យើងអាចសង្កេតបានថា អំឡុងពេលសម្រាប់ទាមទារឱ្យចែកចំណែក គឺកំណត់ត្រឹមពេល ដែលបានទទួលការប្រគល់ប្រាក់ចំពោះប្រាក់ ដែលបានមកពីការលក់ ឬ ពេលដែលបានរឹបអូសប្រាក់ ចំពោះប្រាក់ដែលត្រូវបានរឹបអូសតែប៉ុណ្ណោះ។ មានន័យថា ម្ចាស់បំណុលអាចទាមទារឱ្យចែកចំណែកបាន គឺគិតចាប់ពីការចាប់ផ្តើមការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ រហូតដល់ពេលទទួលប្រាក់។

ប៉ុន្តែអាជ្ញាសាលា អាចចែកចំណែកឱ្យម្ចាស់បំណុល ដែលបានសុំឱ្យចែកចំណែក នៅក្រោយពេលអ្នកទិញបានបង់ថ្លៃលក់ហើយ ក្នុងករណីដែលមានឯកសារដូចខាងក្រោមត្រូវបានដាក់[109]៖

• ឯកសារចម្លងយថាភូតនៃសេចក្តីសម្រេចដែលកំណត់ថាលុបចោលលិខិតអនុវត្ត ក្រៅពីលិខិតយថាភូតដែលកំណត់ក្នុងចំណុច ច កថាខណ្ឌទី២ នៃមាត្រា ៣៥០ ឬឯកសារចម្លងយថាភូតនៃសេចក្តីសម្រេចដែលកំណត់ថា លុបចោលការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន។

• ឯកសារចម្លងយថាភូតនៃសេចក្តីសម្រេច ដែលបានកំណត់ថាមិនអនុញ្ញាតឱ្យអនុវត្តដោយបង្ខំ។

• អនុសារសាលក្រមស្ថាពរ ឬ អនុសារសាលដីកាស្ថាពរ ដែលប្រកាសថាការផ្សះផ្សារ ឬ ការទទួលស្គាល់ដែលទាក់ទងនឹងលិខិតអនុវត្តគ្មានអានុភាព។

[107]. មាត្រា ៣៨៨ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[108]. មាត្រា ៣៨៨ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[109]. មាត្រា ៣៩៣ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

- ឯកសារចម្លងយថាភូតនៃកំណត់ហេតុ ឬ ឯកសារផ្សេងទៀត ដែលក្រឡាបញ្ជីបានធ្វើ ដែលបញ្ជាក់ថា លិខិតអនុវត្ត ដែលត្រូវបានកំណត់ពីចំណុច ខ រហូតដល់ចំណុច ង កថាខណ្ឌទី២ នៃមាត្រា ៣៥០ បាត់បង់អានុភាពដោយសារការដកពាក្យបណ្ដឹង ឬ មូលហេតុផ្សេងទៀត។
- ឯកសារចម្លងយថាភូត ដែលកំណត់អំពីការផ្សះផ្សា តាមនីតិវិធីនៃការសម្រេចសេចក្ដី ដែលបានកំណត់ថាមិនអនុវត្តដោយបង្ខំ ឬ ដកពាក្យសុំឱ្យអនុវត្តដោយបង្ខំនោះវិញ។
- ឯកសារដែលបញ្ជាក់អំពីការដាក់ប្រាតិភោគ ដើម្បីឱ្យរួចផុតពីការអនុវត្តដោយបង្ខំ។
- ឯកសារចម្លងយថាភូតនៃសេចក្ដីសម្រេច ដែលកំណត់បង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំ និងការលុបចោលការចាត់ចែងការអនុវត្ត។
- ឯកសារចម្លងយថាភូតនៃសេចក្ដីសម្រេច ដែលកំណត់ការបង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំមួយរយៈ។
- ឯកសារដែលសរសេរថា ម្ចាស់បំណុលទទួលសំណង ឬ បានយល់ព្រមពន្យារពេលដែលត្រូវសងនៅក្រោយពេលលិខិតអនុវត្តត្រូវបានបង្កើត។

## ២.៤.២ ការអនុវត្តការចែកចំណែក

### ២.៤.២.១ ករណីដែលមានម្ចាស់បំណុលតែម្នាក់

អាជ្ញាសាលា ត្រូវយកប្រាក់ ដែលបានមកពីការលក់ចលនវត្ថុរឹបអូស ឬ ប្រាក់ដែលបានមកពីការរឹបអូសប្រគល់ទៅឱ្យម្ចាស់បំណុលនៃកាអនុវត្ត ព្រមទាំងសោហ៊ុយសម្រាប់ការអនុវត្ត ហើយបើនៅមានប្រាក់នៅសល់អាជ្ញាសាលាត្រូវប្រគល់ទៅឱ្យកូនបំណុលនៃការអនុវត្តវិញ។

### ២.៤.២.២ ករណីដែលមានម្ចាស់បំណុលច្រើននាក់

ករណីដែលប្រាក់បានមកពីការលក់ចលនវត្ថុ ឬ ប្រាក់ដែលបានមកពីការរឹបអូស អាចសងបំណុលរបស់ម្ចាស់បំណុលនីមួយៗ និងសោហ៊ុយសម្រាប់ការអនុវត្តបានទាំងអស់ អាជ្ញាសាលា ត្រូវចែកចំណែកចំពោះម្ចាស់បំណុល ហើយត្រូវប្រគល់ប្រាក់ ដែលនៅសល់ទៅឱ្យកូនបំណុលនៃការអនុវត្តវិញ[110]។

ករណីដែលប្រាក់មិនគ្រប់ចំនួនសម្រាប់ចែកចំណែក ឬ ផ្សេងទៀត អាជ្ញាសាលាមិនអាចចែកចំណែកឱ្យទៅម្ចាស់បំណុលទាំងអស់បានភ្លាមៗទេ ដែលករណីនេះអាជ្ញាសាលាត្រូវកំណត់ថ្ងៃក្នុងអំឡុងពេល ២ សប្ដាហ៍ ជាថ្ងៃត្រូវពិភាក្សាគ្នាអំពីការចែកចំណែកនៃប្រាក់ ដែលបានមកពីការលក់ ឬ ប្រាក់ដែលបានមកពីការរឹបអូស ហើយត្រូវជូនដំណឹងពីពេលវេលា និងទីកន្លែងទៅម្ចាស់បំណុលនីមួយៗ[111]។ បើម្ចាស់បំណុលនីមួយៗបានពិភាក្សាគ្នាដាច់ស្រេចហើយនោះ អាជ្ញាសាលា ត្រូវចែកចំណែកតាមការពិភាក្សាគ្នារវាងម្ចាស់បំណុលទាំងនោះ។ ផ្ទុយទៅវិញ

[110] . មាត្រា ៣៩៩ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[111] . មាត្រា ៣៩៩ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

ប្រសិនបើម្ចាស់បំណុលមិនបានពិភាក្សាគ្នាឱ្យដាច់ស្រេចទេនោះ អាជ្ញាសាសាលា ត្រូវរាយការណ៍អំពីហេតុការណ៍ នេះទៅសាលាដំបូងដែលខ្លួនស្ថិតនៅ ដើម្បីធ្វើជាអ្នកចែកចំណែកបន្ត[112]។

**២.៤.២.៣ វិសាលភាពនៃម្ចាស់បំណុលដែលត្រូវទទួលចំណែក**

ម្ចាស់បំណុលដែលត្រូវទទួលចំណែក គឺជាបុគ្គលដែលបានកំណត់ក្នុងចំណុចនីមួយៗដូចខាងក្រោម[113]៖

- ម្ចាស់បំណុលនៃការអនុវត្ត សំដៅដល់ម្ចាស់បំណុល ដែលបានដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះ ចលនវត្ថុ។
- ម្ចាស់បំណុលដែលទាមទារឱ្យចែកចំណែក រហូតដល់ពេលដែលអាជ្ញាសាលា បានទទួលការប្រគល់ ប្រាក់ចំពោះប្រាក់ដែលបានមកពីការលក់ សំដៅដល់ម្ចាស់បំណុល ដែលបានទាមទារឱ្យចែកចំណែក តាមរយៈការរួមបញ្ចូលរឿងក្តី និងទាមទារឱ្យចែកចំណែករបស់ម្ចាស់បំណុលដែលមានឯកសិទ្ធិ ឬ សិទ្ធិ លើការបញ្ចាំ។
- ម្ចាស់បំណុលដែលទាមទារឱ្យចែកចំណែក រហូតដល់ពេលដែលរឹបអូសប្រាក់ចំពោះប្រាក់ ដែលបាន រឹបអូស សំដៅដល់ម្ចាស់បំណុល ដែលបានទាមទារឱ្យចែកចំណែកតាមរយៈការរួមបញ្ចូលរឿង និង ទាមទារឱ្យចែកចំណែករបស់ម្ចាស់បំណុលដែលមានឯកសិទ្ធិ ឬ សិទ្ធិលើការបញ្ចាំ។

**២.៤.៣ អានុភាពនៃការចែកចំណែក**

**២.៤.៣.១ ការចាត់ទុកថាដល់ពេលកំណត់ត្រូវសង**

ចំពោះសិទ្ធិលើបំណុលដែលកំណត់ពេលពិតប្រាកដ ពុំទាន់មកដល់ ត្រូវចាត់ទុកថា កំណត់ពេលសងនោះ បានចូលមកដល់ហើយ[114]។ មានន័យថា ទោះបីជាម្ចាស់បំណុលបានទាមទារឱ្យចែកចំណែកដោយផ្អែកលើ សិទ្ធិលើបំណុល ដែលមិនទាន់ដល់ពេលកំណត់ត្រូវសងក៏ដោយ ក៏អានុភាពនៃការចែកចំណែក នាំឱ្យទទួល ស្គាល់ថាសិទ្ធិលើបំណុលនោះបានដល់ពេលកំណត់ត្រូវសងហើយ។ ហើយករណីនេះ ម្ចាស់បំណុលអាចទទួល យកចំណែកបានហើយ។

ឧទាហរណ៍៖ ម្ចាស់បំណុល ដែលមានសិទ្ធិលើការបញ្ចាំលើចលនវត្ថុ និងមានសិទ្ធិលើបំណុលចំនួន ១.៥០០ USD (មួយពាន់ប្រាំរយដុល្លារអាមេរិក) ចំពោះកូនបំណុលនៃការអនុវត្ត ហើយពេលកំណត់ ដែលត្រូវ សងនៅឆ្នាំ២០២៤ បានទាមទារឱ្យអាជ្ញាសាលាចែកចំណែក ដែលនឹងត្រូវចែកចំណែកនៅ ខែតុលា ឆ្នាំ២០២៣។ ពេលចូលមកដល់នីតិវិធីបែងចែកចំណែក ពេលកំណត់ដែលត្រូវសងនៅឆ្នាំ២០២៤ ត្រូវសន្មត់ថាបានមកដល់ ហើយ។ ដូច្នេះអាជ្ញាសាលា អាចចែកចំណែកឱ្យម្ចាស់បំណុល ដែលមានសិទ្ធិលើការបញ្ចាំនោះបាន។

112 . មាត្រា ៤០១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

113 . មាត្រា ៣៩៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

114 . មាត្រា ៣៩៩ កថាខណ្ឌទី ៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

**២.៤.៣.២ ការផ្ញើប្រាក់ចំណែករបស់ម្ចាស់បំណុលទៅតុលាការ**

បន្ទាប់ពីការចែកចំណែកបានបញ្ចប់ហើយ អាជ្ញាសាលា ត្រូវផ្ញើប្រាក់ដែលស្មើនឹងចំណែករបស់ម្ចាស់បំណុល ដែលត្រូវទទួលទៅសាលាដំបូងដែលខ្លួនស្ថិតនៅ ប្រសិនបើមានហេតុការណ៍ដូចខាងក្រោម ហើយត្រូវរាយការណ៍ទៅសាលាដំបូងអំពីហេតុការណ៍នោះ[115]៖

- បើសិទ្ធិលើបំណុលនោះ មានភ្ជាប់នូវលក្ខខណ្ឌបង្អង់ ឬ កំណត់ពេលមិនពិតប្រាកដ។
- បើសិទ្ធិលើបំណុលនោះ ជាសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការរឹបអូសជាបណ្តោះអាសន្ន។
- បើមានការដាក់ឯកសារចម្លងយថាភូតនៃសេចក្តីសម្រេច ដែលកំណត់ការបង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំមួយរយៈ។
- បើមានការដាក់ឯកសារចម្លងយថាភូតនៃសេចក្តីសម្រេច ដែលហាមឃាត់ការអនុវត្តមួយរយៈនៃឯកសិទ្ធិ ឬ សិទ្ធិលើការបញ្ចាំដែលទាក់ទងនឹងសិទ្ធិលើបំណុលនោះ។
- បើម្ចាស់បំណុលមិនបានបង្ហាញខ្លួន ដើម្បីទទួលចំណែកនៅពេលចែកចំណែក

115 . មាត្រា ៣៩៣ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

# ជំពូកទី ៣
# បញ្ហាប្រឈម និងដំណោះស្រាយ
# នៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ

# ជំពូកទី ៣

# បញ្ហាប្រឈម និងដំណោះស្រាយនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ

## ៣.១ បញ្ហាប្រឈម

រហូតមកដល់បច្ចុប្បន្ននេះ ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុនៅតែបន្តមានបញ្ហាជាច្រើនកើតឡើងជារឿយៗ។ បញ្ហាប្រឈម ក្នុងន័យនេះគឺសំដៅដល់ឧបសគ្គដែលរារាំង ឬ ធ្វើឱ្យអាក់ខានដល់ការអនុវត្តដោយបង្ខំដែលកើតមានឡើងក្នុងនីតិវិធីអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ដែលមិនអាចឱ្យការអនុវត្តអាចធ្វើទៅបាន ឬ ធ្វើទៅដោយមិនរលូនជាដើម។

### ៣.១.១ បញ្ហាទាក់ទងនឹងនីតិវិធីច្បាប់

#### ៣.១.១.១ ភាពខ្វះចន្លោះ និងភាពស្មុគស្មាញនៃនីតិវិធីច្បាប់

ភាពខ្វះចន្លោះ និងភាពស្មុគស្មាញ គឺយើងចង់សំដៅទៅលើបញ្ញត្តិនៃនីតិវិធីអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ដែលខ្លឹមសារហាក់មានភាពពិបាកយល់ លំហូរនីតិវិធីវែងឆ្ងាយ ពិបាកអនុវត្ត នៅមានចន្លោះខ្វះខាត និងប្រកបទៅដោយឧបសគ្គ។

ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ ជាបញ្ញត្តិគោលដើម្បីធ្វើការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ហើយនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ គឺជាផ្នែកមួយនៃនីតិវិធីអនុវត្តដោយបង្ខំ។ បញ្ញត្តិទូទៅនៃការអនុវត្តដោយបង្ខំគឺត្រូវបានចែងក្នុងគន្ថីទី៦ ហើយផ្នែកនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ស្ថិតក្នុងផ្នែកទី២ នៃជំពូកទី២។ ក្រៅពីបញ្ញត្តិនៃក្នុងគន្ថីទី៦ បញ្ញត្តិផ្សេងទៀត ក៏ត្រូវបានប្រើប្រាស់ផងដែរ មានដូចជាគន្ថីនៃបញ្ញត្តិទូទៅ គន្ថីទី២ គន្ថីទី៣ និងគន្ថីទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីនេះ។ ក្រៅពីនេះ មានលិខិតបទដ្ឋានគតិយុត្តជាច្រើនទៀត ដែលត្រូវប្រើប្រាស់ក្នុងនីតិវិធីអនុវត្តដោយបង្ខំចំពោះចលនវត្ថុ។

ដើម្បីអាចអនុវត្តនីតិវិធីបង្ខំចំពោះចលនវត្ថុបាន គឺត្រូវឆ្លងកាត់នីតិវិធីជាច្រើនជំហានដូចជា ការដាក់ពាក្យសុំការរឹបអូស ការលក់ និងការបែងចែកចំណែកផងដែរ។ ក្នុងជំហាននៃនីតិវិធីនីមួយៗ គឺបង្គាប់នូវលក្ខខណ្ឌតម្រូវ និងបែបបទជាច្រើនដែលត្រូវបំពេញ តាំងតែពីចាប់ផ្ដើមរហូតដល់បញ្ចប់ ដោយតម្រូវឱ្យអ្នកអនុវត្ត មានចំណេះដឹងជាក់លាក់ ពោលគឺមានភាពស្មុគស្មាញខ្លាំងដើម្បីធ្វើវាឱ្យបានល្អ។ ក្នុងករណីដែលការដាក់លក់មិនមានអ្នកទិញ អាជ្ញាសាលាចាំបាច់ប្រកាសដាក់លក់ចលនវត្ថុនោះសារជាថ្មី ជាច្រើនដងរហូតទាល់តែលក់ដាច់ មានន័យថា អាជ្ញាសាលាចាំបាច់ដើរនីតិវិធីដដែលៗជាច្រើនដង។

#### ៣.១.១.២ កង្វះការយល់ដឹងរបស់ប្រជាពលរដ្ឋ

ច្បាប់ គឺជាបន្ទាត់សង្គមដែលពុំអាចល្មើសបាន កាលណាប្រជាជនក្នុងប្រទេសមួយ ឬ រដ្ឋមួយមានចំណេះដឹង ឬ ការយល់ដឹងផ្នែកច្បាប់បានច្រើន ការអនុវត្តច្បាប់នៅក្នុងប្រទេស ឬ រដ្ឋនោះនឹងមានភាពល្អប្រសើរ។

បច្ចុប្បន្ននេះយើងឃើញថាប្រជាពលរដ្ឋមានការយល់ដឹងផ្នែកច្បាប់នៅកម្រិតទាប ឬ តិចតួចបំផុត ព្រោះថាក្រៅពីការប្រកបការងារចិញ្ចឹមជីវិតប្រចាំថ្ងៃ មានភាគរយតិចណាស់ ដែលប្រជាពលរដ្ឋចំណាយពេលសិក្សាស្វែងយល់ ឬ ស្រាវជ្រាវអំពីច្បាប់ ជាពិសេសពាក់ព័ន្ធទៅនឹងនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុនេះតែម្តង គឺពួកគាត់ស្ទើរតែពុំដែលធ្លាប់បានឮ និងពុំបានដឹងថាតើនីតិវិធីអនុវត្តដោយបង្ខំចំពោះចលនវត្ថុមានគោលបំណងអ្វី និងដំណើរការការអនុវត្តបែបណានោះទេ  ដែលជាហេតុនាំឱ្យនីតិវិធីមួយនេះកាន់តែពិបាកក្នុងការអនុវត្តសម្រាប់មន្ត្រីអនុវត្ត។ ដោយប្រជាពលរដ្ឋយល់ថាការអនុវត្តប្រភេទនេះ គឺជាការប្រើអំណាចដោយរំលោភបំពាន ឬ ដោយខុសច្បាប់ពីសំណាក់ស្ថាប័នរដ្ឋ ហើយនឹងនាំឱ្យមានការរារាំងមិនឱ្យការអនុវត្តរបស់មន្ត្រីអនុវត្តដំណើរការទៅបានរលូននោះទេ។

### ៣.១.១.៣ ការផ្សព្វផ្សាយច្បាប់នៅមានកម្រិត

ការផ្សព្វផ្សាយច្បាប់ គឺជាការចូលរួមក្នុងការពង្រឹងនីតិរដ្ឋ។ សព្វថ្ងៃនេះ ការផ្សព្វផ្សាយច្បាប់មានបញ្ហាខ្វះចន្លោះច្រើន ដើម្បីបញ្ជ្រាបចំណេះដឹងផ្នែកច្បាប់ដល់ពលរដ្ឋ អ្នកសិក្សាស្រាវជ្រាវពីច្បាប់ រួមទាំងអ្នកប្រកបវិជ្ជាជីវៈច្បាប់ផងដែរ។ យើងនឹងបែងចែកកង្វះការផ្សព្វផ្សាយច្បាប់តាមរូបភាព បីយ៉ាង គឺការផ្សព្វផ្សាយច្បាប់តាមរយៈឯកសាររឹង (បណ្ណាល័យ ឬ តាំងទុកក្នុងអាគារ) ការផ្សព្វផ្សាយច្បាប់តាមរយៈការចុះបង្ហាត់បង្ហាញផ្ទាល់ និងការផ្សព្វផ្សាយច្បាប់តាមរយៈបណ្តាញសង្គម។

- **ការផ្សព្វផ្សាយច្បាប់តាមរយៈឯកសាររឹងតាមបណ្ណាល័យ**

បណ្ណាល័យ គឺជាមធ្យោបាយមួយក្នុងចំណោមមធ្យោបាយដទៃទៀតដើម្បីផ្សព្វផ្សាយនូវច្បាប់។ បច្ចុប្បន្ននេះ ឯកសារច្បាប់ទាក់ទងទៅនឹងនីតិវិធីអនុវត្តដោយបង្ខំ និងឯកសារបញ្ញត្តិទាក់ទងផ្សេងទៀត គឺពិបាកក្នុងការស្វែងរកយកមកសិក្សា ពោលនៅក្នុងបណ្ណាល័យខ្លះ យើងរកតែឯកសារច្បាប់សឹងតែពុំមានផង ដែលនេះជាចំណុចខ្វះខាតមួយនៃការផ្សព្វផ្សាយច្បាប់។

នៅតាមបណ្តាក្រសួងពាក់ព័ន្ធនឹងនីតិវិធីអនុវត្តដោយបង្ខំ ឬ ក្រសួងដែលបានផ្តួចផ្តើមធ្វើលិខិតគតិយុត្តទាក់ទងនឹងការអនុវត្តដោយបង្ខំពុំទាន់មានបណ្ណាល័យ ដើម្បីរក្សាទុកឯកសារទាំងនោះសម្រាប់ការស្រាវជ្រាវនៅឡើយទេ។ បើសិនជាចង់ស្វែងរកឯកសារដើម ឬ ឯកសារណាមួយនោះ គឺចាំបាច់ចំណាយពេលយូរដើររកសឹងតែគ្រប់ទីកន្លែង ពេលខ្លះពុំមានឃើញទៀតផងទាំងដែលឯកសារនោះបានកំពុងដាក់ឱ្យប្រើប្រាស់។

- **ការផ្សព្វផ្សាយច្បាប់តាមរយៈការបង្ហាត់បង្ហាញផ្ទាល់**

ការផ្សព្វផ្សាយច្បាប់តាមរយៈការចុះបង្ហាត់បង្ហាញផ្ទាល់នាពេលកន្លងមក ភាគច្រើនគឺផ្តោតទៅលើច្បាប់ព្រហ្មទណ្ឌ ឬ ទាក់ទងទៅនឹងកិច្ចសន្យាជាដើម។ ចំពោះនីតិវិធីអនុវត្តដោយបង្ខំចំពោះចលនវត្ថុវិញ គឺពុំសូវមានការចុះបង្ហាត់បង្ហាញនោះទេ។ ករណីខ្លះការបង្ហាត់បង្ហាញនីតិវិធីអនុវត្តដោយបង្ខំ ត្រូវបានបង្កើតឡើងតាមរយៈ

អ្នកវិជ្ជាជីវៈច្បាប់ដែលមានបទពិសោធន៍យូរឆ្នាំ ហើយការបង្ហាត់បង្ហាញត្រូវបានភ្ជាប់នូវបទពិសោធន៍របស់វាគ្មិនដែលធ្លាប់កើតឡើង តែដើម្បីអាចទទួលបាននូវការចែករំលែកនោះចាំបាច់ត្រូវបង់ប្រាក់។ ម៉្យាងទៀតការចែករំលែករបស់អ្នកមានបទពិសោធន៍ដែលធ្វើជាលក្ខណៈចង្អៀត ខ្លះត្រូវបានអនុញ្ញាតសម្រាប់តែអ្នកវិជ្ជាជីវៈ ខ្លះអនុញ្ញាតត្រឹមអ្នកសិក្សាស្រាវជ្រាវច្បាប់ទើបអាចចូលរួមបាន ចំណែកឯពលរដ្ឋទូទៅមិនបានសូវមានឱកាសឡើយ។

• **ការផ្សព្វផ្សាយច្បាប់តាមរយៈបណ្តាញសង្គម**

សព្វថ្ងៃនេះ ទោះបីជាមានបណ្តាញសង្គមច្រើនប្រភេទក៏ដោយ ក៏ប្រជាពលរដ្ឋជាច្រើនពុំទាន់បានទទួលនូវចំណេះដឹងផ្នែកច្បាប់បានទូលំទូលាយនៅឡើយទេ។ ការផ្សព្វផ្សាយច្បាប់នៅតាមបណ្តាញសង្គម គឺនៅមានភាពចង្អៀត និងពុំទាន់មានភាពសម្បូរបែបទេ។ ភាពចង្អៀតនៃការផ្សព្វផ្សាយច្បាប់ នៅត្រង់នេះគឺមានន័យថាការផ្សព្វផ្សាយច្បាប់ទៅដល់ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន នៅមានលក្ខណៈតូចចង្អៀតនៅឡើយ។

ប្រជាពលរដ្ឋមួយចំនួន ជាពិសេសមនុស្សវ័យចំណាស់ ដែលលោកមិនទាន់ចេះ ឬ ចេះតិចតួចបំផុតនូវការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យា ដើម្បីទទួលបានការផ្សព្វផ្សាយអំពីច្បាប់។ ម៉្យាងវិញទៀត ចំនួនអ្នកប្រើប្រាស់ប្រព័ន្ធបណ្តាញសង្គមនៅកម្ពុជាសព្វថ្ងៃនេះ ភាគច្រើនពុំទាន់ចេះវិធីសាស្ត្រនៃការស្រាវជ្រាវរកព័ត៌មានពាក់ព័ន្ធច្បាប់នៅក្នុងបណ្តាញសង្គមនៅឡើយទេ។

### ៣.១.១.៤ ការយល់ដឹងរបស់មន្ត្រីអនុវត្តនៅមានកម្រិត

មន្ត្រីអនុវត្ត យើងសំដៅទាំងតុលាការអនុវត្ត ក្រឡាបញ្ជី អាជ្ញាសាលា សារការី និងមន្ត្រីនៃស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត។ ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ អ្នកដែលមានតួនាទីចម្បង គឺអាជ្ញាសាលា ដែលមានតួនាទីធ្វើការរឹបអូសចលនវត្ថុ និងប្តូរជាប្រាក់ ដើម្បីជួយសម្រេចនូវសិទ្ធិទាមទាររបស់ម្ចាស់បំណុល។ បច្ចុប្បន្ននេះមន្ត្រីដែលពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំចំពោះចលនវត្ថុមួយចំនួន មានចំណេះដឹងពាក់ព័ន្ធទៅនឹងនីតិវិធីអនុវត្តដោយបង្ខំចំពោះចលនវត្ថុនៅមានកម្រិតនៅឡើយ។ តួយ៉ាងអាជ្ញាសាលា ដែលទទួលបន្ទុកលើការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ខ្វះខាតនូវការយល់ដឹងអំពីនីតិវិធីអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ជាកត្តាមួយក្នុងចំណោមកត្តាផ្សេងៗទៀត ដែលនាំឱ្យមានការរាំងស្ទះដល់ការអនុវត្ត ឬ ការអនុវត្តនីតិវិធីខុសពីបញ្ញត្តិច្បាប់។ ជាពិសេសអាជ្ញាសាលា ដែលទើបតែចូលបម្រើការងារ ពុំមានបទពិសោធន៍ច្រើន អាចនឹងមិនដឹងអំពីគន្លឹះ ដើម្បីដោះស្រាយនូវបញ្ហាកកស្ទះនៅចំណុចណាមួយ ឬ ហៅថាមិនចេះបត់បែនដើម្បីសម្រួលឱ្យការអនុវត្តបានជោគជ័យ។

ឧទាហរណ៍៖ អាជ្ញាសាលា ទទួលបន្ទុកលើការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ពុំមានភាពច្បាស់លាស់ពីចំណុចណាមួយដូចជា ពុំបានយល់ដឹងអំពីនីតិវិធីកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែកដោយមិនបានដើរនីតិវិធីនេះ នឹងនាំឱ្យមានការខាតប្រយោជន៍ ដល់ម្ចាស់បំណុលផ្សេងទៀតដែលច្បាប់ប្រគល់សិទ្ធិអោយ។

### ៣.១.២ កង្វះមន្ត្រីអនុវត្ត និងកង្វះការចូលរួមពីមន្ត្រីពាក់ព័ន្ធ

#### ៣.១.២.១ កង្វះមន្ត្រីអនុវត្ត

ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ គឺស្ថិតក្រោមសមត្ថកិច្ចរបស់អាជ្ញាសាលា។ តែយើងបានឃើញហើយថាក្រមនីតិវិធីរដ្ឋប្បវេណីបានកំណត់នូវភារកិច្ចមួយចំនួនដល់អាជ្ញាសាលា កិច្ចការខ្លះជាជំនួយ រីឯកិច្ចការខ្លះជាកាតព្វកិច្ចចាំបាច់ត្រូវបំពេញដូចជា ការស្រាវជ្រាវអំពីសិទ្ធិលើចលនវត្ថុដែលនឹងបន្តអត្ថិភាពក្រោយការលក់ជាទម្រង់ នៃភារកិច្ចជំនួយចំពោះតុលាការ ឯការលក់ចលនវត្ថុ គឺជាកាតព្វកិច្ចចាំបាច់មិនអាចខានបាន។

យ៉ាងណាមិញ មុននឹងក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា អនុម័ត និងប្រកាសឱ្យប្រើនៅឆ្នាំ ២០០៦ កម្ពុជានៅតែបន្តអនុវត្តច្បាប់ស្តីពីវិធីអនុវត្តក្រមរដ្ឋប្បវេណីដដែល តែត្រូវបានប្រគល់ភារកិច្ចអនុវត្តជូនព្រះរាជអាជ្ញា-ព្រះរាជអាជ្ញារង ជាអ្នកអនុវត្តជំនួសវិញដោយប្រកាសរបស់ក្រសួងយុត្តិធម៌។ ក្រោយពេលដែលក្រមនីតិវិធីរដ្ឋប្បវេណី ប្រកាសឱ្យប្រើ គេឃើញមានប្រើពាក្យអាជ្ញាសាលាច្រើននៅក្នុងនីតិវិធីអនុវត្ត។ តាមពិតទៅរហូតមកដល់បច្ចុប្បន្ននេះ ទាំងក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមនីតិវិធីព្រហ្មទណ្ឌ បានប្រគល់ភារកិច្ចមួយចំនួនដល់អាជ្ញាសាលាជាអ្នកអនុវត្តផ្ទាល់។ ទាក់ទងទៅនឹងបញ្ហាពុំមានមន្ត្រីអាជ្ញាសាលាអនុវត្តមុខងារដែលមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ក្រសួងយុត្តិធម៌បានចេញសេចក្តីប្រកាសលេខ ៣០ កយ.ប្រក/០៧ ស្តីពី មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៧ នៅក្នុងសេចក្តីប្រកាសនេះ មានគោលដៅកំណត់អ្នកទទួលបន្ទុកកិច្ចការអាជ្ញាសាលា មានដូចជាព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង មានន័យថាកិច្ចការអាជ្ញាសាលាដែលច្បាប់ប្រគល់ឱ្យត្រូវអនុវត្តដោយព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងជំនួសវិញ។

ក្រោយពីសិស្សអាជ្ញាសាលាជំនាន់ទី១ បានតាំងស៊ុបទើបមានប្រកាស ដែលប្រគល់កិច្ចការឱ្យអាជ្ញាសាលាអនុវត្តវិញ គឺសេចក្តីប្រកាសលេខ ០៦២ កយ.ប្រក/១៩ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩ ស្តីពីបែបបទសម្រាប់អនុវត្តការងាររបស់មន្ត្រីអាជ្ញាសាលា នៃក្រសួងយុត្តិធម៌។ តែយ៉ាងណាក៏ដោយ ប្រកាសនេះ គឺកំណត់តែចំពោះសាលាដំបូង ដែលមានអាជ្ញាសាលាស្ថិតនៅតែប៉ុណ្ណោះ បើមើលទៅសិស្សអាជ្ញាសាលា ដែលត្រូវបានតែងតាំងមានត្រឹមតែ ២៨ រូបដែលប្រចាំការនៅខេត្តចំនួន ៧ ប៉ុណ្ណោះ មានដូចជា៖ រាជធានីភ្នំពេញ កណ្តាល ព្រះសីហនុ ពោធិ៍សាត់ បាត់ដំបង សៀមរាប និងបន្ទាយមានជ័យ។ មានន័យថាសាលាដំបូងដទៃទៀតនៅតែព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារងជាអ្នកទទួលបន្ទុកក្នុងការអនុវត្តដដែល។ ដែលនេះជាបញ្ហាប្រឈមមួយ ដែលពិបាកក្នុងការអនុវត្តនីតិវិធីនៃការអនុវត្តដោយបង្ខំឱ្យបានឆាប់រហ័ស។

#### ៣.១.២.២ កង្វះការចូលរួមពីមន្ត្រីពាក់ព័ន្ធ

នៅក្នុងដំណើរការប្រព្រឹត្តទៅនៃនីតិវិធីអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ការសហការពីស្ថាប័នពាក់ព័ន្ធដូចជាអាជ្ញាធរដែនដីជាដើម គឺជាកត្តាដែលនាំឱ្យនីតិវិធីនៃការអនុវត្តទទួលបានលទ្ធផលឆាប់រហ័សគោរពតាមគោលការណ៍ស្តីពីយុត្តិធម៌ និងឆាប់រហ័ស។ កាលណាកិច្ចនីតិវិធី មានភាពយឺតយ៉ាវស្មើនឹងការផ្តល់ភាពអយុត្តិធម៌

បើកាលណាកិច្ចនីតិវិធីលឿន និងឆាប់រហ័ស យុត្តិធម៌ក៏ឆាប់ទទួលបាន ការខូចខាតប្រយោជន៍ដោយសារការចំណាយពេលក៏កាត់បន្ថយផងដែរ។

បច្ចុប្បន្ននេះ យើងឃើញថាមន្ត្រីពាក់ព័ន្ធមួយចំនួន មានភាពយឺតយ៉ាវក្នុងការបំពេញភារកិច្ចរបស់ខ្លួនដែលច្បាប់បានបញ្ញត្តិមក ឬ អាចនិយាយបានថាមិនសូវមានការចូលរួមសហការ នាំឱ្យពេលវេលានៃយុត្តិធម៌ចេះតែបន្លាយវែងទៅៗ តួយ៉ាងការចុះបញ្ជីផ្ទុកផ្តាក់ចំណាយពេលយូរ ការចុះស្រាវជ្រាវវាយតម្លៃរបស់អ្នកវាយតម្លៃមិនទាន់បានច្បាស់លាស់ល្អ។ ជាពិសេសនៅតាមមូលដ្ឋាន គេសង្កេតឃើញថាអាជ្ញាធរពុំសូវមានការចូលរួមសហការជាមួយនឹងអ្នកចុះទៅអនុវត្ត ដូចជាកងកម្លាំងតាមមូលដ្ឋានពុំបានសហការរៀបចំសណ្តាប់ធ្នាប់ដល់ការអនុវត្តច្បាប់របស់ស្ថាប័នអនុវត្តជាដើម។ កត្តាដែលមិនមានការចូលរួមសហការពីសំណាក់អាជ្ញាធរតាមមូលដ្ឋានដែលនឹងត្រូវចុះទៅរឹបអូសចលនវត្ថុនោះ នឹងធ្វើឱ្យការរឹបអូសចលនវត្ថុដោយស្ថាប័នអនុវត្ត ឬ អាជ្ញាសាលាមិនអាចធ្វើទៅបាននោះទេ។

### ៣.១.៣ ការលួចចាត់ចែងទ្រព្យរបស់កូនបំណុលនៃការអនុវត្តមុនពេលការរឹបអូស

កូនបំណុលនៃការអនុវត្តខ្លះមានចរិតខិលខូច បានលួចលក់ ផ្ទេរ ឬ ចាត់ចែងតាមបែបផ្សេងទៀតចំពោះចលនវត្ថុដែលនឹងត្រូវអាជ្ញាសាលារឹបអូស មានដូចជាលក់មុននឹងការរឹបអូស ឬ ផ្ទេរទៅឱ្យតតិយជនជាដើម។ ការលួចចាត់ចែងបែបនេះ ធ្វើឱ្យអាជ្ញាសាលាបាត់បង់នូវកម្មវត្ថុ ដែលត្រូវរឹបអូសយកមកលក់ ហើយត្រូវស្វែងរកសញ្ញាណចលនវត្ថុផ្សេងទៀត ដើម្បីធ្វើការរឹបអូសម្តងទៀត។ ករណីខ្លះទៀត កូនបំណុលនៃការអនុវត្តបានចាត់ចែង ឬ លក់នូវចលនវត្ថុ ដែលខ្លួនមានអស់តែម្តង ដែលពុំអាចរកអ្វីមករឹបអូសបានឡើយ ធ្វើឱ្យកិច្ចនីតិវិធីអនុវត្តដោយបង្ខំចំពោះចលនវត្ថុមិនអាចបន្តទៅមុខទៀតបាន។

ឧទាហរណ៍៖ នៅពេលដែល A បានដឹងជាមុនថានឹងមានការរឹបអូសនូវទ្រព្យរបស់ខ្លួនដោយអាជ្ញាសាលា ហើយ A នោះមានចរិតខិលខូច ឬ មានគំនិតទុច្ចរិត បានផ្ទេរនូវទ្រព្យទាំងអស់របស់ខ្លួនទៅបងប្អូន ឬ សាច់ញាតិណាម្នាក់ ដែលជាហេតុធ្វើឱ្យអាជ្ញាសាលាពុំអាចស្វែងរកចលនវត្ថុរបស់ A ដើម្បីរឹបអូសបាន និងនាំឱ្យការសម្រេចសិទ្ធិទាមទារ របស់ម្ចាស់បំណុលមានការយឺតយ៉ាវ ឬ មិនអាចដំណើការនីតិវិធីអនុវត្តដោយបង្ខំចំពោះចលនវត្ថុនោះបានតែម្តង។ ព្រោះថាអាជ្ញាសាលា មិនអាចធ្វើការរឹបអូសនូវចលនវត្ថុ ដែលកាន់កាប់ដោយបុគ្គលផ្សេងក្រៅពីកូនបំណុលនៃការអនុវត្តដោយផ្អែកទៅលើលិខិតអនុវត្ត ដែលកំណត់ឈ្មោះរបស់កូនបំណុលនៃការអនុវត្តនោះបានទេ។

### ៣.១.៤ វប្បធម៌អន្តរាគមន៍ពីអ្នកមានអំណាច

ដំណើរការនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ មានករណីខ្លះកូនបំណុលនៃការអនុវត្ត ដែលមានជាប់ខ្សែស្រឡាយជាមួយអ្នកមានឋានៈបុណ្យសក្តិធំក្នុងជួរមន្ត្រីរាជការ ឬ អ្នកមានមុខមាត់ក្នុងសង្គម បានសុំឱ្យមាន

ការអន្តរាគមន៍ពីអ្នកមានអំណាចទាំងនោះ នាំឱ្យដំណើរការនៃនីតិវិធីមានការរាំងស្ទះ។ គេសង្កេតឃើញជារឿយៗ កូនបំណុលនៃការអនុវត្តតែងតែមានការកាងពីអ្នកមានអំណាចមួយចំនួនតូច ដូចជាការយកកងកម្លាំងមករាំង ដល់ការអនុវត្តរបស់ស្ថាប័នអនុវត្ត។

ឧទាហរណ៍៖ កូនបំណុលនៃការអនុវត្ត គឺជាស្នងការរងខេត្ត បានប្រើកងកម្លាំងប្រដាប់អាវុធ ដែលនៅក្រោម បង្គាប់របស់ខ្លួន មកធ្វើការរារាំង មិនឱ្យមន្ត្រីអនុវត្ត ធ្វើការអនុវត្តបានឡើយ។

## ៣.២ ដំណោះស្រាយ

### ៣.២.១ ដំណោះស្រាយបញ្ហាទាក់ទងនឹងនីតិវិធីច្បាប់

#### ៣.២.១.១ ការពិនិត្យ និងកែតម្រូវនូវចំណុចខ្វះខាត ឬ ចំណុចស្មុគស្មាញនៃច្បាប់

ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធទៅនឹងការតាក់តែងច្បាប់ ជាពិសេសក្រសួងយុត្តិធម៌ គួរតែរៀបចំកែលម្អ ទៅលើចំណុចមួយចំនួន ដែលមានភាពមិនច្បាស់លាស់របស់ច្បាប់ ដែលហាក់មានភាពពិបាកយល់ និងពិបាក ក្នុងការអនុវត្ត។ កាលណាច្បាប់មានភាពងាយស្រួលយល់មិនមានភាពស្មុគស្មាញក្នុងការអនុវត្តនោះ ការអនុវត្ត នឹងប្រព្រឹត្តទៅដោយឆាប់រហ័ស។

#### ៣.២.១.២ ការបង្កើនការយល់ដឹងផ្នែកច្បាប់ដល់ប្រជាពលរដ្ឋ

ការបង្កើនការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីច្បាប់ ឬ ការអនុវត្តច្បាប់ គឺជាការចូលរួមពង្រឹងនីតិរដ្ឋ។ កាលណាប្រជាពលរដ្ឋមានចំណេះដឹងផ្នែកច្បាប់សមរម្យហើយ ការបំពានច្បាប់ ក៏មានការកាត់បន្ថយ ការអនុវត្ត ច្បាប់របស់ស្ថាប័នអនុវត្ត ក៏មានភាពងាយស្រួល និងឆាប់រហ័សផងដែរ។ ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធទៅនឹង ការផ្សព្វផ្សាយ ឬ ការអនុវត្តច្បាប់ គួរណាស់តែជម្រុញលើកទឹកចិត្តទៅដល់ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានមិនថា ប្រជាកសិករ អាជីវករ ឬ ពាណិជ្ជករ ឱ្យពួកគាត់មានការសិក្សាស្វែងយល់អំពីច្បាប់ឱ្យបានច្រើន ជាពិសេសបង្កើន ការផ្សព្វផ្សាយអំពីលំហូរនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុនេះ ដើម្បីងាយស្រួលដល់មន្ត្រីអនុវត្តក្នុងការ អនុវត្តច្បាប់។

#### ៣.២.១.៣ ការបង្កើនការផ្សព្វផ្សាយច្បាប់អោយបានទូលំទូលាយ

បច្ចុប្បន្ននេះ យើងឃើញហើយថា ការផ្សព្វផ្សាយច្បាប់ភាគច្រើន គឺមាននៅតាមបណ្តាសាកលវិទ្យាល័យ តែប៉ុណ្ណោះ ដែលមានតែនិស្សិតទេ ទើបអាចទទួលបានចំណេះដឹងផ្នែកច្បាប់បានច្រើន។ ការផ្សព្វផ្សាយច្បាប់ តាមបណ្តាញសង្គមអាចបញ្ជ្រាបចូលក្នុងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋបានច្រើន ព្រោះថាប្រជាពលរដ្ឋភាគ ច្រើន និយមប្រើប្រាស់បណ្តាញសង្គម សម្រាប់ប្រកបអាជីវកម្មអនឡាញ ឬដើម្បីការកម្សាន្តអារម្មណ៍។ ដូច្នេះហើយ ការផ្សព្វផ្សាយច្បាប់តាមរយៈប្រព័ន្ធបណ្តាញសង្គម គឺជាវិធីដ៏ល្អមួយ ដែលអាចផ្សព្វផ្សាយច្បាប់បានទូលំទូលាយ ហើយទទួលបានសមិទ្ធផលច្រើន។

ទោះបីជាមានការផ្សព្វផ្សាយច្បាប់តាមរយៈប្រព័ន្ធបណ្ដាញសង្គមក៏ដោយ ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធទៅនឹងការផ្សព្វផ្សាយ និងការអនុវត្តច្បាប់ គួរតែបន្ថែមការផ្សព្វផ្សាយតាមរយៈការចុះទៅបង្ហាត់បង្ហាញផ្ទាល់នៅតាមបណ្ដាស្រុក ភូមិ តាមបណ្ដាសហគមន៍ ឬ តាមតំបន់នានា ជាពិសេសតំបន់ដែលពិបាកក្នុងការទទួលបានព័ត៌មានតាមរយៈបណ្ដាញសង្គម។

**៣.២.១.៤ ពង្រឹងចំណេះដឹងដល់មន្ត្រីអនុវត្ត**

ដោយហេតុតែការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ មានការពិបាក ដូច្នេះហើយកត្តាចំណេះដឹងរបស់មន្ត្រីអនុវត្តត្រូវតែមានភាពច្បាស់លាស់ និងម៉ឺងម៉ាត់ក្នុងការអនុវត្ត ក៏ដូចជាការពង្រឹងបន្ថែមទៅលើចំណេះដឹងរបស់មន្ត្រីអនុវត្ត ក្រសួងយុត្តិធម៌ គួរតែមានការពិនិត្យទៅលើរបាយការណ៍ការងាររបស់មន្ត្រីអនុវត្តឱ្យបានទៀងទាត់ និងបង្កើតវគ្គបណ្ដុះបណ្ដាលខ្លីៗអំពីការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ដើម្បីពង្រឹងបន្ថែមពាក់ព័ន្ធនឹងនីតិវិធីអនុវត្តដោយបង្ខំចំពោះចលនវត្ថុដល់មន្ត្រីដែលទទួលបន្ទុកអនុវត្ត។ ជាពិសេសការចែករំលែកនូវបទពិសោធន៍ពីសំណាក់មន្ត្រីអនុវត្ត ដែលមានបទពិសោធន៍ច្រើនពាក់ព័ន្ធជាមួយនឹងនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុនេះ គឺជាការពង្រឹង និងផ្ដល់ចំណេះដឹងពាក់ព័ន្ធនឹងនីតិវិធីនេះ ដ៏មានប្រសិទ្ធិភាពបំផុត។

ឧទាហរណ៍៖ អាជ្ញាសាលា ដែលបានឆ្លងកាត់ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុច្រើន គួរតែចែករំលែកទៅអាជ្ញាសាលាដែលទើបតែចេញប្រកបការងារ។

**៣.២.២ បង្កើនសមាសភាពមន្ត្រីអនុវត្ត និងពង្រឹងកិច្ចសហការគ្នាជាមួយស្ថាប័នពាក់ព័ន្ធ**

**៣.២.២.១ បង្កើនសមាសភាពមន្ត្រីអនុវត្ត**

បច្ចុប្បន្នសមាសភាពមន្ត្រីអនុវត្ត (អាជ្ញាសាលា) គឺមានចំនួនតិចតួចនៅឡើយ បើធៀបទៅនឹងសំណុំរឿងអនុវត្តដោយបង្ខំចំពោះចលនវត្ថុនាពេលបច្ចុប្បន្ន។ យើងបានដឹងហើយថា នីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ គឺមានភាពស្មុគស្មាញ និងត្រូវការចំណាយពេលវេលាយូរ គិតចាប់តាំងពីពេល ដែលម្ចាស់បំណុលនៃការអនុវត្តបានដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ រហូតដល់នីតិវិធីនៃការចែកចំណែកដោយអាជ្ញាសាលា។ នៅពេលដែលសំណុំរឿងមានចំនួនច្រើន ហើយមន្ត្រីអនុវត្តមានចំនួនតិច ជាកត្តាដែលនាំឱ្យមានការកកស្ទះសំណុំរឿង ព្រោះថាការអនុវត្តនីតិវិធីអនុវត្តដោយបង្ខំត្រូវការចំណាយពេលយូរ និងមានការអូសបន្លាយនីតិវិធីមួយចំនួនផងដែរនោះ ការសម្រេចសិទ្ធិទាមទាររបស់ម្ចាស់បំណុលនៃការអនុវត្តនឹងមិនអាចប្រព្រឹត្តទៅបានឆាប់រហ័ស ដែលនាំឱ្យមានការខូចខាតប្រយោជន៍របស់ម្ចាស់បំណុលនៃការអនុវត្តផងដែរ។

**៣.២.២.២ ពង្រឹងកិច្ចសហការរវាងមន្ត្រីអនុវត្ត និងស្ថាប័នពាក់ព័ន្ធ**

ទោះបីជាមានការបង្កើនសមាសភាពមន្ត្រីអនុវត្តហើយក៏ដោយ ការអនុវត្តដោយបង្ខំក៏នៅតែមិនអាចប្រព្រឹត្តទៅបាន ឬ អនុវត្តបាននោះទេ ប្រសិនបើមិនមានការចូលរួមសហការពីស្ថាប័នពាក់ព័ន្ធមួយចំនួន ក្នុងន័យនេះ យើងសំដៅដល់ទាំងអាជ្ញាធរភូមិ-ឃុំ ស្នងការខេត្ត កងរាជអាវុធហត្ថ ជាដើម ដែលជាជំនួយដល់ការអនុវត្តនីតិវិធី

ឱ្យបានរលូន។ កាលណាចុះស្រាវជ្រាវអំពីបច្ចុប្បន្នភាពនៃចលនវត្ថុ អ្នកស្រាវជ្រាវតែងតែចង់ដឹងអំពីព័ត៌មានបន្ថែមលើចលនវត្ថុ ដែលត្រូវរឹបអូស ជាពិសេសពីអាជ្ញាធរមូលដ្ឋាននៃទីកន្លែង ដែលចលនវត្ថុនោះស្ថិតនៅ។

ពាក់ព័ន្ធនឹងការចុះស្រាវជ្រាវ ក៏ដូចជាការរឹបអូសចលនវត្ថុ ករណីមួយចំនួន ដែលពិបាកក្នុងការធ្វើការ អ្នកអនុវត្តតែងតែស្នើកងកម្លាំងសាធារណៈ ដើម្បីការពារ ឬ ទប់ស្កាត់បាតុភូតអាក្រក់កើតឡើងជាយថាហេតុ (ការរារាំងពីសំណាក់អ្នកមានអំណាច)។ ដូច្នេះហើយកងកម្លាំងសាធារណៈ ត្រូវតែមានកិច្ចសហប្រតិបត្តិការប្រកបដោយស្មារតីសហការខ្ពស់ជាមួយអ្នកអនុវត្ត។ ដើម្បីពង្រឹងកិច្ចសហការរវាងមន្ត្រីអនុវត្តជាមួយនឹងអាជ្ញាធរមូលដ្ឋាន ក្រសួង ឬ ស្ថាប័ន គួរតែមានវិធានការតឹងរឹងចំពោះមន្ត្រីដែលមិនចូលរួមសហការ ជាមួយមន្ត្រីអនុវត្តដូចជាការដាក់ពិន័យ ឬ ការដាក់ទណ្ឌកម្មរដ្ឋបាល ជាដើម។

**៣.២.៣ ចាត់វិធានការតឹងរឹង ដើម្បីទប់ស្កាត់ការលួចចាត់ចែងទ្រព្យរបស់កូនបំណុលនៃការអនុវត្ត**

កូនបំណុលនៃការអនុវត្ត ដែលបានដឹងអំពីការរឹបអូសរបស់ស្ថាប័នអនុវត្ត ជាពិសេសកូនបំណុលដែលត្រូវបានតុលាការប្រកាសសាលក្រមឱ្យចាញ់ក្តី នៅក្នុងបណ្តឹងអង្គសេចក្តី និងនៅមុនពេលអាជ្ញាសាលាចាប់ផ្តើមនីតិវិធីអនុវត្តដោយបង្ខំ អាជ្ញាសាលាតែងតែធ្វើការជូនដំណឹងឱ្យអនុវត្តដោយស្ម័គ្រចិត្ត ដូច្នេះដើម្បីទប់ស្កាត់ការចាត់ចែងរបស់កូនបំណុលនៃការអនុវត្ត ម្ចាស់បំណុលដែលតុលាការបានប្រកាសសាលក្រមឱ្យឈ្នះក្តី ត្រូវដាក់ពាក្យសុំរក្សាការពារទៅលើទ្រព្យរបស់កូនបំណុល និងសូមកុំឱ្យតុលាការលុបចោលនូវដីការសម្រេចរក្សាការពារ ព្រោះថានៅពេលដែលតុលាការលុបចោលនូវដីកាសម្រេចរក្សាការពារលើទ្រព្យរបស់កូនបំណុល កូនបំណុលមានឱកាសច្រើនដើម្បីធ្វើការចាត់ចែងនូវទ្រព្យរបស់ខ្លួន។ ជាពិសេសអាជ្ញាសាលា គួរតែមានវិធានការតឹងរឹងដល់កូនបំណុលនៃការអនុវត្ត និងអ្នកដែលទទួលផលពីការលួចចាត់ចែងនោះ ដូចជាការពិន័យជាប្រាក់ជាដើម។

**៣.២.៤ លុបបំបាត់វប្បធម៌អន្តរាគមន៍របស់អ្នកមានអំណាច**

វប្បធម៌អន្តរាគមន៍ គួរតែបញ្ចប់ ការអន្តរាគមន៍ពីអ្នកមានអំណាច បុណ្យស័ក្តិ រារាំងដល់ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ គឺជាអំពើដែលធ្វើឱ្យរាំងស្ទះដល់ការអនុវត្តច្បាប់ និងជាការចូលដៃដល់ជនបានប្រព្រឹត្តអំពើខុសច្បាប់។ កាលណាសង្គមមួយសម្បូរទៅដោយការអន្តរាគមន៍មិនត្រឹមត្រូវ គឺជាការជួយជ្រោមជ្រែងអំពើខុសច្បាប់មានន័យថាជួយឱ្យច្បាប់មិនត្រូវបានអនុវត្ត។

ដើម្បីទប់ស្កាត់ និងបញ្ឈប់វប្បធម៌អន្តរាគមន៍ ស្ថាប័ន ឬ អង្គភាពត្រូវតែមានវិធានការតឹងរឹង និងអនុវត្តឱ្យបានម៉ឺងម៉ាត់ចំពោះមន្ត្រីរបស់ខ្លួន ដែលបានប្រើប្រាស់អំណាចក្នុងមុខងារ ទៅកាងនូវអំពើប្រព្រឹត្តខុសច្បាប់។ ជាពិសេសស្ថាប័នអនុវត្ត ក៏ពុំត្រូវស្តាប់ ឬ ធ្វើតាមការបញ្ជារពីសំណាក់អ្នកមានអំណាច ដែលបានធ្វើការអន្តរាគមន៍ទៅលើការអនុវត្តការងាររបស់ខ្លួន។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីធ្វើការបកស្រាយលើប្រធានបទ “ **ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ** ” រួចមក យើងឃើញថាការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ គឺជានីតិវិធីដែលមានអំណាចបង្ខំពីសំណាក់រដ្ឋ ហើយមានស្ថាប័នអនុវត្តជាអ្នកតំណាង។ ក្នុងនីតិវិធីអនុវត្តដោយបង្ខំចំពោះចលនវត្ថុមានអាជ្ញាសាលា ជាអ្នកដើរតួជំនួសឱ្យរដ្ឋអំណាច។ នីតិវិធីអនុវត្តដោយបង្ខំ ត្រូវបានចែងក្នុងគន្ថីទី៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០០៦ ក្នុងគន្ថីនេះមាន ៤ជំពូក ហើយនីតិវិធីអនុវត្តដោយបង្ខំចំពោះចលនវត្ថុមានបញ្ញត្តិក្នុងផ្នែកទី២ ជំពូកទី២។ មួយវិញទៀត ដើម្បីអនុវត្តដោយបង្ខំចំពោះចលនវត្ថុបាន មិនត្រឹមតែប្រើប្រាស់បញ្ញត្តិក្នុងផ្នែកទី២ នៃជំពូកទី២ នេះនោះទេ គឺត្រូវការបញ្ញត្តិ និងលិខិតបទដ្ឋានគតិយុត្តដទៃទៀតដូចជា ចាប់ពីគន្ថីទី១ រហូតដល់គន្ថីទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ទោះបីជាមាត្រា៣៣៥ ពុំបានបញ្ញត្តិថាគន្ថីទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីត្រូវយកមកអនុវត្តក្តី ក៏បញ្ញត្តិនេះចាំបាច់ត្រូវយកមកប្រើដែរ ដោយហេតុថាវាជាបញ្ញត្តិទូទៅ ដែលត្រូវប្រើប្រាស់គ្រប់គន្ថីនៃក្រមនីតិវិធីរដ្ឋប្បវេណី។

ឆ្លងតាមការបកស្រាយខាងលើមកយើងឃើញថា ដើម្បីសម្រេចសិទ្ធិទាមទារជូនម្ចាស់បំណុលតាមរយៈការអនុវត្តដោយបង្ខំចំពោះចលនវត្ថុបាន ស្ថាប័នអនុវត្តត្រូវអនុវត្តច្រើនដំណាក់កាលដូចដែលបានរៀបរាប់នៅក្នុងជំពូកទី២ ដែលចាប់ផ្តើមពីការដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ដំណាក់កាលបន្ទាប់ ការរឹបអូសចលនវត្ថុដោយអាជ្ញាសាលា និងបន្ទាប់មកទៀតការរៀបចំការលក់ ឬ ការប្តូរជាប្រាក់នូវចលនវត្ថុដែលបានរឹបអូស និងចុងក្រោយការបែងចែកចំណែកទៅម្ចាស់បំណុលនៃការអនុវត្ត។ ដំណាក់កាលនីមួយៗ គឺទាមទារនូវលក្ខខណ្ឌជាច្រើនទើបស្ថាប័នអនុវត្តអាចដំណើការនីតិវិធីបាន ប្រសិនបើពុំបានបំពេញគ្រប់លក្ខខណ្ឌនៃដំណាក់កាលនីមួយៗនោះទេនឹងនាំឱ្យមានការរាំងស្ទះ និងយឺតយ៉ាវក្នុងការសម្រេចសិទ្ធិទាមទាររបស់ម្ចាស់បំណុលនៃការអនុវត្ត។

ផ្អែកតាមការបកស្រាយជាហូរមកឃើញថា ក្រៅពីលក្ខខណ្ឌតម្រូវតាមបញ្ញត្តិច្បាប់ ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុក៏ទាមទារឱ្យមានការចូលរួមពីស្ថាប័នពាក់ព័ន្ធជាច្រើនតួយ៉ាងអាជ្ញាធរដែនដី និងអ្នកវាយតម្លៃជាដើម។ ដោយហេតុនៃនីតិវិធីវែងឆ្ងាយ និងច្រើនដំណាក់កាល គឺបាននាំឱ្យកិច្ចនីតិវិធីមាន បញ្ហាប្រឈមកើតឡើងជារឿយៗក្នុងការអនុវត្តជាក់ស្តែង។ បញ្ហាប្រឈមយើងខ្ញុំបានលើកមកបង្ហាញមានដូចជា៖

- ❖ បញ្ហាទាក់ទងនឹងនីតិវិធីច្បាប់
- ❖ កង្វះការយល់ដឹងពីនីតិវិធីអនុវត្តដោយបង្ខំ
- ❖ កង្វះធនធានមនុស្ស
- ❖ ការចូលរួមអន្តរាគមន៍ពីអ្នកមានអំណាច

❖ ផលវិបាកក្នុងនិតិវិធី

យ៉ាងណាមិញ យើងខ្ញុំក៏បានធ្វើការលើកឡើងនូវដំណោះស្រាយមួយចំនួន ដែលបានអនុវត្តរួចមកហើយ ឬ កំពុងអនុវត្ត និងគួរតែអនុវត្តនៅថ្ងៃអនាគត មានដូចជាទាក់ទងទៅនឹង៖

❖ ដំណោះស្រាយបញ្ហាទាក់ទងនិងនីតិវិធីច្បាប់

❖ បង្កើនចំនួនអ្នកអនុវត្ត

❖ ពង្រឹងចំណេះដឹងរបស់មន្ត្រីអនុវត្ត

❖ បង្កើនការសហការណ៍ពីពីស្ថាប័នពាក់ព័ន្ធ និងប្រជាពលរដ្ឋ

❖ បង្កើននូវការផ្សព្វផ្សាយច្បាប់តាមគ្រប់មធ្យោបាយ

❖ លុបបំបាត់វប្បធម៌អន្តរាគមន៍ពីអ្នកមានអំណាចក្នុងសង្គម

ដំណោះស្រាយនៃបញ្ហាប្រឈម ដែលបានរៀបរាប់ខាងលើនេះ គឺជាការចាំបាច់ក្នុងការកែតម្រូវ និងពង្រឹងឱ្យបានម៉ឺងម៉ាត់សម្រាប់ការអនុវត្តនីតិវិធីមួយនេះឱ្យកាន់តែប្រសើរឡើង និងឆាប់រហ័ស មិនថាក្នុងពេលបច្ចុប្បន្ន ឬ នាពេលអនាគត។

# អនុសាសន៍

# អនុសាសន៍

ឆ្លងកាត់តាមការសិក្សាស្រាវជ្រាវអំពីប្រធានបទ “ **ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ** ” ឃើញថាការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ មានការកើនឡើងច្រើននៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន។ ថ្វីដ្បិតតែនៅក្នុងជំពូកទី៣ យើងខ្ញុំបានរៀបរាប់អំពីបញ្ហាប្រឈម និងដំណោះស្រាយហើយក្តី ក៏នីតិវិធីមួយនេះនៅតែមានផ្តល់នូវគុណសម្បត្តិ និងគុណវិបត្តិផ្សេងៗផងដែរ។ ដូច្នេះហើយយើងខ្ញុំទាំងពីរ សូមមានជាមតិសំណូមពរមួយចំនួនដើម្បីជាការបន្ថែមទៅលើការដោះស្រាយរាល់បញ្ហាប្រឈមដែលកើតមានឡើង និងដើម្បីការពារផលប្រយោជន៍ដល់ភាគីទាំងសងខាងនៅក្នុងសំណុំរឿងអនុវត្តដោយបង្ខំដូចតទៅៈ

- សំណូមពរដល់ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធទៅនឹងការតាក់តែងច្បាប់ ជាពិសេសក្រសួងយុត្តិធម៌ឱ្យធ្វើការកែតម្រូវនូវចំណុចស្មុគស្មាញនៃច្បាប់ ដែលពាក់ព័ន្ធទៅនឹងនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ និងបំពេញបន្ថែមនូវចំណុចខ្វះខាតមួយចំនួន ដែលនាំឱ្យការអនុវត្តរបស់ស្ថាប័នអនុវត្តមានភាពរាំងស្ទះ ឬមានការយឺតយ៉ាវ។
- ពន្លឿន និងពង្រឹងយន្តការស្ថាប័នអនុវត្តឱ្យបានកាន់តែល្អប្រសើរ ដើម្បីអាចអនុវត្តឱ្យបានប្រសើរនូវនីតិវិធីអនុវត្តដោយបង្ខំចំពោះចលនវត្ថុនេះចាំបាច់មានការយល់ដឹងឱ្យបានស៊ីជម្រៅអំពីនីតិវិធី មានការសហការណ៍ពីស្ថាប័នពាក់ព័ន្ធ ពន្លឿននីតិវិធីដូចជានីតិវិធីបញ្ជូន នីតិវិធីចុះបញ្ជីជាដើម។ ក្រៅពីនេះ គួរណាស់តែមានការធានានូវនីតិវិធីលក់-ទិញឱ្យកាន់តែល្អ ពោលធានានូវការទិញរបស់អ្នកដាក់ពាក្យស្នើសុំ ហើយពន្យល់អំពីការទុកចិត្តបានចំពោះការលក់-ទិញដល់ប្រជាពលរដ្ឋដើម្បីបង្កើនជំនឿលើការស្នើសុំទិញ។
- ការប្រើប្រាស់យន្តការស្ម័គ្រចិត្ត គឺជាវិធីនាំមកនូវគុណប្រយោជន៍ដល់ភាគីទាំងសងខាង ជាពិសេសចំណេញទាំងពេលវេលា និងការចំណាយសម្រាប់នីតិវិធីមានចំនួនតិច។ ប្រសិនបើកូនបំណុលពុំមានលទ្ធភាពពេញលេញក្នុងការសងទៅម្ចាស់បំណុលទេ កូនបំណុលគួរតែមានការស្នើសុំជាមធ្យោបាយផ្សេងៗដើម្បីសងដូចជាការ សងមួយផ្នែកម្តងៗ ឬ ពន្យារពេលមួយរយៈជាដើម។
- បង្កើនការផ្សព្វផ្សាយច្បាប់ ជាពិសេសនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុដល់ប្រជាពលរដ្ឋព្រោះថាការដែលមានការរារាំងពីសំណាក់ប្រជាពលរដ្ឋ គឺជាការរាំងស្ទះចំពោះការអនុវត្ត ដែលធ្វើឱ្យការអនុវត្តមិនអាចប្រព្រឹត្តទៅបានឆាប់រហ័ស និងមានភាពអយុត្តិធម៌ដល់ម្ចាស់បំណុលស្របច្បាប់ ដែលត្រូវទទួលបានចំណែក។ ដូច្នេះហើយស្ថាប័នដែលមានសមត្ថកិច្ច រួមទាំងអ្នកមានចំណេះដឹង និងបទពិសោធន៍ផ្នែកច្បាប់ គួរណាស់តែ ចែករំលែកនូវចំណេះដឹង និងបទពិសោធន៍ផ្នែកច្បាប់ដល់ប្រជាពលរដ្ឋទូទៅ កុំឱ្យមានអំពើរារាំងទៅលើចំណាត់ការរបស់ស្ថាប័នអនុវត្តបន្តទៅទៀត។ ការផ្សព្វផ្សាយច្បាប់ គឺជាកត្តាសំខាន់ណាស់ ដើម្បីចូលរួមចំណែកក្នុងការកសាងនីតិរដ្ឋ។

# ឯកសារយោង

# ឯកសារយោង

## ១.ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។
- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧។
- ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១, ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦។
- សេចក្តីព្រាងច្បាប់លើកទី ៣ ស្តីពីអាជ្ញាសាលា ( កែសម្រួលដោយក្រុមប្រឹក្សាអ្នកច្បាប់ និងរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ) ឆ្នាំ២០១២។
- ប្រកាសស្តីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាលេខ ៣០.កយប្រក/០៧, ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៧ របស់ក្រសួងយុត្តិធម៌។
- ប្រកាសស្តីពីបែបបទសម្រាប់អនុវត្តការងាររបស់មន្ត្រីអាជ្ញាសាលា នៃក្រសួងយុត្តិធម៌លេខ ០៦២.កយប្រក/១៩, ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩។
- ប្រកាសស្តីពីការតាំងស៊ប់មន្ត្រីអាជ្ញាសាលាក្នុងក្របខណ្ឌលេខ ០៦៦.កយប្រក/១៨, ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៨ របស់ក្រសួងយុត្តិធម៌។
- សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមនីតិវិធីរដ្ឋប្បវេណី,រៀបចំដោយក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី របស់ក្រសួងយុត្តិធម៌ បោះពុម្ពនៅឆ្នាំ២០០៧។

## ២.សៀវភៅតែងនិពន្ធ

- វចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត។
- សន្ទានុក្រមពាក្យច្បាប់ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី របស់ទីស្តីការគណៈរដ្ឋមន្ត្រី បោះពុម្ពលើកទី១ ឆ្នាំ២០០៧។

# ឧបសម្ព័ន្ធ

# **បញ្ជីឧបសម្ព័ន្ធ**

**១. ឧបសម្ព័ន្ធគតិយុត្ត**

**ឧបសម្ព័ន្ធទី១ ៖** ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

**ឧបសម្ព័ន្ធទី២ ៖** ប្រកាសស្តីពីបែបបទសម្រាប់អនុវត្តការងាររបស់មន្ត្រីអាជ្ញាសាលា នៃក្រសួងយុត្តិធម៌ លេខ ០៦២.កយប្រក/១៩, ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩។

**ឧបសម្ព័ន្ធទី៣ ៖** ប្រកាសស្តីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាលេខ ៣០.កយប្រក/០៧, ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៧ របស់ក្រសួងយុត្តិធម៌។

**ឧបសម្ព័ន្ធទី៤ ៖** រូបមន្តអនុវត្ត

**២. ឧបសម្ព័ន្ធរូបភាព**

- **ឧបសម្ព័ន្ធទី១៖** ការអនុវត្តភារកិច្ចអាជ្ញាសាលាលក់ឡាយឡុងតាមតុលាការ
- **ឧបសម្ព័ន្ធទី២៖** ការអនុវត្តភារកិច្ចអាជ្ញាសាលាចុះរឹបអូសចលនវត្ថុ
- **ឧបសម្ព័ន្ធទី៣៖** ការអនុវត្តភារកិច្ចអាជ្ញាសាលាឱ្យប្រគល់ចលនវត្ថុ

# ក្រម

# នីតិវិធីរដ្ឋប្បវេណី

ព្រះរាជក្រម

នស/រកម/០៧០៦/០២១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ប្រកាសឱ្យប្រើ

ក្រមនីតិវិធីរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០០៦នាសម័យប្រជុំពេញអង្គលើកទី១នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

សាលាជម្រះក្ដីផ្សេងគ្នា អាចប្ដឹងទៅតុលាការដែលមានសមត្ថកិច្ចលើការទាមទារណាមួយក៏បានដែរ ដោយបញ្ចូលការទាមទារផ្សេងទៀតជាមួយគ្នា ។

**មាត្រា ១២.–** ការកំណត់តុលាការដែលមានសមត្ថកិច្ច

ក្នុងករណីដែលតុលាការមានសមត្ថកិច្ចមិនអាចអនុវត្តនូវសិទ្ធិជម្រះក្ដីបានដោយសារច្បាប់ ឬ ហេតុការណ៍ពិត ឬ ករណីដែលសមត្ថកិច្ចសាលាជម្រះក្ដីមិនអាចកំណត់បានដោយសារដែនសមត្ថកិច្ចនៃតុលាការមិនពិតប្រាកដ តុលាការកំពូលត្រូវកំណត់តុលាការដែលមានសមត្ថកិច្ច ដោយដីកាសម្រេច តាមពាក្យសុំ ។

**មាត្រា ១៣.–** ការព្រមព្រៀងក្នុងការកំណត់តុលាការដែលមានសមត្ថកិច្ច

១-ការព្រមព្រៀងដែលកំណត់តុលាការដែលមានសមត្ថកិច្ចជម្រះក្ដី នឹងមានអានុភាពលុះត្រាតែការព្រមព្រៀងនោះ ត្រូវបានធ្វើឡើងរវាងពាណិជ្ជករនិងពាណិជ្ជករ ឬ នីតិបុគ្គលនិងនីតិបុគ្គល ឬ ពាណិជ្ជករនិងនីតិបុគ្គល ចំពោះតែការជំនុំជម្រះក្ដីលើកទី ១ ។

២-ការព្រមព្រៀងដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ នឹងមានអានុភាពលុះត្រាតែការព្រមព្រៀងនោះ ត្រូវបានធ្វើឡើង ចំពោះបណ្ដឹងដែលផ្អែកលើទំនាក់ទំនងគតិយុត្តដែលបានកំណត់ ហើយត្រូវបានធ្វើឡើងជាលាយល័ក្ខណ៍អក្សរ ។

**មាត្រា ១៤.–** សមត្ថកិច្ចសាលាជម្រះក្ដីដែលបានកើតឡើងដោយគ្មានការតវ៉ាពីចុងចម្លើយ

នៅពេលដែលចុងចម្លើយបានធ្វើសេចក្ដីដោះសាអំពីអង្គសេចក្ដី នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ បានឆ្លើយទាញហេតុផលអំពីអង្គសេចក្ដីនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់រួចហើយ នៅតុលាការនៃការជំនុំជម្រះលើកទី ១ ដោយគ្មានការតវ៉ាអំពីកំហុសនៃសមត្ថកិច្ចសាលាជម្រះក្ដីនោះ តុលាការនេះត្រូវមានសមត្ថកិច្ចជម្រះក្ដី ។

**មាត្រា ១៥.–** ករណីលើកលែងនៃការអនុវត្តចំពោះសមត្ថកិច្ចផ្ដាច់មុខរបស់សាលាជម្រះក្ដី ដែលច្បាប់បានកំណត់

បញ្ញត្តិនៃមាត្រា ១៣ (ការព្រមព្រៀងក្នុងការកំណត់តុលាការដែលមានសមត្ថកិច្ច) និង មាត្រា ១៤ (សមត្ថកិច្ចសាលាជម្រះក្ដីដែលបានកើតឡើងដោយគ្មានការតវ៉ាពីចុងចម្លើយ) ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានបញ្ញត្តិនៃច្បាប់កំណត់

សមត្ថកិច្ចផ្តាច់មុខចំពោះបណ្តឹង ។

**មាត្រា ១៦.–** ការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ

តុលាការអាចពិនិត្យភស្តុតាងចំពោះបញ្ហាដែលទាក់ទងនឹងសមត្ថកិច្ចសាលាជម្រះក្តី ដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន ។

**មាត្រា ១៧.–** មូលដ្ឋាននៃពេលវេលាសម្រាប់កំណត់សមត្ថកិច្ចសាលាជម្រះក្តី

សមត្ថកិច្ចសាលាជម្រះក្តីត្រូវកំណត់តាមពេលដាក់ពាក្យបណ្តឹង ។

**មាត្រា ១៨.–** ការចាត់ចែងបណ្តឹងខុសសមត្ថកិច្ចសាលាជម្រះក្តី

១-ប្រសិនបើតុលាការយល់ឃើញថា បណ្តឹងទាំងមូល ឬ ផ្នែកណាមួយ មិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួនទេ តុលាការនេះត្រូវផ្ទេរបណ្តឹងនោះទៅតុលាការដែលមានសមត្ថកិច្ច តាមពាក្យសុំរបស់ភាគី ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។

២-ពាក្យសុំផ្ទេរបណ្តឹងត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ លើកលែងតែករណីដែលដាក់ពាក្យសុំនៅកាលបរិច្ឆេទ ។ នៅពេលធ្វើពាក្យសុំនេះ ត្រូវបញ្ជាក់ឱ្យច្បាស់លាស់អំពីមូលហេតុនៃពាក្យសុំនោះ ។

**មាត្រា ១៩.–** ការផ្ទេរដើម្បីជៀសវាងពីការយឺតយ៉ាវ ជាអាទិ៍

១-ទោះបីជាបណ្តឹងណាមួយស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួនក៏ដោយ ប្រសិនបើតុលាការនៃការជំនុំជម្រះលើកទី ១ យល់ឃើញថាចាំបាច់ដើម្បីជៀសវាងពីការយឺតយ៉ាវហួសហេតុនៃនីតិវិធី ឬ ដើម្បីធ្វើឱ្យមានសមធម៌រវាងគូភាគី ដោយពិចារណាអំពីលំនៅឋានរបស់ភាគីនិងសាក្សីដែលត្រូវសាកសួរ ទីតាំងនៃវត្ថុដែលនឹងត្រូវបានត្រួតពិនិត្យ និង កាលៈទេសៈផ្សេងៗ តុលាការនោះអាចផ្ទេរបណ្តឹងទាំងមូល ឬ ផ្នែកណាមួយ ទៅតុលាការផ្សេងទៀត ដែលមានសមត្ថកិច្ច តាមពាក្យសុំរបស់ភាគី ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន ។

២-ក្នុងករណីដែលមានពាក្យសុំ ដែលបានកំណត់ក្នុងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ តុលាការត្រូវសម្រេច ដោយសួរយោបល់របស់ភាគីម្ខាងទៀត ។ ក្នុងករណីដែលតុលាការសម្រេចនូវការផ្ទេរដែលបានកំណត់ក្នុងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន នោះតុលាការអាចសួរយោបល់គូភាគីបាន ។

៤-អ្នកតំណាងពិសេសត្រូវមានការប្រគល់សិទ្ធិដូចអាណាព្យាបាល ដើម្បីធ្វើសកម្មភាពបណ្ដឹង ។

**មាត្រា ៣៧.-** ការជូនដំណឹងអំពីការរលត់នៃសិទ្ធិតំណាងដែលច្បាប់បានកំណត់

១-ការរលត់នៃសិទ្ធិតំណាងដែលច្បាប់បានកំណត់ មិនត្រូវមានអានុភាព បើគ្មានការជូនដំណឹងអំពីការរលត់សិទ្ធិនោះ ពីសាមីខ្លួន ឬ អ្នកតំណាង ទៅភាគីម្ខាងទៀត ។

២-បុគ្គលដែលជូនដំណឹងអំពីការរលត់នៃសិទ្ធិតំណាងដែលច្បាប់បានកំណត់ ត្រូវរាយការណ៍ទៅតុលាការ អំពីការជូនដំណឹងអំពីការរលត់សិទ្ធិនោះ ជាលាយល័ក្ខណ៍អក្សរ ។

**មាត្រា ៣៨.-** ការអនុវត្តដូចគ្នាចំពោះអ្នកតំណាងនៃនីតិបុគ្គល

បញ្ញត្តិនៃក្រមនេះដែលទាក់ទងនឹងការតំណាងដែលច្បាប់បានកំណត់ និង អ្នកតំណាងដែលច្បាប់បានកំណត់ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកតំណាងនៃនីតិបុគ្គល ។

## ផ្នែកទី ២
## សហបណ្ដឹង

**មាត្រា ៣៩.-** ល័ក្ខខ័ណ្ឌទូទៅនៃសហបណ្ដឹង

បើមានមូលហេតុណាមួយរវាងបុគ្គលច្រើននាក់ដូចមានចែងខាងក្រោមនេះ បុគ្គលទាំងនោះអាចប្ដឹង ឬ អាចត្រូវគេប្ដឹង ក្នុងនាមជាអ្នកសហបណ្ដឹង :

ក-បើសិទ្ធិ ឬ កាតព្វកិច្ច ដែលជាកម្មវត្ថុនៃបណ្ដឹងនោះដូចគ្នា ។

ខ-បើសិទ្ធិ ឬ កាតព្វកិច្ច ដែលជាកម្មវត្ថុនៃបណ្ដឹងនោះ ផ្អែកលើមូលហេតុដូចគ្នាលើអង្គហេតុ និង អង្គច្បាប់ ។

គ-បើសិទ្ធិ ឬ កាតព្វកិច្ច ដែលជាកម្មវត្ថុនៃបណ្ដឹងនោះ មានប្រភេទដូចគ្នា ហើយផ្អែកលើមូលហេតុ ដែលមានប្រភេទដូចគ្នាលើអង្គហេតុ និង អង្គច្បាប់ ។

**មាត្រា ៤០.-** ឋានៈនៃអ្នកធ្វើសហបណ្ដឹង ក្នុងសហបណ្ដឹងធម្មតា

សកម្មភាពបណ្ដឹងដែលបុគ្គលម្នាក់ក្នុងចំណោមអ្នកធ្វើសហបណ្ដឹងបានធ្វើ សកម្មភាពបណ្ដឹងរបស់ភាគីម្ខាងទៀត ដែលបានធ្វើចំពោះបុគ្គលម្នាក់ក្នុងចំណោមអ្នកធ្វើសហបណ្ដឹង

៥-ចំពោះដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ ខាងលើនេះ អាចប្ដឹងជំទាស់បាន ។

**មាត្រា ៦៥.-** ការសម្រេចសេចក្ដីលើបន្ទុកនៃការបង់ប្រាក់ប្រដាប់ក្ដី

១-ក្នុងការសម្រេចសេចក្ដីដើម្បីបញ្ចប់រឿងក្ដី តុលាការត្រូវធ្វើការសម្រេចសេចក្ដីអំពីបន្ទុកនៃប្រាក់ប្រដាប់ក្ដីទាំងអស់ នៅថ្នាក់នៃការជម្រះក្ដីនោះ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។

២-ក្នុងករណីដែលតុលាការជាន់ខ្ពស់បានផ្លាស់ប្ដូរសេចក្ដីសម្រេចអង្គសេចក្ដី តុលាការត្រូវធ្វើការសម្រេចអំពីបន្ទុកនៃប្រាក់ប្រដាប់ក្ដីទាំងអស់ឡើងវិញ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តផងដែរ ចំពោះករណីដែលតុលាការដែលទទួលបណ្ដឹងដែលត្រូវបានបញ្ជូនត្រឡប់មកវិញ ឬ ត្រូវបានផ្ទេរ សម្រេចសេចក្ដីដើម្បីបញ្ចប់រឿងក្ដីនោះ ។

៣-ក្នុងករណីដែលរឿងក្ដីនោះបានចប់ដោយមិនធ្វើទៅតាមការសម្រេចសេចក្ដីទេនោះ តុលាការនៃការជំនុំជម្រះលើកទី ១ ត្រូវបង្គាប់ឱ្យទទួលបន្ទុកក្នុងការបង់ប្រាក់ប្រដាប់ក្ដីនោះ តាមពាក្យសុំ ដោយដីកាសម្រេច ។ ប៉ុន្ដែ ចំពោះបណ្ដឹងដែលបានផ្សះផ្សាគ្នាហើយនោះ ប្រាក់ប្រដាប់ក្ដីត្រូវបានបង់ទៅតាមការព្រមព្រៀងគ្នា ហើយប្រសិនបើគ្មានការព្រមព្រៀងគ្នាទេ ភាគីនីមួយៗត្រូវទទួលបន្ទុកក្នុងការបង់រៀងៗខ្លួន ។

**មាត្រា ៦៦.-** នីតិវិធីដើម្បីកំណត់ជាស្ថាពរនូវចំនួនប្រាក់ប្រដាប់ក្ដី

១-ចំនួនប្រាក់ប្រដាប់ក្ដីដែលត្រូវទទួលបន្ទុកបង់ ត្រូវកំណត់ដោយក្រឡាបញ្ជីរបស់តុលាការនៃការជំនុំជម្រះលើកទី ១ តាមពាក្យសុំ នៅក្រោយពេលដែលសេចក្ដីសម្រេចអំពីបន្ទុកនោះបានបង្កើតអានុភាពនៃការអនុវត្ត ។

២-ចំពោះករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើគូភាគីទាំងសងខាងទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្ដី ប្រាក់ដែលភាគីនីមួយៗត្រូវទទួលបន្ទុកបង់នោះ ត្រូវបានចាត់ទុកថា បានធ្វើការទូទាត់ជាមួយនឹងគ្នា ចំពោះចំនួនទឹកប្រាក់ដែលត្រូវគ្នារួចហើយ ។

៣-ការចាត់ចែងលើពាក្យសុំដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ នឹងមានអានុភាព បន្ទាប់ពីបានជូនដំណឹង តាមរបៀបដែលអាចចាត់ទុកថាសមរម្យ ។

៤-ការធ្វើបណ្ដឹងតវ៉ាចំពោះការចាត់ចែងដែលបានកំណត់ក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវធ្វើឡើងក្នុងអំឡុងពេល ១ (មួយ) សប្ដាហ៍ ក្រោយពីបានទទួលដំណឹងនោះ ។

ក្នុងករណីដែលតុលាការទទួលស្គាល់ថា បណ្តឹងតវ៉ានោះមានមូលហេតុត្រឹមត្រូវ តុលាការត្រូវកំណត់ចំនួននៃបន្ទុកប្រាក់ប្រដាប់ក្តី ដោយខ្លួនឯង ។

៥-អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ ខាងលើនេះ មិនអាចពន្យារបានឡើយ ។

## ផ្នែកទី ៣
## ប្រាតិភោគលើប្រាក់ប្រដាប់ក្តី

**មាត្រា ៦៧.-** ដីកាសម្រេចបង្គាប់ឱ្យដាក់ប្រាតិភោគ

១-ប្រសិនបើដើមចោទគ្មានលំនៅឋាន ទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មនៅព្រះរាជាណាចក្រកម្ពុជាទេ តុលាការត្រូវបង្គាប់ឱ្យដើមចោទដាក់ប្រាតិភោគលើប្រាក់ប្រដាប់ក្តី តាមពាក្យសុំរបស់ចុងចម្លើយ ដោយដីកាសម្រេច ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តផងដែរចំពោះករណីដែលប្រាតិភោគនោះមានការខ្វះខាត ។

២-ប្រសិនបើចុងចម្លើយបានធ្វើសេចក្តីដោះសានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ បានឆ្លើយទាញហេតុផលអំពីអង្គសេចក្តីនៃបណ្តឹងនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ក្រោយពីបានដឹងថា មានមូលហេតុដែលតម្រូវឱ្យដាក់ប្រាតិភោគ នោះចុងចម្លើយមិនអាចដាក់ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបានឡើយ ។

៣-ចុងចម្លើយដែលបានដាក់ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចបដិសេធមិនព្រមតទល់នឹងបណ្តឹងនេះរហូតដល់ពេលដែលដើមចោទដាក់ប្រាតិ-ភោគបាន ។

៤-តុលាការត្រូវកំណត់នូវចំនួននៃប្រាតិភោគ និង អំឡុងពេលដែលត្រូវដាក់ប្រាតិ-ភោគ នៅក្នុងដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

៥-ចំនួននៃប្រាតិភោគ ត្រូវកំណត់ដោយយកចំនួនសរុបនៃប្រាក់ប្រដាប់ក្តីដែលចុងចម្លើយត្រូវចំណាយនៅគ្រប់ថ្នាក់នៃការជំនុំជម្រះ ជាមូលដ្ឋាន ។

៦-ចំពោះដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

២-ភាគីដែលស្នើសុំឱ្យពិនិត្យភស្តុតាង គប្បីបំភ្លឺឱ្យច្បាស់លាស់អំពីអង្គហេតុដែលត្រូវបញ្ជាក់ និង ទំនាក់ទំនងរវាងអង្គហេតុនោះនិងភស្តុតាង ។

៣-ការស្នើសុំឱ្យពិនិត្យភស្តុតាង ក៏អាចធ្វើមុនកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ មុនកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់បានដែរ ។

៤-ការស្នើសុំឱ្យសាកសួរសាក្សី និង សាមីភាគី បើអាចធ្វើបាន ត្រូវធ្វើជាមួយគ្នាឱ្យស្រេចតែម្តង ។

**មាត្រា ១២៦.–** ការទទួលយកភស្តុតាង

តុលាការត្រូវពិនិត្យភស្តុតាងដែលភាគីបានស្នើសុំឱ្យពិនិត្យ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្ត ចំពោះភស្តុតាងដែលគ្មានទំនាក់ទំនងជាមួយនឹងអង្គហេតុដែលនឹងត្រូវបញ្ជាក់ និង ភស្តុតាងឯទៀតដែលតុលាការយល់ឃើញថាមិនចាំបាច់ឡើយ ។

**មាត្រា ១២៧.–** ការពិនិត្យភស្តុតាងដោយសម្ងហវិធី

១-តុលាការត្រូវធ្វើឱ្យការពិនិត្យភស្តុតាងអាចប្រព្រឹត្តទៅជាបន្ទាន់ នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ដំបូង បន្ទាប់ពីបានបញ្ចប់ការរៀបចំចំណុចវិវាទ និង ភស្តុតាងរួចហើយ ។

២-ការសាកសួរទៅលើសាក្សី ឬ សាមីភាគី បើអាចធ្វើបាន ត្រូវតែធ្វើដោយសម្ងហវិធី ។

៣-ឯកសារដែលបម្រុងនឹងប្រើនៅក្នុងការសាកសួរសាក្សី ជាអាទិ៍ ត្រូវដាក់ជូននៅក្នុងអំឡុងពេលដែលសមរម្យ មុនពេលចាប់ផ្តើមធ្វើការសាកសួរទៅលើសាក្សី ជាអាទិ៍ នោះលើកលែងតែឯកសារដែលនឹងប្រើជាភស្តុតាង ដើម្បីប្រជែងលើភាពជំនឿនៃសេចក្តីថ្លែង-ការណ៍របស់សាក្សី ជាអាទិ៍ ។

**មាត្រា ១២៨.–** សិទ្ធិចូលរួមរបស់ភាគី

១-តុលាការត្រូវធានានូវឱកាសឱ្យមានវត្តមានរបស់ភាគី ដើម្បីចូលរួមក្នុងការពិនិត្យភស្តុតាង ។

២-ការពិនិត្យភស្តុតាង អាចធ្វើទៅបាន ទោះជាក្នុងករណីដែលភាគីមិនបានចូលខ្លួនតាមកាលបរិច្ឆេទក៏ដោយ ។

**មាត្រា ១៩០.–** ការបញ្ជូនលិខិតសាលក្រម

១-លិខិតសាលក្រមត្រូវបញ្ជូនទៅឱ្យគូភាគី ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ដោយគិតចាប់ពីថ្ងៃដែលបានប្រកាសសាលក្រមនោះ ។

២-ការបញ្ជូនដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបានធ្វើឡើងដោយអនុសារសាលក្រម ។

## ផ្នែកទី ៤
## អានុភាពនៃសាលក្រម

**មាត្រា ១៩១.–** អត្តពន្ធភាពនៃសាលក្រម

លើកលែងតែក្នុងករណីដែលបានកំណត់ក្នុងមាត្រា ១៩២ (ដីកាសម្រេចកែតម្រូវ) នៃក្រមនេះ តុលាការដែលបានចេញសាលក្រម មិនអាចលុប ឬ កែប្រែសាលក្រមនោះបានទេ ។

**មាត្រា ១៩២.–** ដីកាសម្រេចកែតម្រូវ

១-ក្នុងករណីដែលសាលក្រមមានការគណនាលេខខុស ឬ កត់ខុស ឬ កំហុសជាក់ស្តែងផ្សេងទៀតដែលមានប្រភេទប្រហាក់ប្រហែលគ្នា តុលាការអាចចេញដីកាសម្រេចកែតម្រូវសាលក្រម តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន ។

២-ចំពោះដីកាសម្រេចកែតម្រូវសាលក្រម អាចប្តឹងជំទាស់បាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានបណ្តឹងឧទ្ធរណ៍ស្របច្បាប់ចំពោះសាលក្រមនោះ ។

៣-ដីកាសម្រេចកែតម្រូវត្រូវសរសេរបន្ថែមនៅលើច្បាប់ដើមនៃមូលសាលក្រម និង អនុសារសាលក្រម ។ ប៉ុន្តែ ប្រសិនបើយល់ឃើញថាសមរម្យ តុលាការអាចធ្វើដីកាសម្រេចនេះជាលិខិត ជំនួសការសរសេរបន្ថែមនៅលើច្បាប់ដើមនៃមូលសាលក្រម និង អនុសារសាលក្រម ហើយបញ្ជូនឯកសារចម្លងយថាភូតនៃដីកាសម្រេចនេះ ទៅឱ្យគូភាគីបាន ។

**មាត្រា ១៩៣.–** ពេលដែលសាលក្រមចូលជាស្ថាពរ

១-សាលក្រមមិនអាចចូលជាស្ថាពរ នៅមុនពេលផុតអំឡុងពេលដែលបានកំណត់

ដីកាដែលផ្លាស់ប្តូរសាលក្រមសម្រេចអង្គសេចក្តីនៅពេលក្រោយ ។

**មាត្រា ១៩៨.–** វិសាលភាពបុគ្គលដែលត្រូវទទួលអានុភាពរបស់សាលក្រមស្ថាពរ

សាលក្រមស្ថាពរមានអានុភាពចំពោះបុគ្គលដែលបានកំណត់ដូចខាងក្រោមនេះ :

ក-ភាគី ។

ខ-តតិយជន ក្នុងករណីដែលភាគីធ្វើជាដើមចោទ ឬ ចុងចម្លើយនៃបណ្តឹងជំនួសតតិយជននោះ ។

គ-បុគ្គលដែលទទួលបន្តនូវសិទ្ធិ ឬ កាតព្វកិច្ច ពីអ្នកដែលបានកំណត់ក្នុងចំណុចទាំងពីរខាងលើនេះ ក្រោយពីបណ្តឹងត្រូវបានចាត់ការ ។

ឃ-បុគ្គលដែលកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃការទាមទារ សម្រាប់ផលប្រយោជន៍របស់បុគ្គលដែលបានកំណត់ក្នុងចំណុចទាំងបីខាងលើនេះ ។

**មាត្រា ១៩៩.–** អានុភាពនៃសាលក្រមស្ថាពររបស់តុលាការបរទេស

សាលក្រមស្ថាពររបស់តុលាការបរទេស ត្រូវមានអានុភាព លុះត្រាតែបានបំពេញល័ក្ខខ័ណ្ឌទាំងអស់ ដូចខាងក្រោមនេះ :

ក-បើសិទ្ធិជម្រះក្តីរបស់តុលាការបរទេសត្រូវបានទទួលស្គាល់ ដោយច្បាប់ ឬ សន្ធិសញ្ញា ឬ អនុសញ្ញា ដែលព្រះរាជាណាចក្រកម្ពុជាជាភាគី ។

ខ-បើចុងចម្លើយដែលចាញ់ក្តី បានទទួលការបញ្ជូនដីកាកោះហៅ ឬ ដីកាបង្គាប់ដែលចាំបាច់ដើម្បីចាប់ផ្តើមនីតិវិធី ឬ មិនបានទទួលទេ តែបានឆ្លើយដោះសាតបចំពោះបណ្តឹងនោះ ។

គ-បើខ្លឹមសារនៃសាលក្រម និង នីតិវិធីនៃបណ្តឹងនោះ មិនប៉ះពាល់សណ្តាប់ធ្នាប់សាធារណៈ ឬ ទំនៀមទម្លាប់ល្អនៃព្រះរាជាណាចក្រកម្ពុជា ។

ឃ-បើមានការធានាទៅវិញទៅមករវាងព្រះរាជាណាចក្រកម្ពុជា និង បរទេស ។

## ផ្នែកទី ៥
## សាលក្រមកំបាំងមុខ

**មាត្រា ២០០.–** សាលក្រមកំបាំងមុខដើមចោទ

ករណីដែលភាគីទាំងសងខាងមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ពីរដងជាប់គ្នា ។

**មាត្រា ២២០.–** ការផ្សះផ្សាលើបណ្តឹង

១-ភាគីអាចធ្វើការផ្សះផ្សានៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការផ្សះផ្សាបាន ។

២-ការផ្សះផ្សាដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចធ្វើនៅក្រៅទីតាំងតុលាការក៏បានដែរ ប្រសិនបើតុលាការយល់ឃើញថាសមរម្យ ។

**មាត្រា ២២១.–** ការលះបង់ ឬ ការទទួលស្គាល់នូវការទាមទារ

ការលះបង់នូវការទាមទារ ឬ ការទទួលស្គាល់នូវការទាមទារ ត្រូវធ្វើឡើងនៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការផ្សះផ្សា ។

**មាត្រា ២២២.–** អានុភាពនៃកំណត់ហេតុស្តីពីការសះជា ជាអាទិ៍

ក្នុងករណីដែលមានការសះជា ការលះបង់នូវការទាមទារ ឬ ការទទួលស្គាល់នូវការទាមទារ ត្រូវបានកត់ត្រានៅក្នុងកំណត់ហេតុ កំណត់ត្រានេះ មានអានុភាពដូចគ្នានឹងសាលក្រមស្ថាពរ ។

## ជំពូកទី ៧
## បទប្បញ្ញត្តិពិសេសស្តីពីរឿងក្តីចំនួនទឹកប្រាក់តិច

**មាត្រា ២២៣.–** គោលបំណងនៃនីតិវិធី

នីតិវិធីនៃរឿងក្តីចំនួនទឹកប្រាក់តិច មានគោលបំណងដើម្បីដោះស្រាយវិវាទដ៏ឆាប់រហ័សតាមនីតិវិធីសង្ខេប ។

**មាត្រា ២៤៥.–** ការបំពេញនូវសកម្មភាពបណ្ដឹងនៅពេលក្រោយ

១-ក្នុងករណីដែលមិនអាចគោរពតាមអំឡុងពេលដែលបានកំណត់ក្នុងវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ មាត្រា ២៤៤ (ការពន្យារអំឡុងពេល) ខាងលើនេះ ដោយគ្មានកំហុសរបស់ភាគី ភាគីនោះអាចបំពេញនូវសកម្មភាពបណ្ដឹងដែលគួរតែបានធ្វើនៅក្នុងអំឡុងពេលនោះបាន ក្នុងអំឡុងពេលតែ ១ (មួយ) សប្ដាហ៍ ក្រោយពេលដែលមូលហេតុនោះរលត់ហើយ ។ ប៉ុន្ដែ ចំពោះភាគីដែលនៅបរទេសវិញ អំឡុងពេលនោះ មានចំនួន ២ (ពីរ) ខែ ។

២-អំឡុងពេលដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើ មិនអាចពន្យារបានឡើយ ។

## ផ្នែកទី ២
## ការបញ្ជូន

**មាត្រា ២៤៦.–** គោលការណ៍នៃការបញ្ជូនដោយឆន្ទានុសិទ្ធិ ជាអាទិ៍

១-ការបញ្ជូនត្រូវធ្វើដោយឆន្ទានុសិទ្ធិ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់ ។

២-កិច្ចការបញ្ជូនត្រូវធ្វើឡើងដោយក្រឡាបញ្ជី ។

៣-ការបញ្ជូនត្រូវបានប្រតិបត្តិដោយបុគ្គលិកប្រៃសណីយ៍ អាជ្ញាសាលា ឬ ក្រឡាបញ្ជី ។

**មាត្រា ២៤៧.–** គោលការណ៍នៃការបញ្ជូនដោយការប្រគល់

១-ការបញ្ជូនត្រូវធ្វើឡើង ដោយការប្រគល់នូវឯកសារដែលត្រូវបញ្ជូនទៅជនដែលត្រូវទទួលការបញ្ជូននោះ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់ ។

២-ឯកសារដែលត្រូវបញ្ជូន គឺជាឯកសារចម្លងទាំងអស់ដែលពាក់ព័ន្ធ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់ ។

៣-ក្នុងករណីដែលអ្នកទទួលការបញ្ជូនមិនចេះអក្សរ មន្ត្រីទទួលបន្ទុកការបញ្ជូនគប្បីពន្យល់នូវខ្លឹមសារនៃឯកសារនោះ នៅពេលប្រគល់ឯកសារ ។

**មាត្រា ២៤៨.–** ការបញ្ជូនទៅបុគ្គលអសមត្ថភាពក្នុងបណ្ដឹង ជាអាទិ៍

១-ការបញ្ជូនទៅបុគ្គលអសមត្ថភាពក្នុងបណ្ដឹង ត្រូវធ្វើទៅចំពោះអ្នកតំណាងដែលច្បាប់បានកំណត់ ។

**មាត្រា ៣០០.–** ការបដិសេធចោល ហើយវិនិច្ឆ័យដោយខ្លួនឯង

តុលាការនៃបណ្តឹងសាទុក្ខត្រូវធ្វើការសម្រេចសេចក្តីអំពីរឿងក្តីផ្ទាល់ដោយខ្លួនឯង ចំពោះករណីដូចខាងក្រោមនេះ :

ក-តុលាការនៃបណ្តឹងសាទុក្ខបដិសេធចោលនូវសាលដីកាដើម ឬ សាលក្រមដើម ដោយយកមូលហេតុថា តុលាការនៃការជំនុំជម្រះដើមមានកំហុសក្នុងការអនុវត្តរដ្ឋ-ធម្មនុញ្ញ ឬ ច្បាប់ ឬ បទដ្ឋានគតិយុត្ត ចំពោះអង្គហេតុ ដែលបានចូលជាស្ថាពរ ហើយតុលា-ការនៃបណ្តឹងសាទុក្ខអាចសម្រេចសេចក្តីអំពីរឿងក្តីនោះ ដោយផ្អែកលើអង្គហេតុនេះបាន ។

ខ-តុលាការនៃបណ្តឹងសាទុក្ខបដិសេធចោលនូវសាលដីកាដើម ឬ សាលក្រមដើម ដោយយកមូលហេតុថា រឿងក្តីនោះមិនស្ថិតនៅក្រោមសិទ្ធិជម្រះក្តីរបស់តុលាការ ។

## ជំពូកទី ៤
## បណ្តឹងជំទាស់

**មាត្រា ៣០១.–** របៀបប្តឹងជំទាស់

១-ដើម្បីប្តឹងជំទាស់ ភាគីត្រូវដាក់ពាក្យបណ្តឹងជំទាស់ទៅតុលាការដើម ។ នៅក្នុងករណីនេះ តុលាការដើម ត្រូវធ្វើឱ្យបានឆាប់រហ័ស នូវពាក្យបណ្តឹងជំទាស់ និង សំណុំរឿងទៅតុលាការនៃបណ្តឹងជំទាស់ ។

២-ក្នុងករណីដែលពុំបានសរសេរច្បាស់លាស់អំពីមូលហេតុនៃការទាមទារឱ្យលុបចោល ឬ ផ្លាស់ប្តូរនូវដីកាសម្រេចដើម ក្នុងពាក្យបណ្តឹងជំទាស់ទេ ម្ចាស់បណ្តឹងជំទាស់គប្បីដាក់លិខិតជាលាយល័ក្ខណ៍អក្សរដែលសរសេរអំពីចំណុចនោះ ទៅតុលាការនៃបណ្តឹងជំ-ទាស់ នៅក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ គិតចាប់តាំងពីថ្ងៃដែលបានដាក់ពាក្យបណ្តឹងជំទាស់នោះ ។

**មាត្រា ៣០២.–** បណ្តឹងឧបាស្រ័យចំពោះដីកាសម្រេចរបស់ចៅក្រមដែលទទួលបញ្ជា ឬ ចៅក្រមដែលទទួលការប្រគល់សិទ្ធិ

១-ភាគីដែលមិនយល់ព្រមចំពោះដីកាសម្រេចរបស់ចៅក្រមដែលទទួលបញ្ជា ឬ ចៅក្រមដែលទទួលការប្រគល់សិទ្ធិ អាចដាក់ពាក្យសុំប្តឹងតវ៉ាទៅតុលាការទទួលបណ្តឹងបាន

តែក្នុងករណីដែលច្បាប់អនុញ្ញាតឱ្យប្តឹងជំទាស់ ប្រសិនបើដីកាសម្រេចនោះជាដីកាសម្រេចរបស់តុលាការទទួលបណ្តឹង ។ ប៉ុន្តែ ក្នុងករណីដែលតុលាការទទួលបណ្តឹងជាតុលាការកំពូល ឬ សាលាឧទ្ធរណ៍ ភាគីអាចដាក់ពាក្យសុំប្តឹងតវ៉ាបាន លុះត្រាតែច្បាប់អនុញ្ញាតឱ្យប្តឹងជំទាស់ ប្រសិនបើដីកាសម្រេចនោះជាដីកាសម្រេចរបស់សាលាដំបូង ។

២-ចំពោះដីកាសម្រេចលើពាក្យសុំនៃកថាខណ្ឌទី ១ ខាងលើនេះ អាចធ្វើបណ្តឹងជំទាស់បាន ។

**មាត្រា ៣០៣.–** អំឡុងពេលសម្រាប់ប្តឹងជំទាស់

១-បណ្តឹងជំទាស់ត្រូវធ្វើក្នុងអំឡុងពេល ១ (មួយ) សប្តាហ៍ ដោយគិតចាប់ពីថ្ងៃដែលបានទទួលដំណឹងអំពីដីកាសម្រេច ។

២-អំឡុងពេលនៃកថាខណ្ឌទី ១ ខាងលើនេះ មិនអាចពន្យារបានឡើយ ។

**មាត្រា ៣០៤.–** ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីបណ្តឹងឧទ្ធរណ៍ ឬ បណ្តឹងសាទុក្ខ

១-បញ្ញត្តិស្តីពីបណ្តឹងឧទ្ធរណ៍ និង នីតិវិធីនៃការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្តឹងជំទាស់លើដីកាសម្រេចរបស់សាលាដំបូង និង នីតិវិធីនៃតុលាការនៃបណ្តឹងជំទាស់នោះ លើកលែងតែករណីដែលបញ្ញត្តិនោះមានភាពផ្ទុយនឹងលក្ខណៈបណ្តឹង ឬ នីតិវិធីនោះ ។

២-បញ្ញត្តិស្តីពីបណ្តឹងសាទុក្ខ និង នីតិវិធីទាក់ទងនឹងការជំនុំជម្រះបណ្តឹងសាទុក្ខនោះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្តឹងជំទាស់លើដីកាសម្រេចដែលសាលាឧទ្ធរណ៍បានចេញក្នុងនាមជាតុលាការនៃការជំនុំជម្រះលើកទី ១ និង នីតិវិធីទាក់ទងនឹងបណ្តឹងជំទាស់នោះ លើកលែងតែករណីដែលបញ្ញត្តិនោះមានភាពផ្ទុយនឹងលក្ខណៈនៃបណ្តឹង ឬ នីតិវិធីនោះ ។

**មាត្រា ៣០៥.–** ការផ្អាកអានុភាពនៃដីកាសម្រេចដើម

១-បណ្តឹងជំទាស់ត្រូវផ្អាកអានុភាពនៃដីកាសម្រេចដើម ។

២-តុលាការនៃបណ្តឹងជំទាស់ ឬ តុលាការដែលបានចេញដីកាសម្រេចដើម អាចបង្គាប់ឱ្យផ្អាកជាបណ្តោះអាសន្ននូវការអនុវត្តដោយបង្ខំ ដោយផ្អែកលើដីកាសម្រេចដើម

៤-អំឡុងពេលដែលបានកំណត់ក្នុងវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ៣ ខាងលើនេះ មិនអាចពន្យារបានឡើយ ។

**មាត្រា ៣២៦.-** ការលើកចោលនូវពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលបានធ្វើនៅមុនការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន

១-ប្រសិនបើតុលាការយល់ឃើញថា ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿនដែលបានធ្វើនៅមុនការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន មិនស្របច្បាប់ទេ តុលាការត្រូវលើកចោលនូវពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿននោះ ដោយដីកាសម្រេច ។

២-ចំពោះដីកាសម្រេចដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចប្ដឹងជំទាស់បាន ។

**មាត្រា ៣២៧.-** អានុភាពនៃពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលបានធ្វើនៅមុនការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន

១-ប្រសិនបើមានពាក្យសុំតវ៉ាស្របច្បាប់ចំពោះដីកាសម្រេចដាស់តឿន នៅមុនការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន ដីកាសម្រេចដាស់តឿននោះ ត្រូវបាត់បង់អានុភាពក្នុងទំហំនៃការតវ៉ានោះ ។

២-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះការទាមទារដែលទាក់ទងនឹងការតវ៉ាចំពោះដីកាសម្រេចដាស់តឿន ត្រូវចាត់ទុកថា បានដាក់ពាក្យបណ្ដឹងទៅតុលាការដែលបានកំណត់នៅមាត្រា ៣២០ (ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន) នៃក្រមនេះ នៅពេលដែលមានពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន ។ ក្នុងករណីនេះ ប្រាក់សោហ៊ុយសម្រាប់នីតិវិធីដាស់តឿន គឺជាផ្នែកមួយនៃប្រាក់ប្រដាប់ក្ដី ។

**មាត្រា ៣២៨.-** ការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន

១-ប្រសិនបើកូនបំណុលមិនបានដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលបានធ្វើនៅមុនការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន ក្នុងអំឡុងពេល ២ (ពីរ) សប្ដាហ៍ បន្ទាប់ពីថ្ងៃដែលបានទទួលការបញ្ជូនដីកាសម្រេចដាស់តឿន ឬ បើដីកាសម្រេចដែលលើកចោលនូវពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន មុនការប្រកាសឱ្យអនុវត្តជាបណ្ដោះ-

អាសន្នបានចូលជាស្ថាពរ តុលាការត្រូវប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន ដោយកំណត់បញ្ជាក់បន្ថែមនូវប្រាក់សោហ៊ុយសម្រាប់នីតិវិធីដាស់តឿនលើដីកាសម្រេចដាស់តឿន ដោយឆន្ទានុសិទ្ធិ ។

២-ការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន ត្រូវបញ្ជាក់នៅក្នុងដីកាសម្រេចដាស់តឿន ហើយត្រូវបញ្ជូនទៅភាគី ។

៣-បញ្ញត្តិនៃមាត្រា ១៩៧ (ការបាត់បង់អានុភាពនៃការប្រកាសឱ្យអនុវត្តជាបណ្ដោះ-អាសន្ន និង បដិទានស្ថានភាពដើម) និង កថាខណ្ឌទី ២ នៃមាត្រា ៣២៥ (ការបញ្ជូនដីកាសម្រេចដាស់តឿន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន ដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ៣២៩.-** ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលបានធ្វើនៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន

១-ពាក្យសុំតវ៉ាការដាស់តឿននៃកថាខណ្ឌទី ២ មាត្រា ៣២៣ (ការចេញដីកាសម្រេចដាស់តឿន ជាអាទិ៍) នៃក្រមនេះ ចំពោះដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន ត្រូវធ្វើនៅក្នុងអំឡុងពេល ២ (ពីរ) សប្ដាហ៍ ក្រោយពីបានទទួលការបញ្ជូនដីកាសម្រេចដាស់តឿននោះ ។

២-អំឡុងពេលដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចពន្យារបានឡើយ ។

**មាត្រា ៣៣០.-** ការលើកចោលនូវពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលបានធ្វើនៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន

១-ប្រសិនបើតុលាការយល់ឃើញថា ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលបានធ្វើនៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ននោះ មិនស្របច្បាប់ទេ តុលាការត្រូវលើកចោលពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿននោះ ដោយដីកាសម្រេច ។

២-ចំពោះដីកាសម្រេចដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចប្ដឹងជំ-ទាស់បាន ។

# គន្ថីទី ៦
# ការអនុវត្តដោយបង្ខំ

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### ផ្នែកទី ១
### គោលគំនិត

**មាត្រា ៣៣៤.–** គោលគំនិត

បុគ្គលដែលមានសិទ្ធិទាមទារ ឬ សិទ្ធិប្រាតិភោគដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី ឬ ច្បាប់ផ្សេងទៀត អាចទាមទារឱ្យសម្រេចសិទ្ធិនោះដោយការអនុវត្តដោយបង្ខំ តាមបញ្ញត្តិនៃគន្ថីនេះ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់ផ្សេង ។

**មាត្រា ៣៣៥.–** ការអនុវត្តដូចគ្នា តាមបញ្ញត្តិពីគន្ថីទី ២ ដល់គន្ថីទី ៤

បញ្ញត្តិពីគន្ថីទី ២ ដល់ គន្ថីទី ៤ នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីនៃការអនុវត្តដោយបង្ខំ លើកលែងតែមានបញ្ញត្តិពិសេស ។

### ផ្នែកទី ២
### ស្ថាប័នអនុវត្ត

**មាត្រា ៣៣៦.–** ស្ថាប័នអនុវត្ត

១-ការអនុវត្តដោយបង្ខំត្រូវធ្វើឡើងដោយស្ថាប័នអនុវត្ត តាមពាក្យសុំរបស់ភាគី ។

២-ស្ថាប័នអនុវត្ត គឺតុលាការអនុវត្ត ឬ អាជ្ញាសាលា ។

៣-សាលាដំបូងដែលត្រូវអនុវត្តដោយបង្ខំ តាមបញ្ញត្តិនៃគន្ថីនេះ គឺជាតុលាការអនុវត្ត ។

៤-ការសម្រេចសេចក្តីអំពីបណ្តឹងឧបាស្រ័យ ចំពោះការចាត់ចែងការអនុវត្តដែលធ្វើឡើងដោយអាជ្ញាសាលា ត្រូវធ្វើឡើងដោយសាលាដំបូងដែលអាជ្ញាសាលានោះស្ថិតនៅ ។

**មាត្រា ៣៣៧.-** ការសម្រេចសេចក្តីរបស់តុលាការអនុវត្ត ជាអាទិ៍

១-ការសម្រេចសេចក្តីរបស់តុលាការអនុវត្ត ត្រូវធ្វើឡើងដោយដីកាសម្រេច ។

២-បើយល់ឃើញថាចាំបាច់ នៅពេលចាត់ចែងធ្វើការអនុវត្ត តុលាការអនុវត្តអាចសួរជនដែលទាក់ទងនឹងផលប្រយោជន៍ ឬ ជនផ្សេងទៀតដែលពាក់ព័ន្ធបាន ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសាលាដំបូង ត្រូវសម្រេចសេចក្តីអំពីឧបាស្រ័យ ចំពោះការចាត់ចែងការអនុវត្តដែលធ្វើឡើងដោយអាជ្ញាសាលា ។

**មាត្រា ៣៣៨.-** ការធានាក្នុងការបំពេញមុខនាទីរបស់អាជ្ញាសាលា ជាអាទិ៍

១-ប្រសិនបើអាជ្ញាសាលាជួបប្រទះនឹងការប្រឆាំងនៅពេលបំពេញមុខនាទីរបស់ខ្លួន អាជ្ញាសាលានោះអាចប្រើកម្លាំង ឬ អាចសុំជំនួយពីនគរបាល ឬ កងកម្លាំងផ្សេងទៀតដែលមានសមត្ថកិច្ច ដើម្បីបំបាត់នូវការប្រឆាំងនោះបាន ។

២-ប្រសិនបើអ្នកក្រៅពីអាជ្ញាសាលាដែលបំពេញមុខនាទីពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ តាមការបង្គាប់របស់តុលាការអនុវត្ត ជួបប្រទះនឹងការប្រឆាំងនៅពេលបំពេញមុខនាទីរបស់ខ្លួន អ្នកនោះអាចសុំជំនួយពីអាជ្ញាសាលាបាន ។

**មាត្រា ៣៣៩.-** អ្នកសង្កេតការណ៍

នៅពេលចូលទៅទីកន្លែងរស់នៅដើម្បីបំពេញមុខនាទីរបស់ខ្លួន បើមិនបានជួបនឹងអ្នកចម្បងនៃទីកន្លែងរស់នៅ ឬ អ្នកតំណាងរបស់អ្នកនោះ ឬ ញាតិនៅជាមួយឬអ្នកបម្រើឬអ្នកផ្សេងដែលធ្វើការនៅទីនោះដែលមានការយល់ដឹងសមរម្យទេ អាជ្ញាសាលា ឬ អ្នកក្រៅពីអាជ្ញាសាលាដែលបំពេញមុខនាទីពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ តាមការបង្គាប់របស់តុលាការអនុវត្ត ត្រូវឱ្យមានវត្តមានមន្ត្រីឃុំ សង្កាត់ មន្ត្រីនគរបាល ឬ អ្នកដទៃទៀតដែលអាចទទួលស្គាល់ថាជាសាក្សីសមរម្យ ។ បញ្ញត្តិនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអាជ្ញាសាលាប្រើកម្លាំង ឬ បានទទួលជំនួយពីនគរបាល ឬ កងកម្លាំងផ្សេងទៀតដែលមានសមត្ថកិច្ច តាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៣៣៨ (ការធានាក្នុងការបំពេញមុខនាទីរបស់អាជ្ញាសាលា ជាអាទិ៍) នៃក្រមនេះ ។

**មាត្រា ៣៤០.-** ការអនុវត្តនៅថ្ងៃសម្រាក ឬ ពេលយប់

១-អាជ្ញាសាលា ឬ អ្នកក្រៅពីអាជ្ញាសាលាដែលបំពេញមុខនាទីពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ តាមការបង្គាប់របស់តុលាការអនុវត្ត ត្រូវទទួលការអនុញ្ញាតពីសាលាដំបូងដែលខ្លួនស្ថិតនៅ ឬ តុលាការអនុវត្តដែលចេញការបង្គាប់ ដើម្បីចូលទៅបំពេញមុខនាទីក្នុងទីកន្លែងរស់នៅ នៅថ្ងៃអាទិត្យ ឬ ថ្ងៃឈប់សម្រាកដែលច្បាប់ ឬ បទដ្ឋានគតិយុត្តបានកំណត់ ឬ ពីម៉ោងប្រាំមួយល្ងាច ដល់ម៉ោងប្រាំមួយព្រឹកនៃថ្ងៃបន្ទាប់ ។

២-នៅពេលបំពេញមុខនាទីរបស់ខ្លួន អាជ្ញាសាលា ឬ អ្នកក្រៅពីអាជ្ញាសាលាដែលបំពេញមុខនាទីពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ តាមការបង្គាប់របស់តុលាការអនុវត្ត ត្រូវបង្ហាញលិខិតដែលបញ្ជាក់ថា ខ្លួនបានទទួលការអនុញ្ញាត តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ៣៤១.-** ការយកតាមខ្លួននូវអត្តសញ្ញាណប័ណ្ណ ជាអាទិ៍

នៅពេលបំពេញមុខនាទីរបស់ខ្លួន អាជ្ញាសាលា ឬ អ្នកក្រៅពីអាជ្ញាសាលាដែលបំពេញមុខនាទីពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ តាមការបង្គាប់របស់តុលាការអនុវត្ត ត្រូវយកតាមខ្លួននូវលិខិតដែលបញ្ជាក់អត្តសញ្ញាណ ឬ លក្ខណសម្បត្តិរបស់ខ្លួន ហើយត្រូវបង្ហាញលិខិតនេះ ចំពោះជនដែលទាក់ទងនឹងផលប្រយោជន៍ បើជននោះទាមទារ ។

**មាត្រា ៣៤២.-** ការស្នើសុំជំនួយពីក្រសួងមានសមត្ថកិច្ច

ក្នុងករណីដែលមានភាពចាំបាច់ក្នុងការអនុវត្តដោយបង្ខំ តុលាការអនុវត្តអាចស្នើសុំជំនួយពីក្រសួង ឬ ស្ថាប័នដែលមានសមត្ថកិច្ចបាន ។

**មាត្រា ៣៤៣.-** បញ្ញត្តិពិសេសស្ដីពីបណ្ដឹងជំទាស់នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ

១-ទោះជាមានបញ្ញត្តិនៃមាត្រា ៣០៥ (ការផ្អាកអានុភាពនៃដីកាសម្រេចដើម) នៃក្រមនេះក៏ដោយ ក៏បណ្ដឹងជំទាស់ដែលបានកំណត់នៅក្នុងគន្ថីនេះ មិនត្រូវផ្អាកអានុភាពនៃដីកាសម្រេចដើមឡើយ ។

២-ក្នុងអំឡុងពេលរហូតដល់សេចក្ដីសម្រេចអំពីបណ្ដឹងជំទាស់មានអានុភាព តុលាការនៃបណ្ដឹងជំទាស់អាចចេញដីកាសម្រេចដែលបានកំណត់នៅក្នុងចំណុចខាងក្រោមនេះបាន :

ក-បង្គាប់ឱ្យផ្អាកអានុភាពនៃដីកាសម្រេចដើម ដោយឱ្យដាក់ប្រាតិភោគ ឬ មិនឱ្យដាក់ប្រាតិភោគ ។

ខ-បង្គាប់ឱ្យផ្អាកនីតិវិធីនៃការអនុវត្តដោយបង្ខំមួយផ្នែក ឬ ទាំងមូល ដោយឱ្យដាក់ប្រាតិភោគ ឬ មិនឱ្យដាក់ប្រាតិភោគ ។

**មាត្រា ៣៤៤.-** ការតវ៉ាចំពោះការអនុវត្ត

១-ចំពោះការចាត់ចែងការអនុវត្តរបស់តុលាការអនុវត្ត ដែលមិនអាចប្តឹងជំទាស់បាន អាចតវ៉ាទៅតុលាការអនុវត្តបាន ។

២-ចំពោះការចាត់ចែងការអនុវត្តរបស់អាជ្ញាសាលា និង ការយឺតយ៉ាវ ឬ ការធ្វេសប្រហែសក្នុងការចាត់ចែងអនុវត្តនោះ អាចតវ៉ាទៅសាលាដំបូងដែលអាជ្ញាសាលានោះស្ថិតនៅបាន ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៣៤៣ (បញ្ញត្តិពិសេសស្តីពីបណ្តឹងជំទាស់នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលមានការតវ៉ាចំពោះការអនុវត្ត ។

**មាត្រា ៣៤៥.-** បណ្តឹងជំទាស់ចំពោះដីកាសម្រេចលុបចោល ជាអាទិ៍

១-ចំពោះដីកាសម្រេចដូចខាងក្រោមនេះ អាចប្តឹងជំទាស់បាន:

ក-ដីកាសម្រេចរបស់តុលាការអនុវត្ត ដែលលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំ ។

ខ-ដីកាសម្រេចរបស់សាលាដំបូង ដែលបង្គាប់ឱ្យអាជ្ញាសាលាលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំ ។

គ-ដីកាសម្រេចរបស់សាលាដំបូង ដែលលើកចោលពាក្យសុំតវ៉ាចំពោះការចាត់ចែងរបស់អាជ្ញាសាលា ដែលលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំ ។

២-ដីកាសម្រេចដែលអាចប្តឹងជំទាស់តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវមានអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរទេ ។

## ផ្នែកទី ៤
## លក្ខខណ្ឌនៃការអនុវត្តដោយបង្ខំ

**មាត្រា ៣៤៩.–** របៀបដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ

១-ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ ។

២-នៅក្នុងពាក្យសុំឱ្យអនុវត្តដោយបង្ខំ ត្រូវមានបញ្ជាក់នូវចំណុចដូចខាងក្រោមនេះ ហើយត្រូវភ្ជាប់ជាមួយនឹងលិខិតចម្លងយថាភូតនៃលិខិតអនុវត្ត ដែលមានអានុភាពអនុវត្តៈ

ក-ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋាន របស់ម្ចាស់បំណុលនៃការអនុវត្ត និង កូនបំណុលនៃការអនុវត្ត ហើយនិងឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

ខ-សញ្ញាណនៃលិខិតអនុវត្ត ។

គ-សេចក្ដីសុំឱ្យអនុវត្ត តាមការបង្ខំដោយផ្ទាល់ ឬ ការអនុវត្តជំនួស ឬ វិធានបង្ខំដោយប្រយោល ។

ឃ-សញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ និង វិធីអនុ-វត្តដោយបង្ខំដែលម្ចាស់បំណុលនៃការអនុវត្តសុំ ក្នុងករណីដែលសុំឱ្យអនុវត្តតាមការបង្ខំដោយផ្ទាល់ ។

ង-ខ្លឹមសារនៃសេចក្ដីសម្រេចដែលម្ចាស់បំណុលសុំ ក្នុងករណីដែលសុំឱ្យអនុវត្តដោយបង្ខំ តាមការអនុវត្តជំនួស ឬវិធានបង្ខំដោយប្រយោល ។

៣-ក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្តសុំឱ្យអនុវត្តដោយបង្ខំ ចំពោះផ្នែកណាមួយនៃសិទ្ធិទាមទារដែលបានសរសេរនៅក្នុងលិខិតអនុវត្តដែលបង្គាប់ឱ្យសងជាប្រាក់ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវសរសេរបញ្ជាក់អំពីសេចក្ដីសុំ និង ទំហំនៃសេចក្ដីសុំនោះ ក្នុងពាក្យសុំឱ្យអនុវត្តដោយបង្ខំ ។

**មាត្រា ៣៥០.–** លិខិតអនុវត្ត

១-ការអនុវត្តដោយបង្ខំត្រូវធ្វើឡើង ដោយផ្អែកលើលិខិតអនុវត្ត ។

២-លិខិតអនុវត្ត គឺជាលិខិតដែលបានកំណត់ខាងក្រោមនេះ :

ក-សាលក្រម ឬ សាលដីកាបង្គាប់ឱ្យផ្តល់តាវកាលិកដែលបានចូលជាស្ថាពរ ។

ខ-សាលក្រម ឬ សាលដីកាបង្គាប់ឱ្យផ្តល់តាវកាលិកដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ។

គ-ដីកាសម្រេចបង្គាប់ឱ្យផ្តល់តាវកាលិក ។ ប៉ុន្តែ ចំពោះដីកាសម្រេចដែលមិនត្រូវមានអានុភាពបើមិនទាន់ចូលជាស្ថាពរវិញ មានកម្រិតតែដីកាសម្រេចនោះបានចូលជាស្ថាពរហើយ ។

ឃ-ដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះ-អាសន្ន ។

ង-ការចាត់ចែងរបស់ក្រឡាបញ្ជីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៦៦ (នីតិវិធីដើម្បីកំណត់ជាស្ថាពរនូវចំនួនប្រាក់ប្រដាប់ក្តី) នៃក្រមនេះ ។

ច-លិខិតយថាភូតដែលធ្វើដោយសារការី ចំពោះការទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់មានកំណត់ ។ ប៉ុន្តែ មានកម្រិតតែលិខិតដែលបញ្ជាក់សេចក្តីថ្លែង-ការណ៍ថា កូនបំណុលនឹងទទួលការអនុវត្តដោយបង្ខំភ្លាមៗ ។

ឆ-សាលក្រម ឬ សាលដីការបស់តុលាការបរទេស ដែលមានសាលក្រមអនុ-វត្ត ដែលបានចូលជាស្ថាពរ តាមបញ្ញត្តិនៃមាត្រា ៣៥២ (សាលក្រមអនុវត្តសាលក្រម ឬ សាលដីការបស់តុលាការបរទេស) នៃក្រមនេះ ។

ជ-សេចក្តីសម្រេចមជ្ឈត្តករ ដែលមានដីកាសម្រេចអនុវត្តដែលបានចូលជាស្ថា-ពរតាមបញ្ញត្តិនៃមាត្រា ៣៥៣ (ដីកាសម្រេចអនុវត្តសេចក្តីសម្រេចមជ្ឈត្តករ) នៃក្រមនេះ ។

ឈ-កំណត់ហេតុដែលបានកំណត់នៅក្នុងមាត្រា ២២២ (អានុភាពនៃកំណត់ហេតុស្តីពីការសះជា ជាអាទិ៍) នៃក្រមនេះ និង កំណត់ហេតុផ្សេងទៀតដែលមានអានុភាពដូចសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរ ។

**មាត្រា ៣៥១.-** វិសាលភាពនៃអ្នកដែលអាចអនុវត្តដោយបង្ខំ

១-ការអនុវត្តដោយបង្ខំ អាចធ្វើបាន ដោយចង្អុលអ្នកដែលបានកំណត់ខាងក្រោមនេះ ជាម្ចាស់បំណុលនៃការអនុវត្ត ឬ កូនបំណុលនៃការអនុវត្ត :

ក-ភាគីដែលត្រូវបានបញ្ជាក់នៅក្នុងលិខិតអនុវត្ត ។

សេចក្ដីសម្រេចមជ្ឈត្តករ ។

៩-ចំពោះដីកាសម្រេចអំពីពាក្យសុំឱ្យចេញដីកាសម្រេចអនុវត្ត អាចប្ដឹងជំទាស់បាន ។

១០-ដីកាសម្រេចអនុវត្ត មិនត្រូវមានអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរទេ ។

**មាត្រា ៣៥៤.-** ភាពចាំបាច់នៃរូបមន្តអនុវត្ត និង ស្ថាប័នផ្ដល់រូបមន្តអនុវត្ត

១-ការអនុវត្តដោយបង្ខំត្រូវធ្វើឡើង ដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្ត ។ ប៉ុន្តែ ក្នុងករណីដែលយកឯកសារដែលបានកំណត់ដូចខាងក្រោមនេះជាលិខិតអនុវត្ត ការអនុវត្តដោយបង្ខំ ដោយយកភាគីដែលបានកំណត់ក្នុងលិខិតអនុវត្តនោះធ្វើជាម្ចាស់បំណុលនៃការអនុវត្ត ឬ កូនបំណុលនៃការអនុវត្តត្រូវធ្វើឡើង ដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តនោះ :

ក-សាលក្រមនៃបណ្ដឹងរឿងក្ដីចំនួនទឹកប្រាក់តិចដែលចូលជាស្ថាពរ ។

ខ-សាលក្រមនៃបណ្ដឹងរឿងក្ដីចំនួនទឹកប្រាក់តិចដែលភ្ជាប់ការប្រកាសឱ្យអនុ-វត្តជាបណ្ដោះអាសន្ន ។

គ-ដីកាសម្រេចដាស់តឿនដែលភ្ជាប់ការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន ។

២-រូបមន្តអនុវត្ត ត្រូវផ្ដល់ដោយក្រឡាបញ្ជីនៃតុលាការដែលមានសំណុំរឿងនោះតាមពាក្យសុំ ។ ប៉ុន្តែ ចំពោះលិខិតអនុវត្តដែលបានកំណត់នៅក្នុងចំណុច ច កថាខណ្ឌទី ២ មាត្រា ៣៥០ (លិខិតអនុវត្ត) នៃក្រមនេះ ត្រូវផ្ដល់ដោយសារការីដែលរក្សាទុកនូវលិខិតដើមនោះ ។

**មាត្រា ៣៥៥.-** ពាក្យសុំឱ្យផ្ដល់រូបមន្តអនុវត្ត

១-ពាក្យសុំឱ្យផ្ដល់រូបមន្តអនុវត្ត ត្រូវធ្វើឡើងដោយលិខិតជាលាយល័ក្ខណ៍អក្សរដែលសរសេរចំណុចដូចខាងក្រោមនេះ :

ក-ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត និង កូនបំណុលនៃការអនុវត្ត ហើយនិងឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

ខ-សញ្ញាណនៃលិខិតអនុវត្ត ។

គ-ហេតុការណ៍ និង មូលហេតុ បើការទាមទារឱ្យផ្ដល់រូបមន្តអនុវត្តត្រូវធ្វើឡើង

តាមបញ្ញត្តិនៃមាត្រា ៣៥៦ (រូបមន្តអនុវត្តពិសេស) ឬ កថាខណ្ឌទី ១ នៃមាត្រា ៣៥៨ (ការផ្ដល់រូបមន្តអនុវត្តច្រើនច្បាប់ ជាអាទិ៍) នៃក្រមនេះ ។

២-ក្នុងករណីដែលលិខិតអនុវត្តជាសេចក្ដីសម្រេចដែលមិនបង្កើតអានុភាពបើមិនចូលជាស្ថាពរទេ ប្រសិនបើម្ចាស់បំណុលនៃការអនុវត្តដាក់ពាក្យសុំឱ្យផ្ដល់រូបមន្តអនុវត្តចំពោះលិខិតអនុវត្តនោះ ម្ចាស់បំណុលនៃការអនុវត្តត្រូវភ្ជាប់មកជាមួយពាក្យសុំនូវលិខិតបញ្ជាក់ការចូលជាស្ថាពរនៃសេចក្ដីសម្រេចនោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលច្បាស់លាស់ថា សេចក្ដីសម្រេចនោះបានចូលជាស្ថាពរហើយ ក្នុងសំណុំរឿង ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលម្ចាស់បំណុលនៃការអនុវត្ត ទាមទារឱ្យប្រគល់ថែមទៀតនូវឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ មាត្រា ៣៥៤ (ភាពចាំបាច់នៃរូបមន្តអនុវត្ត និង ស្ថាប័នផ្ដល់រូបមន្តអនុវត្ត) នៃក្រមនេះ ។

**មាត្រា ៣៥៦.-** រូបមន្តអនុវត្តពិសេស

១-នៅក្នុងករណីដែលសិទ្ធិទាមទារដែលត្រូវបានកំណត់នៅក្នុងលិខិតអនុវត្ត ភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ ឬ ពេលកំណត់មិនពិតប្រាកដ ក្រឡាបញ្ជី ឬ សារការីអាចប្រគល់រូបមន្តអនុវត្តបាន លុះត្រាតែម្ចាស់បំណុលនៃការអនុវត្តបានបញ្ជាក់អំពីការបំពេញល័ក្ខខ័ណ្ឌ ឬ ការមកដល់នូវពេលកំណត់មិនពិតប្រាកដនោះ ។

២-ដើម្បីធ្វើការអនុវត្តដោយបង្ខំដោយយកបុគ្គលផ្សេង ក្រៅពីភាគីដែលត្រូវបានសរសេរលើលិខិតអនុវត្ត ធ្វើជាម្ចាស់បំណុលនៃការអនុវត្ត ឬ កូនបំណុលនៃការអនុវត្ត ម្ចាស់បំណុលនៃការអនុវត្តត្រូវទទួលការផ្ដល់រូបមន្តអនុវត្តដែលមានសរសេរនូវហេតុការណ៍នោះ ។

៣-ក្នុងករណីដែលមានភាពច្បាស់លាស់ថា អាចនឹងធ្វើការអនុវត្តដោយបង្ខំ ដោយយកបុគ្គលផ្សេងក្រៅពីភាគីដែលត្រូវបានកំណត់នៅក្នុងលិខិតអនុវត្ត ធ្វើជាម្ចាស់បំណុលនៃការអនុវត្ត ឬ កូនបំណុលនៃការអនុវត្ត ឬ ករណីដែលម្ចាស់បំណុលនៃការអនុវត្តបានបញ្ជាក់ដោយលិខិតអំពីហេតុការណ៍នោះ ក្រឡាបញ្ជី ឬ សារការីអាចផ្ដល់នូវរូបមន្តអនុវត្តដែលបានកំណត់នៅក្នុងកថាខណ្ឌទី២ ខាងលើនេះបាន ។

៤-នៅពេលក្រឡាបញ្ជីផ្តល់រូបមន្តអនុវត្តដោយយោលតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ កថាខណ្ឌទី ៣ ខាងលើនេះ ក្រឡាបញ្ជីនោះត្រូវទទួលសេចក្តីអនុញ្ញាតពីតុលាការដែលខ្លួនស្ថិតនៅ ។

**មាត្រា ៣៥៧.–** ចំណុចដែលត្រូវសរសេរក្នុងរូបមន្តអនុវត្ត

១-ការផ្តល់រូបមន្តអនុវត្ត ត្រូវធ្វើឡើងតាមវិធីសរសេរភ្ជាប់បន្ថែម នៅផ្នែកក្រោមនៃឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត នូវចំណុចនីមួយៗដូចខាងក្រោមនេះ :

ក-បុគ្គលដែលអាចទាមទារឱ្យធ្វើការអនុវត្តដោយបង្ខំបាន ដោយលិខិតអនុវត្តនោះ និង ភាគីម្ខាងទៀត ។

ខ-ហេតុការណ៍ ក្នុងករណីដែលបានផ្តល់រូបមន្តអនុវត្ត តាមបញ្ញត្តិនៃមាត្រា ៣៥៦ (រូបមន្តអនុវត្តពិសេស) នៃក្រមនេះ ។

គ-ទំហំដែលអាចអនុវត្តដោយបង្ខំបាន បើបានផ្តល់រូបមន្តអនុវត្តតែមួយផ្នែកនៃសិទ្ធិទាមទារដែលត្រូវបានកំណត់នៅក្នុងលិខិតអនុវត្ត ។

ឃ-ហេតុការណ៍ ក្នុងករណីដែលផ្តល់រូបមន្តអនុវត្ត តាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៣៥៨ (ការផ្តល់រូបមន្តអនុវត្តច្រើនច្បាប់ ជាអាទិ៍) នៃក្រមនេះ ។

២-ក្រឡាបញ្ជី ឬ សារការី ត្រូវចុះហត្ថលេខាលើរូបមន្តអនុវត្ត ដោយសរសេរថ្ងៃ ខែ ឆ្នាំនៃការផ្តល់ ។

**មាត្រា ៣៥៨.–** ការផ្តល់រូបមន្តអនុវត្តច្រើនច្បាប់ ជាអាទិ៍

១-មានតែនៅក្នុងករណីដែលចាំបាច់ត្រូវការឯកសារចម្លងយថាភូតច្រើនច្បាប់នៃលិខិតអនុវត្ត ដែលភ្ជាប់នឹងរូបមន្តអនុវត្ត ដើម្បីទទួលសំណងពេញលេញនៃសិទ្ធិទាមទារ ឬ នៅក្នុងករណីដែលឯកសារចម្លងយថាភូតនោះបានបាត់បង់តែប៉ុណ្ណោះទេ ទើបអាចផ្តល់រូបមន្តអនុវត្តបន្ថែមទៀតបាន ។

២-បើផ្តល់រូបមន្តអនុវត្ត តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ក្រឡាបញ្ជី ឬ សារការីត្រូវជូនដំណឹងទៅកូនបំណុលនៃការអនុវត្ត អំពីហេតុការណ៍និងមូលហេតុនោះ និង ចំនួននៃឯកសារចម្លងយថាភូតដែលត្រូវបានផ្តល់រូបមន្តអនុវត្ត ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ

ចំពោះករណីដែលប្រគល់បន្ថែមទៀតនូវឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលបាន កំណត់នៅក្នុងវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ មាត្រា ៣៥៤ (ភាពចាំបាច់នៃរូបមន្តអនុវត្ត និង ស្ថាប័នផ្ដល់រូបមន្តអនុវត្ត) នៃក្រមនេះ ។

**មាត្រា ៣៥៩.-** ការសរសេរចូលទៅក្នុងច្បាប់ដើមនៃលិខិតអនុវត្ត

១-នៅពេលផ្ដល់រូបមន្តអនុវត្ត ក្រឡាបញ្ជី ឬ សារការី ត្រូវសរសេរនៅក្នុងច្បាប់ដើម នៃលិខិតអនុវត្ត នូវចំណុចដូចខាងក្រោមនេះ :

ក-ហេតុការណ៍នៃការផ្ដល់រូបមន្តអនុវត្ត ថ្ងៃ ខែ ឆ្នាំដែលផ្ដល់ និង ចំនួនឯកសារ ចម្លងយថាភូតដែលត្រូវបានផ្ដល់រូបមន្តអនុវត្ត ។

ខ-ទំហំដែលអាចអនុវត្តដោយបង្ខំបាន ក្នុងករណីដែលបានផ្ដល់រូបមន្តអនុវត្ត ចំពោះតែមួយផ្នែកនៃសិទ្ធិទាមទារដែលបានកំណត់ នៅក្នុងលិខិតអនុវត្ត ។

គ-ហេតុការណ៍ និង ឈ្មោះ ឬ នាមករណ៍របស់ម្ចាស់បំណុលនៃការអនុវត្ត ឬ កូន បំណុលនៃការអនុវត្ត ក្នុងករណីដែលបានផ្ដល់រូបមន្តអនុវត្ត តាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៣៥៦ (រូបមន្តអនុវត្តពិសេស) នៃក្រមនេះ ។

២-បើក្រឡាបញ្ជីបានប្រគល់ឯកសារចម្លងយថាភូតនៃលិខិតអនុវត្តថែមទៀត តាម បញ្ញត្តិនៃវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ មាត្រា ៣៥៤ (ភាពចាំបាច់នៃរូបមន្តអនុវត្ត និង ស្ថាប័នផ្ដល់រូបមន្តអនុវត្ត) នៃក្រមនេះ ក្រឡាបញ្ជីនោះ ត្រូវសរសេរអំពីហេតុការណ៍នៃការ ផ្ដល់រូបមន្តអនុវត្តនេះ ថ្ងៃ ខែ ឆ្នាំដែលផ្ដល់ និង ចំនួនឯកសារចម្លងយថាភូតដែលបាន ប្រគល់ នៅក្នុងច្បាប់ដើមនៃសាលក្រម ឬ សាលដីកា ឬ ដីកាសម្រេចដាស់តឿន ។

**មាត្រា ៣៦០.-** ការបញ្ជូនលិខិតអនុវត្ត ជាអាទិ៍

ការអនុវត្តដោយបង្ខំ អាចចាប់ផ្ដើមធ្វើបាន តែក្នុងករណីដែលឯកសារចម្លងយថាភូត ឬ ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃលិខិតអនុវត្ត ឬ សេចក្ដីសម្រេចដែលនឹងក្លាយ ជាលិខិតអនុវត្តនៅពេលចូលជាស្ថាពរ ត្រូវបានបញ្ជូនទៅកូនបំណុលនៃការអនុវត្តជាមុន ។ នៅក្នុងករណីដែលរូបមន្តអនុវត្តត្រូវបានផ្ដល់ តាមបញ្ញត្តិនៃមាត្រា ៣៥៦ (រូបមន្តអនុវត្ត ពិសេស) នៃក្រមនេះ ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃរូបមន្តអនុវត្ត និង ឯកសារ ចម្លងដែលមានសេចក្ដីបញ្ជាក់នៃឯកសារដែលម្ចាស់បំណុលនៃការអនុវត្តបានដាក់ តាម

បញ្ញត្តិនៃមាត្រា ៣៥៦ នោះ ក៏ត្រូវបញ្ជូនទៅជាមុនផងដែរ ។

**មាត្រា ៣៦១.-** លក្ខខណ្ឌនៃការចាប់ផ្ដើមអនុវត្តដែលស្ថាប័នអនុវត្តត្រូវស្រាវជ្រាវ

១-ក្នុងករណីសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងលិខិតអនុវត្ត ភ្ជាប់ជាមួយនឹងពេលកំណត់ពិតប្រាកដ ស្ថាប័នអនុវត្ត អាចចាប់ផ្ដើមអនុវត្តដោយបង្ខំបាន លុះត្រាតែពេលកំណត់នោះបានមកដល់ហើយ ។

២-ចំពោះការអនុវត្តដោយបង្ខំ ដោយផ្អែកលើលិខិតអនុវត្តដែលមានដាក់លក្ខខណ្ឌត្រូវដាក់ប្រាតិភោគដើម្បីអនុវត្តដោយបង្ខំ ស្ថាប័នអនុវត្តអាចចាប់ផ្ដើមអនុវត្តដោយបង្ខំបាន លុះត្រាតែម្ចាស់បំណុលនៃការអនុវត្តបានដាក់លិខិតដែលបញ្ជាក់ថា ខ្លួនបានដាក់ប្រាតិ-ភោគនោះរួចហើយ ។

៣-ក្នុងករណីតាវកាលិករបស់កូនបំណុលនៃការអនុវត្ត ត្រូវផ្ដល់ដោយប្ដូរនឹងតាវ-កាលិកតប ស្ថាប័នអនុវត្តអាចចាប់ផ្ដើមអនុវត្តដោយបង្ខំបាន លុះត្រាតែម្ចាស់បំណុលនៃការអនុវត្តបញ្ជាក់ថា ខ្លួនបានផ្ដល់តាវកាលិកតបនោះ ឬ បានស្នើផ្ដល់តាវកាលិកតបនោះ ។

**មាត្រា ៣៦២.-** ពាក្យសុំតវ៉ាអំពីការផ្ដល់រូបមន្តអនុវត្ត ជាអាទិ៍

១-ចំពោះការចាត់ចែងពាក្យសុំឱ្យផ្ដល់រូបមន្តអនុវត្ត បើជាការចាត់ចែងរបស់ក្រឡាបញ្ជី អាចដាក់ពាក្យសុំតវ៉ាទៅតុលាការដែលក្រឡាបញ្ជីនោះស្ថិតនៅ តែបើជាការចាត់ចែងរបស់សារការី អាចដាក់ពាក្យសុំតវ៉ា ទៅសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងនៃការិយាល័យរបស់សារការីនោះ ។

២-ការសម្រេចសេចក្ដីអំពីពាក្យសុំតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើដោយដីកាសម្រេច ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលមានពាក្យសុំឱ្យប្រគល់បន្ថែមទៀតនូវឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ មាត្រា ៣៥៤ (ភាពចាំបាច់នៃរូបមន្តអនុវត្ត និង ស្ថាប័នផ្ដល់រូបមន្តអនុវត្ត) នៃក្រមនេះ ។

# ផ្នែកទី ៧
# សោហ៊ុយសម្រាប់ការអនុវត្ត និង ការមើលសំណុំរឿងនៃការអនុវត្ត

**មាត្រា ៣៧១.-** អត្ថន័យនៃសោហ៊ុយសម្រាប់ការអនុវត្ត និង សោហ៊ុយសម្រាប់នីតិវិធី

អត្ថន័យនៃពាក្យដែលកំណត់នៅក្នុងចំណុចនីមួយៗ ត្រូវអនុលោមទៅតាមបញ្ញត្តិក្នុងចំណុចនីមួយៗខាងក្រោមនេះ :

ក-សោហ៊ុយសម្រាប់ការអនុវត្ត : សំដៅទៅលើពន្ធដាក់ពាក្យសុំដែលបានកំណត់នៅក្នុងមាត្រា ៣៧២ (ពន្ធដាក់ពាក្យសុំ) សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំដែលបានកំណត់នៅក្នុងមាត្រា ៣៧៣ (សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ) និង សោហ៊ុយភាគីដែលបានកំណត់នៅក្នុងមាត្រា ៣៧៤ (សោហ៊ុយភាគី) នៃក្រមនេះ ។

ខ-សោហ៊ុយសម្រាប់នីតិវិធី : សំដៅទៅលើសោហ៊ុយសម្រាប់ផលប្រយោជន៍រួមក្នុងចំណោមសោហ៊ុយសម្រាប់ការអនុវត្តដែលបានកំណត់នៅក្នុងចំណុច ក ខាងលើនេះ ។

**មាត្រា ៣៧២.-** ពន្ធដាក់ពាក្យសុំ

១-ក្នុងករណីដែលដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំទៅតុលាការអនុវត្ត ម្ចាស់បំណុលនៃការអនុវត្តត្រូវបង់ពន្ធចំនួន ១០.០០០ (មួយម៉ឺន) រៀល ទៅតុលាការ ។

២-ក្នុងករណីដែលដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំទៅអាជ្ញាសាលា ម្ចាស់បំណុលនៃការអនុវត្តត្រូវបង់ពន្ធ តាមបញ្ញត្តិដែលកំណត់ផ្សេង ។

**មាត្រា ៣៧៣.-** សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ

ម្ចាស់បំណុលនៃការអនុវត្តត្រូវបង់នូវចំនួនទឹកប្រាក់ដែលកំណត់ដោយតុលាការ ជាសោហ៊ុយចាំបាច់ក្នុងការបញ្ជូនឯកសារ ឬ ធ្វើសកម្មភាពផ្សេងទៀតដើម្បីនីតិវិធីក្នុងការអនុវត្តដោយបង្ខំ ។

**មាត្រា ៣៧៤.-** សោហ៊ុយភាគី

ក្រៅពីសោហ៊ុយដែលបានកំណត់នៅក្នុងមាត្រា ៣៧២ (ពន្ធដាក់ពាក្យសុំ) និង មាត្រា ៣៧៣ (សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ) នៃក្រមនេះ សោហ៊ុយដែលតុលាការទទួលស្គាល់

ចាំបាច់ដើម្បីធ្វើការអនុវត្តដោយបង្ខំ ត្រូវចាត់ទុកថាជាសោហ៊ុយភាគី ។

**មាត្រា ៣៧៥.–** ការបង់សោហ៊ុយជាមុន

១-នៅពេលដែលដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំទៅតុលាការអនុវត្ត អ្នកដែលដាក់ពាក្យសុំត្រូវបង់ជាមុននូវចំនួនទឹកប្រាក់ដែលតុលាការអនុវត្តកំណត់ថាជាសោហ៊ុយចាំបាច់ដើម្បីធ្វើនីតិវិធីនៃការអនុវត្តដោយបង្ខំ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសោហ៊ុយដែលត្រូវបានបង់ជាមុនមានភាពខ្វះ ហើយតុលាការអនុវត្តបង្គាប់ឱ្យបង់ជាមុននូវសោហ៊ុយដែលខ្វះនោះ ។

២-បើអ្នកដាក់ពាក្យសុំមិនបានបង់សោហ៊ុយជាមុនទេ តុលាការអនុវត្តអាចលើកចោលពាក្យសុំឱ្យអនុវត្តដោយបង្ខំ ឬ អាចលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំនោះបាន ។

៣-ចំពោះដីកាសម្រេចលើកចោលពាក្យសុំតាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ អាចប្ដឹងជំទាស់បាន ។

**មាត្រា ៣៧៦.–** បន្ទុកនៃសោហ៊ុយសម្រាប់ការអនុវត្ត

១-សោហ៊ុយសម្រាប់ការអនុវត្ត ជាបន្ទុករបស់កូនបំណុលនៃការអនុវត្ត ។

២-ក្នុងករណីដែលអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ សោហ៊ុយសម្រាប់ការអនុវត្ត អាចប្រមូលយកព្រមគ្នាក្នុងនីតិវិធីនៃការអនុវត្តបាន ដោយពុំចាំបាច់មានលិខិតអនុវត្តទេ ។

**មាត្រា ៣៧៧.–** ការដាក់ប្រាតិភោគ

ដើម្បីដាក់ប្រាតិភោគតាមបញ្ញត្តិនៃគន្ថីនេះ ភាគីត្រូវធ្វើតាមវិធីផ្ញើប្រាក់ ឬ ឧបករណ៍អាចជួញដូរបាន ដែលតុលាការទទួលស្គាល់ថាសមរម្យ ទៅតុលាការដែលបង្គាប់ឱ្យដាក់ប្រាតិភោគនោះ ឬ តុលាការអនុវត្ត ។

**មាត្រា ៣៧៨.–** ការមើលសំណុំរឿងនៃរឿងក្ដីអនុវត្តដោយបង្ខំ ជាអាទិ៍

១-ជនដែលបានធ្វើសេចក្ដីបញ្ជាក់ដំបូងអំពីការពាក់ព័ន្ធនឹងផលប្រយោជន៍ ចំពោះការអនុវត្តដោយបង្ខំដែលធ្វើឡើងដោយតុលាការអនុវត្ត អាចទាមទារមើលសំណុំរឿង ថតចម្លងសំណុំរឿង ឱ្យប្រគល់ឯកសារចម្លងយថាភូត ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់

ឬ ឯកសារដកស្រង់នៃសំណុំរឿង ឬ អាចទាមទារឱ្យប្រគល់លិខិតបញ្ជាក់អំពីចំណុចដែលពាក់ព័ន្ធនឹងរឿងក្តីនោះ ពីតុលាការបាន ដោយបង់ពន្ធ ។

២-ជនដែលបានធ្វើសេចក្តីបញ្ជាក់ដំបូងអំពីការពាក់ព័ន្ធនឹងផលប្រយោជន៍ ចំពោះការអនុវត្តដោយបង្ខំដែលធ្វើឡើងដោយអាជ្ញាសាលា អាចទាមទារមើលសំណុំរឿង ថតចម្លងសំណុំរឿង ឱ្យប្រគល់ឯកសារចម្លងយថាភូត ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ ឬ ឯកសារដកស្រង់នៃសំណុំរឿង ឬ អាចទាមទារឱ្យប្រគល់លិខិតបញ្ជាក់អំពីចំណុចដែលពាក់ព័ន្ធនឹងរឿងក្តីនោះ ពីអាជ្ញាសាលាបាន ដោយបង់ពន្ធ ។

## ជំពូកទី ២
## ការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់

### ផ្នែកទី ១
### ទ្រព្យសម្បត្តិដែលអាចរឹបអូសបាន

**មាត្រា ៣៧៩.-** គោលការណ៍

ការរឹបអូស អាចធ្វើបានចំពោះរូបទ្រព្យ ឬ អរូបទ្រព្យទាំងអស់ដែលធ្លាក់ទៅលើកូនបំណុលនៃការអនុវត្ត លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសនៅក្នុងក្រមនេះ ឬ ច្បាប់ផ្សេង ។

**មាត្រា ៣៨០.-** ចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស

ចលនវត្ថុដែលបានកំណត់ដូចខាងក្រោមនេះ មិនអាចត្រូវរឹបអូសបានទេ ៖

ក-ប្រដាប់ស្លៀកពាក់ ប្រដាប់សម្រាប់ដំណេក តុ ទូ ប្រដាប់សម្រាប់ដាំស្ល និង ប្រដាប់សម្រាប់បិទឃាំងបន្ទប់ របស់កូនបំណុលនៃការអនុវត្ត និង ញាតិដែលរស់នៅជាមួយកូនបំណុលនៃការអនុវត្ត ហើយមានជីវភាពរួមគ្នា ។

ខ-គ្រឿងបរិភោគ និង ទហនវត្ថុ ដែលត្រូវការចាំបាច់ដើម្បីចិញ្ចឹមជីវិតក្នុងអំឡុងពេល ២ (ពីរ) ខែ របស់កូនបំណុលនៃការអនុវត្ត និង ញាតិដែលរស់នៅជាមួយកូនបំណុលនៃការអនុវត្ត ហើយមានជីវភាពរួមគ្នា ។

គ-របបឧបត្ថម្ភជីវភាព របបឧបត្ថម្ភផ្នែកអប់រំ របបឧបត្ថម្ភសុខភាព និង ប្រាក់ ឬ វត្ថុឧបត្ថម្ភផ្សេងទៀតដែលផ្តល់ពីរដ្ឋ ឬ ពីអាជ្ញាធរដែនដី ដើម្បីការពារដល់ជីវភាពរបស់កូនបំណុលនៃការអនុវត្ត ។

ឃ-ផ្នែកប្រាក់តិចជាង ឬ ស្មើនឹង ១.០០០.០០០ (មួយលាន) រៀល ក្រៅពីប្រាក់ដែលបានកំណត់នៅក្នុងចំណុច គ ខាងលើនេះ ។

ង-ឧបករណ៍ ជី សត្វពាហនៈដែលជាចាំបាច់សម្រាប់ការងារកសិកម្មរបស់ខ្លួន និង ចំណីសត្វទាំងនេះ ព្រមទាំងគ្រាប់ពូជ ឬ កសិផលដែលមានប្រភេទដូចគ្នា ដែលត្រូវការចាំបាច់សម្រាប់បន្តការងារកសិកម្មរហូតដល់រដូវបានផលបន្ទាប់ របស់កសិករក្នុងការប្រកបរបរកសិកម្ម ។

ច-មង សំណាញ់ ឬ នេសាទុបករណ៍ផ្សេងៗចាំបាច់ ចំណី និង កូនត្រី ឬ ជលផលប្រភេទដូចគ្នា ដែលត្រូវការចាំបាច់សម្រាប់រកជលផល ឬ ចិញ្ចឹមជលផលរបស់អ្នកប្រកបរបរនេសាទ ។

ឆ-ឧបករណ៍ និង វត្ថុផ្សេងៗដែលចាំបាច់សម្រាប់អ្នកបច្ចេកទេស សិប្បករ កម្មករ និង អ្នកផ្សេងទៀតដែលប្រកបរបរវិជ្ជាជីវៈ ឬ សាជីវកម្ម ដោយប្រើកម្លាំងប្រាជ្ញា កម្លាំងកាយ ។ ប៉ុន្តែ បើជាវត្ថុដែលអ្នកនោះមាន ក្នុងគោលបំណងសម្រាប់លក់ ឬ ជួលវិញ អាចរឹបអូសយកបាន ។

ជ-ព្រះពុទ្ធរូប ក្បួនវិធីសាសនា និង វត្ថុផ្សេងៗដែលចាំបាច់សម្រាប់ពិធីក្នុងសាសនា ។

ឈ-ពង្សាវលី កំណត់ប្រចាំថ្ងៃ បញ្ជីប្រកបមុខរបរ និង ឯកសារប្រភេទដូចគ្នាដែលចាំបាច់របស់កូនបំណុលនៃការអនុវត្ត ។

ញ-គ្រឿងឥស្សរិយយស និង ប័ណ្ណសរសើរផ្សេងទៀតរបស់កូនបំណុលនៃការអនុវត្ត ឬ របស់ញាតិរបស់ជននោះ ។

ដ-ឯកសារ និង ឧបករណ៍ ដែលចាំបាច់ក្នុងការសិក្សា នៅសាលា ឬ នៅស្ថាប័នអប់រំផ្សេងទៀត របស់កូនបំណុលនៃការអនុវត្ត និង ញាតិដែលរស់នៅជាមួយកូនបំណុលនៃការអនុវត្ត ហើយមានជីវភាពរួមគ្នា ។

ឋ-វត្ថុដែលទាក់ទងនឹងតក្កកម្ម ឬ ស្នាដៃនិពន្ធ ដែលមិនទាន់បានផ្សាយជាសាធារណៈ ។

ឌ-អវយវៈសិប្បនិមិត្ត សរីរាង្គសិប្បនិមិត្តផ្សេងទៀត និង ឧបករណ៍ជំនួយខ្លួនប្រាណផ្សេងទៀត ដែលចាំបាច់របស់កូនបំណុលនៃការអនុវត្ត និង ញាតិដែលរស់នៅជាមួយកូនបំណុលនៃការអនុវត្ត ហើយមានជីវភាពរួមគ្នា ព្រមទាំងវត្ថុផ្សេងៗសម្រាប់ថែទាំអ្នកជម្ងឺ ដែលជាកូនបំណុលនៃការអនុវត្ត និង ញាតិដែលរស់នៅជាមួយកូនបំណុលនៃការអនុវត្ត ហើយមានជីវភាពរួមគ្នា ។

ឍ-ម៉ាស៊ីន ឬ ឧបករណ៍ពន្លត់ភ្លើង ឧបករណ៍ជន្លៀសខ្លួនពេលមានអាសន្ន ឬ ឧបករណ៍ផ្សេងទៀត សម្រាប់អាគារ ឬ សំណង់ផ្សេងទៀត ដែលច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងៗតម្រូវឱ្យមានបរិក្ខារ ដើម្បីបង្ការមហន្តរាយ ឬ ការពារសន្តិសុខ ។

**មាត្រា ៣៨១.-** ការប្តូរទំហំនៃចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស

១-សាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅ អាចបង្គាប់ឱ្យលុបចោលទាំងអស់ ឬ មួយផ្នែកនូវការរឹបអូសដែលធ្វើឡើងដោយអាជ្ញាសាលា ឬ អាចអនុញ្ញាតឱ្យរឹបអូសនូវចលន-វត្ថុ ដែលបានកំណត់នៅក្នុងចំណុចនីមួយៗនៃមាត្រា ៣៨០ (ចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស) នៃក្រមនេះ ដោយពិចារណាទៅលើជីវភាព និង ស្ថានភាពផ្សេងៗរបស់កូនបំណុលនៃការអនុវត្ត និង ម្ចាស់បំណុលនៃការអនុវត្ត តាមពាក្យសុំបាន ។

២-ប្រសិនបើស្ថានភាពមានការផ្លាស់ប្តូរ សាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅ អាចអនុញ្ញាតឱ្យរឹបអូសចលនវត្ថុដែលត្រូវបានលុបចោលការរឹបអូស តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ឬ អាចបង្គាប់ឱ្យលុបចោលទាំងអស់ ឬ មួយផ្នែកនូវការរឹបអូសតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ដដែលនេះ តាមពាក្យសុំបាន ។

៣-ប្រសិនបើមានពាក្យសុំឱ្យចេញដីកាសម្រេចលុបចោលនូវការរឹបអូសតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះ សាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅ អាចបង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំនោះ ដោយឱ្យដាក់ប្រាតិភោគ ឬ មិនឱ្យដាក់ប្រាតិភោគបានរហូតដល់ដីកាសម្រេចនោះមានអានុភាព ។

៤-ចំពោះដីកាសម្រេចលើកចោលពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ឬ កថាខណ្ឌទី ២ ខាងលើនេះ និង ចំពោះដីកាសម្រេចអនុញ្ញាតឱ្យរឹបអូស តាមបញ្ញត្តិទាំងឡាយខាងលើនេះ អាចប្តឹងជំទាស់បាន ។

**មាត្រា ៣៨៣.-** ការផ្លាស់ប្តូរទំហំនៃសិទ្ធិលើបំណុលដែលហាមឃាត់មិនឱ្យរឹបអូស

១-តុលាការនៃការអនុវត្តអាចលុបចោលដីកាសម្រេចរឹបអូសទាំងអស់ ឬ មួយផ្នែក ឬ អាចចេញដីកាសម្រេចរឹបអូសសិទ្ធិលើបំណុលទាំងអស់ ឬ មួយផ្នែកដែលត្រូវបានហាមឃាត់ការរឹបអូសតាមបញ្ញត្តិនៃមាត្រា ៣៨២ (សិទ្ធិលើបំណុលដែលហាមឃាត់មិនឱ្យរឹបអូស) នៃក្រមនេះ ដោយពិចារណាទៅលើជីវភាព និង ស្ថានភាពផ្សេងៗរបស់កូនបំណុលនៃការអនុវត្ត និង ម្ចាស់បំណុលនៃការអនុវត្ត តាមពាក្យសុំបាន ។

២-ប្រសិនបើស្ថានភាពមានការផ្លាស់ប្តូរ តុលាការនៃការអនុវត្តអាចរឹបអូសសិទ្ធិលើបំណុល ដែលត្រូវបានលុបចោលដីកាសម្រេចរឹបអូសនោះតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើ ឬ អាចលុបចោលនូវដីកាសម្រេចរឹបអូសទាំងអស់ ឬ មួយផ្នែកតាមបញ្ញត្តិនៃកថាខណ្ឌដដែលនេះ តាមពាក្យសុំបាន ។

៣-ប្រសិនបើមានពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះ តុលាការនៃការអនុវត្ត អាចបង្គាប់ហាមឃាត់កូនបំណុលទី ៣ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ៤០២ (អត្ថន័យនៃការអនុវត្តចំពោះសិទ្ធិលើបំណុល និង តុលាការអនុវត្ត) នៃក្រមនេះ មិនឱ្យបង់ ឬ ផ្តល់តាវកាលិកផ្សេងទៀត ដោយឱ្យដាក់ប្រាតិភោគ ឬ មិនឱ្យដាក់ប្រាតិភោគបាន រហូតដល់ដីកាសម្រេចនោះមានអានុភាព ។

៤-ចំពោះដីកាសម្រេចលើកចោលពាក្យសុំឱ្យលុបចោលដីកាសម្រេចរឹបអូស តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ កថាខណ្ឌទី ២ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

## ផ្នែកទី ២
## ការអនុវត្តចំពោះចលនវត្ថុ

**មាត្រា ៣៨៤.-** ការចាប់ផ្តើមអនុវត្តចំពោះចលនវត្ថុ

១-ពាក្យសុំអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ត្រូវផ្ញើទៅអាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែង ដែលវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំស្ថិតនៅ ។

២-នៅក្នុងពាក្យសុំឱ្យអនុវត្តចំពោះចលនវត្ថុ ក្រៅពីចំណុចនីមួយៗដែលកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ៣៤៩ (របៀបដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ) នៃក្រមនេះ

ត្រូវសរសេរអំពីទីកន្លែងដែលចលនវត្ថុដែលត្រូវរឹបអូសនោះ ស្ថិតនៅ ។

៣-ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ នឹងត្រូវចាប់ផ្តើមដោយការរឹបអូសវត្ថុដែលជាកម្មវត្ថុដោយអាជ្ញាសាលា ។

៤-ចលនវត្ថុដែលបានកំណត់ក្នុងគន្លឹះនេះ មានរួមបញ្ចូលទាំងផលធម្មជាតិដែលមិនទាន់បំបែកពីដីនៅឡើយ ហើយអាចនឹងទទួលផលបានយ៉ាងច្បាស់នៅក្នុងអំឡុងពេល ១ (មួយ) ខែ ។

៥-ប្រសិនបើបានជួបប្រទះកូនបំណុលនៃការអនុវត្តនៅកន្លែងដែលត្រូវរឹបអូស អាជ្ញាសាលាត្រូវដាស់តឿនឱ្យកូនបំណុលនៃការអនុវត្តនោះសងបំណុលដោយស្ម័គ្រចិត្ត នៅមុនពេលចាប់ផ្តើមរឹបអូស ។

៦-ក្នុងការអនុវត្តចំពោះចលនវត្ថុ អាជ្ញាសាលាអាចទទួលសំណងនៃបំណុល និងសំណងសោហ៊ុយសម្រាប់ការអនុវត្ត ដើម្បីម្ចាស់បំណុលនៃការអនុវត្តបាន ។

**មាត្រា ៣៨៥.-** ការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត

១-ចំពោះការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត អាជ្ញាសាលាត្រូវធ្វើដោយកាន់កាប់ចលនវត្ថុនោះ ។

២-នៅពេលធ្វើការរឹបអូសដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាជ្ញាសាលាអាចចូលទៅក្នុងទីកន្លែងរស់នៅរបស់កូនបំណុលនៃការអនុវត្ត ឬ កន្លែងផ្សេងទៀតដែលកូនបំណុលនៃការអនុវត្តនោះកាន់កាប់ ហើយអាចធ្វើការឆែកឆេររកចលនវត្ថុដែលអាចរឹបអូសនោះបាន ។ ក្នុងករណីនេះ បើមានភាពចាំបាច់ អាជ្ញាសាលាអាចធ្វើការចាត់ចែងចាំបាច់ដើម្បីបើកទ្វារដែលបិទ ទូដែក និង ប្រអប់ផ្សេងទៀតបាន ។

៣-ពេលធ្វើការជ្រើសរើសចលនវត្ថុដែលត្រូវរឹបអូស អាជ្ញាសាលាត្រូវគិតពិចារណាដល់ផលប្រយោជន៍របស់កូនបំណុលនៃការអនុវត្ត ក្នុងល័ក្ខខ័ណ្ឌពុំធ្វើឱ្យមានការខូចខាតដល់ផលប្រយោជន៍របស់ម្ចាស់បំណុលនៃការអនុវត្ត ។

៤-ប្រសិនបើយល់ឃើញថាសមរម្យ អាជ្ញាសាលាអាចឱ្យកូនបំណុលនៃការអនុវត្តថែរក្សា គ្រប់គ្រងនូវចលនវត្ថុដែលត្រូវបានរឹបអូស ។ នៅក្នុងករណីនេះ ការរឹបអូសនោះមានអានុភាព លុះត្រាតែចលនវត្ថុដែលបានរឹបអូសនោះ ត្រូវបានបិទស្លាក ឬ ដាក់សញ្ញា

រឹបអូសដោយវិធីផ្សេងទៀត ។

៥-ក្នុងករណីដែលអាជ្ញាសាលាបានឱ្យកូនបំណុលនៃការអនុវត្តថែរក្សា គ្រប់គ្រងនូវចលនវត្ថុដែលបានរឹបអូស តាមបញ្ញត្តិនៃកថាខណ្ឌទី ៤ ខាងលើនេះ ប្រសិនបើយល់ឃើញថាសមរម្យ អាជ្ញាសាលាអាចអនុញ្ញាតឱ្យកូនបំណុលនៃការអនុវត្តប្រើចលនវត្ថុនោះបាន ។

៦-ប្រសិនបើយល់ថាចាំបាច់ អាជ្ញាសាលាអាចថែរក្សាគ្រប់គ្រងដោយខ្លួនឯងវិញនូវចលនវត្ថុដែលបានឱ្យកូនបំណុលនៃការអនុវត្តថែរក្សាគ្រប់គ្រង តាមបញ្ញត្តិនៃកថាខណ្ឌទី ៤ ខាងលើ ឬ អាចលុបចោលនូវការអនុញ្ញាតដែលបានធ្វើតាមបញ្ញត្តិនៃកថាខណ្ឌទី ៥ ខាងលើនេះបាន ។ បញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអាជ្ញាសាលាថែរក្សាគ្រប់គ្រងដោយខ្លួនឯងវិញ នូវចលនវត្ថុដែលបានឱ្យកូនបំណុលនៃការអនុវត្តថែរក្សា គ្រប់គ្រងនោះ ។

**មាត្រា ៣៨៦.-** ការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយបុគ្គលផ្សេងក្រៅពីកូនបំណុលនៃការអនុវត្ត

បញ្ញត្តិនៃកថាខណ្ឌទី ១ ទី ៣ ទី ៤ ទី ៥ និង ទី ៦ នៃមាត្រា ៣៨៥ (ការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយម្ចាស់បំណុលនៃការអនុវត្ត ឬ ចលនវត្ថុដែលកាន់កាប់ដោយតតិយជន ក្នុងករណីដែលតតិយជននោះមិនបដិសេធអំពីការប្រគល់ ។

**មាត្រា ៣៨៧.-** បទប្បញ្ញត្តិពិសេសស្តីពីរថយន្ត ជាអាទិ៍ ដែលបានចុះបញ្ជី

១-ប្រសិនបើរថយន្ត ឬ ទោចក្រយានយន្តដែលត្រូវបានរឹបអូស មានចុះបញ្ជីនៅក្នុងសៀវភៅចុះបញ្ជី អាជ្ញាសាលាត្រូវផ្ទុកផ្តាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចសរសេរនូវហេតុការណ៍នៃការរឹបអូស ចូលទៅក្នុងសៀវភៅចុះបញ្ជីនោះ ។

២-ការរឹបអូសចំពោះរថយន្ត ឬ ទោចក្រយានយន្តដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ នឹងត្រូវមានអានុភាព នៅពេលដែលបានសរសេរនូវហេតុការណ៍នៃការរឹបអូសនោះ ចូលទៅក្នុងសៀវភៅចុះបញ្ជី ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះចលនវត្ថុ ក្រៅពីរថយន្ត ឬ ទោចក្រយានយន្តដែលចាំបាច់ត្រូវចុះបញ្ជី ។

**មាត្រា ៣៨៨.–** ការរួមបញ្ចូលរឿងក្តី

១-ក្នុងករណីដែលមានពាក្យសុំឱ្យអនុវត្តចំពោះចលនវត្ថុបន្ថែមទៀត ទៅលើកូនបំណុលនៃការអនុវត្តដែលបានទទួលការរឹបអូសរួចមកហើយ នៅទីកន្លែងនៃការរឹបអូសដដែលនោះ បើមានចលនវត្ថុដែលមិនទាន់បានរឹបអូសនៅឡើយ អាជ្ញាសាលាត្រូវរឹបអូសចលនវត្ថុនោះ ហើយប្រសិនបើគ្មានចលនវត្ថុដែលអាចរឹបអូសបានទេនោះ អាជ្ញាសាលាត្រូវបញ្ជាក់ច្បាស់លាស់អំពីហេតុការណ៍នេះ ហើយត្រូវរួមបញ្ចូលរឿងក្តីអនុវត្តចំពោះចលនវត្ថុថ្មីនេះ និង រឿងក្តីអនុវត្តចំពោះចលនវត្ថុមុនជាមួយគ្នា ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលមានពាក្យសុំឱ្យអនុវត្តចំពោះចលនវត្ថុ ទៅលើកូនបំណុលនៃការអនុវត្តដែលបានទទួលការអនុវត្តរឹបអូសជាបណ្តោះអាសន្ន នៅទីកន្លែងនៃការអនុវត្តដដែលនោះ ។

២-បើរឿងក្តីអនុវត្តចំពោះចលនវត្ថុទាំងពីរ ត្រូវបានរួមបញ្ចូលគ្នា តាមបញ្ញត្តិនៃវាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១ ខាងលើនេះ ចលនវត្ថុដែលត្រូវបានរឹបអូសក្នុងរឿងក្តីពេលក្រោយនេះ ត្រូវចាត់ទុកថា បានរឹបអូសក្នុងរឿងក្តីពីមុន នៅពេលរួមបញ្ចូលរឿងក្តី ហើយពាក្យសុំនៃរឿងក្តីដែលធ្វើពេលក្រោយនេះ មានអានុភាពជាការទាមទារឱ្យចែកចំណែក ។ បើម្ចាស់បំណុលនៃការអនុវត្តមុន បានដកពាក្យសុំឱ្យអនុវត្តចំពោះចលនវត្ថុ ឬ នីតិវិធីដែលបានចាប់ផ្តើម ដោយពាក្យសុំនោះ ត្រូវបានផ្អាក ឬ ត្រូវបានលុបចោល ចលនវត្ថុដែលត្រូវបានរឹបអូសក្នុងរឿងក្តីមុននេះ ត្រូវចាត់ទុកថា បានរឹបអូសដើម្បីរឿងក្តីនៅពេលក្រោយ នៅពេលរួមបញ្ចូលរឿងក្តី ។

៣-បើរឿងក្តីនៃការអនុវត្តរឹបអូសជាបណ្តោះអាសន្ន និង រឿងក្តីនៃការអនុវត្តចំពោះចលនវត្ថុ ត្រូវបានរួមបញ្ចូលគ្នា តាមបញ្ញត្តិនៃវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ ខាងលើនេះ ចលនវត្ថុដែលត្រូវបានអនុវត្តរឹបអូសជាបណ្តោះអាសន្ន ត្រូវចាត់ទុកថា បានរឹបអូសក្នុងរឿងក្តីនៃការអនុវត្តចំពោះចលនវត្ថុ នៅពេលរួមបញ្ចូលរឿងក្តី ហើយពាក្យសុំនៃរឿងក្តីនៃការអនុវត្តរឹបអូសជាបណ្តោះអាសន្ននេះ មានអានុភាពជាការទាមទារឱ្យចែកចំណែក ។ បើម្ចាស់បំណុលនៃការអនុវត្ត បានដកពាក្យសុំឱ្យអនុវត្តចំពោះចលនវត្ថុ ឬ នីតិវិធីដែលបានចាប់ផ្តើម ដោយពាក្យសុំនោះ ត្រូវបានលុបចោល ចលនវត្ថុដែលត្រូវបានរឹបអូសក្នុងរឿងក្តីនៃការអនុវត្តចំពោះចលនវត្ថុនេះ ត្រូវចាត់ទុកថា បានអនុវត្តរឹបអូសជាបណ្តោះអាសន្ន

ក្នុងរឿងក្តីនៃការអនុវត្តរឹបអូសជាបណ្តោះអាសន្ន នៅពេលរួមបញ្ចូលរឿងក្តី ។

៤-នៅពេលដែលបានរួមបញ្ចូលរឿងក្តី អាជ្ញាសាលាត្រូវជូនដំណឹងអំពីហេតុការណ៍នោះទៅម្ចាស់បំណុលនៃការអនុវត្ត ម្ចាស់បំណុលនៃការអនុវត្តរឹបអូសជាបណ្តោះអាសន្ន និង កូនបំណុលនៃការអនុវត្ត ។

**មាត្រា ៣៨៩.-** ទំហំដែលការរឹបអូសមានអានុភាព

ការរឹបអូសមានអានុភាពទៅលើផលធម្មជាតិដែលកើតចេញមកពីចលនវត្ថុដែលត្រូវបានរឹបអូស ។

**មាត្រា ៣៩០.-** ដីកាសម្រេចបង្គាប់ឱ្យប្រគល់ចលនវត្ថុដែលត្រូវបានរឹបអូស

១-បើចលនវត្ថុត្រូវបានរឹបអូសរួចហើយ ហើយបែរជាធ្លាក់ទៅនៅក្រោមការកាន់កាប់របស់តតិយជន សាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅ អាចបង្គាប់ឱ្យតតិយជននោះប្រគល់ចលនវត្ថុដែលត្រូវបានរឹបអូសនោះទៅអាជ្ញាសាលាបាន ដោយដីកាសម្រេច តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត ។

២-ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើក្នុងអំឡុងពេល ១ (មួយ) សប្តាហ៍ គិតពីថ្ងៃដែលបានដឹងថា ចលនវត្ថុដែលត្រូវបានរឹបអូសនោះកាន់កាប់ដោយតតិយជន ។

៣-ចំពោះដីកាសម្រេចអំពីពាក្យសុំនៃកថាខណ្ឌទី ១ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

៤-ដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំត្រូវអនុវត្តឡើយ បើហួសអំឡុងពេល ២ (ពីរ) សប្តាហ៍ គិតចាប់ពីថ្ងៃដែលបានជូនដំណឹងទៅឱ្យអ្នកដាក់ពាក្យសុំ ។

៥-ដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ អាចអនុវត្តបានទោះនៅមុនពេលបញ្ជូនដីកាសម្រេចនោះទៅឱ្យតតិយជនដែលកាន់កាប់ចលនវត្ថុដែលត្រូវបានរឹបអូសក៏ដោយ ។

៦-សោហ៊ុយដែលចាំបាច់សម្រាប់ដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវចាត់ជាសោហ៊ុយសម្រាប់ផលប្រយោជន៍រួម ចំពោះនីតិវិធីអនុវត្តដោយបង្ខំចំពោះចលនវត្ថុនេះ ។

**មាត្រា ៣៩១.-** ការហាមឃាត់មិនឱ្យរឹបអូសហួសប្រមាណ

១-ការរឹបអូសចលនវត្ថុ មិនត្រូវធ្វើឱ្យហួសកម្រិតចាំបាច់សម្រាប់សំណងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្ត និង សោហ៊ុយសម្រាប់ការអនុវត្តទេ ។

២-ប្រសិនបើបានដឹងច្បាស់ថាការរឹបអូស លើសពីកម្រិតដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ នៅក្រោយពេលដែលបានរឹបអូសរួចហើយ អាជ្ញាសាលាត្រូវលុបចោលការរឹបអូស ត្រឹមផ្នែកដែលបានហួសកម្រិតនោះ ។

**មាត្រា ៣៩២.-** ការហាមឃាត់មិនឱ្យរឹបអូសក្នុងករណីដែលប៉ាន់ប្រមាណឃើញថា គ្មានចំនួនសេសសល់

១-អាជ្ញាសាលាមិនត្រូវរឹបអូសឡើយ ប្រសិនបើប៉ាន់ប្រមាណឃើញថា ចំនួនទឹកប្រាក់ដែលបានមកពីការលក់ចលនវត្ថុដែលត្រូវបានរឹបអូសនោះ គ្មានចំនួនសេសសល់ក្រោយពីបានសងសោហ៊ុយសម្រាប់នីតិវិធីហើយ ។

២-អាជ្ញាសាលាត្រូវលុបចោលការរឹបអូស ប្រសិនបើប៉ាន់ប្រមាណឃើញថា ចំនួនទឹកប្រាក់ដែលបានមកពីការលក់ចលនវត្ថុ ដែលត្រូវបានរឹបអូសនោះ គ្មានចំនួនសេសសល់ក្រោយពីបានសងសិទ្ធិលើបំណុលដែលមានអាទិភាពជាងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្ត និង សោហ៊ុយសម្រាប់នីតិវិធីហើយ ។

**មាត្រា ៣៩៣.-** ការលុបចោលនូវការរឹបអូស ក្នុងករណីដែលប៉ាន់ប្រមាណឃើញថា មិនអាចលក់បាន

អាជ្ញាសាលាអាចលុបចោលការរឹបអូសចលនវត្ថុដែលត្រូវបានរឹបអូសហើយនោះបាន ក្នុងល័ក្ខខ័ណ្ឌដែលបានអនុវត្តការលក់តាមវិធីសមរម្យក៏ដោយ ក៏នៅតែមិនអាចលក់បាន ហើយប៉ាន់ប្រមាណឃើញថា នៅតែមិនអាចលក់បាន នៅពេលអនាគត ។

**មាត្រា ៣៩៤.-** ការទាមទារឱ្យចែកចំណែកពីអ្នកមានឯកសិទ្ធិ ជាអាទិ៍

បុគ្គលដែលមានឯកសិទ្ធិ ឬ មានសិទ្ធិលើការបញ្ចាំ អាចទាមទារឱ្យចែកចំណែកបាន ដោយដាក់ឯកសារដែលបញ្ជាក់អំពីសិទ្ធិនោះ ។

**មាត្រា ៣៩៥.–** វិធីលក់

១-ដើម្បីលក់ចលនវត្ថុដែលត្រូវបានរឹបអូស អាជ្ញាសាលាត្រូវលក់តាមវិធីលក់ឡាយឡុង ដោយផ្ទាល់មាត់ ឬ ដោយដាក់ស្រោមសំបុត្រ ។

២-ទោះបីមានបញ្ញត្តិដូចកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ បើយល់ឃើញថាសមរម្យ ដោយគិតពិចារណាអំពីប្រភេទ និង ចំនួននៃចលនវត្ថុ ជាអាទិ៍ អាជ្ញាសាលាអាចអនុវត្តការលក់ចលនវត្ថុដែលត្រូវបានរឹបអូសនោះ ក្រៅពីរបៀបលក់តាមវិធីលក់ឡាយឡុងដោយផ្ទាល់មាត់ ឬ ដោយដាក់ស្រោមសំបុត្រ ឬ អាចឱ្យបុគ្គលផ្សេងពីអាជ្ញាសាលា អនុវត្តការលក់ចលនវត្ថុដែលត្រូវបានរឹបអូសនោះបាន ដោយទទួលការអនុញ្ញាតពីសាលាដំបូងដែលខ្លួនស្ថិតនៅ ។

៣-អាជ្ញាសាលាត្រូវជូនដំណឹងជាសាធារណៈអំពីចលនវត្ថុដែលត្រូវដាក់លក់ និង វិធីលក់ចលនវត្ថុនោះ ដោយបិទប្រកាស នៅកន្លែងសម្រាប់បិទប្រកាសរបស់តុលាការ ។

៤-កូនបំណុលនៃការអនុវត្ត មិនអាចធ្វើសំណើទិញចលនវត្ថុនោះបានឡើយ ។

៥-ប្រសិនបើអាជ្ញាសាលាអនុញ្ញាតឱ្យទិញ អ្នកទិញត្រូវបង់ថ្លៃភ្លាមៗ ។

៦-ប្រសិនបើចលនវត្ថុនោះត្រូវបានដាក់លក់ម្តងទៀត ដោយសារអ្នកទិញមិនបានបង់ថ្លៃ អ្នកសុំទិញមុននេះ មិនអាចធ្វើសំណើទិញម្តងទៀតបានឡើយ ។

៧-បើបានរឹបអូសចលនវត្ថុដែលមានតម្លៃខ្ពស់ អាជ្ញាសាលាត្រូវជ្រើសតាំងអ្នកវាយតម្លៃ ហើយឱ្យអ្នកវាយតម្លៃនោះ វាយតម្លៃចលនវត្ថុនោះ ។

**មាត្រា ៣៩៦.–** ការរក្សាសណ្តាប់ធ្នាប់នៅកន្លែងលក់

ចំពោះជនណាដែលធ្វើសកម្មភាពរំខានកុំឱ្យការអនុវត្តការលក់ធ្វើឡើងដោយត្រឹមត្រូវ ដូចជាបានធ្វើឱ្យរំខានដល់ជនដទៃទៀតក្នុងការធ្វើសំណើទិញ ឬ បានឃុបឃិតដើម្បីបញ្ចុះតម្លៃលក់ដោយមិនត្រឹមត្រូវ ឬ ចំពោះជនដែលបានប្រើឱ្យធ្វើសកម្មភាពនោះ អាជ្ញាសាលាអាចកម្រិតមិនឱ្យជននោះចូលកន្លែងលក់ ឬ អាចដេញជននោះចេញពីកន្លែងលក់ ឬ អាចមិនឱ្យស្នើសុំទិញបាន ។

**មាត្រា ៣៩៧.–** ការលក់នៅក្នុងពេលដែលការអនុវត្តកំពុងត្រូវបានផ្អាក

១-ក្នុងករណីដែលមានការដាក់ឯកសារដែលបានកំណត់នៅក្នុងចំណុច ក ឬ ចំណុច

ខ កថាខណ្ឌទី ២ នៃមាត្រា ៣៧០ (ការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ) នៃក្រមនេះ ប្រសិនបើមានការបារម្ភថា តម្លៃលក់ចលនវត្ថុដែលត្រូវបានរឹបអូស នឹងចុះថោកខ្លាំង ឬ បើត្រូវចំណាយសោហ៊ុយច្រើនមិនសមរម្យសម្រាប់រក្សាទុកនូវចលនវត្ថុនោះ អាជ្ញាសាលាអាចដាក់ចលនវត្ថុដែលត្រូវបានរឹបអូសនោះលក់បាន ។

២-បើបានលក់ចលនវត្ថុដែលត្រូវបានរឹបអូស តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ អាជ្ញាសាលាត្រូវផ្ញើទុកប្រាក់ដែលបានមកពីការលក់នោះនៅសាលាដំបូងដែលខ្លួនស្ថិតនៅ ។

**មាត្រា ៣៩៨.–** វិសាលភាពនៃម្ចាស់បំណុលដែលត្រូវទទួលចំណែកជាប្រាក់

ម្ចាស់បំណុលដែលត្រូវទទួលចំណែក គឺបុគ្គលដែលបានកំណត់ក្នុងចំណុចនីមួយៗខាងក្រោមនេះ :

ក-ម្ចាស់បំណុលនៃការអនុវត្ត ។

ខ-ម្ចាស់បំណុលដែលបានទាមទារឱ្យចែកចំណែក រហូតដល់ពេលដែលអាជ្ញាសាលាបានទទួលការប្រគល់ប្រាក់ ចំពោះប្រាក់ដែលបានមកពីការលក់ ។

គ-ម្ចាស់បំណុលដែលបានទាមទារឱ្យចែកចំណែក រហូតដល់ពេលដែលបានរឹបអូសប្រាក់ ចំពោះប្រាក់ដែលត្រូវបានរឹបអូស ។

**មាត្រា ៣៩៩.–** ការចែកចំណែកដោយអាជ្ញាសាលា

១-ក្នុងករណីដែលម្ចាស់បំណុលមានតែម្នាក់ ឬ ក្នុងករណីដែលម្ចាស់បំណុលមានច្រើននាក់ ហើយប្រាក់ដែលបានពីការលក់ ឬ ប្រាក់ដែលត្រូវបានរឹបអូស អាចសងចំពោះសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនីមួយៗ និង សោហ៊ុយសម្រាប់ការអនុវត្តទាំងអស់បាន អាជ្ញាសាលាត្រូវចែកចំណែក ចំពោះម្ចាស់បំណុល ហើយត្រូវប្រគល់ប្រាក់នៅសេសសល់ទៅឱ្យកូនបំណុលនៃការអនុវត្តវិញ ។

២-ក្រៅពីករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើបានទទួលប្រាក់ដែលបានពីការលក់ ឬ បានរឹបអូសប្រាក់ អាជ្ញាសាលាត្រូវកំណត់ថ្ងៃក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ជាថ្ងៃដែលត្រូវពិភាក្សាគ្នាអំពីការចែកចំណែកនៃប្រាក់ដែលបានមកពីការលក់ ឬ ប្រាក់ដែលត្រូវបានរឹបអូស ហើយត្រូវជូនដំណឹងពីពេលវេលា និង ទីកន្លែង ទៅម្ចាស់

បំណុលនីមួយៗ ។ បើម្ចាស់បំណុលនីមួយៗបានពិភាក្សាគ្នាដាច់ស្រេចហើយ អាជ្ញាសាលា ត្រូវចែកចំណែកតាមការពិភាក្សានោះ ។

៣-ក្នុងករណីដែលមានការដាក់ឯកសារដែលបានកំណត់ចាប់ពីចំណុច ក រហូតដល់ ចំណុច ឆ កថាខណ្ឌទី ១ នៃមាត្រា ៣៧០ (ការផ្អាក និង ការលុបចោលការអនុវត្តដោយ បង្ខំ) នៃក្រមនេះ ក្រោយពេលអ្នកទិញបានបង់ថ្លៃហើយ បើមានម្ចាស់បំណុលដែលត្រូវ ទទួលចំណែកផ្សេងទៀត ក្រៅពីម្ចាស់បំណុលនៃការអនុវត្ត អាជ្ញាសាលាត្រូវចែកចំណែកឱ្យ ម្ចាស់បំណុលនោះ ។

៤-ក្នុងករណីដែលមានការដាក់ឯកសារដែលបានកំណត់នៅក្នុងចំណុច ក ឬ ចំណុច ខ កថាខណ្ឌទី ២ នៃមាត្រា ៣៧០ (ការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ) នៃ ក្រមនេះ ក្រោយពេលអ្នកទិញបានបង់ថ្លៃហើយ អាជ្ញាសាលាក៏ត្រូវចែកចំណែកនោះផង ដែរ ។

៥-ចំពោះការចែកចំណែក សិទ្ធិលើបំណុលដែលកំណត់ពេលពិតប្រាកដពុំទាន់មក ដល់ ត្រូវចាត់ទុកថា កំណត់ពេលសងនោះបានចូលមកដល់ហើយ ។

**មាត្រា ៤០០.-** ការធ្វើប្រាក់ទុកនៅតុលាការដោយអាជ្ញាសាលា

១-ក្នុងករណីដែលចែកចំណែក តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ កថាខណ្ឌទី ២ នៃ មាត្រា ៣៩៩ (ការចែកចំណែកដោយអាជ្ញាសាលា) នៃក្រមនេះ ប្រសិនបើសិទ្ធិលើបំណុល របស់ម្ចាស់បំណុលដែលត្រូវទទួលចំណែកនោះ មានមូលហេតុដូចបានកំណត់នៅក្នុងចំណុច ខាងក្រោមនេះ អាជ្ញាសាលាត្រូវដាក់ប្រាក់ដែលស្មើនឹងចំណែកនោះ ផ្ញើទុកនៅសាលាដំបូង ដែលខ្លួនស្ថិតនៅ ហើយត្រូវរាយការណ៍អំពីហេតុការណ៍នោះ ទៅសាលាដំបូងនោះ :

ក-បើសិទ្ធិលើបំណុលនោះមានភ្ជាប់នូវល័ក្ខខ័ណ្ឌបង្អង់ ឬ កំណត់ពេលមិនពិត ប្រាកដ ។

ខ-បើសិទ្ធិលើបំណុលនោះជាសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការរឹបអូស ជាបណ្ដោះអាសន្ន ។

គ-បើមានការដាក់ឯកសារដែលបានកំណត់នៅក្នុងចំណុច ក កថាខណ្ឌទី ២ នៃមាត្រា ៣៧០ (ការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ) នៃក្រមនេះ ។

ឃ-បើបានដាក់ឯកសារចម្លងយថាភូតនៃសេចក្ដីសម្រេច ដែលហាមឃាត់ការអនុវត្តមួយរយៈនៃឯកសិទ្ធិ ឬ សិទ្ធិលើការបញ្ចាំដែលទាក់ទងនឹងសិទ្ធិលើបំណុលនោះ ។

២-អាជ្ញាសាលាត្រូវធ្វើទុកនូវទឹកប្រាក់ស្មើនឹងចំណែកចំពោះម្ចាស់បំណុល ដែលមិនបានបង្ហាញខ្លួនដើម្បីទទួលចំណែក នៅសាលាដំបូងដែលខ្លួនស្ថិតនៅ ។

**មាត្រា ៤០១.-** ការជូនដំណឹងទៅសាលាដំបូង

ប្រសិនបើការពិភាក្សាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ៣៩៩ (ការចែកចំណែកដោយអាជ្ញាសាលា) នៃក្រមនេះ ធ្វើមិនបានដាច់ស្រេចទេ អាជ្ញាសាលាត្រូវរាយការណ៍អំពីហេតុការណ៍នេះ ទៅសាលាដំបូងដែលខ្លួនស្ថិតនៅ ។

## ផ្នែកទី ៣
## ការអនុវត្តចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត

**មាត្រា ៤០២.-** អត្ថន័យនៃការអនុវត្តចំពោះសិទ្ធិលើបំណុល និង តុលាការអនុវត្ត

១-ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងប្រាក់ ឬ ប្រគល់ចលនវត្ថុ ត្រូវហៅថា ការអនុវត្តចំពោះសិទ្ធិលើបំណុល ។

២-កូនបំណុលនៃសិទ្ធិលើបំណុលដែលនឹងត្រូវរឹបអូស ត្រូវហៅថា កូនបំណុលទី ៣ ។

៣-ក្នុងការអនុវត្តចំពោះសិទ្ធិលើបំណុល សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងរបស់កូនបំណុលនៃការអនុវត្តដែលបានកំណត់នៅក្នុងមាត្រា ៨ (សមត្ថកិច្ចសាលាជម្រះក្តីដែលបានកំណត់ទៅតាមលំនៅឋាន ជាអាទិ៍) នៃក្រមនេះ គឺជាតុលាការអនុវត្តដែលមានសមត្ថកិច្ច ហើយក្នុងករណីដែលគ្មានកន្លែងខាងលើនោះ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងរបស់កូនបំណុលទី៣ដែលបានកំណត់នៅក្នុងមាត្រា ៨ គឺជាតុលាការអនុវត្តដែលមានសមត្ថកិច្ចវិញ ។

៤-ក្នុងករណីដែលដីកាសម្រេចរឹបអូសបានចេញម្តងទៀតចំពោះសិទ្ធិលើបំណុលដែលត្រូវបានរឹបអូស បើតុលាការអនុវត្តដែលបានចេញដីកាសម្រេចរឹបអូសនោះខុសគ្នា តុលាការអនុវត្តអាចផ្ទេររឿងក្តីនោះ ទៅតុលាការអនុវត្តផ្សេងបាន ។

**មាត្រា ៤០៣.–** ដីកាសម្រេចរឹបអូស

១-ពាក្យសុំឱ្យអនុវត្តចំពោះសិទ្ធិលើបំណុល ត្រូវដាក់ទៅតុលាការអនុវត្ត ។

២-នៅក្នុងពាក្យសុំឱ្យអនុវត្តចំពោះសិទ្ធិលើបំណុល ក្រៅពីចំណុចដែលបានកំណត់នៅក្នុងចំណុចនីមួយៗនៃកថាខណ្ឌទី ២ មាត្រា ៣៤៩ (របៀបដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ) នៃក្រមនេះ ត្រូវបញ្ជាក់អំពីកូនបំណុលទី៣ផងដែរ ។

៣-ក្នុងករណីដែលសុំឱ្យអនុវត្តចំពោះផ្នែកណាមួយនៃសិទ្ធិលើបំណុល ម្ចាស់បំណុលនៃការអនុវត្ត ត្រូវសរសេរបញ្ជាក់ឱ្យបានច្បាស់លាស់នូវទំហំនៃការអនុវត្តនោះ ក្នុងពាក្យសុំឱ្យអនុវត្តចំពោះសិទ្ធិលើបំណុល ។

៤-ការអនុវត្តចំពោះសិទ្ធិលើបំណុល ត្រូវចាប់ផ្ដើម ដោយដីកាសម្រេចរឹបអូសរបស់តុលាការអនុវត្ត ។

៥-ក្នុងដីកាសម្រេចរឹបអូស តុលាការអនុវត្តត្រូវហាមមិនឱ្យកូនបំណុលនៃការអនុវត្តធ្វើការប្រមូលសិទ្ធិលើបំណុល ឬ ការចាត់ចែងផ្សេងទៀត ហើយហាមមិនឱ្យកូនបំណុលទី ៣ សងបំណុលឱ្យកូនបំណុលនៃការអនុវត្តនោះ ។

៦-ដីកាសម្រេចរឹបអូសត្រូវធ្វើឡើង ដោយមិនត្រូវសួរកូនបំណុលនៃការអនុវត្ត និង កូនបំណុលទី ៣ ទេ ។

៧-ដីកាសម្រេចរឹបអូសត្រូវបញ្ជូនទៅឱ្យកូនបំណុលនៃការអនុវត្ត និង កូនបំណុលទី ៣ ។

៨-អានុភាពនៃការរឹបអូស ត្រូវកើតឡើងនៅពេលដែលដីកាសម្រេចរឹបអូសត្រូវបានបញ្ជូនទៅដល់កូនបំណុលទី ៣ ។

៩-នៅពេលដែលដីកាសម្រេចរឹបអូសត្រូវបានបញ្ជូនទៅកូនបំណុលនៃការអនុវត្ត និង កូនបំណុលទី ៣ ក្រឡាបញ្ជីត្រូវជូនដំណឹងអំពីការណ៍នោះ និង ថ្ងៃ ខែ ឆ្នាំនៃការបញ្ជូននោះ ទៅម្ចាស់បំណុលនៃការអនុវត្ត ។

១០-បើដីកាសម្រេចរឹបអូសចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូ-តែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតដែលបានចុះបញ្ជី បានបង្កើតអានុភាព តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត ក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ច ចុះបញ្ជីបញ្ជាក់ថា សិទ្ធិលើបំណុលនោះត្រូវបានរឹបអូសហើយ ។

១១-ចំពោះសេចក្តីសម្រេចអំពីពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូស អាចប្តឹងជំទាស់បាន ។

**មាត្រា ៤០៤.–** ទំហំនៃការរឹបអូស

១-តុលាការអនុវត្ត អាចចេញដីកាសម្រេចរឹបអូសនូវសិទ្ធិលើបំណុលទាំងអស់ដែលត្រូវរឹបអូសនោះ ។

២-ប្រសិនបើតម្លៃនៃសិទ្ធិលើបំណុលដែលបានរឹបអូស លើសតម្លៃនៃសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្ត និង សោហ៊ុយសម្រាប់ការអនុវត្ត នោះតុលាការអនុវត្តមិនត្រូវរឹបអូសសិទ្ធិលើបំណុលផ្សេងទៀតឡើយ ។

៣-ក្នុងករណីដែលសិទ្ធិលើបំណុលមួយភាគត្រូវបានរឹបអូស ឬ ត្រូវបានទទួលការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ប្រសិនបើដីកាសម្រេចរឹបអូសផ្សេងទៀតបានចេញ ដោយលើសភាគដែលសល់នោះទៀត អានុភាពនៃការរឹបអូស ឬ ការអនុវត្តរឹបអូសជាបណ្តោះ-អាសន្ននីមួយៗនោះ មានចំពោះសិទ្ធិលើបំណុលទាំងអស់នោះ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអានុភាពនៃការរឹបអូស ក្នុងករណីដែលសិទ្ធិលើបំណុលទាំងអស់ត្រូវបានរឹបអូស ឬ បានទទួលការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ហើយមានដីកាសម្រេចរឹបអូសផ្សេងទៀតដែលរឹបអូសមួយភាគនៃសិទ្ធិលើបំណុលនោះ ។

**មាត្រា ៤០៥.–** ការដាស់តឿនឱ្យកូនបំណុលទី៣ធ្វើសេចក្តីថ្លែងការណ៍

១-ប្រសិនបើមានពាក្យសុំពីម្ចាស់បំណុលនៃការអនុវត្ត នៅពេលបញ្ជូនដីកាសម្រេចរឹបអូស តុលាការអនុវត្តត្រូវដាស់តឿនឱ្យកូនបំណុលទី៣ធ្វើសេចក្តីថ្លែងការណ៍អំពីចំណុចដែលបានកំណត់ខាងក្រោមនេះ ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ចាប់ពីថ្ងៃបញ្ជូនដីកាសម្រេចរឹបអូស:

ក-អត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិលើបំណុលដែលត្រូវបានរឹបអូសនោះ ហើយប្រភេទចំនួនទឹកប្រាក់ និង ខ្លឹមសារនៃសិទ្ធិលើបំណុល បើមានសិទ្ធិនោះ ។

ខ-អត្ថិភាព ឬ នត្ថិភាពនៃឆន្ទៈសង និង ទំហំនៃការសង ឬ មូលហេតុដែលមិនសង ។

គ-បើមាន សញ្ញាណនៃជនដែលមានអាទិភាពជាងម្ចាស់បំណុលនៃការអនុវត្ត

៣-ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ត្រូវភ្ជាប់ជាមួយឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត និង ឯកសារខាងក្រោមនេះ :

ក-ចំពោះអចលនវត្ថុដែលត្រូវបានចុះបញ្ជី ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជី និង ក្នុងករណីដែលជនដទៃក្រៅពីកូនបំណុលនៃការអនុវត្ត ត្រូវបានចុះនៅក្នុងសៀវភៅចុះបញ្ជី ថាជាកម្មសិទ្ធិករ ឯកសារដែលបញ្ជាក់ថា អចលនវត្ថុនោះជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត ។

ខ-ចំពោះដីដែលមិនបានចុះបញ្ជី ឯកសារដែលបញ្ជាក់ថា ដីនោះជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត ។

**មាត្រា ៤១៨.-** តុលាការអនុវត្ត

ក្នុងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ តុលាការដែលបានកំណត់ខាងក្រោមនេះគឺជាតុលាការអនុវត្តដែលមានសមត្ថកិច្ច:

ក-បើយកដី ឬ អាគារដែលបានចុះបញ្ជី ជាកម្មវត្ថុ គឺសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងនោះ ។

ខ-បើយកចំណែកនៃកម្មសិទ្ធិអវិភាគលើដី ឬ លើអាគារដែលបានចុះបញ្ជី ឬ សិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគដែលបានចុះបញ្ជី ឬ ចំណែកនៃសិទ្ធិទាំងនេះដែលជាសិទ្ធិរួមជាកម្មវត្ថុ គឺសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលត្រូវចុះបញ្ជី ។

**មាត្រា ៤១៩.-** ដីកាសម្រេចចាប់ផ្តើម ជាអាទិ៍

១-នៅពេលចាប់ផ្តើមនីតិវិធីនៃការលក់ដោយបង្ខំ តុលាការអនុវត្តត្រូវចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ ហើយត្រូវប្រកាសអំពីការរឹបអូសអចលនវត្ថុ ដើម្បីម្ចាស់បំណុលនៃការអនុវត្ត ក្នុងដីកាសម្រេចចាប់ផ្តើមនេះ ។

២-ដីកាសម្រេចចាប់ផ្តើមដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបញ្ជូនទៅឱ្យកូនបំណុលនៃការអនុវត្ត ។

៣-ចំពោះដីកាសម្រេចលើកចោលពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ អាចប្តឹងជំទាស់បាន ។

នៃការលក់ដោយបង្ខំ ។

**មាត្រា ៤២៨.–** ការផ្អាកផ្ដាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូស

១-បើពាក្យសុំឱ្យលក់ដោយបង្ខំត្រូវបានដកចេញ ឬ បើអានុភាពនៃដីកាសម្រេចលុបចោលនីតិវិធីលក់ដោយបង្ខំ បានកើតឡើង ក្រឡាបញ្ជីត្រូវផ្អាកផ្ដាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចលុបការចុះបញ្ជីអំពីការរឹបអូស ដែលពាក់ព័ន្ធនឹងដីកាសម្រេចចាប់ផ្ដើមនោះ ។

២-សោហ៊ុយចាំបាច់សម្រាប់ការផ្អាកផ្ដាក់ដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ជាបន្ទុករបស់ម្ចាស់បំណុលនៃការអនុវត្តដែលបានដកពាក្យសុំចេញ ឬ ម្ចាស់បំណុលនៃការអនុវត្តដែលបានទទួលដីកាសម្រេចលុបចោលនោះ ។

**មាត្រា ៤២៩.–** ការចាត់ចែងការរក្សាការពារ

១-ប្រសិនបើកូនបំណុល ឬ អ្នកកាន់កាប់អចលនវត្ថុបានប្រព្រឹត្តអំពើដែលធ្វើឱ្យតម្លៃអចលនវត្ថុចុះថយគួរឱ្យកត់សំគាល់ ឬ ធ្វើឱ្យមានការលំបាកដល់ការលក់ ឬ ការប្រគល់អចលនវត្ថុ ឬ បើមានការបារម្ភថា អ្នកនោះនឹងប្រព្រឹត្តអំពើខាងលើនេះ តុលាការអនុវត្តអាចហាមឃាត់ជនដែលបានប្រព្រឹត្តអំពើទាំងនេះ ឬ ជនដែលត្រូវគេមានការបារម្ភថា នឹងប្រព្រឹត្តអំពើទាំងនេះ មិនឱ្យប្រព្រឹត្តអំពើនោះ ឬ បង្គាប់ឱ្យជននោះធ្វើសកម្មភាពណាមួយជាកំណត់ ឬ បង្គាប់ឱ្យជននោះលះបង់ការកាន់កាប់អចលនវត្ថុហើយឱ្យអាជ្ញាសាលាថែរក្សាគ្រប់គ្រងអចលនវត្ថុនោះបាន ដោយដីកាសម្រេច តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ឬ អ្នកទិញ ដោយឱ្យដាក់ ឬ មិនឱ្យដាក់ប្រាតិភោគ ។ ប៉ុន្តែ មានតែករណីដែលអ្នកកាន់កាប់អចលនវត្ថុ មិនអាចយកមូលហេតុគតិយុត្តនៃសិទ្ធិកាន់កាប់ តតាំងនឹងអ្នកទិញទេ ទើបអាចបង្គាប់ឱ្យជននោះប្រគល់អចលនវត្ថុឱ្យអាជ្ញាសាលា ដើម្បីឱ្យថែរក្សាគ្រប់គ្រងបាន ។

២-ក្នុងករណីចេញដីកាសម្រេចដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ចំពោះអ្នកកាន់កាប់ផ្សេងពីកូនបំណុល តុលាការអនុវត្តត្រូវសួរជននោះ ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានភាពបន្ទាន់ចាំបាច់ត្រូវចេញដីកាសម្រេចនោះ ។

៣-បើស្ថានភាពមានការប្រែប្រួល តុលាការអនុវត្តអាចលុបចោល ឬ កែប្រែដីកា

សម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ តាមពាក្យសុំបាន ។

៤-ចំពោះដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ឬ ទី ៣ ខាងលើនេះ អាចប្ដឹងជំទាស់បាន ។

៥-ដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ទោះជានៅមុនពេលដែលត្រូវបានបញ្ជូនទៅភាគីម្ខាងទៀតក៏ដោយ ក៏អាចអនុវត្តបានដែរ ។

៦-សោហ៊ុយចាំបាច់សម្រាប់ពាក្យសុំ ឬ ការអនុវត្តដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវចាត់ទុកជាសោហ៊ុយសម្រាប់ផលប្រយោជន៍រួមក្នុងនីតិវិធីនៃការលក់ដោយបង្ខំចំពោះអចលនវត្ថុនោះ ។

## កថាភាគទី ២
## លំនាំខណ្ឌនៃការលក់

**មាត្រា ៤៣០.–** ការវាយតម្លៃ

១-តុលាការអនុវត្តត្រូវជ្រើសតាំងអ្នកវាយតម្លៃ និង បង្គាប់ឱ្យវាយតម្លៃអចលនវត្ថុ ដោយផ្អែកលើការស្រាវជ្រាវអំពីសណ្ឋាននៃអចលនវត្ថុ ទំនាក់ទំនងនៃការកាន់កាប់ និង ស្ថានភាពបច្ចុប្បន្នឯទៀត ។

២-ដើម្បីសុំជំនួយពីអាជ្ញាសាលាយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៣៣៨ (ការធានាក្នុងការបំពេញមុខនាទីរបស់អាជ្ញាសាលា ជាអាទិ៍) នៃក្រមនេះ អ្នកវាយតម្លៃត្រូវទទួលការអនុញ្ញាតពីតុលាការអនុវត្ត ។

៣-នៅពេលស្រាវជ្រាវដើម្បីវាយតម្លៃ អ្នកវាយតម្លៃអាចចូលទៅកាន់អចលនវត្ថុ ឬ អាចសួរសំណួរ ឬ ទាមទារឱ្យបង្ហាញឯកសារ ចំពោះកូនបំណុលនៃការអនុវត្ត ឬ តតិយជនដែលកាន់កាប់អចលនវត្ថុនោះបាន ។

៤-បើមានភាពចាំបាច់ អាជ្ញាសាលាដែលអ្នកវាយតម្លៃបានសុំជាជំនួយ តាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៣៣៨ (ការធានាក្នុងការបំពេញមុខនាទីរបស់អាជ្ញាសាលា ជាអាទិ៍) នៃក្រមនេះ អាចធ្វើការចាត់ចែងចាំបាច់ដើម្បីបើកទ្វារដែលបិទបាន នៅក្នុងករណីដែលអ្នកវាយតម្លៃចូលទៅកាន់អចលនវត្ថុ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ ។

ដើម្បីបើកទ្វារដែលបិទបាន ។

**មាត្រា ៤៣៥.–** វិធានការក្នុងករណីដែលមានការបារម្ភថាគ្មានសំណល់

១-ប្រសិនបើយល់ឃើញថា តម្លៃលក់អប្បបរមានៃអចលនវត្ថុ ក្រោយពីបានសងសោហ៊ុយសម្រាប់នីតិវិធីហើយ គ្មានលទ្ធភាពសល់ទេនោះ តុលាការអនុវត្តត្រូវជូនដំណឹងអំពីការណ៍នោះទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត ។

២-តុលាការអនុវត្តត្រូវលុបចោលនូវនីតិវិធីនៃការលក់ដោយបង្ខំ ដែលទាក់ទងនឹងពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត បើម្ចាស់បំណុលនៃការអនុវត្ត មិនបានធ្វើសកម្មភាពដែលបានកំណត់នៅក្នុងចំណុចនីមួយៗខាងក្រោមនេះ :

ក-សំណើថា ខ្លួននឹងទិញអចលនវត្ថុក្នុងតម្លៃស្នើសុំ ក្នុងករណីដែលគ្មានសំណើទិញក្នុងតម្លៃដែលឡើងដល់តម្លៃស្នើសុំនោះ ។ ប៉ុន្តែ សំណើនោះ ត្រូវធ្វើឡើងក្នុងអំឡុងពេល ១ (មួយ) សប្តាហ៍ គិតចាប់ពីថ្ងៃដែលបានទទួលដំណឹងដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ហើយតម្លៃស្នើសុំនោះ ត្រូវលើសពីតម្លៃប៉ាន់ប្រមាណនៃសោហ៊ុយសម្រាប់នីតិវិធី ។

ខ-ការដាក់ប្រាក់ធានាដែលស្មើនឹងតម្លៃស្នើសុំដែលបានកំណត់នៅក្នុងចំណុច ក ខាងលើនេះ ។

## កថាភាគទី ៣
## វិធីលក់

**មាត្រា ៤៣៦.–** វិធីលក់ ជាអាទិ៍

១-ការលក់អចលនវត្ថុ ត្រូវអនុវត្តតាមវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ។

២-តុលាការអនុវត្តអាចកំណត់វិធីលក់ ផ្សេងពីវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ តែក្នុងករណីដែលពុំអាចលក់តាមវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ។

៣-ប្រសិនបើលក់តាមវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់

តុលាការអនុវត្តត្រូវកំណត់កាលបរិច្ឆេទ និង ទីកន្លែងលក់ ហើយត្រូវឱ្យអាជ្ញាសាលាអនុ-វត្តការលក់នោះ ។

៤-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ក្រឡាបញ្ជីត្រូវផ្សាយជាសាធារណៈនូវសញ្ញាណនៃអចលនវត្ថុដែលត្រូវលក់ តម្លៃលក់អប្បបរមា ព្រមទាំងកាលបរិច្ឆេទ និង ទីកន្លែងលក់ ។

៥-បញ្ញត្តិនៃមាត្រា ៣៩៦ (ការរក្សាសណ្ដាប់ធ្នាប់នៅកន្លែងលក់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ។

**មាត្រា ៤៣៧.–** ការធានាលើសំណើទិញ

១-ជនដែលបម្រុងនឹងធ្វើសំណើទិញអចលនវត្ថុ ត្រូវដាក់ប្រាក់ធានាដែលមានចំនួនស្មើនឹងចំនួន ១ ភាគ ១០ (មួយភាគដប់) នៃតម្លៃលក់អប្បបរមា ។ ប៉ុន្តែ បើយល់ឃើញថាសមរម្យ តុលាការអនុវត្តអាចកំណត់ចំនួននៃប្រាក់ធានា លើសពីចំនួននេះបាន ។

២-ប្រសិនបើមានសំណើទិញពីបុគ្គលក្រៅពីអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា តុលាការអនុវត្តត្រូវសងភ្លាមនូវប្រាក់ធានាដែលបានដាក់តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ក្រោយពេលបញ្ចប់ការលក់ដែលធ្វើឡើង ដោយផ្អែកលើបញ្ញត្តិនៃមាត្រា ៤៣៦ (វិធីលក់ជាអាទិ៍) នៃក្រមនេះ ។

**មាត្រា ៤៣៨.–** ការហាមឃាត់មិនឱ្យកូនបំណុលនៃការអនុវត្តធ្វើសំណើទិញ

កូនបំណុលនៃការអនុវត្តពុំអាចធ្វើសំណើទិញបានឡើយ ។

**មាត្រា ៤៣៩.–** ការកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ជាអាទិ៍

១-បើការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់បានបញ្ចប់ អាជ្ញាសាលាត្រូវប្រកាសការបញ្ចប់កាលបរិច្ឆេទនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ក្រោយពេលបានកំណត់អ្នកស្នើសុំទិញ ក្នុងតម្លៃអតិបរមា និង បានប្រកាសនូវនាម ឬ នាមករណ៍របស់អ្នកទិញ និង ថ្លៃលក់ឡាយឡុងនោះ ។

២-បើអ្នកដេញថ្លៃដោយស្រោមសំបុត្រ ដែលបានធ្វើសំណើទិញក្នុងតម្លៃអតិបរមា

កម្ពុជា គឺ ឯកសារដែលបញ្ជាក់ថា នាវានោះជានាវាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ មាត្រា ៤៥៤ (អត្ថន័យនៃនាវា ជាអាទិ៍) នៃក្រមនេះ និង ឯកសារបញ្ជាក់ថា នាវានោះស្ថិតនៅជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត ។

**មាត្រា ៤៥៦.–** តុលាការអនុវត្ត

ចំពោះការអនុវត្តដោយបង្ខំចំពោះនាវា សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលនាវាស្ថិតនៅ នៅពេលចេញដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ មានសមត្ថកិច្ចជាតុលាការអនុវត្ត ។

**មាត្រា ៤៥៧.–** ដីកាសម្រេចចាប់ផ្ដើម ជាអាទិ៍

១-នៅពេលចាប់ផ្ដើមនីតិវិធីនៃការលក់ដោយបង្ខំ តុលាការអនុវត្តត្រូវចេញដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ ហើយត្រូវបង្គាប់ឱ្យអាជ្ញាសាលាដកហូតយកលិខិតបញ្ជាក់សញ្ជាតិនាវានោះ ជាអាទិ៍ មកប្រគល់ជូនតុលាការអនុវត្ត ។

២-ក្នុងដីកាសម្រេចចាប់ផ្ដើមដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការអនុវត្តត្រូវប្រកាស អំពីការរឹបអូសនាវានោះជាប្រយោជន៍របស់ម្ចាស់បំណុលនៃការអនុវត្ត ហើយត្រូវហាមឃាត់កូនបំណុលនៃការអនុវត្ត ចំពោះការចេញដំណើរនៃនាវានោះ ។

៣-ដីកាសម្រេចចាប់ផ្ដើមដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបញ្ជូនទៅឱ្យកូនបំណុលនៃការអនុវត្ត ។

៤-បើបានចេញដីកាសម្រេចចាប់ផ្ដើមដែលយោងទៅតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ចំពោះនាវាកម្ពុជាដែលបានចុះបញ្ជីហើយ ក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីអំពីការរឹបអូសដែលពាក់ព័ន្ធនឹងដីកាសម្រេចចាប់ផ្ដើមនោះជាបន្ទាន់ ។

៥-អានុភាពនៃការរឹបអូស នឹងកើតឡើងនៅពេលបានធ្វើការបញ្ជូនដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ។ ប៉ុន្តែ បើការចុះបញ្ជីអំពីការរឹបអូសត្រូវបានធ្វើមុនការបញ្ជូនដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ អានុភាពនោះនឹងកើតឡើងនៅពេលបានចុះបញ្ជី ។

៦-បើអាជ្ញាសាលាបានដកហូតយកលិខិតបញ្ជាក់សញ្ញាតិនាវា ជាអាទិ៍ នៅមុនពេលបញ្ជូនដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ ឬ នៅមុនពេលចុះបញ្ជីអំពីការរឹបអូសអានុភាពនៃការរឹបអូសនោះ កើតឡើងនៅពេលដកហូត ។

៧-ចំពោះដីកាសម្រេចលើកចោលពាក្យសុំការលក់ដោយបង្ខំនេះ អាចប្ដឹងជំទាស់បាន ។

**មាត្រា ៤៥៨.-** ការកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក និង ការផ្លាស់ប្ដូរពេលកំណត់នោះ

១-ក្នុងករណីដែលអានុភាពនៃការរឹបអូសដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្ខំ បានកើតឡើង តុលាការអនុវត្តត្រូវកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក ។

២-បើមិនបានចេញដីកាសម្រេចអនុញ្ញាតឱ្យលក់ នៅក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែកទេ តុលាការអនុវត្តអាចផ្លាស់ប្ដូរកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែកនោះបាន ។

**មាត្រា ៤៥៩.-** ដីកាសម្រេចបង្គាប់ឱ្យប្រគល់លិខិតបញ្ជាក់សញ្ញាតិនាវា ជាអាទិ៍ នៅមុនពេលដាក់ពាក្យសុំ

១-ក្នុងករណីដែលមានការបារម្ភថា នឹងមានការលំបាកខ្លាំងក្នុងការអនុវត្តដោយបង្ខំចំពោះនាវា បើមិនដកហូតយកលិខិតបញ្ជាក់សញ្ញាតិនាវានោះ ជាអាទិ៍ នៅមុនការដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះនាវាទេ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលនាវានោះត្រូវបានចុះបញ្ជី អាចចេញដីកាសម្រេចបង្គាប់ឱ្យកូនបំណុលនៃការអនុវត្ត ប្រគល់លិខិតបញ្ជាក់សញ្ញាតិនាវា ជាអាទិ៍ ទៅឱ្យអាជ្ញាសាលាបាន តាមពាក្យសុំ ។ បើនាវានោះពុំបានចុះបញ្ជីទេ ឬ បើមានស្ថានភាពជាបន្ទាន់ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលនាវានោះស្ថិតនៅ អាចចេញដីកាសម្រេចនេះបាន ។

២-ដើម្បីដាក់ពាក្យសុំតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវបង្ហាញនូវឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត ហើយត្រូវធ្វើសេចក្ដីបញ្ជាក់ដំបូងអំពីមូលហេតុដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ នេះ ។

៣-ដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបញ្ជូនទៅឱ្យកូនបំណុលនៃការអនុវត្ត ។

៤-ចំពោះដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

៥-ចំពោះដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ទោះនៅមុនពេលបញ្ជូនទៅឱ្យកូនបំណុលនៃការអនុវត្តក៏ដោយ ក៏អាចអនុវត្តបានដែរ ។ សោហ៊ុយចាំបាច់សម្រាប់ការអនុវត្តនេះ ត្រូវចាត់ជាសោហ៊ុយសម្រាប់ផលប្រយោជន៍រួម ក្នុងនីតិវិធីនៃការលក់ដោយបង្ខំ ។

៦-ដីកាសម្រេចបង្គាប់ឱ្យប្រគល់លិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ទៅឱ្យអាជ្ញាសាលាដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំត្រូវអនុវត្តឡើយ បើហួសអំឡុងពេល ២ (ពីរ) សប្តាហ៍ គិតចាប់ពីថ្ងៃដែលបានជូនដំណឹងទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត ។

៧-បើម្ចាស់បំណុលនៃការអនុវត្តមិនបានដាក់លិខិតដែលបញ្ជាក់ថា ខ្លួនបានដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះនាវា នៅក្នុងអំឡុងពេល ៥ (ប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃដែលបានទទួលការប្រគល់លិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍នោះទេ អាជ្ញាសាលាត្រូវសងលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍នោះ ទៅឱ្យកូនបំណុលនៃការអនុវត្តវិញ ។

**មាត្រា ៥៦០.–** ការជ្រើសតាំងអ្នកថែរក្សាគ្រប់គ្រង ជាអាទិ៍

១-បើទទួលស្គាល់ថាចាំបាច់ តុលាការអនុវត្តអាចជ្រើសតាំងអ្នកថែរក្សាគ្រប់គ្រងចំពោះនាវាដែលត្រូវបានចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្តបាន ។

២-តុលាការអនុវត្តត្រូវត្រួតពិនិត្យអ្នកថែរក្សាគ្រប់គ្រង ។ អ្នកថែរក្សាគ្រប់គ្រងត្រូវបំពេញមុខនាទីរបស់ខ្លួន ដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ។ នៅក្នុងករណីដែលអ្នកថែរក្សាគ្រប់គ្រងបានបញ្ចប់ភារកិច្ចនោះ អ្នកនោះត្រូវរាយការណ៍អំពីការគណនានូវចំណូលចំណាយក្នុងការថែរក្សាគ្រប់គ្រងទៅតុលាការអនុវត្ត ដោយគ្មានការយឺតយ៉ាវ ។

ក-ឯកសារចម្លងយថាភូតនៃសេចក្ដីសម្រេចដែលកំណត់ការបង្គាប់ឱ្យផ្អាកការអនុវត្តសិទ្ធិប្រាតិភោគមួយរយៈ ។

ខ-ឯកសារដែលសរសេរថា ម្ចាស់បំណុលបានទទួលសំណងនៃសិទ្ធិលើបំណុលដែលត្រូវបានធានាដោយសិទ្ធិប្រាតិភោគ ឬ បានយល់ព្រមពន្យារពេលត្រូវសងចំពោះសិទ្ធិលើបំណុលនោះ នៅក្រោយពេលលិខិតអនុវត្តដែលបានកំណត់នៅក្នុងមាត្រា ៤៩៦ (លិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគ) នៃក្រមនេះ ត្រូវបានបង្កើត ។

ប៉ុន្តែ ចំពោះករណីដែលបានកំណត់នៅក្នុងចំណុច ខ ខាងលើ អានុភាពផ្អាក មានត្រឹមតែ២ (ពីរ) ខែប៉ុណ្ណោះ ។

៣-បញ្ញត្តិនៃមាត្រា ៣៧០ (ការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ) នៃក្រមនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះការអនុវត្តសិទ្ធិប្រាតិភោគ ។

៤-បញ្ញត្តិនៃមាត្រា ៣៤៥ (បណ្ដឹងជំទាស់ចំពោះដីកាសម្រេចលុបចោល ជាអាទិ៍) នៃក្រមនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលលុបចោលការចាត់ចែងការអនុវត្ត ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ៤៩៩.–** ការលក់ដោយបង្ខំដោយសិទ្ធិឃាត់ទុក និង ការលក់ដោយបង្ខំដើម្បីប្ដូរជាប្រាក់

ការលក់ដោយបង្ខំដោយសិទ្ធិឃាត់ទុក និង ការលក់ដោយបង្ខំដើម្បីប្ដូរជាប្រាក់ ដោយយោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ឬ ច្បាប់ផ្សេងទៀត ត្រូវអនុវត្តតាមបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីនេះ ដែលកំណត់អំពីការលក់ដោយបង្ខំដើម្បីអនុវត្តសិទ្ធិប្រាតិភោគ ។

## ផ្នែកទី ២
## ការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ

**មាត្រា ៥០០.–** ល័ក្ខខ័ណ្ឌនៃការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ

ទោះបីជាក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្តមិនដាក់លិខិតអនុវត្តដែលបានកំណត់នៅក្នុងមាត្រា ៤៩៦ (លិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគ) នៃក្រមនេះ ទៅអាជ្ញាសាលាក៏ដោយ បើបានដាក់ចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគ ឬ បានដាក់ឯកសារ

ដែលបញ្ជាក់ថា អ្នកកាន់កាប់ចលនវត្ថុបានយល់ព្រមចំពោះការរឹបអូស ក៏ការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុអាចចាប់ផ្តើមបានដែរ ។

**មាត្រា ៥០១.-** ការតវ៉ាចំពោះការអនុវត្ត នូវការរឹបអូសចលនវត្ថុ

បើការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុត្រូវបានចាប់ផ្តើម ដោយយោងតាមបញ្ញត្តិនៃមាត្រា ៥០០ (ល័ក្ខខ័ណ្ឌនៃការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ) នៃក្រមនេះ កម្មសិទ្ធិករនៃចលនវត្ថុ ឬ កូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានា អាចយកនត្ថិភាព ឬ ការរលត់នៃសិទ្ធិប្រាតិភោគ មកធ្វើជាមូលហេតុ ក្នុងពាក្យសុំតវ៉ាចំពោះការអនុវត្តនូវការរឹបអូសនោះបាន ។

**មាត្រា ៥០២.-** ចំណុចដែលត្រូវសរសេរ ក្នុងពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ

ក្នុងពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ អ្នកដាក់ពាក្យសុំត្រូវសរសេរនូវចំណុចខាងក្រោមនេះ :

ក-សញ្ញាណនៃម្ចាស់បំណុលនៃការអនុវត្ត កម្មសិទ្ធិករនៃចលនវត្ថុដែលជាកូនបំណុលនៃការអនុវត្ត កូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានា និង អ្នកតំណាង ។

ខ-សញ្ញាណនៃសិទ្ធិប្រាតិភោគ និង សិទ្ធិលើបំណុលដែលត្រូវបានធានា ។

គ-សញ្ញាណនៃចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តសិទ្ធិប្រាតិភោគ និង ទីកន្លែងនៃចលនវត្ថុនោះ ។

ឃ-ហេតុការណ៍ និង ទំហំនៃផ្នែកនៃសិទ្ធិលើបំណុលដែលត្រូវបានធានា បើធ្វើការអនុវត្តសិទ្ធិប្រាតិភោគ ចំពោះផ្នែកមួយនៃសិទ្ធិលើបំណុលដែលត្រូវបានធានានោះ ។

**មាត្រា ៥០៣.-** បញ្ញត្តិស្តីពីការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ដែលមិនត្រូវអនុវត្ត

បញ្ញត្តិនៃមាត្រា ៣៨០ (ចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស) មាត្រា ៣៨១ (ការប្តូរទំហំនៃចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស) និង មាត្រា ៣៩១ (ការហាមឃាត់មិនឱ្យរឹបអូសហួសប្រមាណ) នៃក្រមនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះនីតិវិធីនៃការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ ។

៤-ចំពោះដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

៥-ចំពោះដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ ទោះជានៅមុនពេលបញ្ជូនទៅឱ្យភាគីម្ខាងទៀតក៏ដោយ ក៏អាចអនុវត្តបានដែរ ។

**មាត្រា ៥២២.-** ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ

បញ្ញត្តិនៃផ្នែកទី ៤ (ការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ) ជំពូកទី ៣ គន្ថីទី ៦ នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការលក់ដោយបង្ខំដែលជាការអនុវត្តសិទ្ធិប្រាតិភោគដែលយកនាវាជាកម្មវត្ថុ លើកលែងតែមានបញ្ញត្តិពិសេស ។

**មាត្រា ៥២៣.-** បញ្ញត្តិដែលត្រូវបានបកស្រាយ

ឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ៤៥៩ (ដីកាសម្រេចបង្គាប់ឱ្យប្រគល់លិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ នៅមុនពេលដាក់ពាក្យសុំ) នៃក្រមនេះ ត្រូវបានបកស្រាយថា ឯកសារដែលបានកំណត់នៅក្នុងមាត្រា ៤៩៦ (លិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគ) ។

## ជំពូកទី ៤
## ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលគ្មានគោលបំណងឱ្យសងជាប្រាក់

**មាត្រា ៥២៤.-** ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ជាអាទិ៍

១-ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ឬ នាវាឬវត្ថុផ្សេងទៀតដែលមនុស្សរស់នៅក្នុងនោះ ត្រូវធ្វើតាមវិធីដែលអាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើកន្លែងដែលវត្ថុដែលជាកម្មវត្ថុស្ថិតនៅ រំលាយការកាន់កាប់វត្ថុដែលជាកម្មវត្ថុរបស់កូនបំណុលនៃការអនុវត្ត ហើយធ្វើឱ្យម្ចាស់បំណុលនៃការអនុវត្ត ទទួលបាននូវការកាន់កាប់នោះ ។

២-ការអនុវត្តដោយបង្ខំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចធ្វើបាន លុះត្រាតែម្ចាស់បំណុលនៃការអនុវត្ត ឬ អ្នកតំណាងរបស់ម្ចាស់បំណុលនៃការអនុវត្ត

នោះ បានបង្ហាញខ្លួននៅកន្លែងអនុវត្ត ។

៣-នៅពេលធ្វើការអនុវត្តដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាជ្ញាសាលាអាចចូលទៅក្នុងអចលនវត្ថុ នាវា ឬ វត្ថុផ្សេងទៀតដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត ហើយបើចាំបាច់ អាចធ្វើការចាត់ចែងជាចាំបាច់ដើម្បីបើកទ្វារដែលបិទនោះ ។

៤-នៅក្នុងការអនុវត្តដោយបង្ខំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាជ្ញាសាលាត្រូវដកចេញនូវចលនវត្ថុដែលមិនមែនជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំនោះ ហើយត្រូវប្រគល់ចលនវត្ថុទាំងនោះទៅឱ្យកូនបំណុលនៃការអនុវត្ត ឬ អ្នកតំណាងរបស់កូនបំណុលនោះ ឬ ញាតិនៅជាមួយឬអ្នកបម្រើឬអ្នកផ្សេងដែលធ្វើការនៅទីនោះដែលមានការយល់ដឹងសមរម្យ ។ ក្នុងករណីនេះ ប្រសិនបើមិនអាចប្រគល់ចលនវត្ថុនោះទៅឱ្យជនទាំងឡាយដែលបានរៀបរាប់ខាងលើនេះបានទេ អាជ្ញាសាលាត្រូវថែរក្សាគ្រប់គ្រងចលនវត្ថុនោះ ។

៥-សោហ៊ុយសម្រាប់ថែរក្សាគ្រប់គ្រងតាមបញ្ញត្តិនៃកថាខណ្ឌទី ៤ ខាងលើនេះ ត្រូវចាត់ជាសោហ៊ុយសម្រាប់ការអនុវត្ត ។

៦-បើមិនអាចប្រគល់ចលនវត្ថុដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ ឱ្យទៅជនដូចបញ្ញត្តិក្នុងកថាខណ្ឌនោះទេ អាជ្ញាសាលាអាចលក់ចលនវត្ថុនោះ តាមវិធីលក់នៃការអនុវត្តចំពោះចលនវត្ថុបាន ។

៧-បើបានលក់ចលនវត្ថុតាមបញ្ញត្តិនៃកថាខណ្ឌទី ៦ ខាងលើនេះ អាជ្ញាសាលាត្រូវដកចេញពីចំនួនទឹកប្រាក់ដែលបានមកពីការលក់នូវសោហ៊ុយដែលបានចំណាយក្នុងការលក់ និង ការថែរក្សាគ្រប់គ្រង ហើយត្រូវធ្វើទុកប្រាក់ដែលនៅសេសសល់នោះ នៅសាលាដំបូងដែលខ្លួនស្ថិតនៅ ។

៨-បើបានបញ្ចប់ការអនុវត្តដោយបង្ខំដូចបញ្ញត្តិក្នុងកថាខណ្ឌទី ១ និង ទី ៤ ខាងលើនេះហើយ អាជ្ញាសាលាត្រូវជូនដំណឹងនោះទៅឱ្យកូនបំណុលនៃការអនុវត្ត ។

**មាត្រា ៥២៥.-** ការអនុវត្តដោយបង្ខំឱ្យប្រគល់ចលនវត្ថុ

១-ការអនុវត្តដោយបង្ខំឱ្យប្រគល់ចលនវត្ថុក្រៅពីចលនវត្ថុ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៥២៤ (ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ជាអាទិ៍) នៃក្រម

នេះ ត្រូវធ្វើតាមវិធីដែលអាជ្ញាសាលានៃសាលាដំបូង ដែលមានសមត្ថកិច្ចលើកន្លែងដែលវត្ថុដែលជាកម្មវត្ថុស្ថិតនៅ ដកយកចលនវត្ថុពីកូនបំណុលនៃការអនុវត្ត ហើយប្រគល់ចលនវត្ថុនោះ ទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត ។

២-ប្រសិនបើម្ចាស់បំណុលនៃការអនុវត្ត ឬ អ្នកតំណាងពុំបានបង្ហាញខ្លួននៅទីកន្លែងធ្វើការអនុវត្តដោយបង្ខំ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះទេ អាជ្ញាសាលាអាចល្បូរការអនុវត្តដោយបង្ខំនោះបាន បើទទួលស្គាល់ថា ពុំអាចជៀសវាងបានដោយគិតពិចារណាលើប្រភេទ និង ចំនួន ជាអាទិ៍ នៃចលនវត្ថុដែលពាក់ព័ន្ធនោះ ។

៣-ក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្តដោយបង្ខំ ឬ អ្នកតំណាងពុំបានបង្ហាញខ្លួន នៅទីកន្លែងធ្វើការអនុវត្តដោយបង្ខំឱ្យប្រគល់ចលនវត្ថុទេ បើបានដកយកចលនវត្ថុនោះពីកូនបំណុលនៃការអនុវត្ត អាជ្ញាសាលាត្រូវថែរក្សាគ្រប់គ្រងចលនវត្ថុនោះ ។

៤-បញ្ញត្តិនៃកថាខណ្ឌទី ៦ នៃមាត្រា ៣៨៤ (ការចាប់ផ្តើមអនុវត្តចំពោះចលនវត្ថុ) កថាខណ្ឌទី ២ នៃមាត្រា ៣៨៥ (ការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត) និង បញ្ញត្តិចាប់ពីកថាខណ្ឌទី ៤ រហូតដល់ទី ៨ នៃមាត្រា ៥២៤ (ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ជាអាទិ៍) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តដោយបង្ខំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ៥២៦.-** ការអនុវត្តដោយបង្ខំឱ្យប្រគល់ ក្នុងករណីវត្ថុដែលជាកម្មវត្ថុ ត្រូវបានកាន់កាប់ដោយតតិយជន

១-ក្នុងករណីដែលតតិយជនកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ ហើយតតិយជននោះមានករណីយកិច្ចត្រូវប្រគល់វត្ថុនោះឱ្យទៅកូនបំណុលនៃការអនុវត្ត ការអនុវត្តដោយបង្ខំឱ្យប្រគល់វត្ថុនេះ ត្រូវធ្វើតាមវិធីដែលតុលាការអនុវត្តរឹបអូសសិទ្ធិទាមទារឱ្យប្រគល់របស់កូនបំណុលនៃការអនុវត្តដែលមានចំពោះតតិយជននោះ ហើយចេញដីកាសម្រេចអនុញ្ញាតឱ្យម្ចាស់បំណុលនៃការអនុវត្ត អនុវត្តសិទ្ធិទាមទារនោះ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ៣ និង ទី ៤ នៃមាត្រា ៤០២ (អត្ថន័យនៃការអនុវត្តចំពោះសិទ្ធិលើបំណុល និង តុលាការអនុវត្ត) មាត្រា ៤០៣ (ដីកាសម្រេចរឹបអូស) មាត្រា ៤០៥ (ការដាស់តឿនឱ្យកូនបំណុលទី៣ធ្វើសេចក្តីថ្លែងការណ៍) មាត្រា ៤០៦ (ការប្រគល់លិខិត

បញ្ញាក់សិទ្ធិលើបំណុល) ព្រមទាំងកថាខណ្ឌទី ១ ទី ២ និង ទី ៤ នៃមាត្រា ៤១០ (ការប្រមូលបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តដោយបង្ខំ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ៥២៧.–** ការអនុវត្តជំនួស

១-ក្នុងករណីដែលកាតព្វកិច្ចមានខ្លឹមសារដែលឱ្យធ្វើសកម្មភាពណាមួយ ហើយអាចឱ្យតតិយជនធ្វើជំនួសកូនបំណុលបាន ការអនុវត្តដោយបង្ខំចំពោះកាតព្វកិច្ចនោះ ត្រូវធ្វើតាមវិធីដែលតុលាការអនុវត្តចេញដីកាសម្រេចអនុញ្ញាតឱ្យម្ចាស់បំណុលនៃការអនុវត្ត ឱ្យតតិយជនបំពេញសកម្មភាពនោះជំនួស ដោយប្រើសោហ៊ុយរបស់កូនបំណុលនៃការអនុវត្តតាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត ។

២-តុលាការអនុវត្តដែលបញ្ញត្តិនៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ គឺតុលាការដែលបានកំណត់នៅក្នុងចំណុចនីមួយៗ តាមការបែងចែកនៃលិខិតអនុវត្តដែលបានកំណត់ក្នុងចំណុច ក ឬ ចំណុច គ កថាខណ្ឌទី ៣ នៃមាត្រា ៣៦៣ (បណ្ដឹងតវ៉ាចំពោះការទាមទារ) នៃក្រមនេះ ។

៣-បើចេញដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការអនុវត្តត្រូវសួរកូនបំណុលនៃការអនុវត្ត ។

៤-បើចេញដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការអនុវត្តអាចបង្គាប់ឱ្យកូនបំណុលនៃការអនុវត្ត បង់សោហ៊ុយដែលត្រូវការចាំបាច់សម្រាប់បំពេញសកម្មភាពដែលបានកំណត់ក្នុងដីកាសម្រេចនោះ ទៅឱ្យម្ចាស់បំណុលនៃការអនុវត្តជាមុនបានតាមពាក្យសុំ ។

៥-ចំពោះសេចក្ដីសម្រេចអំពីពាក្យសុំឱ្យអនុវត្តដោយបង្ខំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ឬ អំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ ខាងលើនេះ អាចប្ដឹងជំទាស់បាន ។

៦-បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៣៣៨ (ការធានាក្នុងការបំពេញមុខនាទីរបស់អាជ្ញាសាលា ជាអាទិ៍) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអនុវត្តដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

៧-បញ្ញត្តិចាប់ពីកថាខណ្ឌទី ១ រហូតដល់កថាខណ្ឌទី ៦ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលកាតព្វកិច្ចមានខ្លឹមសារដែលមិនឱ្យធ្វើសកម្មភាពណាមួយ ហើយម្ចាស់បំណុលនៃការអនុវត្តទាមទារឱ្យដកយកចេញនូវលទ្ធផលនៃសកម្មភាពផ្ទុយនឹងករណីយកិច្ចមិនត្រូវធ្វើសកម្មភាព ទាមទារឱ្យបង្កើតការសាងសង់ ដើម្បីបង្ការសកម្មភាពផ្ទុយនោះ ឬ ទាមទារមធ្យោបាយផ្សេងទៀតដែលសមរម្យ ដោយប្រើសោហ៊ុយរបស់កូនបំណុលនៃការអនុវត្ត ។

**មាត្រា ៥២៨.–** វិធានបង្ខំដោយប្រយោល

១-ការអនុវត្តដោយបង្ខំចំពោះកាតព្វកិច្ចដែលមានគោលបំណងឱ្យធ្វើ ឬ មិនឱ្យធ្វើសកម្មភាពណាមួយ ក៏អាចធ្វើបានតាមវិធីដែលតុលាការអនុវត្តចេញដីកាសម្រេចបង្គាប់ឱ្យកូនបំណុលនៃការអនុវត្ត បង់នូវចំនួនទឹកប្រាក់ជាកំណត់ដែលទទួលស្គាល់ថាសមរម្យដើម្បីធានាការអនុវត្តកាតព្វកិច្ច ទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត ស្របទៅតាមអំឡុងពេលនៃការយឺតយ៉ាវ ឬ កំណត់អំឡុងពេលដែលទទួលស្គាល់ថាសមរម្យដើម្បីអនុវត្តកាតព្វកិច្ច ហើយបង្គាប់ឱ្យកូនបំណុលនៃការអនុវត្ត បង់នូវចំនួនទឹកប្រាក់ជាកំណត់ដែលទទួលស្គាល់ថាសមរម្យដើម្បីធានាការអនុវត្តកាតព្វកិច្ច ទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត ដោយភ្លាមៗ បើពុំបានអនុវត្តក្នុងអំឡុងពេលនោះ ។

២-តុលាការអនុវត្តដែលបញ្ញត្តិនៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ គឺតុលាការដែលកំណត់នៅក្នុងចំណុចនីមួយៗ តាមការបែងចែកនៃលិខិតអនុវត្តដែលបានកំណត់ក្នុងចំណុច ក ឬ ចំណុច គ កថាខណ្ឌទី ៣ នៃមាត្រា ៣៦៣ (បណ្ដឹងតវ៉ាចំពោះការទាមទារ) នៃក្រមនេះ ។

៣-បើមានការផ្លាស់ប្ដូរស្ថានភាព តុលាការអនុវត្តអាចផ្លាស់ប្ដូរដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត ឬរបស់កូនបំណុលនៃការអនុវត្តបាន ។

៤-បើចេញដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ ទី ៣ ខាងលើនេះ តុលាការអនុវត្តត្រូវសួរភាគីម្ខាងទៀតនៃអ្នកដាក់ពាក្យសុំ ។

៥-ក្នុងករណីដែលមានការបង់ប្រាក់ដែលត្រូវបានបង្គាប់តាមបញ្ញត្តិនៃកថាខណ្ឌទី ១

មាត្រា ៤៦២ (ការអនុញ្ញាតឱ្យនាវាធ្វើដំណើរ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផង ដែរ ចំពោះការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន តាមរបៀបដែលបង្គាប់ឱ្យដកហូតលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ។

**មាត្រា ៥៦៩.–** ការលុបចោលការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ដោយធ្វើប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន

១-បើកូនបំណុលបានធ្វើប្រាក់ស្មើនឹងចំនួនប្រាក់ដែលបានកំណត់តាមបញ្ញត្តិនៃមាត្រា ៥៤៧ (ប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន) នៃក្រមនេះ នៅតុលាការ តុលាការអនុវត្តរក្សាការពារ ឬ សាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅ ត្រូវលុបចោលនូវការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៣៨៥ (បណ្ដឹងជំទាស់ចំពោះដីកាសម្រេចលុបចោល ជាអាទិ៍) នៃក្រមនេះ ដែលត្រូវយកអនុវត្តដូចគ្នា នៅក្នុងមាត្រា ៥៦៤ (ការអនុវត្តដូចគ្នា តាមបញ្ញត្តិនៃគន្ថីទី ៦) ក៏ដោយ ក៏ដីកាសម្រេចដែលធ្វើឡើង តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មានអានុភាពភ្លាមៗដែរ ។

**មាត្រា ៥៧០.–** ការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន

ការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន ត្រូវអនុវត្តតាមវិធីដូចគ្នានឹងវិធីអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ឬវិធីអនុវត្តដោយបង្ខំ ។

**មាត្រា ៥៧១.–** អានុភាពនៃការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់

១-បើដីកាសម្រេចដែលហាមឃាត់មិនឱ្យកូនបំណុលផ្ទេរការកាប់កាប់វត្ថុ និង បង្គាប់ឱ្យកូនបំណុលប្រគល់វត្ថុទៅអាជ្ញាសាលា ដោយដកហូតការកាន់កាប់នោះ ហើយបង្គាប់ឱ្យអាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុនោះ ដើម្បីរក្សាការពារសិទ្ធិទាមទារឱ្យប្រគល់វត្ថុនោះ ត្រូវបានចេញ អាជ្ញាសាលាត្រូវប្រកាសជាសាធារណៈថា កូនបំណុលត្រូវបានហាមឃាត់ការផ្ទេរការកាប់កាប់វត្ថុនោះ ហើយអាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុនោះ ដោយបិទលិខិតប្រកាសជាសាធារណៈ តាមរបៀបដែលពុំងាយបកចេញ ឬ តាមរបៀបសមរម្យផ្សេងទៀត ។

២-បើការចាត់ចែងជាបណ្ដោះអាសន្នដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបានអនុវត្ត ម្ចាស់បំណុលអាចធ្វើការអនុវត្តដោយបង្ខំឱ្យប្រគល់វត្ថុបាន ដោយផ្អែកលើលិខិតអនុវត្តនៃអង្គសេចក្ដី ។ ប៉ុន្តែ ម្ចាស់បំណុលអាចអនុវត្តបានតែចំពោះជនដែលកាន់កាប់វត្ថុនោះ ដោយដឹងថា ការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ននោះត្រូវបានធ្វើហើយ ។

៣-ជនដែលកាន់កាប់វត្ថុដែលពាក់ព័ន្ធក្រោយពេលការអនុវត្តចាត់ចែងជាបណ្ដោះ-អាសន្ន ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបានសន្មតថា កាន់កាប់វត្ថុនោះ ដោយដឹងថា ការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ននោះ ត្រូវបានធ្វើហើយ ។

## គន្ថីទី ៩

## អវសានប្បញ្ញត្តិ

### ជំពូកតែមួយ

### អវសានប្បញ្ញត្តិ

**មាត្រា ៥៨៧.–** ការអនុវត្តក្រមនេះ

ក្រោយពីចូលជាធរមាន ក្រមនេះត្រូវផ្សព្វផ្សាយរយៈពេល ១ (មួយ) ឆ្នាំ ទើបអនុវត្ត ។

**មាត្រា ៥៨៨.–** ការធ្វើឱ្យនិរាករណ៍នូវច្បាប់ផ្សេង ជាអាទិ៍

១-ច្បាប់ដែលបានកំណត់ដូចខាងក្រោមនេះ ត្រូវបាត់បង់អានុភាព ចាប់ពីថ្ងៃដែលក្រមនេះត្រូវបានអនុវត្ត :

ក-ច្បាប់ស្តីអំពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឱ្យប្រើដោយក្រឹត្យលេខ ៥១ ក្រ ចុះថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ១៩៩២ ។

ខ-ច្បាប់ស្តីពីប្រាក់ប្រដាប់ក្តី ដែលត្រូវបានប្រកាសឱ្យប្រើដោយក្រឹត្យលេខ ០៧ ក្រ ចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

២-បញ្ញត្តិនៃច្បាប់ផ្សេងទៀត ដែលមានអានុភាពនៅពេលក្រមនេះត្រូវបានអនុវត្ត ហើយផ្ទុយនឹងបញ្ញត្តិនៃក្រមនេះ ត្រូវចាត់ទុកថា គ្មានអានុភាព ត្រឹមទំហំដែលផ្ទុយនឹងក្រមនេះ ចាប់ពីថ្ងៃដែលក្រមនេះត្រូវបានអនុវត្ត ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ៦ ខែ កក្កដា ឆ្នាំ ២០០៦

នស.រកម.០៧០៦.០១០ **ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**ហត្ថលេខា**

**អង្គ វង្សវឌ្ឍានា**

លេខ : ៧៨៣ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០០៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ :..០៦៤.គយរ.ប្រក.១៩

# ប្រកាស

## ស្តីពី

## បែបបទសម្រាប់អនុវត្តការងាររបស់មន្ត្រីអាជ្ញាសាលា នៃក្រសួងយុត្តិធម៌

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩០៣ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញប្រកាសលេខ ៣០ កយប្រក ០៧ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៧ របស់ក្រសួងយុត្តិធម៌ ស្តីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា
- បានឃើញប្រកាសលេខ ០៩៣ កយប្រក/១៨ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៨ របស់ក្រសួងយុត្តិធម៌ ស្តីពីការកែសម្រួល និងផ្ទេរភារកិច្ចមន្ត្រីអាជ្ញាសាលាក្នុងក្របខណ្ឌក្រសួងយុត្តិធម៌
- យោងតាមតម្រូវការចាំបាច់ក្នុងការអនុវត្តការងាររបស់មន្ត្រីអាជ្ញាសាលា នៃក្រសួងយុត្តិធម៌

## សម្រេច

ប្រការ១.

១.១.មន្ត្រីអាជ្ញាសាលា ត្រូវទទួលបន្ទុកអនុវត្តកិច្ចការអាជ្ញាសាលានៅក្នុងដែនសមត្ថកិច្ច នៃសាលាដំបូងដែលខ្លួនប្រចាំការ។

១.២.សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ត្រូវប្រគល់កិច្ចការទាំងឡាយណាដែលជាសមត្ថកិច្ចរបស់អាជ្ញាសាលា ជូនទៅមន្ត្រីអាជ្ញាសាលា ដែលកំពុងប្រចាំការនៅទីនោះ ដើម្បីអនុវត្តការងារតាមច្បាប់ជាធរមាន លើកលែងតែ សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ដែលមិនទាន់មានមន្ត្រីអាជ្ញាសាលាប្រចាំការ ត្រូវបន្តអនុវត្តតាមប្រកាសលេខ ៣០ កយប្រក ០៧ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៧ របស់ក្រសួងយុត្តិធម៌ ស្តីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា។

ប្រការ២.

២.១. សាលាដំបូងរាជធានី-ខេត្ត មានភារកិច្ចជួយសម្របសម្រួលនូវរាល់កិច្ចការរដ្ឋបាលរបស់មន្ត្រីអាជ្ញាសាលា ដោយត្រូវចេញដីកាសម្រេចស្តីពីការបែងចែកសំណុំរឿង និងលេខលំដាប់សំណុំរឿង សម្រាប់ប្រគល់ជូនមន្ត្រីអាជ្ញាសាលាដែលកំពុងប្រចាំការនៅទីនោះ។

២.២.មន្ត្រីអាជ្ញាសាលាដែលប្រចាំការនៅសាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត មានសិទ្ធិប្រើប្រាស់ត្រារបស់សាលាដំបូងរាជធានី-ខេត្តនោះជាបណ្តោះអាសន្ន ហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មី ឬច្បាប់ស្តីពីលក្ខន្តិកៈអាជ្ញាសាលាចូលជាធរមាន។

ប្រការ៣.

មន្ត្រីអាជ្ញាសាលាដែលប្រចាំការនៅសាលាដំបូងរាជធានី-ខេត្ត ត្រូវស្នើសុំគោលការណ៍ណែនាំជាមុនពីក្រសួងយុត្តិធម៌ រាល់ការអនុវត្តដោយបង្ខំទាំងឡាយណាដែលអាចនឹងមានការប្រឆាំង ជាហេតុបង្កអោយមានភាពចលាចល វឹកវរ ឬអសន្តិសុខដល់សង្គម និងប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈធ្ងន់ធ្ងរដែលមិនអាចគ្រប់គ្រងបាន។

ប្រការ៤.

សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ត្រូវធ្វើរបាយការណ៍ ស្តីពីកិច្ចការអាជ្ញាសាលាប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ជូនក្រសួងយុត្តិធម៌តាមកាលកំណត់។

ប្រការ៥.

ខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋានកិច្ចការតុលាការ គ្រប់អគ្គនាយកដ្ឋាន គ្រប់អង្គភាពចំណុះក្រសួងយុត្តិធម៌ សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃពុធ ១០រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩

**រដ្ឋមន្ត្រី**

**អង្គ វង្សវឌ្ឍនា**

កន្លែងទទួល៖

-ទីស្តីការគណៈរដ្ឋមន្ត្រី

-តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល

-សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍

-គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

« ដើម្បីជូនជ្រាប »

-ដូចប្រការ៥

« ដើម្បីអនុវត្ត »

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
✧✧✧

ទីស្តីការក្រសួងយុត្តិធម៌

លេខៈ ០០១.គយ/ប្រក/០៧

# ប្រកាស
## ស្តីពី
## មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា

********

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញក្រឹត្យលេខ ០៦.ក្រ ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ របស់ក្រសួងយុត្តិធម៌
- បានឃើញសេចក្តីបង្គាប់លេខ ១១៧ ស.រ.រ.៩៧ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៩៧ របស់ក្រសួងយុត្តិធម៌ ស្តីពីការអនុវត្តសាលក្រម សាលដីកាស្ថាពរ និង សេចក្តីសម្រេចផ្សេងៗរបស់តុលាការ
- យោងតាមការចាំបាច់ក្នុងការអនុវត្តក្រមនីតិវិធីរដ្ឋប្បវេណី

## ស ម្រេ ច

**ប្រការៈ ១** ការកំណត់មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា

១- ព្រះរាជអាជ្ញា និង ព្រះរាជអាជ្ញារង នៃសាលាដំបូង ត្រូវអនុវត្តកិច្ចការរបស់

អាជ្ញាសាលា ក្នុងនាមជាមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា នៅក្នុងដែនសមត្ថកិច្ចនៃសាលាដំបូងដែលខ្លួនស្ថិតនៅក្រោម ក្នុងអំឡុងពេលរហូតដល់កាលបរិច្ឆេទនៃការអនុវត្តច្បាប់ស្តីពីអាជ្ញាសាលា ។

២-មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ត្រូវអនុវត្តកិច្ចការខាងក្រោមនេះ នៅក្នុងដែនសមត្ថកិច្ចនៃសាលាដំបូងដែលខ្លួនស្ថិតនៅក្រោម :

ក-កិច្ចការដែលបានកំណត់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ឬ ច្បាប់ផ្សេងទៀត ថា ត្រូវចាត់ចែងដោយអាជ្ញាសាលា ។

ខ-កិច្ចការពាក់ព័ន្ធនឹងការរក្សា ការគ្រប់គ្រងវត្ថុ ឬ សកម្មភាពផ្សេងទៀតដែលសេចក្តីសម្រេចរបស់តុលាការកំណត់ថា ត្រូវចាត់ចែងដោយអាជ្ញាសាលា ។

**ប្រការ ២** អ្នកអនុវត្តកិច្ចការជំនួស អ្នកជំនួយក្នុងការអនុវត្តកិច្ចការ ជាអាទិ៍

១-មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ត្រូវអនុវត្តកិច្ចការដោយខ្លួនឯង ។ ប៉ុន្តែ ក្នុងករណីដែលប្រតិបត្តិការបញ្ជូន ដោយយោងតាមកថាខណ្ឌទី ៣ មាត្រា ២៤៦ (គោលការណ៍នៃការបញ្ជូនដោយរន្ធានុសិទ្ធិ ជាអាទិ៍) នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រសិនបើមានមូលហេតុពិសេសដែលមិនអាចអនុវត្តកិច្ចការនោះដោយខ្លួនឯង មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា អាចឱ្យអ្នកអនុវត្តកិច្ចការជំនួស អនុវត្តកិច្ចការនោះជំនួសខ្លួន ដោយទទួលការអនុញ្ញាតពីប្រធានសាលាដំបូងដែលខ្លួនស្ថិតនៅក្រោម ។

២-ក្នុងករណីដែលមានការចាំបាច់ក្នុងការអនុវត្តកិច្ចការ មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា អាចប្រើអ្នកបច្ចេកទេស ឬ កម្មករបាន ។

៣-ក្នុងករណីដែលមានការចាំបាច់ក្នុងការអនុវត្តកិច្ចការ មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា អាចប្រើអ្នកជំនួយក្នុងការអនុវត្តកិច្ចការ ដោយទទួលការអនុញ្ញាតពីប្រធានសាលាដំបូងដែលខ្លួនស្ថិតនៅក្រោម ។

៤-ប្រធានសាលាដំបូង អាចលុបចោលនូវការអនុញ្ញាតដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ៣ នៅពេលណាក៏បានដែរ ។

**ប្រការ ៣** ជំនួយក្នុងការអនុវត្តកិច្ចការ

១-ប្រសិនបើមានការលំបាកពិសេស ក្នុងការអនុវត្តកិច្ចការដោយឯកឯង ឬ មាន

ការចាំបាច់ពិសេសផ្សេងទៀត ក្នុងការអនុវត្តកិច្ចការរបស់ខ្លួន មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា អាចស្នើសុំជំនួយពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាផ្សេងទៀត ដោយទទួលការអនុញ្ញាតពីប្រធានសាលាដំបូងដែលខ្លួនស្ថិតនៅក្រោម ។

២-ប្រសិនបើមិនអាចទទួលជាមុននូវការអនុញ្ញាតដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ដោយសារមានភាពចាំបាច់បន្ទាន់ចំពោះរឿងក្តី មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ត្រូវទទួលការអនុញ្ញាតនោះភ្លាម ក្រោយការស្នើសុំជំនួយ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលានីមួយៗ អាចទទួលការបង់ ឬ ការសងនូវសោហ៊ុយចាំបាច់ក្នុងការអនុវត្តកិច្ចការ ។

**ប្រការ ៤** ការរក្សាទុកនូវប្រាក់ដែលបានទទួលតាមកិច្ចការ ជាអាទិ៍

១-មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ត្រូវប្រគល់ប្រាក់ ឬ វត្ថុផ្សេងទៀតដែលខ្លួនបានរឹបអូស ឬ បានទទួលការប្រគល់ តាមការអនុវត្តកិច្ចការរបស់ខ្លួន ទៅអ្នកដែលត្រូវទទួលប្រាក់ ឬ វត្ថុនោះភ្លាម ឬ សាលាដំបូងដែលមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលានោះស្ថិតនៅក្រោម ត្រូវរក្សាទុកនូវប្រាក់ ឬ វត្ថុនោះ លើកលែងតែករណីដែលត្រូវតម្កល់ ឬ ករណីផ្សេងទៀតដែលច្បាប់បានកំណត់ ។

២-នៅពេលដែលទទួលប្រាក់ ឬ វត្ថុផ្សេងទៀតពីភាគី ឬ បុគ្គលផ្សេងទៀត តាមការអនុវត្តកិច្ចការរបស់ខ្លួន មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ត្រូវចេញលិខិតបញ្ជាក់ការទទួល (បង្កាន់ដៃ) ហើយត្រូវតក់ត្រាឱ្យបានច្បាស់លាស់នូវចំនួនទឹកប្រាក់ ឬ ប្រភេទ និង ចំនួននៃវត្ថុដែលខ្លួនបានទទួល និង ថ្ងៃ ខែ ឆ្នាំទទួល នៅក្នុងសំណុំរឿង ។

**ប្រការ ៥** ការចាត់ចែងកិច្ចការ

១-មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ត្រូវចាត់ចែងកិច្ចការ តាមពាក្យសុំ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះកិច្ចការដែលតុលាការឱ្យមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ចាត់ចែងដោយផ្ទាល់ ក្នុងនាមជាកិច្ចការដែលជាផ្នែកមួយនៃនីតិវិធីនៃរឿងក្តីដែលតុលាការនោះកំពុងចាត់ការ ។

២-ការបែងចែកកិច្ចការរបស់មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ត្រូវកំណត់ដោយ



5

ដីកាសម្រេចរបស់ប្រធានតុលាការដែលមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលានោះបំពេញការងារ ។ ប៉ុន្តែ ចំពោះកិច្ចការដែលសេចក្តីសម្រេចរបស់តុលាការកំណត់ថា ត្រូវចាត់ចែងដោយមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាជាកំណត់ណាម្នាក់ ក្នុងចំណោមកិច្ចការដែលបានកំណត់នៅក្នុងចំណុច ខ កថាខណ្ឌទី ២ នៃប្រការ ១ (មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា) មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលានោះ ត្រូវចាត់ចែងកិច្ចការនោះ ។

ប្រការ ៦ ការដកហូត

១-មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ត្រូវដកហូតពីការអនុវត្តមុខការរបស់ខ្លួនក្នុងករណីដែលបានកំណត់នៅក្នុងចំណុចនីមួយៗខាងក្រោមនោះ :

ក-កាលណាមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ឬ សហព័ទ្ធរបស់មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលានោះ ជាភាគី ឬ មានទំនាក់ទំនងនៃសិទ្ធិរួម ឬ កាតព្វកិច្ចរួមជាមួយនឹងភាគី ។

ខ-កាលណាមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ជាញាតិលោហិតក្នុងថ្នាក់ទី ៦ (ប្រាំមួយ) ឬ ញាតិពន្ធក្នុងថ្នាក់ទី ៣ (បី) ឬ ញាតិដែលរស់នៅជាមួយមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលានោះ ។

គ-កាលណាមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ជាអ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល ហិតូបត្ថម្ភកៈ ឬ អ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ ។

ឃ-កាលណាមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ជាអ្នកតំណាងរបស់ភាគីចំពោះកិច្ចការដែលខ្លួនត្រូវចាត់ចែង ។

២-ភាគីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មានរួមទាំងជនរងគ្រោះក្នុងរឿងក្តីព្រហ្មទណ្ឌ ។

ប្រការ ៧ ឧបាស្រ័យ

ចំពោះពាក្យសុំឧបាស្រ័យចំពោះការគណនាសោហ៊ុយ ឬ ការចាត់ចែងផ្សេងទៀតរបស់មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាស្តីពីកិច្ចការដែលត្រូវបានចាត់ចែង តាមពាក្យសុំ ឬ ចំពោះពាក្យសុំឧបាស្រ័យចំពោះការយឺតយ៉ាវ ឬ ការធ្វេសប្រហែសក្នុងការចាត់ចែងកិច្ចការទាំងនោះ ត្រូវអនុលោមតាមករណីនៃការតវ៉ាចំពោះការអនុវត្តដែលបានកំណត់



5

នៅក្នុងកថាខណ្ឌទី ២ មាត្រា ៣៨៤ (ការតវ៉ាចំពោះការអនុវត្ត) នៃក្រមនីតិវិធីរដ្ឋប្បវេណី លើកលែងតែករណីដែលមានបញ្ញត្តិពិសេស នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ។

ប្រការ ៨ របៀបដាក់ពាក្យសុំ

១-ពាក្យសុំចំពោះមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ត្រូវធ្វើដោយដាក់លិខិតជាលាយល័ក្ខណ៍អក្សរដែលសរសេរបញ្ជាក់ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាង ព្រមទាំងខ្លឹមសារនៃចំណុចដែលសុំនោះ ។

២-ក្នុងករណីដែលពាក្យសុំត្រូវបានដាក់ដោយអ្នកតំណាង ត្រូវភ្ជាប់លិខិតបញ្ជាក់សិទ្ធិតំណាង ជាមួយនឹងពាក្យសុំ ។

ប្រការ ៩ លំដាប់នៃការចាត់ចែងកិច្ចការ

មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ត្រូវចាត់ចែងកិច្ចការ តាមលំដាប់ដែលខ្លួនបានទទួល លើកលែងតែករណីដែលមានស្ថានភាពពិសេស ។

ប្រការ ១០ ម៉ោងធ្វើការ និង ការចាត់ចែងកិច្ចការក្រៅម៉ោងធ្វើការ

១-ម៉ោងធ្វើការរបស់មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា គឺចាប់ពីម៉ោងប្រាំពីរព្រឹក ដល់ម៉ោងប្រាំល្ងាច ។

២-ប្រសិនបើមានភាពចាំបាច់បន្ទាន់ ឬ ភាពចាំបាច់ពិសេសផ្សេងទៀត មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ត្រូវចាត់ចែងកិច្ចការ ទោះជាក្រៅម៉ោងធ្វើការក៏ដោយ ។

ប្រការ ១១ ការយកតាមខ្លួននូវអត្តសញ្ញាណប័ណ្ណ

នៅពេលបំពេញមុខនាទីរបស់ខ្លួន មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ត្រូវយកតាមខ្លួននូវលិខិតដែលបញ្ជាក់អត្តសញ្ញាណរបស់ខ្លួន ហើយត្រូវបង្ហាញលិខិតនេះ ចំពោះជនដែលទាក់ទងនឹងផលប្រយោជន៍ បើជននោះទាមទារ ។

ប្រការ ១២ ចំណុចត្រូវសរសេរនៅក្នុងកំណត់ហេតុ 5

១-មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ត្រូវធ្វើកំណត់ហេតុស្ដីពីការបំពេញមុខនាទីរបស់ខ្លួន ។

២-នៅក្នុងកំណត់ហេតុដែលមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាត្រូវធ្វើ ត្រូវកត់ត្រានូវចំណុចខាងក្រោមនេះ ហើយត្រូវសរសេរឈ្មោះ និង ចុះហត្ថលេខា :

ក-សណ្ឋានរឿងក្ដី ។

ខ-ពេលវេលា និង ទីកន្លែងដែលបំពេញមុខនាទី ។

គ-ខ្លឹមសារនៃកិច្ចការដែលបានចាត់ចែង ។

ឃ-ថ្ងៃ ខែ ឆ្នាំ ដែលធ្វើកំណត់ហេតុ ។

**ប្រការ ១៣** ពន្ធដាក់ពាក្យសុំ

១-ក្នុងករណីដែលដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ទៅមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ម្ចាស់បំណុលនៃការអនុវត្តត្រូវបង់ពន្ធចំនួន ៥.០០០ (ប្រាំពាន់) រៀល ទៅសាលាដំបូងដែលមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលានោះស្ថិតនៅក្រោម ។

២-ក្នុងករណីដែលដាក់ពាក្យសុំឱ្យអនុវត្តការចាត់ចែងរក្សាការពារ ទៅមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា អ្នកដាក់ពាក្យសុំត្រូវបង់ពន្ធចំនួន ៥.០០០ (ប្រាំពាន់) រៀល ទៅសាលាដំបូងដែលមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលានោះស្ថិតនៅក្រោម ។

**ប្រការ ១៤** សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ

១-អ្នកដាក់ពាក្យសុំ ត្រូវទទួលបន្ទុកក្នុងការបង់ ឬ ការសងនូវសោហ៊ុយចាំបាច់ដើម្បីចាត់ចែងកិច្ចការដែលមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាត្រូវធ្វើ តាមពាក្យសុំនេះ ។

២-ចំពោះសោហ៊ុយចាំបាច់ដើម្បីចាត់ចែងកិច្ចការដែលតុលាការឱ្យមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ចាត់ចែងដោយផ្ទាល់ តុលាការត្រូវទទួលបន្ទុកនូវសោហ៊ុយនោះ ។

៣-សោហ៊ុយដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ មានដូចតទៅ :

ក-សោហ៊ុយធ្វើដំណើរ និង សោហ៊ុយស្នាក់នៅ សម្រាប់មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ។

ខ-សោហ៊ុយសម្រាប់ការផ្ញើឯកសារ ទូរស័ព្ទ និង ទូរសារ ជាអាទិ៍ ។ 5

គ-សោហ៊ុយសម្រាប់ការជូនដំណឹងជាសាធារណៈ ។

ឃ-សោហ៊ុយធ្វើដំណើរ ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ និង សោហ៊ុយស្នាក់នៅសម្រាប់អ្នកសង្កេតការណ៍ដែលបានកំណត់នៅក្នុងមាត្រា ៣៣៩ (អ្នកសង្កេតការណ៍) នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ង-កម្រៃសម្រាប់អ្នកបច្ចេកទេស ឬ កម្មករ ។

ច-សោហ៊ុយសម្រាប់ការដឹកជញ្ជូន ថែរក្សា និង គ្រប់គ្រងវត្ថុ ។

ឆ-សោហ៊ុយសម្រាប់ការប្រមូលផល ។

ជ-សោហ៊ុយសម្រាប់ការទទួលលិខិតបញ្ជាក់ពីស្ថាប័នសាធារណៈ ។

ឈ-សោហ៊ុយសម្រាប់ថត និង ផ្តិតរូបថត ដើម្បីថតស្ថានភាពបច្ចុប្បន្ននៃវត្ថុ ។

ញ-សោហ៊ុយសម្រាប់ការធ្វើលិខិតបញ្ជាក់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៩ នៃមាត្រា ៤១៣ (ដីកាសម្រេចបង្គាប់ឱ្យលក់) នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ដ-សោហ៊ុយធ្វើដំណើរ ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ សោហ៊ុយស្នាក់នៅ និង កម្រៃសម្រាប់អ្នកវាយតម្លៃ ។

ឋ-សោហ៊ុយធ្វើលិខិតរាយការណ៍ដែលត្រូវដាក់ជូនទៅតុលាការអនុវត្ត ។

ឌ-សោហ៊ុយចាំបាច់សម្រាប់ការលក់តាមវិធីផ្សេងពីវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ។

៤-ចំពោះការគណនាចំនួននៃសោហ៊ុយធ្វើដំណើរ និង សោហ៊ុយស្នាក់នៅដែលបានកំណត់នៅក្នុងចំណុច ក នៃកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវអនុលោមទៅតាមករណីនៃក្រឡាបញ្ជី ។

**ប្រការ ១៥** ការបង់សោហ៊ុយជាមុន

១-ចំពោះកិច្ចការដែលមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាត្រូវធ្វើ តាមពាក្យសុំ សាលាដំបូងដែលមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលានោះស្ថិតនៅក្រោម អាចបង្គាប់ឱ្យអ្នកដាក់ពាក្យសុំបង់ជាមុននូវសោហ៊ុយចាំបាច់ដើម្បីចាត់ចែងកិច្ចការនោះ តាមចំនួនទឹកប្រាក់ដែលកំណត់ដោយតុលាការ ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអ្នកដាក់ពាក្យសុំនោះ បានទទួលការសង្គ្រោះលើបណ្តឹង ។ 5

២- ក្នុងករណីដែលអ្នកដាក់ពាក្យសុំមិនបង់ជាមុននូវចំនួនទឹកប្រាក់ដែលបានកំណត់ នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាអាចលើកចោលពាក្យសុំនោះបាន ។

**ប្រការ ១៦** បញ្ញត្តិពិសេសក្នុងករណីនៃពាក្យសុំដោយអ្នកដែលបានទទួលការសង្គ្រោះលើបណ្តឹង

ក្នុងចំណោមសោហ៊ុយចាំបាច់ដើម្បីចាត់ចែងកិច្ចការអនុវត្តដោយបង្ខំដែលមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាត្រូវធ្វើ តាមពាក្យសុំរបស់អ្នកដែលបានទទួលការសង្គ្រោះលើបណ្តឹង ប្រសិនបើមានសោហ៊ុយខ្លះដែលមិនអាចប្រមូលពីកូនបំណុលនៃការអនុវត្ត រដ្ឋត្រូវទទួលបន្ទុកនូវសោហ៊ុយនោះ ។

**ប្រការ ១៧** អានុភាពនៃប្រកាសនេះ

ប្រកាសនេះមានអានុភាពអនុវត្ត ចាប់ពីកាលបរិច្ឆេទដែលក្រមនីតិវិធីរដ្ឋប្បវេណីត្រូវបានអនុវត្ត ។ ✓

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០៧

រដ្ឋមន្ត្រី

អង្គ វង្សវឌ្ឍនា

**ចម្លងជូន ៖**

- តុលាការខេត្ត-ក្រុង
  "ដើម្បីអនុវត្ត"
- តុលាការកំពូល និង អយ្យការអមតុលាការកំពូល
- សាលាឧទ្ធរណ៍ និង អយ្យការអមសាលាឧទ្ធរណ៍
- អយ្យការអមតុលាការខេត្ត-ក្រុង
- តុលាការយោធា និង អយ្យការអមតុលាការយោធា
- អគ្គាធិការដ្ឋានកិច្ចការតុលាការ
- នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី
- គណៈមេធាវី
  "ដើម្បីជ្រាប"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីព្រាង

# ច្បាប់ស្តីពីអាជ្ញាសាលា

(កែសម្រួលដោយក្រុមប្រឹក្សាអ្នកច្បាប់ និង រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ)

(សេចក្តីព្រាងលើកទី ៣)

Downloaded from http://www.khmerlaws.org

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.- គោលបំណង**

ច្បាប់នេះមានគោលបំណងធានាការអនុវត្តក្រមនីតិវិធីរដ្ឋប្បវេណី ក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ពាក់ព័ន្ធឱ្យមានប្រសិទ្ធភាព។

**មាត្រា ២.- គោលដៅ**

ច្បាប់នេះមានគោលដៅកំណត់អំពីឋានៈ ការតែងតាំង ការចាត់តាំង ការគ្រប់គ្រងការអនុវត្តមុខងាររបស់អាជ្ញាសាលា និងចំណុចចាំបាច់ផ្សេងទៀតទាក់ទងនឹងអាជ្ញាសាលា។

**មាត្រា ៣.- វិសាលភាព**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះអាជ្ញាសាលានៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី ២

## ការប្រឡងជ្រើសរើស ការតែងតាំងកម្មសិក្សាការី និងការតាំងស៊ប់ក្នុងក្របខ័ណ្ឌ

**មាត្រា ៤ ថ្មី.- លក្ខខណ្ឌចូលរួមប្រឡងជ្រើសរើស**

ត្រូវបានប្រឡងជ្រើសរើសមកចូល ជាសិស្សអាជ្ញាសាលានូវបេក្ខជនសញ្ជាតិខ្មែរដែលមានកាយសម្បទាមាំមួនទាំងពីរភេទ ដូចខាងក្រោម៖

ក- បេក្ខជនដែលមានបរិញ្ញាបត្រនីតិសាស្ត្រ និងមានអាយុយ៉ាងច្រើនបំផុតត្រឹម ៣០ (សាមសិប) ឆ្នាំ គិតមកដល់ថ្ងៃប្រឡង។

ខ- បេក្ខជនដែលមានបរិញ្ញាបត្រនីតិសាស្ត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកនីតិសាស្ត្រ ព្រមទាំងមានអាយុយ៉ាងច្រើនបំផុតត្រឹម ៣៥ (សាមសិបប្រាំ) ឆ្នាំ គិតមកដល់ថ្ងៃប្រឡង។

គ- បេក្ខជនជាមន្ត្រីរាជការ ដែលមានបរិញ្ញាបត្រនីតិសាស្ត្រឡើងទៅ និងមានអាយុយ៉ាងច្រើនបំផុតត្រឹម ៤០ (សែសិប) ឆ្នាំ គិតមកដល់ថ្ងៃប្រឡង និងមិនដែលមានទណ្ឌកម្មវិន័យដែលនាំឱ្យបាត់បង់សិទ្ធិសម្បទាវិជ្ជាជីវៈរបស់ខ្លួន។



Downloaded from http://www.khmerlaws.org

ការកំណត់ចំនួនអាជ្ញាសាលាដែលត្រូវជ្រើសរើស ត្រូវសម្រេចដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដោយសហការជិតស្និទ្ធជាមួយរាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ។

**មាត្រា ៥ ថ្មី** *(មាត្រា ៦ ចាស់)*.- **ការជ្រើសរើសដោយគ្មានចូលរៀនវគ្គបណ្តុះបណ្តាល**

អាចត្រូវបានជ្រើសរើសដោយគ្មានការចូលរៀនវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈអាជ្ញាសាលា ចៅក្រមដែលមានបទពិសោធន៍ការងារយ៉ាងតិច ៥ (ប្រាំ) ឆ្នាំ និងក្រឡាបញ្ជីដែលមានបទពិសោធន៍យ៉ាងតិច ៧ (ប្រាំពីរ) ឆ្នាំ និងមិនដែលមានទណ្ឌកម្មវិន័យដែលធ្ងន់ធ្ងរដោយបាត់បង់នីតិសម្បទាវិជ្ជាជីវៈរបស់ខ្លួន។

ការប្រឡងជ្រើសរើសត្រូវធ្វើ ប្រសិនបើបេក្ខជនដាក់ពាក្យមានចំនួនលើសពីការកំណត់ដែលធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដោយសហការជិតស្និទ្ធជាមួយរាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ។

**មាត្រា ៦ ថ្មី** *(មាត្រា ៦ ចាស់)* .- **ការតែងតាំងអាជ្ញាសាលាកម្មសិក្សាការី**

ការតែងតាំងកម្មសិក្សាការីត្រូវធ្វើឡើងតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

អាជ្ញាសាលាកម្មសិក្សាការីត្រូវធ្វើកម្មសិក្សា៖

- រយៈពេល ១២ (ដប់ពីរ) ខែ សម្រាប់សិស្សចេញពីសាលាបណ្តុះបណ្តាលអាជ្ញាសាលាដែលមានសញ្ញាបត្រវិជ្ជាជីវៈអាជ្ញាសាលាដែលចេញដោយរាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ។
- រយៈពេល ៦ (ប្រាំមួយ) ខែ សម្រាប់សិក្ខាកាមដែលទទួលជោគជ័យក្នុងវគ្គវិក្រឹត្យការនៅរាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ។

ចំនួនក្របខណ្ឌអាជ្ញាសាលាត្រូវសម្រេចដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដោយសហការជិតស្និទ្ធជាមួយរាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ។

**មាត្រា ៧ ថ្មី** *(មាត្រា ៧ ចាស់)*.- **វិធានបទ និងនីតិវិធីនៃការប្រឡងជ្រើសរើស និងរយៈពេលនៃការបណ្តុះបណ្តាល**

វិធានបទ នីតិវិធីនៃការប្រឡងជ្រើសរើស និងរយៈពេលនៃការបណ្តុះបណ្តាល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។



Downloaded from http://www.khmerlaws.org

# ជំពូកទី ៣

## ផ្នែក: ការតែងតាំង ការចាត់តាំង បេសកកម្មការងារ និងការអនុវត្តមុខងារ

**មាត្រា ៨ ថ្មី** *(មាត្រា ៥ ចាស់)*- **ឋានៈ មុខងារ ការចូលបំពេញមុខងារ និងចំណុះអង្គភាព**

អាជ្ញាសាលា គឺជាមន្ត្រីរាជការក្នុងក្របខ័ណ្ឌក្រសួងយុត្តិធម៌។

អាជ្ញាសាលា ត្រូវចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឱ្យទៅបំពេញមុខងារនៅសាលាដំបូងរាជធានី ខេត្ត អនុលោមតាមលទ្ធផលនៃការជ្រើសរើសរបស់សិស្សអាជ្ញាសាលា ឬសិក្ខាកាមវិក្រឹត្យការវិជ្ជាជីវៈអាជ្ញាសាលា ដោយឈរលើគោលការណ៍ចំណាត់ថ្នាក់នៃលទ្ធផលសិក្សាដែលប្រកាសដោយរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ។

ក្នុងករណីមានកិច្ចការចាំបាច់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវចាត់តាំងអាជ្ញាសាលាដែលបំពេញមុខងារនៅសាលាដំបូង ឱ្យទៅបំពេញការងារនៅសាលាឧទ្ធរណ៍ ឬតុលាការកំពូល តាមសំណើរបស់ សាលាឧទ្ធរណ៍ ឬតុលាការកំពូល។

អាជ្ញាសាលា ត្រូវអនុវត្តកិច្ចការខាងក្រោមនេះ៖

ក- កិច្ចការដែលក្រមនីតិវិធីរដ្ឋប្បវេណី ក្រមនីតិវិធីព្រហ្មទណ្ឌ ឬបទដ្ឋានគតិយុត្តផ្សេងទៀត កំណត់ថាត្រូវចាត់ចែងដោយអាជ្ញាសាលា។

ខ- កិច្ចការពាក់ព័ន្ធនឹងការរក្សា ការគ្រប់គ្រងវត្ថុ ឬសកម្មភាពផ្សេងទៀតដែលសេចក្តីសម្រេចរបស់តុលាការកំណត់ថាត្រូវចាត់ចែងដោយអាជ្ញាសាលា។

មុខងារអាជ្ញាសាលា មានវិសមិតភាពជាមួយនឹងមុខងារជាមេធាវីក្រុមអធិបតី នៅក្រុមអាណាព្យាបាល នោតារី មេធាវី និងអ្នករាជការសាធារណៈផ្សេងទៀត។

**មាត្រា ៩ ថ្មី.- ការតែងតាំងអាជ្ញាសាលា**

ការតាំងស៊ប់អាជ្ញាសាលាពេញសិទ្ធ ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យក្នុងឋានន្តរស័ក្តិ គ៣-១៥ តាមសំណើពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក្រោយពីទទួលបានការវាយតម្លៃពីសាលាដំបូងដែលសាមីខ្លួនធ្វើកម្មសិក្សា។

ការតែងតាំង ការតម្លើងថ្នាក់ ឬឋានន្តរស័ក្តិ ការដាក់វិន័យ ត្រូវអនុវត្តតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល លើកលែងតែមានបញ្ញត្តិចែងផ្សេងពីនេះ។



Downloaded from http://www.khmerlaws.org

## ជំពូកទី ៣

## ឋានៈ ការតែងតាំង ការចាត់តាំង បែបបទទទួលការងារ និងការអនុវត្តមុខងារ

**មាត្រា ៨ ថ្មី** *(មាត្រា ៩ ចាស់)*- **ឋានៈ មុខងារ កន្លែងបំពេញមុខងារ និងឯកសណ្ឋាន**

អាជ្ញាសាលា គឺជាមន្ត្រីរាជការក្នុងក្របខ័ណ្ឌក្រសួងយុត្តិធម៌។

អាជ្ញាសាលា ត្រូវចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឱ្យទៅបំពេញមុខងារនៅសាលាដំបូងរាជធានី ខេត្ត អនុលោមតាមលទ្ធផលនៃការជ្រើសរើសរបស់សិស្សអាជ្ញាសាលា ឬសិក្ខាកាមវិក្រឹត្យការវិជ្ជាជីវៈអាជ្ញាសាលា ដោយឈរលើការពិចារណាលើតម្រូវការនិងលទ្ធផលសិក្សាដែលចេញប្រកាសដោយរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ។

ក្នុងករណីមានកិច្ចការចាំបាច់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវចាត់តាំងអាជ្ញាសាលាដែលបំពេញមុខងារនៅសាលាដំបូង ឱ្យទៅបំពេញការងារនៅសាលាឧទ្ធរណ៍ ឬតុលាការកំពូល តាមសំណើរបស់ សាលាឧទ្ធរណ៍ ឬតុលាការកំពូល។

អាជ្ញាសាលា ត្រូវអនុវត្តកិច្ចការខាងក្រោមនេះ៖

ក- កិច្ចការដែលក្រមនីតិវិធីរដ្ឋប្បវេណី ក្រមនីតិវិធីព្រហ្មទណ្ឌ ឬបទដ្ឋានគតិយុត្តផ្សេងទៀតកំណត់ថាត្រូវចាត់ចែងដោយអាជ្ញាសាលា។

ខ- កិច្ចការពាក់ព័ន្ធនឹងការរក្សា ការគ្រប់គ្រងវត្ថុ ឬសកម្មភាពផ្សេងទៀតដែលសេចក្តីសម្រេចរបស់តុលាការកំណត់ថាត្រូវចាត់ចែងដោយអាជ្ញាសាលា។

មុខងារអាជ្ញាសាលា មានវិសមិតភាពជាមួយនឹងមុខងារជាចៅក្រមអយ្យការ ចៅក្រមអាសនៈ សារការី មេធាវី និងអ្នករាជការសាធារណៈផ្សេងទៀត។

**មាត្រា ៩ ថ្មី- ការតែងតាំងអាជ្ញាសាលា**

ការតាំងស៊ប់អាជ្ញាសាលាពេញសិទ្ធ ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យក្នុងឋានន្តរស័ក្តិ គ៣-១៥ តាមសំណើពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក្រោយពីទទួលបានការវាយតម្លៃពីសាលាដំបូងដែលសាមីខ្លួនធ្វើកម្មសិក្សា។

ការតែងតាំង ការតម្លើងថ្នាក់ ឬឋានន្តរស័ក្តិ ការដាក់វិន័យ ត្រូវអនុវត្តតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល លើកលែងតែមានបញ្ញត្តិផ្សេងពីនេះ។



Downloaded from http://www.khmerlaws.org

**មាត្រា ១០ ថ្មី** *(មាត្រា ៥ ចាស់)*- **ប្រាក់បៀវត្សរ៍ និងកម្រៃ**

អាជ្ញាសាលា ត្រូវទទួលប្រាក់បៀវត្សរ៍ និងមួយផ្នែកនៃកម្រៃដែលត្រូវបង់ចូលជាថវិការដ្ឋ ចំពោះការអនុវត្តមុខងាររបស់ខ្លួន។ កម្រៃមួយផ្នែកដែលអាជ្ញាសាលាត្រូវទទួលបាន ត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងយុត្តិធម៌។

**មាត្រា ១១ ថ្មី** *(មាត្រា ៦ ចាស់)*- **ការត្រួតពិនិត្យលើការអនុវត្តមុខងារ**

អាជ្ញាសាលាត្រូវទទួលការត្រួតពិនិត្យពីសាលាដំបូង លើមុខងាររបស់ខ្លួន។

ប្រធានសាលាដំបូង ឬចៅក្រមដែលត្រូវបានចាត់តាំងដោយប្រធានសាលាដំបូង អាចធ្វើការ ចាត់ចែងត្រួតពិនិត្យការអនុវត្តមុខងាររបស់អាជ្ញាសាលាដូចខាងក្រោម៖

ក- ពិនិត្យស្រាវជ្រាវមើល កំណត់ហេតុ បញ្ជី ប្រាក់ ឬវត្ថុដែលពាក់ព័ន្ធនឹងការថែរក្សា។ ពិនិត្យស្រាវជ្រាវមើលកំណត់ហេតុ បញ្ជីរបស់អាជ្ញាសាលា ឬការបង្គាប់ឱ្យអាជ្ញាសាលាប្រគល់វត្ថុដែលថែរក្សាទាំងនោះ ។

ខ- ការចូលរួមក្នុងការអនុវត្តមុខងាររបស់អាជ្ញាសាលា និងការសង្កេតមើលការអនុវត្តមុខងារនោះ។

គ- បង្គាប់ឱ្យអាជ្ញាសាលាធ្វើសេចក្ដីរាយការណ៍ ដោយកំណត់អំពីចំណុចដែលត្រូវរាយការណ៍។

ឃ- ផ្ដល់ការប្រុងប្រយ័ត្នចំពោះអាជ្ញាសាលា អំពីការចាត់ចែងកិច្ចការ និងអាកប្បកិរិយារបស់ភាគីដែលត្រូវទទួលការអនុវត្ត។

ក្នុងករណីមានហេតុការណ៍ចាំបាច់ដែលពាក់ព័ន្ធនឹងការចាត់ចែង ត្រួតពិនិត្យ ប្រធានសាលាដំបូងត្រូវធ្វើសេចក្ដីរាយការណ៍អំពីមតិយោបល់របស់ខ្លួន ឬមតិយោបល់របស់ចៅក្រមទទួលបន្ទុក ជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក្នុងរយៈពេលមួយដែលសមស្រប។

## ជំពូកទី ៤

## ការបំពេញមុខនាទី

**មាត្រា ១២ ថ្មី** *(មាត្រា ៧ ចាស់)*- **សមត្ថកិច្ចដែនដី**

អាជ្ញាសាលា ត្រូវបំពេញមុខនាទីរបស់ខ្លួន នៅក្នុងសមត្ថកិច្ចដែនដីនៃសាលាដំបូងដែលអាជ្ញាសាលានោះបំពេញការងារ។ ប៉ុន្តែ ក្នុងករណីដែលមានការអនុញ្ញាតពីតុលាការ អាជ្ញាសាលាអាចបំពេញមុខនាទីរបស់ខ្លួននៅក្រៅសមត្ថកិច្ចដែនដីនោះបាន។



Downloaded from http://www.khmerlaws.org

ការអនុញ្ញាតដែលបានកំណត់ក្នុងវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវផ្តល់ដោយតុលាការអនុវត្ត ក្នុងករណីអាជ្ញាសាលាបំពេញមុខងាររបស់ខ្លួន តាមការបង្គាប់របស់តុលាការអនុវត្ត។ ករណីផ្សេងពីនេះ ការអនុញ្ញាតត្រូវផ្តល់ដោយប្រធានសាលាដំបូងដែលអាជ្ញាសាលានោះបំពេញការងារ។

ក្នុងករណីដែលតុលាការផ្តល់ការអនុញ្ញាត ដោយយោងតាមបញ្ញត្តិនៃវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវកម្រិតតែក្នុងករណីដែលបានកំណត់ខាងក្រោមនេះ៖

ក- ករណីដែលត្រូវរឹបអូសចលនវត្ថុច្រើន ហើយដែលមានចលនវត្ថុខ្លះក្នុងចំណោមចលនវត្ថុទាំងនោះស្ថិតនៅក្រៅសមត្ថកិច្ចដែនដីនៃសាលាដំបូងដែលអាជ្ញាសាលានោះបំពេញការងារ។

ខ- ករណីដែលត្រូវរឹបអូសជាបណ្តោះអាសន្ននូវចលនវត្ថុច្រើន ហើយដែលចលនវត្ថុខ្លះក្នុងចំណោមចលនវត្ថុទាំងនោះ ស្ថិតនៅក្រៅសមត្ថកិច្ចដែនដីនៃសាលាដំបូងដែលអាជ្ញាសាលានោះបំពេញការងារ។

គ- ករណីដែលត្រូវអនុវត្តដោយបង្ខំឱ្យប្រគល់ចលនវត្ថុច្រើន ហើយដែលចលនវត្ថុខ្លះក្នុងចំណោមចលនវត្ថុទាំងនោះ ស្ថិតនៅក្រៅសមត្ថកិច្ចដែនដីនៃសាលាដំបូងដែលអាជ្ញាសាលានោះ បំពេញការងារ។

ឃ- ករណីដែលមានការអនុវត្តការចាត់ចែងជាបណ្តោះអាសន្នដែលបង្គាប់ឱ្យប្រគល់ចលនវត្ថុច្រើន ហើយដែលចលនវត្ថុខ្លះក្នុងចំណោមចលនវត្ថុទាំងនោះ ស្ថិតនៅក្រៅសមត្ថកិច្ចដែនដីនៃសាលាដំបូងដែលអាជ្ញាសាលានោះបំពេញការងារ។

ង- ករណីដែលចាំបាច់ពិសេសដើម្បីថែរក្សាគ្រប់គ្រងចលនវត្ថុដែលត្រូវបានរឹបអូសរួចហើយ។

ច- ករណីដែលចាំបាច់ពិសេសដើម្បីថែរក្សាគ្រប់គ្រងចលនវត្ថុដែលត្រូវបានរឹបអូសជាបណ្តោះអាសន្នរួចហើយ។

ឆ- ករណីដែលចាំបាច់ពិសេសដើម្បីថែរក្សាគ្រប់គ្រងចលនវត្ថុដែលជាកម្មវត្ថុនៃការចាត់ចែងជាបណ្តោះអាសន្ន។

ជ- ករណីដែលចលនវត្ថុត្រូវបានរឹបអូសជាបណ្តោះអាសន្នរួចហើយ តែបែរជាទៅស្ថិតនៅក្រៅសមត្ថកិច្ចនៃសាលាដំបូងដែលអាជ្ញាសាលានោះ បានធ្វើការរឹបអូសក្នុងការបំពេញការងាររបស់ខ្លួន ហើយដែលចាំបាច់ត្រូវយកចលនវត្ថុនោះមកវិញ។

ឈ- ករណីដែលចលនវត្ថុត្រូវបានរឹបអូសជាបណ្តោះអាសន្នរួចហើយ តែបែរជាទៅស្ថិតនៅក្រៅសមត្ថកិច្ចដែនដីនៃសាលាដំបូងដែលអាជ្ញាសាលានោះ បានធ្វើការរឹបអូសជាបណ្តោះអាសន្នក្នុងការបំពេញការងាររបស់ខ្លួន ហើយដែលមានការចាំបាច់យកចលនវត្ថុនោះវិញ។



Downloaded from http://www.khmerlaws.org

ញ- ករណីដែលបណ្តឹងវត្ថុជាកម្មវត្ថុនៃការចាត់ចែងជាបណ្តោះអាសន្ន ស្ថិតនៅជាស្ថិតនៅក្រៅសមត្ថកិច្ចដែនដីនៃសាលាដំបូងដែលអាជ្ញាសាលានោះ បានធ្វើការអនុវត្តការចាត់ចែងជាបណ្តោះអាសន្នក្នុងការបំពេញការងារ ហើយដែលមានការចាំបាច់ត្រូវយកវត្ថុនោះមកវិញ។

ដ- ករណីការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ឬនាវា ឬវត្ថុផ្សេងទៀត ដែលមនុស្សរស់នៅក្នុងនោះស្ថិតនៅក្រោម និងក្រៅសមត្ថកិច្ចដែនដីនៃសាលាដំបូងដែលអាជ្ញាសាលា បំពេញការងារ។

ឋ- ករណីការអនុវត្តការចាត់ចែងជាបណ្តោះអាសន្ន ដែលបង្គាប់ឱ្យប្រគល់ អចលនវត្ថុ ឬនាវា ឬវត្ថុផ្សេងទៀតដែលមនុស្សរស់នៅក្នុងនោះ ស្ថិតនៅក្រោម និងក្រៅសមត្ថកិច្ចដែនដីនៃសាលាដំបូងដែលអាជ្ញាសាលាបំពេញការងារ។

ក្រៅពីករណីដែលបានកំណត់នៅក្នុងចំណុចនីមួយៗខាងលើនេះ ក្នុងករណីដែលមានភាពចាំបាច់ក្នុងការបំពេញមុខងារនៅក្រៅសមត្ថកិច្ចដែនដី នៃសាលាដំបូងដែលអាជ្ញាសាលានោះបំពេញការងារ។

**មាត្រា ១៣ ថ្មី *(មាត្រា ១០ ចាស់)*.- អ្នកអនុវត្តកិច្ចការជំនួស អ្នកជំនួយក្នុងការអនុវត្តកិច្ចការ**

ជាគោលការណ៍ អាជ្ញាសាលាត្រូវអនុវត្តកិច្ចការដោយខ្លួនឯង។ ប៉ុន្តែ ក្នុងករណីដែល ប្រតិបត្តិការបង្ខំ ដោយយោងតាមកថាខណ្ឌទី ៣ មាត្រា ២៤៦ (គោលការណ៍នៃការបញ្ជូនដោយ អន្តរនុសិទ្ធិជាអាទិ៍) នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រសិនបើមានមូលហេតុពិសេសដែលមិនអាចអនុវត្ត កិច្ចការនោះដោយខ្លួនឯង អាជ្ញាសាលាអាចឱ្យអ្នកអនុវត្តកិច្ចការជំនួស អនុវត្តកិច្ចការនោះជំនួសខ្លួន ដោយមានការអនុញ្ញាតពីប្រធានសាលាដំបូងដែលខ្លួនបំពេញការងារ។

ក្នុងករណីដែលមានការចាំបាច់ក្នុងការអនុវត្តកិច្ចការ អាជ្ញាសាលាអាចប្រើអ្នកបច្ចេកទេស ឬកម្មករបាន។

ក្នុងករណីដែលមានការចាំបាច់ក្នុងការអនុវត្តកិច្ចការ អាជ្ញាសាលាអាចប្រើអ្នកជំនួយក្នុងការអនុវត្តកិច្ចការ ដោយមានការអនុញ្ញាតពីប្រធានសាលាដំបូងដែលខ្លួនបំពេញការងារ។

ប្រធានសាលាដំបូងអាចលុបចោលនូវការអនុញ្ញាតដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នៃកថាខណ្ឌទី ១ និងកថាខណ្ឌទី ៣ ខាងលើនេះ នៅពេលណាក៏បាន។

**មាត្រា ១៤ ថ្មី *(មាត្រា ១១ ចាស់)*.- អ្នកក្រឡាបញ្ជីដែលចាត់ចែងកិច្ចការរបស់អាជ្ញាសាលា**

ក្នុងករណីដែលមានការចាំបាច់ពិសេសក្នុងការចាត់ចែងការងាររបស់អាជ្ញាសាលា ប្រធានសាលាដំបូងអាចធ្វើការកំណត់ជាមុននូវក្រឡាបញ្ជីដែលបំពេញកិច្ចការរបស់អាជ្ញាសាលា ដោយកម្រិត ឬមិនកម្រិតនូវប្រភេទនៃកិច្ចការនោះ ហើយឱ្យអ្នកនោះបំពេញកិច្ចការរបស់អាជ្ញាសាលាទាំងស្រុង ឬ មួយភាគបាន។



Downloaded from http://www.khmerlaws.org

ក្នុងករណីដែលមានការចាំបាច់បន្ទាន់ ដោយសារអាជ្ញាសាលាមានគ្រោះថ្នាក់ ឬដោយសារមូលហេតុផ្សេងទៀត ប្រធានសាលាដំបូងអាចឱ្យក្រឡាបញ្ជីដែលបានកំណត់តាមកថាខណ្ឌទី ១ ខាងលើនេះបំពេញការងាររបស់អាជ្ញាសាលា ទាំងស្រុង ឬមួយភាគបាន។

កម្រៃ ឬទាំងសោហ៊ុយដែលត្រូវបង់សម្រាប់បំពេញកិច្ចការអាជ្ញាសាលាដែលបានធ្វើដោយក្រឡាបញ្ជី ដោយអនុលោមតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ឬទី ២ ខាងលើនេះ គឺជាចំណូលរបស់រដ្ឋ។

**មាត្រា ១៥ ថ្មី *(មាត្រា ១២ ចាស់)*.- ជំនួយក្នុងការអនុវត្តកិច្ចការ**

ប្រសិនបើមានការលំបាកពិសេសក្នុងការអនុវត្តកិច្ចការដោយខ្លួនឯង ឬមានការចាំបាច់ពិសេសផ្សេងទៀតក្នុងការអនុវត្តកិច្ចការរបស់ខ្លួន អាជ្ញាសាលាអាចស្នើសុំជំនួយពីអាជ្ញាសាលាផ្សេងទៀត ដោយទទួលការអនុញ្ញាតពីប្រធានសាលាដំបូងដែលខ្លួនបំពេញការងារ។

ប្រសិនបើមិនអាចទទួលនូវការអនុញ្ញាតជាមុនដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ដោយសារមានភាពចាំបាច់បន្ទាន់ចំពោះរឿងក្តី អាជ្ញាសាលាត្រូវសុំការអនុញ្ញាតភ្លាមពីប្រធានតុលាការ ក្រោយពីបានស្នើសុំជំនួយពីអាជ្ញាសាលាផ្សេងទៀត។

ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី២ ខាងលើនេះ អាជ្ញាសាលានីមួយៗអាចទទួលកម្រៃមួយផ្នែកដែលត្រូវបានបង់ចូលជាថវិការដ្ឋ និងការបង់ ឬការសងនូវសោហ៊ុយចាំបាច់ក្នុងការអនុវត្តកិច្ចការរៀងៗខ្លួនពីរដ្ឋ។

**មាត្រា ១៦ ថ្មី *(មាត្រា ១៣ ចាស់)*.- ការរក្សាទុកនូវប្រាក់ដែលបានទទួលតាមកិច្ចការ**

អាជ្ញាសាលាត្រូវប្រគល់ប្រាក់ ឬវត្ថុផ្សេងដែលខ្លួនបានរឹបអូស ឬបានទទួលដោយការប្រគល់តាមការអនុវត្តកិច្ចការរបស់ខ្លួនទៅឱ្យអ្នកដែលទទួលប្រាក់ ឬវត្ថុនោះភ្លាម ឬត្រូវប្រគល់ទៅសាលាដំបូងដែលអាជ្ញាសាលានោះបំពេញការងារ ដើម្បីរក្សាទុកនូវប្រាក់ ឬវត្ថុនោះ លើកលែងតែករណីដែលសាលាដំបូងត្រូវប្រគល់ទៅជនដែលត្រូវទទួលវត្ថុនោះភ្លាមៗ ឬតម្កល់វត្ថុនោះ ឬករណីផ្សេងទៀតដែលច្បាប់បានកំណត់ ។

នៅពេលដែលទទួលប្រាក់ ឬវត្ថុផ្សេងទៀតពីភាគី ឬបុគ្គលផ្សេងទៀត តាមការអនុវត្តកិច្ចការរបស់ខ្លួន អាជ្ញាសាលាត្រូវចេញបង្កាន់ដៃបញ្ជាក់ការទទួលដែលត្រូវកត់ត្រាឱ្យបានច្បាស់លាស់នូវចំនួនទឹកប្រាក់ ឬប្រភេទនិងចំនួននៃវត្ថុដែលខ្លួនបានទទួល និងកាលបរិច្ឆេទនៃការទទួលពីភាគី ឬបុគ្គលផ្សេងទៀតនោះ និងរក្សាទុកនៅក្នុងសំណុំរឿង។



Downloaded from http://www.khmerlaws.org

## ជំពូកទី៥

## ការចាត់ចែងកិច្ចការ និងបណ្តឹងទាស់អាស្រ័យ

**មាត្រា ១៨ ថ្មី** *(មាត្រា ១៥ ចាស់)*.- **ការចាត់ចែងកិច្ចការ**

អាជ្ញាសាលាត្រូវចាត់ចែងកិច្ចការតាមពាក្យសុំ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះកិច្ចការដែលតុលាការឱ្យអាជ្ញាសាលាចាត់ចែងដោយផ្ទាល់ ក្នុងនាមជាកិច្ចការដែលជាផ្នែកមួយនៃនីតិវិធីនៃរឿងក្តីដែលតុលាការនោះកំពុងចាត់ការ។

ការបែងចែកកិច្ចការរបស់អាជ្ញាសាលា ត្រូវកំណត់ដោយដីកាសម្រេចរបស់ប្រធានសាលាដំបូងដែលអាជ្ញាសាលានោះបំពេញការងារ។ ប៉ុន្តែចំពោះកិច្ចការដែលមានចរិតសម្រេចរបស់តុលាការបានកំណត់ថាត្រូវចាត់ចែងដោយអាជ្ញាសាលាជាក់លាក់ណាម្នាក់ក្នុងចំណោមកិច្ចការដែលបានកំណត់ នៅក្នុង ចំណុច ខ កថាខណ្ឌទី៣ នៃមាត្រា ៨ (ឋានៈ មុខងារ កន្លែងបំពេញមុខងារ និងវិសមិតភាព) នៃច្បាប់នេះ អាជ្ញាសាលានោះត្រូវចាត់ចែងកិច្ចការដោយផ្ទាល់។

**មាត្រា ១៩ ថ្មី** *(មាត្រា ១៥ ចាស់)*.- **មូលហេតុនៃការដកខ្លួនដោយឯកឯង និងការដកហូតសិទ្ធិនៃការអនុវត្តមុខងារ**

អាជ្ញាសាលាអាចស្នើសុំដកខ្លួនដោយឯកឯងបាន ឬត្រូវបានដកហូតសិទ្ធិអនុវត្តមុខការដោយប្រធានសាលាដំបូងដែលអាជ្ញាសាលានោះបំពេញការងារតាមការស្នើសុំពីភាគី
ក្នុងករណីដែលបានកំណត់នៅក្នុងចំណុច នីមួយៗ ដូចខាងក្រោមនេះ៖

ក- កាលណាអាជ្ញាសាលា ឬសហព័ទ្ធ ឬអតីតសហព័ទ្ធរបស់អាជ្ញាសាលា ជាភាគីណាមួយក្នុងរឿងក្តី ឬមានទំនាក់ទំនងនៃសិទ្ធិរួម ឬកាតព្វកិច្ចរួមជាមួយនឹងភាគីណាមួយ។

ខ- កាលណាអាជ្ញាសាលាជាញាតិលោហិត ឬញាតិពន្ធរហូតដល់ថ្នាក់ទី ៤ រាប់ទាំងថ្នាក់ទី ៤ នេះផង របស់ភាគីណាមួយ ឬញាតិដែលរស់នៅជាមួយអាជ្ញាសាលានោះជាភាគីណាមួយនៃរឿងក្តី។

គ- កាលណាអាជ្ញាសាលាជាអ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល ហិតូបត្ថម្ភកៈ ឬអ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ ជាភាគីណាមួយ។

ឃ- កាលណាអាជ្ញាសាលាជាអ្នកតំណាងរបស់ភាគីចំពោះកិច្ចការដែលខ្លួនត្រូវចាត់ចែង។

ង- កាលណាអាជ្ញាសាលាធ្លាប់ជាអ្នករឿងក្តីធ្លាប់ ឬកំពុងមានវិវាទនៅតុលាការជាមួយភាគីណាមួយ។



Downloaded from http://www.khmerlaws.org

**មាត្រា ១៩ ថ្មី** *(មាត្រា ១៦ ចាស់)*.- **ការស្នើសុំដកខ្លួនដោយឯកឯង និងការដកហូតចេញពីការអនុវត្តមុខការ**

ក្នុងករណីដែលបានកំណត់ក្នុងមាត្រា ១៨ (មូលហេតុនៃការដកខ្លួនដោយឯកឯង និងការដកហូតចេញពីមុខការ) ខាងលើនេះ ភាគី ឬអាជ្ញាសាលា អាចស្នើសុំទៅប្រធានសាលាដំបូងដែលអាជ្ញាសាលានោះបំពេញការងារ។

**មាត្រា ២០ ថ្មី.- ការជូនដំណឹងអំពីពាក្យប្ដឹង និងចម្លើយការពាររបស់អាជ្ញាសាលាពាក់ព័ន្ធនឹងការប្ដឹងដកហូតការអនុវត្តមុខការ**

ពាក្យប្ដឹងត្រូវជូនដំណឹងដល់អាជ្ញាសាលាដែលគេប្ដឹងដកហូតការអនុវត្តមុខការ។

ក្នុងរយៈពេល ៨ (ប្រាំបី) ថ្ងៃ បន្ទាប់ពីការជូនដំណឹងនេះ អាជ្ញាសាលាដែលគេប្ដឹងត្រូវធ្វើចម្លើយការពារដោយមានសំអាងហេតុថា ខ្លួនយល់ព្រម ឬជំទាស់នឹងការប្ដឹងដកហូត ការអនុវត្តមុខការនេះ។ ចម្លើយការពារនេះត្រូវបញ្ជូនទៅប្រធានសាលាដំបូងដែលខ្លួនបំពេញមុខការ ដើម្បី សម្រេច។

Silence means approval

**មាត្រា ២១ ថ្មី.- ការសម្រេចលើពាក្យប្ដឹងដកហូតការអនុវត្តមុខការរបស់អាជ្ញាសាលា**

ការសម្រេចលើពាក្យបណ្ដឹងដកហូតការអនុវត្តមុខការរបស់អាជ្ញាសាលា ត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃទទួលពាក្យបណ្ដឹង។ ប្រសិនបើ ប្រធានសាលាដំបូងយល់ឃើញថាពាក្យប្ដឹងមានមូលហេតុត្រឹមត្រូវ ប្រធានសាលាដំបូងត្រូវចាត់តាំងអាជ្ញាសាលាថ្មីជំនួសអាជ្ញាសាលាដែលគេប្ដឹងដកហូត។ ក្នុងករណីពាក្យប្ដឹងត្រូវបដិសេធចោល អ្នកប្ដឹងអាចត្រូវទទួលពិន័យមិនលើសពី ២០០.០០០ (ពីរសែន) រៀល ដោយមិនទាត់ចោលនូវសំណងជម្ងឺចិត្តដែលអាជ្ញាសាលាទាមទារ ។

ការសម្រេចត្រូវធ្វើឡើងដោយដីការបស់ប្រធានសាលាដំបូងដែលអាជ្ញាសាលានោះបំពេញមុខងារ។ ដីកានេះ មិនអាចប្ដឹងតវ៉ាបានទៀយ។ ដីកានេះត្រូវជូនដំណឹងភ្លាម ដល់អាជ្ញាសាលាដែលត្រូវគេប្ដឹងដកហូត និងដល់អ្នកប្ដឹងសុំដកហូត។

**មាត្រា ២២ ថ្មី** *(មាត្រា ១៧ ចាស់)*.- **បណ្ដឹងទាមទារសំណង**

បណ្ដឹងទាមទារសំណងចំពោះការខកខានមិនបានបំពេញការងារ ឬការធ្វើមិនបានល្អនៃការងាររបស់អាជ្ញាសាលា ស្ដីពីកិច្ចការដែលត្រូវបានធ្វើឡើងតាមពាក្យប្ដឹងសុំ ឬបណ្ដឹងទាមទារសំណងចំពោះការបាត់បង់ឯកសារ ឬការធ្វេសប្រហែសក្នុងការថែរក្សាឯកសារទាំងនោះ ត្រូវអនុលោមតាមករណីនៃការតវ៉ា ចំពោះការអនុវត្តដែលបានអនុវត្តនៅក្នុងកថាខណ្ឌទី២ នៃមាត្រា៣៥៤ (ការតវ៉ាចំពោះការអនុវត្ត) នៃក្រមនីតិវិធីរដ្ឋប្បវេណី លើកលែងតែករណីដែលមានបញ្ញត្តិពិសេសនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី។



Downloaded from http://www.khmerlaws.org

**មាត្រា ២៣ ថ្មី** *(មាត្រា ១៨ ចាស់)*.- **របៀបដាក់ពាក្យសុំអន្តរាគមន៍ដោយខ្លួនឯង**

ពាក្យសុំចំពោះអាជ្ញាសាលាត្រូវធ្វើជាលាយលក្ខណ៍អក្សរដែលមានសេចក្ដីបញ្ជាក់ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគី ហើយនិងឈ្មោះនិងអាសយដ្ឋានរបស់អ្នកតំណាង ព្រមទាំងខ្លឹមសារនៃចំណុចដែលសុំនោះ។

ក្នុងករណីដែលពាក្យសុំត្រូវបានដាក់ដោយអ្នកតំណាង ត្រូវភ្ជាប់លិខិតបញ្ជាក់សិទ្ធិតំណាង ជាមួយនឹងពាក្យសុំ។

**មាត្រា ២៤ ថ្មី** *(មាត្រា ១៩ ចាស់)*.- **លំដាប់នៃការចាត់ចែងកិច្ចការ**

អាជ្ញាសាលាត្រូវចាត់ចែងកិច្ចការតាមលំដាប់ដែលបានទទួល លើកលែងតែករណីដែលមានស្ថានភាពពិសេស។

**មាត្រា ២៥ ថ្មី** *(មាត្រា ២០ ចាស់)*.- **ការចាត់ចែងកិច្ចការក្រៅម៉ោងធ្វើការ**

ប្រសិនបើមានភាពចាំបាច់បន្ទាន់ ឬភាពចាំបាច់ពិសេសផ្សេងទៀត អាជ្ញាសាលាត្រូវចាត់ចែងកិច្ចការទោះជាក្រៅម៉ោងធ្វើការក៏ដោយ។

**មាត្រា ២៦ ថ្មី** *(មាត្រា ២១ ចាស់)*.- **ការយកតាមខ្លួននូវអត្តសញ្ញាណប័ណ្ណ**

នៅពេលបំពេញមុខងាររបស់ខ្លួន អាជ្ញាសាលាត្រូវយកតាមខ្លួននូវលិខិតដែលបញ្ជាក់អត្តសញ្ញាណរបស់ខ្លួន ហើយត្រូវបង្ហាញលិខិតនេះចំពោះជនដែលទាក់ទងនិងផលប្រយោជន៍ បើជននោះទាមទារ។

**មាត្រា ២៧ ថ្មី** *(មាត្រា ២២ ចាស់)*.- **ចំណុចត្រូវសរសេរនៅក្នុងកំណត់ហេតុ**

អាជ្ញាសាលាត្រូវធ្វើកំណត់ហេតុស្ដីពីការបំពេញមុខងាររបស់ខ្លួន។

នៅក្នុងកំណត់ហេតុដែលអាជ្ញាសាលាត្រូវធ្វើ ត្រូវកត់ត្រានូវចំណុចខាងក្រោមនេះ ហើយត្រូវសរសេរឈ្មោះ និងចុះហត្ថលេខា៖

ក- សញ្ញាណរឿងក្ដី។

ខ- ពេលវេលានិងទីកន្លែងបំពេញមុខងារ។

គ- ខ្លឹមសារនៃកិច្ចការដែលបានចាត់ចែង។

ឃ- កាលបរិច្ឆេទនៃការធ្វើកំណត់ហេតុ។



Downloaded from http://www.khmerlaws.org

## ជំពូកទី៦

## កម្រៃនិងសោហ៊ុយ

**មាត្រា ២៨ ថ្មី** *(មាត្រា ២៣ ចាស់)*.- **ករណីដែលទទួលកម្រៃ**

អាជ្ញាសាលាត្រូវទទួលកម្រៃមួយផ្នែកដែលត្រូវបានបង់ចូលជាថវិការដ្ឋ ក្នុងការចាត់ចែងការងារ ដែលមានចែងក្នុងចំណុចខាងក្រោមនេះ៖

ក- ការបញ្ជូនឯកសារ ដោយយោងតាមកថាខណ្ឌទី៣ មាត្រា ២៤៦ (គោលការណ៍នៃការបញ្ជូនដោយអាជ្ញាកុសិទ្ធិ ជាអាទិ៍) នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ខ- ជំនួយដោយយោងតាមកថាខណ្ឌទី ២ មាត្រា ៣៣៨ (ការធានាក្នុងការបំពេញមុខងាររបស់អាជ្ញាសាលាជាអាទិ៍) នៃក្រមនីតិវិធីរដ្ឋប្បវេណី។

គ- ការមើលសំណុំរឿងក្តី ឬការថតចម្លងសំណុំរឿង ការសុំឱ្យប្រគល់ឯកសារចម្លងយថាភូត ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ ឬឯកសារដកស្រង់នៃសំណុំរឿង ឬការសុំឱ្យប្រគល់លិខិតបញ្ជាក់អំពីចំណុចដែលពាក់ព័ន្ធនឹងរឿងក្តី ដោយយោងតាមកថាខណ្ឌទី ២ មាត្រា ៣៤៨ (ការមើល សំណុំរឿងនៃរឿងក្តីអនុវត្តដោយបង្ខំ ជាអាទិ៍) នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ឃ- ការអនុវត្តការរឹបអូសឬការរឹបអូសជាបណ្តោះអាសន្ននូវចលនវត្ថុ ដោយយោងតាមកថាខណ្ឌទី៣ មាត្រា ៣៨៩ (ការចាប់ផ្តើមអនុវត្តចំពោះចលនវត្ថុ) និងកថាខណ្ឌទី១ មាត្រា៥៦៨ (ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ) នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ង- ការទទួលសំណងដោយយោងតាមកថាខណ្ឌទី៦ មាត្រា ៣៨៩ (ការចាប់ផ្តើមអនុវត្តចំពោះចលនវត្ថុ) នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ច- កិច្ចការពាក់ព័ន្ធនឹងនីតិវិធី ដោយយោងតាមកថាខណ្ឌទី១ មាត្រា ៣៩៨ (ការរួមបញ្ចូល រឿងក្តី) នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ឆ- ការទទួលនូវចលនវត្ថុដើម្បីប្តូរជាប្រាក់ ដោយយោងតាមកថាខណ្ឌទី៩ មាត្រា ៣៩០ (ដីកាសម្រេចបង្គាប់ឱ្យប្រគល់ចលនវត្ថុដែលត្រូវបានរឹបអូស) នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ជ- កិច្ចការពាក់ព័ន្ធនឹងការទាមទារឱ្យចែកចំណែក ដោយយោងតាមមាត្រា ៣៩៩ (ការទាមទារឱ្យចែកចំណែកពីអ្នកមានឯកសិទ្ធិជាអាទិ៍) នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ឈ- កិច្ចការពាក់ព័ន្ធនឹងការលក់ឬការប្តូរជាប្រាក់ផ្សេងទៀត ដោយយោងតាមកថាខណ្ឌទី១ នៃមាត្រា៤១៣ (ដីកាសម្រេចបង្គាប់ឱ្យលក់) កថាខណ្ឌទី១នៃមាត្រា ៤១៤ (ការអនុវត្ត



Downloaded from http://www.khmerlaws.org

និកាសម្រេចរឹបអូសសិទ្ធិទាមទារឲ្យប្រគល់ចលនវត្ថុ) កថាខណ្ឌទី៣ នៃមាត្រា៥៣៦ (វិធីលក់ ជាអាទិ៍)កថាខណ្ឌ ទី២ នៃមាត្រា ៥៦៩ (វិធីលក់ជាអាទិ៍)និងកថាខណ្ឌទី ៦ នៃមាត្រា ៥២៥ (ការអនុវត្តដោយបង្ខំឲ្យ ប្រគល់អចលនវត្ថុជាអាទិ៍) នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ញ- ការអនុវត្តការចែកចំណែក ដោយយោងតាមមាត្រា ៣៩៩ (ការចែកចំណែកដោយអាជ្ញាសាលា) នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ដ- ការបង្គាប់ឲ្យឈប់ការកាន់កាប់អចលនវត្ថុ ហើយថែរក្សាអចលនវត្ថុនោះ ដោយយោងតាមកថាខណ្ឌ ទី ១ មាត្រា ៥២៩ (ការចាត់ចែងរក្សាការពារ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ឋ- ការដកហូតឬរឹបអូសលិខិតបញ្ជាក់សញ្ញាតិផាត ជាអាទិ៍ ដោយយោងតាមកថាខណ្ឌទី ១ មាត្រា ៥៥៩ (ដីកា សម្រេចបង្គាប់ឲ្យប្រគល់លិខិតបញ្ជាក់ផាត ជាអាទិ៍ នៅមុនពេលដាក់ពាក្យសុំ) និងកថាខណ្ឌទី ១ មាត្រា ៥៦៨ (ការអនុវត្តរឹបអូសបណ្ដោះអាសន្នចំពោះនាវា) នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ឌ- ការថែរក្សានាវា ដោយយោងតាមមាត្រា ៥៦០ (ការជ្រើសតាំងអ្នកថែរក្សាគ្រប់គ្រងជាអាទិ៍) នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ឍ- ការលើកយកចេញនូវការកាន់កាប់អចលនវត្ថុ ឬនាវា ឬវត្ថុផ្សេងទៀតដែលមនុស្សរស់នៅក្នុងនោះពីកូនបំណុល ហើយប្រគល់ការកាន់កាប់នោះទៅឲ្យម្ចាស់បំណុលដោយយោងតាមកថាខណ្ឌទី ១ មាត្រា ៥២៥ (ការអនុវត្តដោយបង្ខំឲ្យប្រគល់អចលនវត្ថុ ជាអាទិ៍) នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ណ- ការដកយកចលនវត្ថុពីកូនបំណុល ហើយប្រគល់ទៅឲ្យម្ចាស់បំណុលដោយយោងតាម កថាខណ្ឌទី ១ មាត្រា ៥២៥ (ការអនុវត្តដោយបង្ខំឲ្យប្រគល់ចលនវត្ថុ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ត- ការអនុវត្តដោយផ្អែកលើដីកាសម្រេចអនុញ្ញាត ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ មាត្រា ៥២៧ (ការអនុវត្តជំនួស) នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ថ-ការរក្សាវត្ថុដែលជាកម្មវត្ថុនៃការចាត់ចែងជាបណ្ដោះអាសន្ន ឬកិច្ចការផ្សេងទៀតដោយយោងតាម មាត្រា ៥៤៥ (វិធីចាត់ចែងជាបណ្ដោះអាសន្ន) នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ទ- ការប្រកាសជាសាធារណៈ ដោយយោងតាមកថាខណ្ឌទី ១ មាត្រា ៥៣១ (អានុភាពនៃការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់)នៃក្រមនីតិវិធីរដ្ឋប្បវេណី ។



Downloaded from http://www.khmerlaws.org

ឃ- ការពិនិត្យស្ថានភាពនៃការថែរក្សាគ្រប់គ្រងដោយកូនបំណុល ឬអ្នកផ្សេងទៀតនូវចលនវត្ថុ ដែលបានអនុវត្តការរឹបអូស ឬការរឹបអូសជាបណ្ដោះអាសន្ន ឬវត្ថុផ្សេងទៀត ដែលអាជ្ញាសាលាកំពុង ថែរក្សាគ្រប់គ្រង ។

ង- កិច្ចការដែលបានកំណត់នៅក្នុងចំណុចនីមួយៗនៃកថាខណ្ឌទី ៣ មាត្រា ៩ (មុខងារ និង កន្លែង អនុវត្តកិច្ចការ) នៃច្បាប់នេះ ហើយដែលជាកិច្ចការ ក្រៅពីកិច្ចការដែលបានកំណត់ពី ចំណុច ក ដល់ចំណុច ឃ ខាងលើនេះ ។

ក្នុងករណីដែលអាជ្ញាសាលាទៅដល់ទីកន្លែងដែលខ្លួនបំពេញកិច្ចការដែលបានកំណត់ នៅក្នុងចំណុចនីមួយៗនៃកថាខណ្ឌទី ១ ខាងលើនេះ ប៉ុន្តែអាជ្ញាសាលានោះមិនអាចបំពេញកិច្ចការនោះ ដោយមានមូលហេតុដែលមិនមែនជាការទទួលខុសត្រូវរបស់ខ្លួន អាជ្ញាសាលានោះត្រូវទទួលកម្រៃមួយផ្នែកដែលត្រូវបានបង់ចូលថវិការដ្ឋ ដែលទាក់ទងនឹងកិច្ចការនោះ ទោះបីជាពុំបានសម្រេច កិច្ចការនោះក៏ដោយ ។

**មាត្រា ២៩ ថ្មី** *(មាត្រា ២៤ ចាស់)*.- **ចំនួនប្រាក់កម្រៃ**

ចំនួនប្រាក់កម្រៃនៃកិច្ចការដែលបានកំណត់ពីចំណុច ក ដល់ចំណុច ឃ នៃកថាខណ្ឌទី ១ នៃមាត្រា ២៨ ថ្មី (ករណីដែលទទួលកម្រៃ) ខាងលើនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដោយពិចារណាលើទំហំនៃកិច្ចការផលប្រយោជន៍ដែលភាគីនឹងទទួល ស្ថានភាពនៃតម្លៃទំនិញ ស្ថានភាពនៃប្រាក់បៀវត្សរ៍ទូទៅ និង ស្ថានភាពទាំងឡាយផ្សេងទៀត ។

ចំនួនប្រាក់កម្រៃនៃកិច្ចការដែលបានកំណត់នៅក្នុងចំណុច ង នៃកថាខណ្ឌទី ១ នៃមាត្រា ២៨ ថ្មី (ករណីដែលទទួលកម្រៃ) ខាងលើនេះ ត្រូវកំណត់ដោយតុលាការដែលបង្គាប់ឱ្យអាជ្ញាសាលាបំពេញកិច្ចការនោះក្នុងការសម្រេចសេចក្ដី ឬប្រធានតុលាការដែលអាជ្ញាសាលានោះបំពេញការងារ ដោយពិចារណាលើចំនួនប្រាក់កម្រៃនៃកិច្ចការប្រហាក់ប្រហែលគ្នាក្នុងចំណោមកិច្ចការទាំងឡាយដែលបានកំណត់នៅក្នុងចំណុចនីមួយៗនៃកថាខណ្ឌទី ១ នៃមាត្រា ២៨ ថ្មី (ករណីដែលទទួលកម្រៃ) ខាង លើនេះ ។

**មាត្រា ៣០ ថ្មី** *(មាត្រា ២៥ ចាស់)*.- **ពេលវេលាទទួលប្រាក់កម្រៃ**

អាជ្ញាសាលាត្រូវទទួលប្រាក់កម្រៃមួយផ្នែកដែលត្រូវបានបង់ចូលជាថវិការដ្ឋ នៅពេលដែលបានកំណត់ក្នុងចំណុចនីមួយៗខាងក្រោមនេះ ៖

ក- ពេលបានបញ្ចប់កិច្ចការនោះ ។

ខ- ពេលដែលលែងចាំបាច់ធ្វើកិច្ចការនោះបន្តទៀត ។

គ- ពេលដែលលែងអាចបំពេញកិច្ចការនោះបាន ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ មាត្រា ២៨ ថ្មី (ករណីដែលទទួលកម្រៃ) នៃច្បាប់នេះ ។



Downloaded from http://www.khmerlaws.org

**មាត្រា ៣១ ថ្មី** *(មាត្រា ២៦ ចាស់)*.- **ប្រភេទនៃសោហ៊ុយ**

អាជ្ញាសាលាត្រូវទទួលការបង់ ឬការសងពីអ្នកស្នើសុំនូវសោហ៊ុយដែលចាំបាច់ក្នុងការបំពេញកិច្ចការ ។

សោហ៊ុយដែលអាជ្ញាសាលាត្រូវទទួលការបង់ ឬការសងពីអ្នក មានដូចតទៅ ៖

ក- សោហ៊ុយផ្ញើការជូនដំណឹង ។

ខ- ប្រាក់ឧបត្ថម្ភ និងសោហ៊ុយធ្វើដំណើររបស់អ្នកសង្កេតការណ៍ដែលបានកំណត់នៅក្នុងមាត្រា ៣៣៩ (អ្នកសង្កេតការណ៍) នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

គ- ប្រាក់កម្រៃរបស់អ្នកបច្ចេកទេស និងកម្មករ ។

ឃ- សោហ៊ុយសម្រាប់ការដឹកជញ្ជូន ការថែរក្សាគ្រប់គ្រង ការត្រួតពិនិត្យ និងការពារការរក្សាទុក ។

ង- សោហ៊ុយសម្រាប់ការប្រមូលផល ។

ច- សោហ៊ុយសម្រាប់ការទទួលការបញ្ជាក់ពីស្ថាប័នរដ្ឋ ឬអង្គភាពសាធារណៈផ្សេង ទៀត ។

ឆ- សោហ៊ុយសម្រាប់រូបថតដែលថតដើម្បីកំណត់ហេតុស្ដីពីស្ថានភាពបច្ចុប្បន្ននៃវត្ថុ ។

ជ- សោហ៊ុយសម្រាប់ការធ្វើលិខិតបញ្ជាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ នៃមាត្រា ៤១៣ (ដីកាសម្រេចបង្គាប់ឲ្យលក់)នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ឈ- សោហ៊ុយធ្វើដំណើរ និងស្នាក់នៅរបស់អាជ្ញាសាលា ។

ញ- ប្រាក់ឧបត្ថម្ភ សោហ៊ុយធ្វើដំណើរ សោហ៊ុយស្នាក់នៅ និងកម្រៃរបស់អ្នកវាយតម្លៃ ។

ដ- សោហ៊ុយសម្រាប់ការរាយការណ៍ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ មាត្រា ៤០០ (ការ ផ្ញើប្រាក់ទុកនៅតុលាការដោយអាជ្ញាសាលា) និងមាត្រា ៤០១ (ការជូនដំណឹងទៅសាលាដំបូង) នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ឋ- សោហ៊ុយចាំបាច់សម្រាប់ការលក់តាមវិធី ក្រៅពីការលក់ឡាយឡុងដោយមាត់ ក្រោមសំបុត្រ ឬដោយផ្ទាល់មាត់ ។

ឌ- សោហ៊ុយក្រៅពីសោហ៊ុយដែលបានកំណត់ពីចំណុច ក ដល់ចំណុច ឋ ខាងលើ នេះ ហើយដែលត្រូវបានកំណត់ដោយច្បាប់ផ្សេង ឬប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ៣២ ថ្មី** *(មាត្រា ២៧ ចាស់)*.- **ចំនួនសោហ៊ុយ**

ចំនួនសោហ៊ុយដែលអាជ្ញាសាលាត្រូវទទួលការបង់ ឬសងពីអ្នក មានដូចតទៅ ៖

ក- ចំនួនទឹកប្រាក់ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ចំពោះសោហ៊ុយដែលបានកំណត់នៅក្នុងចំណុច ខ និងពីចំណុច ជ ដល់ចំណុច ឌ កថាខណ្ឌទី ២ នៃមាត្រា មាត្រា ៣១ ថ្មី (ប្រភេទនៃសោហ៊ុយ) ខាងលើនេះ ។



Downloaded from http://www.khmerlaws.org

ខ- ចំនួនទឹកប្រាក់ដែលបានចំណាយចាំបាច់ជាក់ស្តែង ចំពោះសោហ៊ុយដែលបានកំណត់នៅក្នុងចំណុច ក និងពីចំណុច គ ដល់ចំណុច ឆ កថាខណ្ឌទី ២ នៃមាត្រា ៣១ ថ្មី (ប្រភេទនៃសោហ៊ុយ) ខាងលើនេះ ។

**មាត្រា ៣៣ ថ្មី *(មាត្រា ២៨ ចាស់)*.- បុគ្គលដែលមានបន្ទុកត្រូវបង់ថ្លៃកម្រៃ ឬសោហ៊ុយ**

បុគ្គលដែលមានបន្ទុកត្រូវបង់កម្រៃដូចមានចែងក្នុងមាត្រា ២៨ ថ្មី (ចំនួនប្រាក់កម្រៃ) និងត្រូវសងសោហ៊ុយដូចមានចែងក្នុងមាត្រា ៣២ ថ្មី (ចំនួនសោហ៊ុយ)គឺ ៖

ក- ចំពោះកិច្ចការដែលអាជ្ញាសាលាជាត់ចែងតាមពាក្យសុំ គឺ អ្នកដាក់ពាក្យសុំអនុវត្ត ។

ខ- ចំពោះកិច្ចការដែលតុលាការបានឱ្យអាជ្ញាសាលាបំពេញដោយផ្ទាល់ គឺ តុលាការ។

ចំពោះករណីដូចមានចែងក្នុងចំណុច ក នៃកថាខណ្ឌទី ១ ខាងលើនេះ កម្រៃ និង សោហ៊ុយ ត្រូវបង់ទៅសាលាដំបូងដែលអាជ្ញាសាលានោះស្ថិតនៅ ។

**មាត្រា ៣៤ ថ្មី *(មាត្រា ២៩ ចាស់)*.- អាជ្ញាយុកាល**

សិទ្ធិទទួលកម្រៃមួយផ្នែក និងទទួលការសងសោហ៊ុយដែលអាជ្ញាសាលាបានបង់ជំនួសជាមុន និងត្រូវរលត់ ដោយអាជ្ញាយុកាល ប្រសិនបើអាជ្ញាសាលាមិនបានអនុវត្តសិទ្ធិនោះក្នុងអំឡុងពេល ៥(ប្រាំ) ឆ្នាំ ។

**មាត្រា ៣៥ ថ្មី *(មាត្រា ៣០ ចាស់)*.- ការបង់ជាមុន**

ចំពោះកិច្ចការដែលអាជ្ញាសាលាត្រូវចាត់ចែង តាមពាក្យសុំ អាជ្ញាសាលានោះអាចបង្គាប់ឱ្យអ្នកដាក់ពាក្យសុំបង់ជាមុននូវកម្រៃ និងសោហ៊ុយចាំបាច់ដើម្បីចាត់ចែងកិច្ចការនោះ តាមចំនួនទឹកប្រាក់ដែលត្រូវបានប៉ាន់ប្រមាណដោយយោងតាមបញ្ញត្តិនៃប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្ត ឡើយ ចំពោះករណីអ្នកដាក់ពាក្យសុំនោះបានទទួលការ សង្គ្រោះលើបណ្តឹង ។

ការបង់ចំនួនទឹកប្រាក់ប៉ាន់ប្រមាណជាមុនដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាង លើនេះ ត្រូវធ្វើទៅសាលាដំបូងដែលអាជ្ញាសាលាបំពេញការងារ។

ប្រសិនបើអ្នកដាក់ពាក្យសុំមិនបង់ជាមុននូវចំនួនទឹកប្រាក់ប៉ាន់ប្រមាណដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ខាងលើនេះអាជ្ញាសាលាអាចបោះបង់ចោលពាក្យសុំនោះបាន ។

អ្នកដាក់ពាក្យសុំដែលបានបង់ជាមុននូវចំនួនទឹកប្រាក់ប៉ាន់ប្រមាណដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះ ត្រូវរួចផុតពីកាតព្វកិច្ចបង់ ឬសងនូវកម្រៃ និងសោហ៊ុយត្រឹមកម្រិតទឹកប្រាក់ដែលខ្លួនបានបង់ពីមុន នោះ ។



Downloaded from http://www.khmerlaws.org

**មាត្រា ៣៦ ថ្មី** *(មាត្រា ៣១ ចាស់)*.- **ការផ្តល់ជំនួយសង្គ្រោះលើកលែងថ្លៃ និងសោហ៊ុយ**

ក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ ឬការអនុវត្តរក្សាការពារដែលអាជ្ញាសាលាជាស្ថាប័នអនុវត្ត ចំពោះបុគ្គលដែលគ្មានលទ្ធភាពគ្រប់គ្រាន់ក្នុងការបង់ប្រាក់ថ្លៃ និងសោហ៊ុយដែលចាំបាច់ដើម្បីបំពេញនូវកិច្ចការរបស់អាជ្ញាសាលា ឬបុគ្គលដែលអាចមានការលំបាកយ៉ាងខ្លាំងក្នុងការទ្រទ្រង់ជីវភាពដោយសារការបង់ថ្លៃ និងសោហ៊ុយនោះ សាលាដំបូងដែលអាជ្ញាសាលាបំពេញការងារ អាចចេញដីកាសម្រេចឱ្យជួយសង្គ្រោះចំពោះការបង់ប្រាក់នេះតាមពាក្យសុំ។ ប៉ុន្តែបញ្ញត្តិនេះ មិនអាចត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែល ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ឬពាក្យសុំឱ្យអនុវត្តរក្សាការពារ នឹងត្រូវលើកចោលដោយសារពាក្យសុំនេះប្រាកដជាខុសច្បាប់។

ចំពោះហេតុនៃការផ្តល់ជំនួយសង្គ្រោះនេះ ត្រូវធ្វើសេចក្តីបញ្ជាក់ដំបូងដូចដែលមានចែងក្នុង មាត្រា ១៣១ (សេចក្តីបញ្ជាក់ដំបូង) នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**មាត្រា ៣៧ ថ្មី** *(មាត្រា ៣២ ចាស់)*.- **ខ្លឹមសារនៃជំនួយសង្គ្រោះលើកលែងថ្លៃ និងសោហ៊ុយ**

ដីកាសម្រេចឱ្យជួយសង្គ្រោះលើកលែងថ្លៃនិងសោហ៊ុយ ត្រូវមានអានុភាពទៅតាមការកំណត់ក្នុងដីកាសម្រេចដូចខាងក្រោមនេះ ៖

ក- ការពន្យារពេលបង់ប្រាក់ថ្លៃនិងសោហ៊ុយ។

ខ- ការអនុគ្រោះមិនបាច់ឱ្យបង់ប្រាក់ថ្លៃ និងសោហ៊ុយ។ ប៉ុន្តែការសម្រេចនេះអាចធ្វើបានចំពោះតែករណីណាដែលតុលាការបានយល់ឃើញថាសមស្រប ដោយគិតពិចារណាលើលទ្ធភាពគ្រប់គ្រាន់របស់ភាគីជាអាទិ៍ នៅក្រោយពេលដែលការពន្យារពេលនោះ បានរលត់។

ដីកាសម្រេចឱ្យជួយសង្គ្រោះលើកលែងថ្លៃនិងសោហ៊ុយនេះ អាចមានអានុភាពទៅលើតែបុគ្គលដែលបានទទួលដីកានោះប៉ុណ្ណោះ។

ក្នុងករណីដែលបុគ្គលដែលបានទទួលដីកាសម្រេចឱ្យជួយសង្គ្រោះចំពោះការបង់ប្រាក់ថ្លៃ និងសោហ៊ុយដែលចាំបាច់ដើម្បីបំពេញកិច្ចការរបស់អាជ្ញាសាលាខាងលើ ត្រូវបានរកឃើញថាគ្មានលក្ខខណ្ឌដែលបានកំណត់នៅក្នុងមាត្រា ៣៦ ថ្មី (ការផ្តល់ជំនួយសង្គ្រោះលើកលែងថ្លៃនិងសោហ៊ុយ) ខាងលើនេះ ឬបុគ្គលនោះបានបាត់បង់លក្ខខណ្ឌទាំងនោះ សាលាដំបូងដែលអាជ្ញាសាលាបំពេញការងារអាចលុបចោលដីកាសម្រេចឱ្យជួយសង្គ្រោះចំពោះការបង់ថ្លៃនិងសោហ៊ុយនោះបាន ហើយបង្គាប់ឱ្យបុគ្គលនោះបង់ប្រាក់ដែលបានពន្យារពេលបាន ឬអនុគ្រោះមិនឱ្យបង់នៅពេលណាក៏បានតាមពាក្យសុំរបស់បុគ្គលដែលមានទំនាក់ទំនងនឹង ផលប្រយោជន៍ ឬដោយគន្លងសិទ្ធិរបស់ខ្លួនដោយដីកាសម្រេច។

ចំពោះដីកាសម្រេចដែលបានកំណត់ក្នុងមាត្រា ៣៦ ថ្មី (ការផ្តល់ជំនួយសង្គ្រោះលើកលែងថ្លៃ និងសោហ៊ុយ) ខាងលើនេះ និងមាត្រានេះ អាចប្តឹងជំទាស់បាន។



Downloaded from http://www.khmerlaws.org

ចំពោះនីតិវិធីសម្រេចដែលបានកំណត់ក្នុងមាត្រា៣១ (ការផ្តល់ជំនួយសង្គ្រោះលើកថ្លៃ និង សោហ៊ុយ) ខាងលើនេះ និងមាត្រានេះ និងបណ្តឹងជំទាស់នឹងនីតិវិធីសម្រេចនេះ ត្រូវអនុវត្តដោយអនុលោមតាមករណី នៃនីតិវិធីសម្រេចនិងបណ្តឹងជំទាស់ដែលបានកំណត់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ។

**មាត្រា ៣៨ ថ្មី *(មាត្រា ៣៣ ចាស់)*.- បញ្ញត្តិពិសេសស្តីពីបន្ទុករបស់រដ្ឋចំពោះកម្រៃនិងសោហ៊ុយ**

ក្នុងចំណោមកម្រៃនិងសោហ៊ុយទាំងប៉ុន្មានដែលត្រូវទាត់ទែងកិច្ចការចំពោះការអនុវត្តដោយបង្ខំ និងការអនុវត្តវិធានការ ដែលអាជ្ញាសាលាត្រូវធ្វើតាមពាក្យសុំរបស់បុគ្គលដែលបានទទួលការសង្គ្រោះលើកថ្លៃ និង សោហ៊ុយ ប្រសិនបើមានកម្រៃឬសោហ៊ុយខ្លះដែលរដ្ឋមិនអាចប្រមូលបានពីកូនបំណុលនៃការអនុវត្ត រដ្ឋត្រូវផ្តល់កម្រៃ ឬសោហ៊ុយនោះ តាមការទាមទាររបស់អាជ្ញាសាលា។

## ជំពូកទី៧

## អន្តរប្បញ្ញត្តិ

**មាត្រា ៣៩ ថ្មី *(មាត្រា ៣៤ ចាស់)*.- រឿងក្តីដែលច្បាប់នេះត្រូវអនុវត្ត**

ច្បាប់នេះត្រូវអនុវត្តចំពោះរឿងក្តីដែលពាក្យសុំត្រូវបានដាក់ទៅអាជ្ញាសាលា ឬតុលាការបង្គាប់ដោយផ្ទាល់ឱ្យអាជ្ញាសាលាទាត់ទែងកិច្ចការ ចាប់ពីកាលបរិច្ឆេទនៃការអនុវត្តច្បាប់នេះ។

ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី១ខាងលើនេះក៏ដោយ ក៏បញ្ញត្តិនៃច្បាប់នេះមិនត្រូវយកមកអនុវត្តចំពោះករណីខាងក្រោម៖

ក- ក្នុងករណីដែលដាក់ពាក្យសុំឱ្យអនុវត្តចំពោះចលនវត្ថុបន្ថែមទៀត នៅទីកន្លែងដែលមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាដែលបានកំណត់នៅក្នុងប្រកាសលេខ ៣០ គយ ប្រក/០៧ ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០៧ របស់ក្រសួងយុត្តិធម៌ស្តីពីមន្ត្រីទទួលបន្ទុកកិច្ចការ អាជ្ញាសាលា (តទៅហៅថា "មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា") បានរឹបអូស ចលនវត្ថុម្តងរួចហើយ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា ៣៥៨ (ការរួមបញ្ចូលរឿងក្តី) នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ខ- ករណីដែលដាក់ពាក្យសុំឱ្យអនុវត្តចំពោះចលនវត្ថុដែលមន្ត្រីទទួលបន្ទុកកិច្ចការ អាជ្ញាសាលា បានរឹបអូសជាបណ្តោះអាសន្ន។



Downloaded from http://www.khmerlaws.org

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យសុំអនុវត្តដោយបង្ខំ

**ម្ចាស់បំណុលនៃការអនុវត្ត ៖** ឈ្មោះ............ ភេទ....... ជាតិខ្មែរ កើតឆ្នាំ.......... កាន់អត្តសញ្ញាណប័ណ្ណលេខ ................ ចុះថ្ងៃទី....... ខែ.......... ឆ្នាំ......... មានអាសយដ្ឋានបច្ចុប្បន្នស្ថិតនៅ............ ភូមិ.......... សង្កាត់............ ក្រុងបាត់ដំបង ខេត្តបាត់ដំបង ។

**សហកូនបំណុលនៃការអនុវត្ត ៖** ឈ្មោះ ................ ភេទ............ ជាតិខ្មែរ កើតឆ្នាំ........... កាន់អត្តសញ្ញាណប័ណ្ណលេខ ................... និងឈ្មោះ ................ ជាតិខ្មែរ កើតឆ្នាំ.......... កាន់អត្តសញ្ញាណប័ណ្ណលេខ .................... មានអាសយដ្ឋានរួមគ្នាស្ថិតនៅ................ ភូមិ............ សង្កាត់............ ក្រុងបាត់ដំបង ខេត្តបាត់ដំបង ។

**សូមគោរពជូន**
**ឯកឧត្តមប្រធានសាលាដំបូងខេត្តបាត់ដំបង**

**កម្មវត្ថុ ៖** សំណើសុំអនុវត្តដោយបង្ខំចំពោះចលនវត្ថុ មានទីតាំងស្ថិតនៅភូមិ............ សង្កាត់............. ក្រុងបាត់ដំបង ខេត្តបាត់ដំបង

**យោង ៖** - ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ ។
- សាលក្រមរដ្ឋប្បវេណីលេខ ........... ចុះថ្ងៃទី....... ខែ........... ឆ្នាំ............ របស់សាលាដំបូងខេត្តបាត់ដំបង ។
- រូបមន្តអនុវត្តសាលក្រមលេខ ........... ចុះថ្ងៃទី....... ខែ........ ឆ្នាំ.............របស់សាលាដំបូងខេត្តបាត់ដំបង ។

តបតាមកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំសូមគោរព និងជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបនូវចំណុចសំខាន់ៗ ដែលជាមូលដ្ឋាននៃការអនុវត្តដូចខាងក្រោម ៖

**១.សញ្ញាណនៃលិខិតអនុវត្ត**

ឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលមានអានុភាពអនុវត្តគឺ**សាលក្រមរដ្ឋប្បវេណីលេខ ........ ចុះថ្ងៃទី...........ខែ............. ឆ្នាំ.............** របស់សាលាដំបូងខេត្តបាត់ដំបង ដែលមានខ្លឹមសារ ៖

១.បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ ............ និងឈ្មោះ .................. សងប្រាក់ជាប្រាក់ដុល្លារចំនួន **២៤,០០០ USD (ពីរម៉ឺន បួនពាន់ដុល្លារអាមេរិក)** និងប្រាក់រៀលចំនួន **៥,៥០០,០០០៛ (ប្រាំលាន ប្រាំសែនរៀល)** ទៅឲ្យដើមចោទឈ្មោះ ............ ។

២.សាលក្រមនេះប្រកាសអនុវត្តជាបណ្តោះអាសន្ន មានអានុភាពអនុវត្តបង្ខំតាមច្បាប់ ដូចមានបញ្ជាក់នៅក្នុងរូបមន្តអនុវត្តសាលក្រមលេខ ................ ចុះថ្ងៃទី......... ខែ............. ឆ្នាំ............ របស់សាលាដំបូងខេត្តបាត់ដំបង ។

**២.សេចក្តីស្នើសុំឲ្យអនុវត្ត**

សំណើសុំឲ្យស្ថាប័នអនុវត្ត សាលាដំបូងខេត្តបាត់ដំបង អនុវត្តតាមវិធានបង្ខំដោយផ្ទាល់តាមអំណាច **សាលក្រមរដ្ឋប្បវេណីលេខ ............ ចុះថ្ងៃទី............ខែ......... ឆ្នាំ............របស់សាលាដំបូងខេត្តបាត់ដំបង** ។

**៣.សញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្ត**

ចលនវត្ថុរបស់ឈ្មោះ............ និងឈ្មោះ................ មានទីតាំងស្ថិតនៅភូមិ............ សង្កាត់............. ក្រុងបាត់ដំបង ខេត្តបាត់ដំបង ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាពិនិត្យ និងអនុវត្តដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ ។

បាត់ដំបង ថ្ងៃទី.........ខែ......... ឆ្នាំ............

**ស្នាមមេដៃស្តាំ**

..................

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ

## ការផ្សាយជាសាធារណៈអំពី

## ការលក់ឡាយឡុងដោយស្រោមសំបុត្រ

យើង .................................. ក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ មាត្រា ៤៣៦ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

បានឃើញ សំណុំរឿងអនុវត្តលេខ ... ចុះថ្ងៃទី... ខែ... ឆ្នាំ ... របស់សាលាដំបូងរាជធានីភ្នំពេញ ។

**សូមប្រកាសថា ៖**

ចំពោះរឿងក្តីស្តីពីការអនុវត្តដោយបង្ខំលេខ ... ចុះថ្ងៃទី... ខែ... ឆ្នាំ ... របស់សាលាដំបូងរាជធានីភ្នំពេញ សូមជម្រាបជូនដល់ភាគីដែលមានប្រយោជន៍ ពាក់ព័ន្ធទាំងអស់ឲ្យបានជ្រាបថា ចំពោះ[redacted]ចលនវត្ថុ[redacted]ានទីតាំងស្ថិតនៅ...................... រាជធានីភ្នំពេញ ។

យោង ៖

-វិធីលក់ ៖ លក់ឡាយឡុងដោយស្រោមសំបុត្រ

-កាលបរិច្ឆេទនៃការលក់ ៖ ម៉ោង ... ថ្ងៃទី... ខែ... ឆ្នាំ ...

-ទីកន្លែងលក់ ៖ បន្ទប់លក់នៃអាជ្ញាសាលានៃដំបូងរាជធានីភ្នំពេញ ។

-តម្លៃលក់អប្បបរមា ៖ ចាប់ពី ............$ (................ដុល្លារអាមេរិក) ឡើងទៅ ។

[redacted]

-វិធីផ្តល់ប្រាក់ធានាលើសំណើទិញខាងលើ ៖ ដោយប្រាក់សុទ្ធ ឬ ដោយមូលប្បទានប័ត្រ ចំនួន១០% (ដប់ភាគរយ) នៃតម្លៃលក់ ។

-អំឡុងពេលសម្រាប់ឲ្យសាធារណៈជនមើលអំពី "ឯកសារលំអិតអំពីវត្ថុ និង របាយការណ៍ស្តីពីការវាយតម្លៃ" ជាអាទិ៍គឺចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... រហូតដល់ ថ្ងៃទី... ខែ... ឆ្នាំ... ។

-កាលបរិច្ឆេទដើម្បីចេញដីកាសម្រេចអនុញ្ញាតឲ្យលក់ ថ្ងៃទី... ខែ... ឆ្នាំ...

រាជធានីភ្នំពេញ,ថ្ងៃទី .... ខែ........ ឆ្នាំ.............

**ក្រឡាបញ្ជី**

[redacted]

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យសុំផ្ដល់សំណើទិញ**

ខ្ញុំបាទឈ្មោះ ...................... អាយុ...ឆ្នាំ មានទីលំនៅ..................................................

**គោរពជូន**

**អគ្គនាយកនៃសាលាដំបូងរាជធានីភ្នំពេញ**

ចំពោះរឿងក្ដីនៃការអនុវត្តដោយបង្ខំចំពោះ[redacted]ចលនវត្ថុលេខ........... ចុះថ្ងៃទី...... ខែ...... ឆ្នាំ...... ខ្ញុំបាទ.............................. សូមផ្ដល់សំណើទិញ[redacted]ចលនវត្ថុក្នុងតម្លៃដែលបានកំណត់ខាងក្រោមនេះ ៖

| | |
|---|---|
| រឿងក្ដីលេខ | លេខ........... ចុះថ្ងៃទី...... ខែ...... ឆ្នាំ...... |
| លេខ[redacted]ចលនវត្ថុ | ........................................................ |
| អ្នកដែលផ្ដល់សំណើទិញ | ឈ្មោះ.................................................. អាស័យដ្ឋាន................................................ |
| អ្នកតំណាងដោយអាណត្តិ | ........................................................ |
| តម្លៃលក់ដែលស្នើសុំទិញ | ........................................................ |
| ប្រាក់ធានាលើសំណើទិញ | ........................................................ |
| វិធីផ្ដល់ប្រាក់ធានាលើសំណើទិញខាងលើ | ដោយមូលប្បទានប័ត្រ |

រាជធានីភ្នំពេញ,ថ្ងៃទី .... ខែ........ ឆ្នាំ.............

**អ្នកផ្ដល់សំណើទិញ**

[redacted]

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ

## ដីកាសម្រេចកំណត់អំឡុងពេលបង់ថ្លៃលក់

យើង ...................................................... ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ មាត្រា៤៤៧.១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

បានឃើញ សំណុំរឿងអនុវត្តលេខ ... ចុះថ្ងៃទី... ខែ... ឆ្នាំ... របស់សាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ ដីកាសម្រេចអនុញ្ញាតឲ្យលក់លេខ ....................... ចុះថ្ងៃទី... ខែ... ឆ្នាំ ... របស់សាលាដំបូងរាជធានីភ្នំពេញ ។

### សាលាដំបូងរាជធានីភ្នំពេញសម្រេច

ស្តីពី[redacted]ចលនវត្ថុដែលមាននៅក្នុងបញ្ជី[redacted]ចលនវត្ថុ តុលាការសម្រេចកំណត់អំឡុងពេលដើម្បីឲ្យអ្នកទិញបង់ថ្លៃលក់ដោយគិតចាប់ពីថ្ងៃនេះតទៅ រហូតដល់ថ្ងៃ... ខែ... ឆ្នាំ... រៀងរាល់ម៉ោងធ្វើការ ។

រាជធានីភ្នំពេញ,ថ្ងៃទី .... ខែ........ ឆ្នាំ.............

**ចៅក្រម**

[redacted]

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សេចក្តីថ្លែងការណ៍**

**ស្តីពីការបង់ថ្លៃលក់អចលនវត្ថុ**

**គោរពជូន**

**ក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ**

រាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ...

ចំពោះរឿងក្តីនៃការលក់ដោយបង្ខំចំពោះ[redacted]ចលនវត្ថុលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ... របស់សាលាដំបូងរាជធានីភ្នំពេញ ខ្ញុំឈ្មោះ ..................... ភេទ... អាយុ...ឆ្នាំ ជាភាគីអ្នកទិញ បានបង់ថ្លៃលក់[redacted]ចលនវត្ថុ ជាអាទិ៍ដូចខាងក្រោម ៖

| សេចក្តីរាយការណ៍ | តម្លៃ |
|---|---|
| ថ្លៃលក់ (ប្រាក់ធានា ១០%ត្រូវបានដកចេញ) | |
| ពន្ធចុះបញ្ជីផ្ទេរកម្មសិទ្ធិនៃ[redacted]ចលនវត្ថុ | |
| ពន្ធលុបចោលការចុះបញ្ជីអំពីការរឹបអូស ជាអាទិ៍ | |
| សោហ៊ុយផ្ញើលិខិតផ្ទុកផ្តាក់អោយចុះបញ្ជីទៅ[redacted] | |
| សោហ៊ុយផ្ញើឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីទៅក្រឡាបញ្ជី | |
| សោហ៊ុយផ្ញើឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃ សៀវភៅចុះបញ្ជីបញ្ជូនទៅអ្នកទិញ | |
| សរុប | |

នៅកាលបរិច្ឆេទដដែលនេះ ខ្ញុំ......................ក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ បានទទួល ការបង់ថ្លៃដូចដែលបានសរសេរខាងលើនេះ ។

**ក្រឡាបញ្ជី**

[redacted]

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំទាមទារអោយចែកចំណែក

ខ្ញុំបាទឈ្មោះ.............. អាយុ...ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅ......................................

**សូមគោរពចូលមក**

**លោកចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ**

**កម្មវត្ថុ ៖** សំណើសុំទាមទារអោយចែកចំណែកពាក់ព័ន្ធករណីលក់ដោយបង្ខំនូវ[redacted]ចលនវត្ថុ ដែលមានក្នុងសំណុំរឿងអនុវត្តលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ... របស់សាលាដំបូងរាជធានីភ្នំពេញ ។

តបតាមកម្មវត្ថុខាងលើ ខ្ញុំបាទសូមជម្រាបជូនលោកប្រធានមេត្តាជ្រាបថា ខ្ញុំមានសិទ្ធិលើបំណុលចំពោះ កូនបំណុលនៃការអនុវត្តព្រោះជាកូនបំណុលនៃការអនុវត្តបានជំពាក់ប្រាក់ខ្ញុំបាទ ដោយផ្អែកលើ................. ដែលមានទឹកប្រាក់ចំនួន.......................... ។

ដូច្នេះ ខ្ញុំបាទពិតជាមានលក្ខណៈសម្បត្តិជាម្ចាស់បំណុលដែលមានសិទ្ធិទាមទារអោយចែកចំណែក ដោយសារខ្ញុំបាទមានលិខិតអនុវត្តដែលមានអានុភាពអនុវត្តតាមច្បាប់ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកប្រធានមេត្តាអនុញ្ញាតអោយខ្ញុំបាទចូលរួមចំណែកនៅក្នុងករណីលក់ដោយបង្ខំនូវ[redacted]ចលនវត្ថុដែលមានសំណុំរឿងអនុវត្តលេខ ... ចុះថ្ងៃទី... ខែ... ឆ្នាំ... របស់សាលា ដំបូងរាជធានីភ្នំពេញ ដោយក្តីអនុគ្រោះ ។

សូមលោកប្រធានមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី................ ខែ................ ឆ្នាំ......................

**ស្នាមមេដៃអ្នកដាក់ពាក្យសុំ**

[redacted]

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# លិខិតគណនាអំពីសិទ្ធិលើបំណុល

**គោរពជូន**

**ក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ**

រាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ...

ខ្ញុំឈ្មោះ.................. ភេទ... អាយុ...ឆ្នាំ មានអាសយដ្ឋាននៅ...............................

ស្តីពីរឿងក្តីនៃការលក់ដោយបង្ខំចំពោះ[redacted]ចលនវត្ថុលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ... របស់សាលាដំបូងរាជធានីភ្នំពេញ

ខ្ញុំសូមធ្វើការគណនានូវចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលដូចខាងក្រោម៖

១ ចំនួនទឹកប្រាក់សរុបសិទ្ធិលើបំណុល ៖..................................

២ ប្រាក់ដើម

ក/ ចំនួនទឹកប្រាក់បច្ចុប្បន្ននៃប្រាក់ដើម ៖..................................

ខ/ កាលបរិច្ឆេទនៃការកើតសិទ្ធិលើបំណុល ៖..................................

គ/ មូលហេតុនៃការកើតសិទ្ធិលើបំណុល ៖កិច្ចសន្យាខ្ចីបរិភោគ

ឃ/ ការបង្ហាញនូវលិខិតអនុវត្ត ៖សាលក្រម

៣ ការប្រាក់

ក/ ចំនួនទឹកប្រាក់បច្ចុប្បន្ននៃការប្រាក់ ៖..................................

ខ/ រយៈពេល ៖..................................

គ/ ចំនួនថ្ងៃ ខែ ឆ្នាំ ៖..................................

ឃ/ ការប្រាក់ ៖ ១០%ក្នុងមួយឆ្នាំ

[redacted]

៤ ចំនួនទឹកប្រាក់នៃការខូចខាត

ក/ ចំនួនទឹកប្រាក់បច្ចុប្បន្ននៃការខូចខាត :..............................

ខ/ រយៈពេល :..............................

គ/ ចំនួនថ្ងៃ ខែ ឆ្នាំ :..............................

ឃ/ អាត្រា : ២០%ក្នុងមួយឆ្នាំ

៥ សោហ៊ុយសម្រាប់អនុវត្ត : ..............................

**ស្នាមមេដៃម្ចាស់បំណុល**

[redacted]

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

លេខ

## លិខិតជូនដំណឹង

### ទៅម្ចាស់បំណុលនៃការអនុវត្តអំពីការទាមទារឲ្យចែកចំណែក

យើង ............................................ ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ មាត្រា ៤២៦ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី របស់ព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ **នស/រកម/០៧០៦/០២១** ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៧ ។

សូមជម្រាបមកឈ្មោះ ................ ភេទ... អាយុ...ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន.......................................................................................... រាជធានីភ្នំពេញ ។

ដោយមានលោក .......................................... ជាមេធាវីតំណាងដោយអាណត្តិ ។

ដែលជាម្ចាស់បំណុលនៃការអនុវត្ត អំពីការទាមទារឲ្យចែកចំណែក ដែលពាក់ព័ន្ធនឹងករណីលក់ដោយបង្ខំនូវ[redacted]ចលនវត្ថុរវាងឈ្មោះ ................. ភេទ... អាយុ...ឆ្នាំ ជនជាតិខ្មែរ ដែលជាម្ចាស់បំណុលនៃការអនុវត្ត និងឈ្មោះ ..................... ដែលជាកូនបំណុលនៃការអនុវត្ត ។

រាជធានីភ្នំពេញ,ថ្ងៃទី .... ខែ........ ឆ្នាំ.............

**ចៅក្រម**

[redacted]

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

លេខ

## លិខិតជូនដំណឹង

### នៅកូនបំណុលនៃការអនុវត្តអំពីការទាមទារឲ្យចែកចំណែក

យើង ............................ ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ មាត្រា ៤២៦ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី របស់ព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៧ ។

សូមជម្រាបមកឈ្មោះ ......................... ភេទ... អាយុ...ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន....................................................................................រាជធានីភ្នំពេញ ។

ដោយមានលោក ......................... ជាមេធាវីតំណាងដោយអាណត្តិ ។

ដែលជាកូនបំណុលនៃការអនុវត្ត អំពីការទាមទារឲ្យចែកចំណែក ដែលពាក់ព័ន្ធនឹងករណីលក់ដោយបង្ខំនូវ[redacted]ចលនវត្ថុរវាងឈ្មោះ .................. ភេទ... អាយុ...ឆ្នាំ ជនជាតិខ្មែរ ដែលជាម្ចាស់បំណុលនៃការអនុវត្ត និងឈ្មោះ ...................... ភេទប្រុស អាយុ...ឆ្នាំ ដែលជាកូនបំណុលនៃការអនុវត្ត ។

រាជធានីភ្នំពេញ,ថ្ងៃទី .... ខែ........ ឆ្នាំ.............

**ចៅក្រម**

[redacted]

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ

**ដីកាសម្រេច**

**ស្តីពី**

**ការកំណត់កាលបរិច្ឆេទនៃការចែកចំណែក**

យើង ........................ ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

បានឃើញ មាត្រា ៨៧៨ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

បានឃើញ សំណុំរឿងអនុវត្តលេខ ... ចុះថ្ងៃទី... ខែ... ឆ្នាំ... របស់សាលាដំបូងរាជធានីភ្នំពេញ ។

**ហេតុដូច្នេះសម្រេច**

ចំពោះរឿងក្តីស្តីពីការលក់ដោយបង្ខំលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ... របស់សាលាដំបូងរាជធានីភ្នំពេញ ចំពោះ[redacted]ចលនវត្ថុដែលមានវិញ្ញាបនប័ត្រលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ... តុលាការកំណត់កាលបរិច្ឆេទនៃការ ចែកចំណែកនៅថ្ងៃទី... ខែ... ឆ្នាំ... វេលាម៉ោង.............

រាជធានីភ្នំពេញ,ថ្ងៃទី .... ខែ........ ឆ្នាំ.............

**ចៅក្រម**

[redacted]

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

## តារាងចែកចំណែក

យើង ........................................................ ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ មាត្រា ៤៩០ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី

បានឃើញ សំណុំរឿងអនុវត្តដោយបង្ខំលេខ ... ចុះថ្ងៃទី... ខែ... ឆ្នាំ... របស់សាលាដំបូងរាជធានីភ្នំពេញ ។

ចំពោះរឿងក្តីស្តីពីការលក់ដោយបង្ខំចំពោះ[redacted]ចលនវត្ថុលេខ ... ចុះថ្ងៃទី... ខែ... ឆ្នាំ... របស់សាលាដំបូងរាជធានីភ្នំពេញ សាលាដំបូងរាជធានីភ្នំពេញបានធ្វើតារាងចែកចំណែកដូចដែលបានសរសេរនៅក្នុងទំព័រ បន្ទាប់នេះ ។

រាជធានីភ្នំពេញ,ថ្ងៃទី .... ខែ........ ឆ្នាំ.............

**ចៅក្រម**

[redacted]

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងអនុវត្តលេខ...

ចុះថ្ងៃទី... ខែ... ឆ្នាំ...

## កំណត់ហេតុស្តីពីការបែងចែកចំណែក

ឆ្នាំ... ខែ... ថ្ងៃទី... វេលាម៉ោង... នៅសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ: សំណុំរឿងអនុវត្តលេខ ... ចុះថ្ងៃទី... ខែ... ឆ្នាំ... របស់សាលាដំបូងរាជធានីភ្នំពេញ ។

-ម្ចាស់បំណុលឈ្មោះ ... ភេទ... អាយុ...ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន....... រាជធានីភ្នំពេញ

ដោយមានលោក ..................... ជាមេធាវីតំណាងដោយអាណត្តិ ។

-កូនបំណុលឈ្មោះ ... ភេទ... អាយុ...ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន...... រាជធានីភ្នំពេញ

ដោយមានលោក ..................... ជាមេធាវីតំណាងដោយអាណត្តិ ។

បានធ្វើការបែងចែកចំណែកដូចខាងក្រោម:

-បានប្រគល់ប្រាក់ឲ្យទៅលោក ............... ជាមេធាវីតំណាងដោយអាណត្តិឲ្យម្ចាស់បំណុលឈ្មោះ ..................... ភេទ... អាយុ...ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន............ រាជធានីភ្នំពេញ ចំនួន ........................(........................ ដុល្លាអាមេរិក) ។

[redacted]

[redacted]

# ឧបសម្ព័ន្ធទី២

# ឧបសម្ព័ន្ធរូបភាព

## ១.ការអនុវត្តភារកិច្ចអាជ្ញាសាលាលក់ឡាយឡុងតាមតុលាការ (ម.៣៩៥)



## ២.ការអនុវត្តភារកិច្ចអាជ្ញាសាលាចុះរឹបអូសចលនវត្ថុ (ម.៣៨៤ )



## ៣.ការអនុវត្តភារកិច្ចអាជ្ញាសាលាឱ្យប្រគល់ចលនវត្ថុ (ម.៥២៩)

